# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៥៣

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ឡៅពី**លើកទ័ពទៅវាយបែកបន្ទាយ**ទៀវយឹម** ៗរត់ទៅចូលនៅក្នុងស្រុកឡុកសៀ រហូតទៅដល់**ឡៅជៀង**ធ្វើសំបុត្រទៅដល់**ទៀវឡូ** ឲ្យលើកទ័ពមកជួយច្បាំងនឹង**ឡៅពី**។)*

**ឯឡៅពី**ក៏យកសំបុត្រដែល**ខុងបេង**ឲ្យកំណត់ទៅដល់នោះ មកពិគ្រោះនឹង**ហងតុង**ថា **ខុងបេង**ប្រាប់មកយើងថា នឹងលើកកងទ័ពមកជួយយើងនោះតាំងពីខែស្រាពណ៍ប្រាំកើតមកដល់ឥឡូវ មើលតាមសំបុត្រក៏យូរថ្ងៃណាស់ ហើយប្រហែលនឹងលើកកងទ័ពមកជិតដល់ហើយដឹង? យើងក៏មិនត្រូវនៅស្ងៀម ត្រូវតែរិះគិតចាត់ការលើកទាហានទៅប្រសព្វគ្នានឹងកងទ័ព**ខុងបេង**ឯស្រុកឡុកសៀ។ **ហងតុង**ថា ឥឡូវទាហាន**ទៀវយឹម**ឃើញយើងមិនទាន់ចេញច្បាំង គង់នឹងបានចិត្តកំរើបឡើងទៀត យើងត្រូវចាត់ទាហានលើកទៅចោមវាយប្លន់យកបន្ទាយក្នុងពេលអាធ្រាត្រយប់នេះចុះ **ទៀវយឹម**ឃើញថាយើងខ្លាចហើយ ក៏នឹងព្រងើយកន្តើយធ្វេសប្រមាទ យើងនឹងព្រួតវាយឲ្យបែកតែម្តង រួចសឹមលើកកន្លងហួសទៅប្រសព្វគ្នានឹងទ័ព**ខុងបេង**។ **ឡៅពី**យល់ឃើញត្រូវផង ក៏ឲ្យបម្រុងត្រៀមទាហានទុកស្រេច លុះដល់ពេលយប់ប្រមាណយាមពីរប្លាយ **ឡៅពី**ឃើញស្ងាត់បានការ ក៏លើកពលទាហានចេញពីបន្ទាយចូលទៅចោមវាយទ័ព**ទៀវយឹម**ជាបីប៉ែក ឲ្យទាហានបំបែកដុតភ្លើងគ្រប់កន្លែង។ **ទៀវយឹម**និងទាហានទាំងនោះ មិនទាន់ដឹងខ្លួនក៏ភ្ញាក់តក់ស្លុតជាជ្រួលច្របល់ បែកខ្ញែកគ្នាជាកោលាហលពេញបន្ទាយ រត់ពារទម្លាយចេញទៅអស់គ្មានសល់ ខ្លះក៏រត់វិលវល់ចូលព្រៃ ខ្លះក៏រត់កាត់សំដៅទៅស្រុកឡុកសៀ។ **ឡៅពី**ក៏លើក

ពលដេញតាមកាប់សម្លាប់យកបានគ្រឿងសាស្ត្រាវុធជាច្រើន។ ទាហាន**ទៀវយឹម**រត់ចូលទៅក្នុងបានជាច្រើន **ឡៅពី**តាមទៅហែកទម្លាយយកបន្ទាយមិនបាន ក៏ឲ្យទាហានថយមកតាំងបន្ទាយឆ្ងាយពីស្រុកនោះប្រហែលមួយរយសិន (៤គ.ម)។

លុះកន្លងមកពីរថ្ងៃ **ឡៅពី**ក៏លើកទាហានព័ទ្ធស្រុកឡុកសៀជុំវិញ ឯ**ទៀវយឹម**ក៏មិនបានចេញតដៃ ឲ្យទាហានប្រុងប្រយ័ត្នគិតរក្សាតែពីក្នុង **ឡៅពី**ក៏លើកទាហានចូលកាច់យកគយទិសឯលិច បើកចំហាមិនព័ទ្ធទិសឯជើង និងទិសខាងត្បូង ប្រាថ្នានឹងឲ្យមនុស្សក្នុងស្រុករត់ចេញ ក៏បង្ខំទាហានឲ្យទន្ទ្រានចូលបំពារឲ្យខាងតែបាន។ **ទៀវយឹម**ឡើងលើសើនបន្ទាយក្រឡេកមើលឃើញ**ឡៅពី**ជិះសេះដើរត្រួតត្រាទាហានតាំងពីម៉ោងបីព្រឹករហូតដល់ថ្ងៃរសៀលទាប ទាហានទាំងនោះក៏នឿយណាស់ជាច្រើន។ **ទៀវយឹម**ឃើញបានការ ក៏ឲ្យទាហានចុះពីលើសើន កេណ្ឌឲ្យអ្នកស្រុកឡើងទៅប្រចាំការជំនួស ហើយឲ្យជញ្ជូនថ្មគរទុកសម្រាប់ច្បាំងនឹងទាហាន**ឡៅពី** ហើយក៏លើកទាហានចេញតាមផ្លូវទិសខាងត្បូង គេចមកខាងលិច ចូលវាយទ័ព**ឡៅពី** ឲ្យ**លុយតង** និង**ង៉ឡាន់**លើកទាហានចេញតាមទ្វារទិសខាងជើង គេចទៅព័ទ្ធទ័ព**អ៊ុយអៀន**និង**ហាងតុង**។

**ឡៅពី**ចាត់ទាហានឲ្យត្រួតពារទម្លាយចូលមិនបាន ទាល់តែពេលថ្ងៃល្ងាចហើយក៏បន្ថយទាហានចេញទៅវិញ ស្រាប់តែឮសំឡេងផាវអុជឡើង។ **ទៀវយឹម**លើកទាហានផ្ទួនចូលមកវាយ ទាហាន**ឡៅពី**ភ័យណាស់ ក៏បែកខ្ញែកគ្នាជាចលាចល **អ៊ុយអៀន** និង**ហាងតុង**ឃើញដូច្នោះ ក៏ដេញទាហានឲ្យទៅជួយ**ឡៅពី** ទទួល**លុយតង**, **ង៉ឡាន់**លើកទាហានចេញមកស្កាត់ទទឹងពីមុខ នឹងរុញបំពារទៅមិនរួច។ ទាហានទាំងសងខាងក៏ច្រួតប្រកាប់គ្នាជាប់ដៃ **ឡៅពី**ឃើញទាហានស្លាប់ច្រើនណាស់លើសកម្លាំងនឹងទ្រាំតពុំបាន ក៏ញាក់សេះវេះរត់ពី**ទៀវយឹម**ទៅតាមផ្លូវតូចច្រកភ្នំ **ទៀវយឹម**ក៏សង្កុញបង្ខំដេញតាមទៅ។

ខណៈនោះ ទទួល**តៀវហ៊ុយ**លើកមកដល់ជិតស្រុកឡុកសៀ ឃើញផង់ធូលីហុយទ្រលោមពីខាងមុខប្រហែលមួយរយសិន (៤គ.ម) ក៏សម្គាល់ថា កងទ័ពស្រុកកេងជីវច្បាំងតគ្នានឹងកងទ័ពស្រុកឡុកសៀ ទើបបំបោលសេះស្ទុះចូលទៅប្រញាប់។ **ឡៅពី**ឮសំឡេងមនុស្សទ្រហឹងមកពីខាងមុខ មិនដឹងថាជាទ័ព**តៀវហ៊ុយ**លើកមក ក៏យកដៃគក់ទ្រូងហើយស្រែកថា ទេវតាអើយជីវិតខ្ញុំម្ដងនេះត្រូវគេប្រហារបំផ្លាញឲ្យស្លាប់ជាប្រាកដហើយ។ ទទួលក្រឡេកទៅឃើញ**តៀវហ៊ុយ**បំបោលសេះចូលមកនៅពីមុខទាហាន កាន់លំពែងនៅដៃ **ឡៅពី**ត្រេកអរណាស់ស្រែកថា **តៀវហ៊ុយ**ជួយបងផង។ **តៀវហ៊ុយ**ឃើញ**ទៀវឃឹម**ដេញ**ឡៅពី**ជាប់ប្រកិតមក ក៏បរសេះសម្រុកចូលទៅជួយ**ឡៅពី** ស្កាត់ទទឹងពីមុខ**ទៀវឃឹម**ហើយក៏ចូលប្រយុទ្ធគ្នានឹង**ទៀវឃឹម**បានដប់ភ្លែង ទទួល**ងៀមង៉ាន់**បរសេះតាមក្រោយ**តៀវហ៊ុយ**ចូលទៅដល់ទៀត **ទៀវឃឹម**ឃើញដូច្នោះក៏ញាក់សេះថយរត់។ **តៀវហ៊ុយ**ក៏ដេញតាមប្រកិតទៅជិតជើងកំពែង **ទៀវឃឹម**ចូលទៅក្នុងស្រុកបានក៏ឲ្យបិទទ្វារជាប់ ហើយឲ្យទាហានបាញ់ធ្នូចម្រុះមកពីក្នុង។ **តៀវហ៊ុយ**ក៏ញាក់សេះវេះរត់ក្រោយមករក**ឡៅពី** ៗមានសេចក្ដីត្រេកអរណាស់ ក៏នាំ**តៀវហ៊ុយ**ចូលទៅក្នុងបន្ទាយ **តៀវហ៊ុយ**គំនាប់តាមប្រពៃណីហើយជម្រាបថា ឥឡូវអាចារ្យ**ខុងបេង**លើកកងទ័ពទូកមកតាមផ្លូវកឹមកាំង នៅមិនទាន់មកដល់ ខ្ញុំបាទមកដល់មុន ក៏ត្រឡប់បានសេចក្ដីគាប់ប្រសើរទៀត។ **ឡៅពី**សួរថា ផ្លូវនេះជាច្រកជ្រោះជ្រលងរំលោងព្រៃភ្នំធំញឹកញាតស្បាតណាស់ នឹងដើរដោយលំបាក មានទាំងគយល្បាតជាច្រើនសង្កាត់ ជាទីចង្អៀត ហេតុម្ដេចបានជាប្អូនឯងមកដល់មុន? **តៀវហ៊ុយ**ឆ្លើយថា ផ្លូវនេះមានគយល្បាតដល់សែសិបប្រាំអន្លើ ជាទីចង្អៀតលំបាកក៏មែន តែថាខ្ញុំបាទបានអ្នកចាស់ទុំ**ងៀមង៉ាន់**នេះ មានសេចក្ដីភក្ដីដោយសុចរិតជួយជូនដំណើរមកផង បើមុខដល់ទីតំបន់ណា ក៏អាចចេះនិយាយឲ្យភ្នាក់ងារនៅទីតំបន់នោះព្រមចុះចូលដោយស្រួលទាំងអស់ មិនប៉ាន់ទទឹងរឹងនឹងខ្ញុំបាទសោះ បានជាមកដោយស្រួល ឯសេចក្ដីគាប់ប្រសើររបស់លោកអ្នកចាស់នេះ

ជាប្រសើរលើសលុបគ្មានទីបំផុត។ ហើយ**តៀវហ៊ុយ**ក៏ពណ៌នារឿងរ៉ាវដែលបានច្បាំងគ្នានឹង**ងៀមង៉ាន់**នោះ ឲ្យ**ឡៅពី**ស្ដាប់គ្រប់ប្រការ។

**ឡៅពី**ដឹងសេចក្ដីដូច្នោះក៏ត្រេកអរណាស់ និយាយនឹង**ងៀមង៉ាន់**ថា គ្រានេះបើកុំបានអ្នកជាចាស់ មានសេចក្ដីមេត្តាករុណាដល់ប្អូនខ្ញុំ ឧស្សាហ៍នាំផ្លូវមកក៏គង់មានភ័យអន្តរាយពុំខាន ហើយបើគ្មានអ្នកជូនដំណើរមកទេ កាលណាប្អូនខ្ញុំនឹងបានមកដោយស្រួល។ គុណអ្នកមានដល់ខ្ញុំនឹងរកទីបំផុតគ្មាន និយាយហើយ**ឡៅពី**ក៏ដោះក្រោះមាសចេញពីខ្លួន ហុចឲ្យទៅ**ងៀមង៉ាន់**ជារង្វាន់តាមសេចក្ដីគាប់ ហើយសួរទាហានទាំងពួងថា នរណាអាចដឹងថា **អ៊ុយអៀន**និង**ហងតុង**ទាំងពីរនាយនៅឯណាជាប្រការម្ដេចខ្លះ?

ទាហានទាំងពួងជម្រាបថា កាលលោកបែកទ័ពត្រឡប់មកពីក្នុងស្នាមចំបាំងនោះ ខ្ញុំបាទឃើញ**ង៉ំអ៊ី** និង**ឡៅកុយ**លើកទ័ពជំនួនជូនចេញពីស្រុកឡុកសៀ វាយត្រឡប់ខ្ទប់ពីក្រោយ**អ៊ុយអៀន, ហងតុង**នៅក្នុងចំណោមបានប្រយុទ្ធគ្នាជាចលាចល **ហងតុង, អ៊ុយអៀន**លើសកម្លាំងធន់ពុំបាន ក៏នាំគ្នារត់ទៅទិសខាងកើត **តៀវហ៊ុយ**ឮដូច្នោះក៏និយាយនឹង**ឡៅពី**ថា នឹងស្ងៀមនៅពុំបានទេ ត្រូវតែលើកទៅជួយ សូមឲ្យលោកលើកទៅខាងស្ដាំខ្ញុំបាទលើកទៅខាងឆ្វេង វាយខ្ទប់ប្រសព្វគ្នា។ **ឡៅពី**យល់ត្រូវផង ក៏លើកទាហានចេញចាកបន្ទាយ ញែកគ្នាទៅជាមួយនឹង**តៀវហ៊ុយ**ម្នាក់មួយផ្លូវ ឯ**ង៉ំអ៊ី, ឡៅកុយ**ដែលលើកទាហានត្រឡប់ខ្ទប់**ហងតុង** និង**អ៊ុយអៀន**នោះបានឮសំឡេងទាហាន**ឡៅពី** និង**តៀវហ៊ុយ**ស្រែកហ៊ោគឹកកងរំពងចូលទៅក៏ភ័យណាស់ ដឹងថាកងទ័ព**ឡៅពី**លើកទៅខ្ទប់ស្ទាក់ផ្លូវនឹងទៅក៏ពុំបាន ទើបនាំទាហានវេះពីផ្លូវត្រឡប់វង់ចូលទៅក្នុងស្រុកវិញ។ **ឡៅពី**និង**តៀវហ៊ុយ**ក៏បង្ខំដេញទាហានឲ្យស្រួតតាមផ្លូវទៅ។

ឯ**ង៉ំឡាន់, លុយតង** មិនទាន់ដឹងខ្លួនថា **ឡៅពី, តៀវហ៊ុយ**លើកមកពីក្រោយក៏លើកទាហានស្រួតទៅ ដើម្បីនឹងខ្ទប់ចាប់យកខ្លួន**ហងតុង** និង**អ៊ុយអៀន**ឲ្យបាន។

**ហាងតុង** និង**អ៊ុយអៀន**ជូនជាទាល់ខ្លួនណាស់ ក៏ត្រឡប់សេះដេញទាហានចូលតយុទ្ធនឹង**ង៉ឡាន់, លុយតង** ទទួល**ឡៅពី, តៀវហ៊ុយ**លើកទៅទាន់ពីក្រោយ ក៏វាយខ្ទប់ប្រសព្វគ្នា។ **ង៉ឡាន់, លុយតង**ក៏នៅក្នុងចំណោមទ័ពដែលខ្ទប់នោះ ឃើញលើសកម្លាំងនឹងតពុំឈ្នះ ក៏ចុះពីលើសេះនាំទាហានទាំងអស់ចូលទៅគំនាប់**ឡៅពី**សុំចំណុះចុះចូល។ **ឡៅពី**ក៏ទទួលយកទុកធ្វើការជាមួយ ទើបចាត់ការឲ្យទាហានរៀបតាំងកធ្វើបន្ទាយជាប់គ្នា នឹងស្រុកឡុកសៀពីទិសខាងកើត។

**ទៀវយ៉ឹម**ដឹងថា **ង៉ឡាន់, លុយតង**ចុះចូលទៅនៅខាង**ឡៅពី**ហើយ ក៏កើតទុក្ខក្តៅក្នុងចិត្ត ទើបប្រឹក្សាគ្នានឹង**ង៉អ៊ី, ឡៅកុយ, ឡៅឈុន**ថា ឥឡូវ**ង៉ឡាន់** និង**លុយតង**ចូលទៅនៅខាង**ឡៅពី**ហើយ សត្រូវក៏ចូលមកតាំងប្រកិតគ្នាទល់នឹងជើងកំពែង ដូច្នេះ យើងនឹងនៅស្ងៀមម្តេចបាន? ត្រូវតែមានសំបុត្រប្តឹងទៅដល់**ឡៅជៀង**សុំកងទ័ពមកជួយ ហើយយើងនឹងបំបែកទាហានលើកចេញទៅវាយកុំឲ្យសត្រូវតាំងខ្លួនបាន។ **ង៉អ៊ី, ឡៅកុយ, ឡៅឈុន**ក៏យល់តាម។

**ទៀវយ៉ឹម**ទើបតែងសំបុត្រឲ្យបម្រើកាន់ទៅដល់**ឡៅជៀង** ហើយនិយាយនឹង**ឡៅឈុន**ថា វេលាព្រឹកនេះ យើងលើកទាហានចេញទៅច្បាំងនឹង**ឡៅពី** រួចធ្វើជាចាញ់ប្រៀបរត់ថយក្រោយតាមជើងកំពែងទៅទិសខាងជើង ឲ្យ**ង៉អ៊ី**លើកទាហានចេញទៅពួនបង្កប់ស្កាត់ផ្លូវខាងទិសនោះ បើឃើញទាហាន**ឡៅពី**ដេញតាមទៅ ឲ្យនាំគ្នាចេញមកស្ទាក់ផ្លូវវាយប្រសព្វគ្នា ទាហាន**ឡៅពី**មិនទាន់ដឹងខ្លួនក៏នឹងបែកបាក់ទៅឯង យើងនឹងបានជ័យជម្នះដោយងាយ។ ឯខ្លួន**ឡៅកុយ**នោះ ត្រូវឲ្យនៅរក្សាស្រុកជាមួយនឹងខ្លួនអ្នក ជួយគ្នាត្រួតត្រារក្សាទាហានវេលាយាមល្បាតកុំប្រមាទឡើយ។ លុះចាត់ការស្រេចហើយ ដល់ពេលព្រឹក**ទៀវយ៉ឹម**ក៏លើកទាហានស្រែកហ៊ោចេញពីក្នុងស្រុកទៅ។

**តៀវហ៊ុយ**ឃើញ**ទៀវយ៉ឹម**ចេញមក ក៏លើកទាហានចេញពីបន្ទាយឲ្យចូលច្បាំងប្រយុទ្ធគ្នានឹង**ទៀវយ៉ឹម**ជាជ្រួលច្របល់ **តៀវហ៊ុយ**បរសេះចូលតនឹង**ទៀវយ៉ឹម**

បានដប់ពីរភ្លេង **ទៀវយឹម**ធ្វើជាថយរត់ព័ទ្ធជើងកំផែងទៅខាងជើង **តៀវហ៊ុយ**ក៏បំផាយសេះស្ទុះតាមដោយកម្លាំងរហ័ស **ង៉អ៊ី**និងទាហានដែលបង្កប់នៅនោះ លុះឃើញ**តៀវហ៊ុយ**ហួសទៅដល់ក៏ចេញស្រមកស្ទាក់ពីក្រោយ។ **ទៀវយឹម**ក៏វាត្រឡប់ពីមុខមកតចោមព័ទ្ធ**តៀវហ៊ុយ**នៅកណ្ដាលចំណោម ចោមបាញ់នឹងធ្នូពីមុខពីក្រោយឆ្វេងស្ដាំ។ **តៀវហ៊ុយ**នៅក្នុងចំណោមទ័ពមិនដឹងនឹងធ្វើប្រការម្ដេច ចេះតែយកលំពែងគ្រវាសវាត់ព្រួញជុំវិញខ្លួន ទទួល**ជូឡុង**លើកទ័ពទូកមកដល់ ក៏លើកទាហានឡើងគោកស្រូតទៅជួយ**តៀវហ៊ុយ** ក្នុងមួយរំពេចនោះ វាយទម្លាយទ័ព**ង៉អ៊ី**ពីក្រោយចូលទៅកាប់សម្លាប់ទាហានជាច្រើនណាស់ ដែលនៅសល់ពីស្លាប់នោះក៏បែកខ្ចាត់ខ្ចាយអស់ទៅ។ **ជូឡុង**ក៏ចាប់ខ្លួន**ង៉អ៊ី**បាន **តៀវហ៊ុយ**បានការក៏បរពលចូលជាជ្រួលច្របល់កាប់សម្លាប់ទាហាន**ទៀវយឹម**បែករត់ចូលស្រុក។

**តៀវហ៊ុយ**ឃើញ**ជូឡុង**ក៏សួរថា ឥឡូវ**ខុងបេង**នៅឯណា? **ជូឡុង**ប្រាប់ថា **ខុងបេង**មកដល់ហើយ កំពុងអង្គុយនិយាយនឹង**ឡៅពី** តែខ្លួនខ្ញុំលើកពលមកជួយអ្នក។ **តៀវហ៊ុយ** និង**ជូឡុង**មានសេចក្ដីរួសរាយនឹងគ្នា បបួលគ្នានាំយកខ្លួន**ង៉អ៊ី**មកបន្ទាយ ឃើញ**ខុងបេង**អង្គុយសន្ទនានឹង**ឡៅពី**។ **តៀវហ៊ុយ**ក៏ចូលទៅគំនាប់។ **ខុងបេង**សួរថា អ្នកឯងធ្វើម្ដេចបានជាមកដល់មុនយើង? **តៀវហ៊ុយ**ក៏ពណ៌នាឲ្យ**ខុងបេង**ស្ដាប់តាមរឿងដែលបានធ្វើការច្បាំងរៀងមកតាមផ្លូវគ្រប់ប្រការ។ **ខុងបេង**ក៏និយាយនឹង**ឡៅពី**ថា **តៀវហ៊ុយ**នេះពីដើមមកមានចិត្តកាចសាហាវណាស់ ឥឡូវហេតុម្ដេចក៏ចេះមករម្ងាប់ចិត្តបាន ស៊ូយករាជការជាប្រមាណ ដែលចេះអត់ចិត្តបានយ៉ាងនេះពីព្រោះបុណ្យលោកជាប្រធាន។

ខណៈនោះ **ជូឡុង**ក៏នាំខ្លួន**ង៉អ៊ី**ចូលទៅជូន**ឡៅពី** ៗក៏សួរថា ខ្លួនអ្នកនៅក្នុងកណ្ដាប់ដៃយើងដូច្នេះហើយ នឹងចំណុះចុះចូលឬនឹងគិតប្រការម្ដេច? **ង៉អ៊ី**ឆ្លើយថា ខ្លួនខ្ញុំបាទលោកចាប់យកមកនៅក្នុងអំណាចលោក ខ្ញុំបាទក៏សុំនៅជាខ្ញុំលោក ថាហើយក៏ឱនគំនាប់តាមប្រពៃណី។ **ឡៅពី**បានឃើញដូច្នោះក៏ចុះទៅស្រាយចំណង

ចេញពីខ្លួន**ង៉ំអ៊ី**។ **ខុងបេង**ក៏សួរទៅទៀតថា នរណាដែលនៅរក្សាស្រុកឡុកសៀនោះ? **ង៉ំអ៊ី**ឆ្លើយថា **ឡៅឈុន**ជាបុត្រ**ឡៅជៀង**មកនៅឈររក្សាស្រុក ឯទាហានមានតែ**ឡៅកុយ** និង**ទៀវយឹម** ៗជាទាហានឯកក្នុងស្រុកសែឈ្មួនមានថ្វីដៃខ្លាំងពូកែណាស់។

**ខុងបេង**ដឹងដូច្នោះទើបគិតថា នឹងធ្វើការដូចម្តេចឲ្យបានខ្លួន**ទៀវយឹម**ជាមុនសិន ទើបនឹងយកស្រុកសែឈ្មួនបានដោយស្រួល ទើប**ខុងបេង**ឡើងសេះនាំទាហានទៅមើលទីកន្លែងនឹងចូលធ្វើការនោះ លុះទៅដល់ត្រង់ទ្វារគយទិសឯកើត ឃើញព្រៃឫស្សីមួយអន្លើឆ្ងាយពីស្ពានគិមង៉ាន់កៀវប៉ោប្រមាណហុកសិបសិន (២៤០០ម) ទើបឲ្យ**ហាងតុង** និង**អ៊ុយអៀន**ឃុំទាហានម្នាក់មួយពាន់ ចូលទៅពួនបង្កប់ក្នុងព្រៃនោះទាំងសងខាងផ្លូវឆ្វេងស្តាំ ហើយបង្គាប់ថា បើ**ទៀវយឹម**លើកចេញមក ឲ្យវាយខ្ទប់ទាំងសងខាង ឲ្យ**តៀវហ៊ុយ**ឃុំទាហានមួយកងទៅស្កាត់នៅចុងផ្លូវ ឲ្យ**ជូឡុង**ឃុំទាហានមួយកងទៅបង្កប់ខាងទិសឯជើង ហើយផ្តាំថា បើយើងបញ្ឆោត**ទៀវយឹម**ឲ្យលើកទាហានដេញកន្លងចូលផុតស្ពានហួសមក ក៏ឲ្យលើកចេញស្ទាក់ផ្លូវទុក ហើយរើស្ពានចេញឲ្យអស់ កុំឲ្យ**ទៀវយឹម**ត្រឡប់ចូលស្រុកវិញបាន ហើយឲ្យ**ឡៅពី** និង**ងៀមង៉ាន់**ឃុំទាហានអែបនៅខាងខាងត្រើយដើមស្ពាន ចេញទៅចម្ងាយប្រហែលម្ភៃសិន (៨០០ម)។ លុះ**ខុងបេង**ចាត់ចែងរៀបចំរួចហើយ ក៏ឡើងរទេះតូចមួយតែងខ្លួនយ៉ាងសមរម្យ នាំទាហានប្រហែលសាមសិបនាក់ចូលទៅបញ្ឆោត**ទៀវយឹម**ឲ្យចេញមក។

**ទៀវយឹម**ឃើញ**ខុងបេង**ឃុំទាហានចូលទៅឡុកចំអកឲ្យ ក៏ខឹងណាស់ ចាត់ចែងទាហានលើកទៅច្បាំងមួយរំពេច ខណៈកាល**ទៀវយឹម**បកសំបុត្រទៅដល់**ឡៅជៀង**សុំកងទ័ពឲ្យលើកមកជួយនោះ **ឡៅជៀង**ក៏ចាត់ប្រើ**តោអេង**ឃុំទាហានលើកមកឯស្រុកឡុកសៀ **ទៀវយឹម**ក៏ឲ្យ**ទៀវអេក**នៅរក្សាស្រុក ឲ្យ**តោអេង**ឃុំទាហានជាកងក្រោយលើកចេញចាកស្រុក លុះឃើញ**ខុងបេង**ជិះរទេះតូច ឃុំ

ទាហានប្រហែលសាមសិបនាក់ដើរព័ទ្ធមក ក៏ចង្អុលប្រាប់ទាហានថា **ខុងបេង**នោះ យើងបានឮល្បីថាមានប្រាជ្ញា សេចក្តីគិតដឹងតែងកលសឹកបញ្ឆោតជាច្រើនប្រការណាស់ ឥឡូវយើងឃើញធ្វើការចូលមកដូចជាមនុស្សគ្មានប្រាជ្ញាអ្វីសោះ ដូចជាមិនសមនឹងពាក្យដែលឮល្បីនោះឡើយ នឹងខ្លាចអ្វីបែប**ខុងបេង**ប៉ុណ្ណោះ ថាហើយក៏យកដងលំពែងបោះឲ្យទាហានស្ទុះចូលទៅនឹងចាប់យកខ្លួន**ខុងបេង**។

**ខុងបេង**ឃើញ**ទៀវយឹម**ដេញតាមមក ក៏លោតចោលរទេះឡើងសេះបកត្រឡប់មកក្រោយ ធ្វើហាក់បីដូចជាខ្លាច នាំទាហានទាំងអស់រត់ឆ្លងស្ពានទៅត្រើយម្ខាង **ទៀវយឹម**បានការក៏ដេញទាហានលើកតាមទៅ **ជូឡុង**ក៏លើកទាហានចេញស្កាត់ទទឹងពីក្រោយស្ពាន ហើយឲ្យទាហានរុះរើស្ពានចេញអស់ **ឡៅពី**និង**ង៉ៀមង៉ាន់** ឃើញបានការក៏លើកទាហានចេញស្កាត់ទាំងសងខាងផ្លូវ។ **ទៀវយឹម**ឃើញដូច្នោះក៏ភ័យស្លុត គិតឃើញថា**ខុងបេង**តែងកលឧបាយបញ្ឆោត ក៏នាំទាហានលោតរត់ត្រឡប់នឹងចូលទៅក្នុងស្រុកវិញ លុះដល់ចុងស្ពាន ឃើញរុះរើអស់ នឹងឆ្លងទៅពុំរួចក៏នៅស្លាំងកាំងទាំងអស់គ្នា។ **ជូឡុង**ក៏ឲ្យទាហានវាយប្រសព្វចូលទៅ **ទៀវយឹម**ក៏បាក់ទ័ពរត់ត្រឡប់តាមផ្លូវទិសខាងត្បូង ដល់ទី**ហងតុង** និង**អ៊ុយអៀន** ៗក៏ចេញមកស្កាត់ទ័ពពីមុខ និងសងខាង កាប់សម្លាប់ទាហាន**ទៀវយឹម**ស្លាប់ជាច្រើនណាស់ **ទៀវយឹម**ឃើញលើសកម្លាំងនឹងតស៊ូពុំបាន នាំទាហានប្រមាណសាមសិបនាក់បរសេះស្រូតរត់ទៅប្រទះនឹង**តៀវហ៊ុយ**ស្ទាក់ពីចុងផ្លូវនៅទទឹងមុខ សុទ្ធតែគ្រឿងអាវុធចេញមកគគុកគគាក់ ហើយ**តៀវហ៊ុយ**ស្រែកពញ្ញាក់ដោយសំឡេងខ្លាំង ទាហាន**ទៀវយឹម**ក៏ភ័យស្លុតស្មារតីបែកខ្ចាត់ខ្ចាយទៅអស់។ **តៀវហ៊ុយ**ក៏ដេញទាហានចូលចោមព័ទ្ធចាប់យកខ្លួន**ទៀវយឹម**បាន។ **តោអេង**ឃើញ**តៀវហ៊ុយ**ចាប់ខ្លួន**ទៀវយឹម** ហើយយល់ថានឹងខំច្បាំងតទៅពុំឈ្នះទ័ព**ឡៅពី** ក៏នាំគ្នាចូលទៅគំនាប់ចុះចូល។ **ជូឡុង, តៀវហ៊ុយ** នូវអស់នាយទ័ពនាយកងទាំងពួង លុះបានជ័យជម្នះហើយ ក៏នាំគ្នាលើកត្រឡប់ទ័ពមកបន្ទាយ។ **ជូឡុង**ទើបយកខ្លួន**តោអេង**ទៅជូន**ឡៅពី** ៗក៏មិន

បានយកទោស**តោអេង** ត្រឡប់ឲ្យបំណាច់រង្វាន់ទៅវិញ។ ខណៈនោះ **តៀវហ៊ុយ**ក៏នាំយកខ្លួន**ទៀវយឹម**ចូលទៅជូន**ឡៅពី** ៗសួរថា បណ្ដានាយទាហានដែលមានក្នុងស្រុកសែឈួននេះ ក៏រមែងខ្លាចអំណាចយើងចូលមកគំនាប់អស់ហើយ នៅតែខ្លួនអ្នកឯងមួយនេះ ហេតុម្ដេចទើបមករឹងទទឹងនឹងយើងខ្លាំងម្ល៉េះ? ដែលខ្លួនមិនព្រមចុះចូលយើងដូច្នេះ ព្រោះគិតឃើញប្រការម្ដេច?

**ទៀវយឹម**ឮ**ឡៅពី**និយាយដូច្នេះក៏ខឹងណាស់ មិនបានខ្លាចដល់សេចក្ដីស្លាប់ ស្រែកគំហកថា ខ្លួនយើងជាជាតិទាហានមិនមានខ្លាចអន្ដរាយស្លាយជីវិត គិតត្រឡប់ទៅចំណុះចុះចូលដល់អ្នកដទៃប្រាថ្នានឹងរក្សាជីវិតវិញ មិនស្រឡាញ់ស្រុកនោះក៏មិនគួរជាមនុស្សទៀងត្រង់នឹងនាយចៅហ្វាយ ធម្មតាស្រីដែលល្អក៏មិនត្រូវប្រាថ្នាស្វាមីដល់ពីរ បើលោកនឹងបង្ខំឲ្យយើងចំណុះចុះចូលនោះ បើទទឹងពុំឈ្នះក៏ត្រូវតែគំនាប់ទៅ តែយើងនៅមិនមានចិត្តនឹងគិតភក្ដីមេត្រីដល់លោកទេ ហើយក៏ជេរ**ឡៅពី**ជាពាក្យទ្រគោះអសុរោះខ្លាំងណាស់។ **ខុងបេង**ឮដូច្នោះក៏ខឹងណាស់ បង្គាប់ឲ្យទាហាននាំខ្លួន**ទៀវយឹម**ទៅប្រហារជីវិតបង់។

**ឡៅពី**ឃើញថា**ទៀវយឹម**ជាមនុស្សត្រង់សុចរិតនឹងនាយចៅហ្វាយ ក៏ឲ្យមានចិត្តគិតសង្វេគ ទើបនាំយកសព**ទៀវយឹម**ទៅបញ្ចុះទុកនៅទីដើមស្ពានគិមង៉ាន់កៀវប៉ោ ហើយនាំឲ្យចារឹកអក្សរដាក់នៅថ្មផ្លាក់ទុកថា “**ទៀវយឹមជាមនុស្សត្រង់**” ប្រាថ្នានឹងឲ្យមនុស្សទាំងពួងយកតួយ៉ាងតទៅមុខ។

លុះព្រឹកឡើង **ឡៅពី**ប្រើ**ង៉ៀមង៉ាន់**និង**ង៉ឹអ៊ី** នូវបណ្ដានាយទាហានកូនទាហានក្នុងស្រុកសែឈួន ដែលចូលមកនៅនឹង**ឡៅពី**នោះ លើកទាហានជាមុខចូលទៅក្នុងស្រុកឡុកសៀ លុះទាហានលើកទៅដល់ជើងកំផែងហើយ ក៏ស្រែកហៅ**ឡៅឈុន**និង**ឡៅកុយ**ថា ការប្រទាល់គួរដល់ប៉ុណ្ណោះហើយ កុំបីរឹងទទឹងតទៅទៀតឡើយ ចូរប្រញាប់បើកទ្វារចេញមកគំនាប់**ឡៅពី**ដោយល្អទៅចុះ ទោះនឹងខំមានៈនៅក៏ឃើញ

ថានឹងរក្សាការពារស្រុកនេះពុំបានទេ កុំឲ្យមកបានសេចក្ដីក្ដៅក្រហាយដល់អាណាប្រជានុរាស្ត្រទាំងពួងឡើយ។

**ឡៅកុយ**ឈរនៅលើកំពែង បានឮសំឡេងស្រែកឡើងទៅដូច្នោះ ក៏ខឹងណាស់ ស្រែកតបមកវិញជាពាក្យទ្រគោះអសុរោះ មិនមានគួរសមនឹងចំណុះចុះចាញ់។ **ងៀមង៉ាន់**ឃើញ**ឡៅកុយ**មានចិត្តព្រហើនកោងកាចដូច្នោះក៏ខឹងណាស់ ចាប់លំពែងនឹងពួយឡើងទៅ ទទួល**ទៀវអេក**កាត់ក្បាល**ឡៅកុយ**ទម្លាក់ចុះមកឲ្យ ហើយក៏បើកទ្វារស្រុកចេញមកទទួល**ងៀមង៉ាន់** ៗមានចិត្តត្រេកអរណាស់ ទើបនាំទាហានទាំងពួងចូលទៅក្នុងស្រុក។

**ឡៅឈុន**ឃើញទាហាន**ឡៅពី**ចូលស្រទៅ ក៏ឲ្យបើកទ្វារទិសខាងកើតនាំទាហានស្រូតរត់ចេញទៅស្រុកសែឈួន លុះ**ឡៅពី**ចូលទៅក្នុងស្រុកហើយក៏សួរថា នរណាមានសេចក្ដីស្វាមីភក្ដិនឹងយើង បានកាត់ក្បាល**ឡៅកុយ**ទម្លាក់មកឲ្យនោះ? **ងៀមង៉ាន់**ឆ្លើយថា **ទៀវអេក**នោះដែលមកគំនាប់លោក បានកាត់ក្បាល**ឡៅកុយ**ទម្លាក់បោះមកឲ្យ។ **ឡៅពី**ក៏ឲ្យបំណាច់រង្វាន់ដល់**ទៀវអេក**ជាច្រើន ហើយក៏ចាត់ចែងអ្នកស្រុកឲ្យនៅជាសុខមិនឲ្យទាហានណាទៅបៀតបៀនឲ្យកើតអន្តរាយ។

**ខុងបេង**ថា ឥឡូវស្រុកឡុកសៀបានមកយើងហើយ ឯស្រុកសែឈួនក៏ដូចជានៅក្នុងកណ្ដាប់ដៃយើងដែរ បើយើងនឹងលើកទៅវាយយកវេលាណាក៏បាន តែអាណាខេត្តដែលត្រូវចំណុះស្រុកសែឈួននោះមិនទាន់រាបទាប សុំឲ្យលោកចាត់**ទៀវអេក** និង**ង៉ុំអ៊ី**ឲ្យនាំ**ជូឡុង**លើកទាហានទៅប្រាបប្រាមស្រុកតេងតាំង ឲ្យ**ងៀមង៉ាន់**និង**តោអេង**នាំ**តៀវហ៊ុយ**លើកទាហានទៅសង្កត់ស្រុកតេកយ៉ុង ដែលនៅរឹងទទឹងនោះឲ្យចុះចូលជាប្រក្រតី ចាត់ចែងមុខមន្ត្រីឲ្យនៅរក្សាស្រុកតាមភូមិលំនៅស្រេចហើយ ទើបឲ្យលើកកងទ័ពទៅវាយយកស្រុកសែឈួនឲ្យព្រមគ្នា។ នាយទ័ពនាយកងទាំងពួង លុះបានទទួលការដែល**ខុងបេង**ចាត់ចែងដូច្នេះហើយ ទាំងអស់គ្នាក៏លើកទាហានចេញទៅ។

**ខុងបេង**ក៏សួរអ្នកស្រុកសែឈ្នួនថា យើងនឹងលើកទ័ពទៅវាយយកស្រុកសែឈ្នួនក្នុងគ្រានេះ តើតាមផ្លូវដែលនឹងលើកទៅនោះ មានគយបន្ទាយជាទីរាំងផ្លូវនៅប៉ុន្មានអន្លើ? ពួកអ្នកស្រុកឆ្លើយជម្រាបថា មានគយកឹមកុក ជាបន្ទាយធំមាំមួនណាស់នៅតំបន់នោះ មួយទៀត គយកឹមកុកនោះទាហានក៏ស្រុះស្រួល ទាំងខ្លាំងពូកែមានថ្វីដៃណាស់ បើវាយបានបន្ទាយនោះហើយ ក៏មិនមានទីដទៃនឹងទទឹងទៀតបាន នឹងលើកទៅវាយយកស្រុកសែឈ្នួនបានដោយងាយណាស់។

**ខុងបេង**ដឹងដូច្នោះ ក៏ឲ្យប្រុងប្រៀបរៀបទាហាននឹងលើកទៅ **ហួតចេង**ថា ដែលលោកនឹងលើកទៅវាយយកស្រុកសែឈ្នួននោះ ខ្ញុំបាទយល់ឃើញថា អាណាប្រជានុរាស្ត្រនឹងបានសេចក្តីក្តៅក្រហាយណាស់ សុំឲ្យលោកបង្អង់កងទ័ពទុកសិន ព្រោះស្រុកឡុកសៀក៏បានជារបស់លោកហើយ ស្រុកសែឈ្នួនដូចនៅក្នុងកណ្តាប់ដៃលោកដែរ។ ខ្ញុំបាទនឹងមានសំបុត្រទៅដល់**ឡៅជៀង**មួយច្បាប់ ឲ្យចេញមកចំណុះចុះចូលលោកតាមប្រពៃណី **ឡៅជៀង**ដឹងថាស្រុកឡុកសៀនេះបានមកលោកហើយ ក៏នឹងព្រមចំណុះមិនខាន បើជារឹងទទឹងប្រការម្តេច សឹមយើងលើកទ័ពទៅវាយជាក្រោយ។ **ខុងបេង**យល់ត្រូវផង ទើបឲ្យបង្អង់កងទ័ពឈប់ ហើយឲ្យ**ហួតចេង**មានសំបុត្រទៅដល់**ឡៅជៀង**។

ឯ**ឡៅឈុន** លុះរត់ទៅដល់ស្រុកសែឈ្នួនហើយ ក៏ពណ៌នាប្រាប់ហេតុដំណើរឲ្យបិតាស្តាប់គ្រប់ប្រការ **ឡៅជៀង**ក៏ឲ្យប្រមូលមន្ត្រីខ្ញុំរាជការចូលមកប្រឹក្សាថា ឥឡូវស្រុកឡុកសៀខូចហើយ មុខជា**ឡៅពី**នឹងលើកទ័ពចូលមកភ្ជាប់ដល់ស្រុកយើងឯនេះទៀតជាប្រាកដណាស់ យើងនឹងគិតការពារយ៉ាងណាឲ្យបានគង់ល្អតទៅ?

**តែ-ត** ទីប្រឹក្សាឆ្លើយថា **ឡៅពី**បានស្រុកឡុកសៀក៏មែន តែពួកទាហានសុទ្ធតែជាមនុស្សផ្តេសផ្តាស ព្រោះច្រើនតែពួកឈ្លើយ មិនបានជាចិត្តមួយនឹងជួយធ្វើការឲ្យអស់ពីចិត្តទេ នឹងធ្វើការក៏ពុំសូវព្រមព្រៀងគ្នា ហើយតិចតួចផង មិនធួននឹងធ្វើសង្គ្រាមនឹងយើងបាន សុំឲ្យលោកចាត់មនុស្សចេញទៅបណ្តេញកៀរយកអាណា

ប្រជានុរាស្ត្រក្នុងស្រុកប៉ាសេទិសខាងលិច ឲ្យឆ្លងស្ទឹងប៉ោស៊ុយចូលមកនៅត្រើយខាងស្រុកយើងឲ្យអស់ ហើយឲ្យដុតបំផ្លាញស្បៀងអាហារដែលនាំយកមិនបាននៅសល់ប៉ុន្មាននោះឲ្យអស់កុំឲ្យទុក បើ**ឡៅពី**នឹងលើកទ័ពមកព័ទ្ធស្រុកយើង ស្បៀងអាហារក្នុងស្រុកយើងក៏មានច្រើនបរិបូរ ត្រូវតែខំរក្សាស្រុកទុកឲ្យមាំ កុំឲ្យធ្វើវិនាសបាន ឯ**ឡៅពី**មកពីស្រុកឆ្ងាយ គង់នឹងអស់ស្បៀងអាហារ បើទ្រាំនៅយូរតទៅយកស្រុកយើងមិនបាន អស់ផុតស្បៀងអាហារវេលាណាសេនាទាហានមានតែថយកម្លាំងចុះ ទោះនឹងធ្វើការក៏មិនពេញដៃ មុខជានឹងលើកទ័ពត្រឡប់ទៅឯង ទាហានយើងមានកម្លាំងស្រុះស្រួលគ្នា ក៏នឹងលើកចោមវាយយកស្រុកវិញខាងចុងដែរ មុខជានឹងចាប់**ឡៅពី**បានដោយងាយ។

**ឡៅជៀង**ថា ធម្មតាសត្រូវមកធ្វើអន្តរាយ គួរតែរកឧបាយការពាររក្សាស្រុកទុក កុំឲ្យអាណាប្រជានុរាស្ត្របានសេចក្ដីក្ដៅក្រហាយ នេះសត្រូវលើកមកមិនទាន់នឹងបានច្បាំងតកម្លាំងគ្នាឲ្យឃើញយ៉ាងណា ស្រាប់តែទៅកៀរយកគ្រួសារអ្នកស្រុកឲ្យកើតទុក្ខព្រាត់ទីលំនៅបានសេចក្ដីក្ដៅក្រហាយទទេៗ យើងគ្នេរមិនយល់ឃើញផងសោះ។ កាល**ឡៅជៀង**កំពុងប្រឹក្សានោះ ទទួល**អ៊ុយគួន**យកសំបុត្រ**ហ្លួតចេង**ចូលទៅឲ្យ**ឡៅជៀង** ៗហែកស្រោមមើលឃើញសេចក្ដីថា ខ្ញុំបាទ**ហ្លួតចេង** សូមគំនាប់មកដល់លោកជ្រាប ព្រោះពីដើមលោកមានចិត្តស្រឡាញ់**ឡៅពី**ដោយសុចរិតមិនមានគិតវង្កៀសពីអ្វីសោះ បានជាប្រើខ្ញុំបាទឲ្យនាំទាហានទៅទទួល**ឡៅពី**មកដល់ស្រុកសែឈួន ប្រាថ្នានឹងឲ្យជួយផ្ទុបផ្ទួនការពាររក្សាស្រុកឲ្យមានសេចក្ដីសុខតទៅ ឥឡូវលោកមកជឿកាន់យកពាក្យសម្ដីមនុស្សញុះញង់ លោកក៏មិនបានស្ទង់ពិគ្រោះឲ្យហ្មត់ចត់ ទើបបានសេចក្ដីព្រាត់ប្លាតមេត្រី**ឡៅពី**ទៅវិញត្រឡប់បានសេចក្ដីទោមនស្សជាទុក្ខម្នេញទៅជាសត្រូវនឹងគ្នា ឯ**ឡៅពី**ក៏បានធ្វើការធំលើសលុបមិនឈប់បង្អង់មកដល់ប៉ុណ្ណោះហើយ មួយទៀតអាណាខេត្តឯទៀតក៏ចំណុះចុះចូលទៅខាង**ឡៅពី**អស់ហើយ នៅឡើយតែត្រឹមស្រុកសែឈួនប៉ុណ្ណោះ សូមឲ្យលោកត្រិះរិះ

ប្រែប្រួលសម្រួលតាមកាលៈទេសៈ គួរនឹងចំណុះចុះចូល**ឡៅពី**តាមប្រពៃណីទៅវិញស្រួលជាជាង ព្រោះ**ឡៅពី**ជាមនុស្សប្រកបដោយស័ត្យពិតត្រង់ល្អណាស់ ហើយមានចិត្តនោះស្មោះសរស្រឡាញ់អ្នកទាំងពួង គ្មានអាឃាតព្យាបាទនរណា បើលោកពិគ្រោះពិចារណាឃើញគួរនឹងការហើយ ក៏ឲ្យចេញមកគំនាប់តាមស្រួលទៅចុះ ដើម្បីនឹងបានសេចក្ដីសុខតទៅ **ឡៅពី**មិនមានចង់សត្រូវនឹងលោកជាប្រាកដ។

**ឡៅជៀង**មើលចប់សេចក្ដីខឹងណាស់ ឈ្លីសំបុត្រនោះចោលមួយរំពេច ហើយជេរថា អាចោរលក់ម្ចាស់ វាពោលមកយ៉ាងនេះ ប្រាថ្នានឹងយកប្រយោជន៍ចំពោះខ្លួនវា បង់កម្លាំងដែលបានទំនុកបម្រុងឲ្យវាមានយសស័ក្តិរៀងមក វាមិនយកចិត្តស្រឡាញ់ឯងដោយស្មោះត្រង់បង់សេចក្ដីកតញ្ញូសោះ ហើយក៏បណ្ដេញអ្នកកាន់សំបុត្រនោះឲ្យថយចេញមួយរំពេច ទើបប្រើ**អ៊ុយហួន**ជាប្អូនភរិយា និង**លីយៀម**ឲ្យលើកទាហានបីម៉ឺនទៅរក្សាគយកឹមកុកទុកឲ្យមាំមួន។ **តាំងហោ**ទីប្រឹក្សាក៏ចូលទៅនិយាយនឹង**ឡៅជៀង**ថា សុំឲ្យលោកមានសំបុត្រទៅដល់**ទៀវឡូ**ចៅហ្វាយស្រុកហាន់តុង សូមឲ្យលើកកងទ័ពមកជួយចុះ មុខជាតស៊ូនឹង**ឡៅពី**បាន។ **ឡៅជៀង**ថា ដែលអ្នកនឹងឲ្យទៅសុំកងទ័ពស្រុកហាន់តុងមកជួយនោះ **ទៀវឡូ**និងយើងក៏ជាសត្រូវនឹងគ្នា កាលណាគេនឹងមកជួយ។

**តាំងហោ**ថា ទោះបី**ទៀវឡូ**ទាស់អធ្យាស្រ័យនឹងយើងយ៉ាងណាតែវេលានេះ **ឡៅពី**ធ្វើការធំលើសលុបខ្លាំងណាស់ បើបានស្រុកសែឈ្នួនវេលាណា ក៏គង់នឹងទន្ទ្រានទៅយកស្រុកហាន់តុងទៀតជាប្រាកដ ព្រោះស្រុកសែឈ្នួនដូចនៅត្រង់រឹមបបូរមាត់ ស្រុកហាន់តុងឧបមាដូចធ្មេញ បើបបូរមាត់ភ្លាត់ច្រហាទៅហើយ មិនលែងឡើយនឹងឃើញធ្មេញនោះ ព្រោះនៅជិតគ្នាណាស់ សូមឲ្យលោកមានសំបុត្រទៅនិយាយទុកថា **ឡៅពី**វេលានេះធ្វើការមានកម្លាំងជិតពេញផែនដីទៅហើយ សុំឲ្យ**ទៀវឡូ**រិះគិតជួយទៅវិញទៅមកកុំឲ្យអន្តរាយស្រុកទាំងសងខាង **ទៀវឡូ**ក៏គង់នឹង

គិតខ្លាចមិនអាចបង្អង់ឈប់ទេ យូរឆាប់ក៏គង់នឹងលើកពលរេហ៍មកជួយលោកទេ**ឡៅជៀង**យល់ឃើញត្រូវផង ក៏តែងសំបុត្រចាត់បម្រើឲ្យកាន់ទៅដល់**ទៀវឡូ**។

*លោកអ្នកអានអាចស្វែងរកសៀវភៅផ្សេងទៀតតាមរយៈប្លក់៖*

www.khmerliterature.wordpress.com

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៥៤

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ម៉ាឈៀវ**បែកទ័ពរត់ពី**ចូឆូ**ទៅ ទៅនៅស្រុកធៀវក្រៅស្រុកចិន ហើយវិលមកវាយស្រុកគីជីវ រហូតដល់**គួនអ៊ូ**មានបម្រើទៅសុំ**ឡៅពី**តស៊ូនឹង**ម៉ាឈៀវ**។ **ខុងបេង**មានសំបុត្រទៅឃាត់**គួនអ៊ូ** ៗក៏ឈប់ខានមិនបានចូលទៅដល់**ឡៅពី**។)*

**ឯម៉ាឈៀវ**កាលបែកទ័ពរត់ពី**ចូឆូ** ទៅពីទន្លេអ៊ុយហោ គ្រានេះក៏ទៅនៅស្រុកធៀវក្រៅដែនស្រុកចិនបានប្រហែលបីខែ ក៏បញ្ចុះបញ្ចូលទាហានបានជាច្រើន ក៏ទៅវាយយកអាណាខេត្តតំបន់ដែលចំណុះ**ចូឆូ**បានជាច្រើនអន្លើ ហើយក៏លើកទៅវាយស្រុកគីជីវ **អ៊ុយខង**ចៅហ្វាយស្រុកគីជីវ ឲ្យសំបុត្រទៅដល់**ហែហ៊ួអៀន**ឲ្យលើកទៅជួយ។ **ហែហ៊ួអៀន**ក៏ព្រងើយកន្តើយមិនសូវយកចិត្តទុកដាក់ មិនបានឲ្យដំណឹងទៅដល់**ចូឆូ** ៗមិនបានលើកទ័ពទៅជួយ**អ៊ុយខង**សោះ។ **អ៊ុយខង**ចេះតែចាំកងទ័ព**ហែហ៊ួអៀន**ជាយូរថ្ងៃណាស់ មិនឃើញលើកទៅសោះ កងទ័ព**ម៉ាឈៀវ**ក៏លើកព័ទ្ធស្រុក។ **អ៊ុយខង**គិតនឹងលើកទ័ពចេញទៅចំណុះចុះចូល**ម៉ាឈៀវ**។

ពេលនោះ**អៀវហ៊ួ**នាយទាហានចូលទៅស្រែកឃាត់ហាមថា ដែលនឹងលើកចេញទៅចំណុះចុះចូល**ម៉ាឈៀវ**តែម្តងនោះ ខ្ញុំមិនពេញចិត្តសោះ ព្រោះ**ម៉ាឈៀវ**ជាមនុស្សអកតញ្ញូនឹងចៅហ្វាយនាយ មិនបានសុចរិតពិតត្រង់សោះ ត្រូវការអ្វីនឹងចេញទៅចំណុះបើខុសក៏ស៊ូតែស្លាប់ក្នុងស្រុកតែម្តងទៅជាជាង។ **អ៊ុយខង**ថា ឥឡូវបើការបុផុជ្ជនទាល់តួមកដល់ប៉ុណ្ណេះហើយ អ្នកឯងនឹងមកឃាត់ហាមយើងមិនឲ្យចេញទៅចំណុះចុះចូលគេធ្វើម្តេចបាន។ **អ៊ុយខង**មិនស្តាប់ក៏បើកទ្វារស្រុកចេញទៅទទួល**ម៉ាឈៀវ**ឲ្យចូលទៅក្នុងស្រុកហើយគំនាប់តាមប្រពៃណី។ **ម៉ាឈៀវ**ទៅដល់

ស្រុកគីជីវហើយថា អ្នកឯងបើកទ្វារទទួលគំនាប់យើងគ្រានេះ នឹងបានចំណុះចុះចូលតាមសុភាពសុចរិតពិតត្រង់ក៏ទេ ហេតុពីព្រោះទាល់ច្រកនឹងរកទីចៀសវាងមិនបានហើយ បានជាធ្វើដូច្នេះ បើអ្នកឯងស្មោះត្រង់ភក្តីនឹងយើង ក៏គួរធ្វើពីដើមដំបូងតាមស្រួលទៅចុះ នេះពុំមែនធ្វើតាមអំពើសុចរិតពិតត្រង់ យូរទៅក៏គង់នឹងគិតប្រទូសរ៉ាយយើងវិញ យើងនឹងជឿទុកចិត្តក៏មិនបាន ថាហើយក៏បង្គាប់ទាហានឲ្យនាំយកខ្លួន**អ៊ុយខង**និងគ្រប់គ្រួទៅប្រហារជីវិតទាំងអស់។ ទាហានទាំងពួងក៏ជម្រាបថា **អៀវហ្ស៊ី**នេះជាទាហាន**អ៊ុយខង** កាលពីដើម**អ៊ុយខង**នឹងចង់ចេញមកគំនាប់លោកនោះ **អៀវហ្ស៊ី**ឃាត់ហាមទទឹងនឹងចិត្តលោក គឺគ្មានចិត្តភក្តីនឹងលោកសោះ សុំឲ្យលោកយក**អៀវហ្ស៊ី**ទៅសម្លាប់ចេញ។ **ម៉ាឈៀវ**ថា **អៀវហ្ស៊ី**ទទឹងទាស់ដូច្នោះជាប្រពៃណី ព្រោះជាមនុស្សទៀងត្រង់នឹងសម្លាប់ចេញពុំគួរ គួរតាំង**អៀវហ្ស៊ី**ឲ្យជានាហ្មឺនធំនៅរក្សាស្រុកគីជីវ។ **អៀវហ្ស៊ី**គំនាប់ហើយថា ឥឡូវភរិយាខ្ញុំបាទស្លាប់ ឯស្រុកលិមអៀ នឹងសុំលាលោកទៅតែងការសពមួយខែពីរខែសិន បើស្រេចការហើយ ខ្ញុំបាទនឹងត្រឡប់វិលមករកលោកវិញ។ **ម៉ាឈៀវ**ក៏ព្រមអនុញ្ញាតឲ្យ**អៀវហ្ស៊ី**ទៅ។ **អៀវហ្ស៊ី**លា**ម៉ាឈៀវ**ទៅដល់ស្រុកឡុកសេ ដែល**កៀវឃឹម**ជាកូនរបស់មាតារក្សាខេត្តនៅនោះ ក៏ត្រង់ចូលទៅរកមាតា**កៀវឃឹម** គំនាប់ហើយយំសោកថា ខ្លួនខ្ញុំបាទទៅនៅធ្វើការជាមួយនឹង**អ៊ុយខង**ឯស្រុកគីជីវ មិនបានការពាររក្សានាយចៅហ្វាយរបស់ខ្លួនឲ្យផុតសេចក្តីអន្តរាយ ទទួល**ម៉ាឈៀវ**អាសត្រូវផែនដីមកសម្លាប់**អ៊ុយខង**ទៅ ខ្ញុំបាទមិនដឹងបើនឹងគិតម្តេច ព្រោះខ្មាសមុខមិនដឹងនឹងយកទៅទុកឯណាបានឡើយ បានសេចក្តីអប្បយសដល់បណ្តាជនអ្នកស្រុកទាំងពួងខ្លាំងណាស់ ព្រោះធ្វើមនុស្សរក្សានាយចៅហ្វាយមិនបាន ឥឡូវអាណាប្រជានុរាស្ត្រក្នុងស្រុកគីជីវក៏ក្តៅក្រហាយឈឺចិត្តតែគ្រប់គ្នា គិតនឹងប្រទូសរ៉ាយ**ម៉ាឈៀវ**វិញឲ្យបានហេតុអ្វីបងខ្ញុំបានធ្វើដល់ចៅហ្វាយស្រុកឡុកសេ មិនបានចាត់ចែងទាហានលើកទៅជួយកម្ចាត់សត្រូវចេញ ខំនៅស្ងៀមទៅបាន មិនមានឈឺចិត្តសោះឡើយ។

មាតា**កៀវឃឹម**ជាចាស់មានអាយុ៨២ ឮដូច្នោះក៏ឲ្យហៅខ្លួន**កៀវឃឹម**មកប្រាប់ថា ឥឡូវស្រុកគីជីវ មានទ័ព**ម៉ាឈៀវ**លើកទៅប្រទូសរ៉ាយ **អ៊ុយខង**ក្ស័យជីវិតទៅហើយ ចៅក៏នៅព្រងើយមិនលើកទាហានទៅជួយ ទាល់តែអន្តរាយស្រុកបានទៅគេអស់ ទោសកំហុសក៏នឹងមានមកចំពោះខ្លួនចៅជាទម្ងន់មិនខាន បើដឹងការនេះទៅដល់**ចូឆូ**វេលាណាក៏នឹងយកទោសវេលានោះ ហើយនិយាយនឹង**អៀវហ៊ួ**ថា ខ្លួនចៅខាងនេះបានទទួលគំនាប់ជាប់ប្ដេជ្ញានឹង**ម៉ាឈៀវ** ៗក៏ជឿចិត្តឥតពិភាល់តម្កើងខ្លួនឲ្យធ្វើនាហ្មឺនបានស៊ីបៀវត្សគេហើយ ហេតុម្ដេចក៏គេចមកគិតមិត្តទ្រុសនឹងគេវិញ ទៅជាមនុស្សអកតញ្ញូនិរគុណគេទៅទៀត។ **អៀវហ៊ួ**ឆ្លើយថា ដែលខ្ញុំបាទចំណុះចុះចូល**ម៉ាឈៀវ**នោះមិនមែនជាការសុចរិតប្រាកដទេ ប្រាថ្នាគ្រាន់តែដោះជីវិតខ្លួនប៉ុណ្ណោះ ដើម្បីនឹងអនុគ្រោះដល់អ្នកស្រុក បានជាប្រែមុខមកដល់នេះ ព្រោះនឹងគិតធ្វើការសងសឹកវិញឲ្យបាន។ **កៀវឃឹម**ថា **ម៉ាឈៀវ**នោះមានថ្វីដៃខ្លាំងពូកែណាស់ ដែលនឹងគិតកម្ចាត់ចេញក៏កម្រ។ **អៀវហ៊ួ**ថា ទោះបីថ្វីដៃវាខ្លាំងពូកែក៏មែន តែមិនបានជាមនុស្សមានសតិបញ្ញាដែលនឹងយល់ការរាក់ជ្រៅក្នុងផ្លូវសង្គ្រាមប៉ុន្មានទេ ប្រសិនបើលោកនឹងគិតកម្ចាត់ចេញក៏គង់បាន។ កាលខ្ញុំបាទនឹងមកនោះ ក៏បានណាត់ការទុកនឹង**ឡេងខ្វាន់**, **ទៀវហេង** បើបងនឹងលើកទាហានទៅកម្ចាត់**ម៉ាឈៀវ**វេលាណា អ្នកទាំងពីរក៏នឹងទទួលជាកលសឹក ចាត់ការក្នុងស្រុកស្រាប់ហើយ។

មាតា**កៀវឃឹម**ថា បើដូច្នោះចូរទៅគិតកម្ចាត់ចេញឲ្យឆាប់ចុះ បើលុះទុកឲ្យយូរទៅគេក៏មានគំនិតគិតឃើញការម្យ៉ាងៗ យើងក៏ធ្វើគេពុំបាន មានសេចក្ដីលំបាក ធម្មតាកើតមកជាមនុស្សរាល់គ្នា នរណាៗក៏ត្រូវតែស្លាប់ម្ដងម្នាក់ដូចគ្នា បើចៅនឹងធ្វើសង្គ្រាមហើយ មិនត្រូវគិតខ្លាចសេចក្ដីស្លាប់នោះឡើយ។ មួយទៀតក៏មិនត្រូវគិតអាល័យរាមុខរាក្រោយដល់ម្ដាយនេះឡើយ បើថាព្រួយវិតក្កដល់ម៉ែហើយ ម៉ែក៏នឹងស្លាប់ឲ្យហើយរួចសឹមទៅចុះ។ ម្ដាយគិតនេះគឺកុំឲ្យព្រួយរវល់ដល់ទៅ**កៀវឃឹម** ៗ

ឮមាតាថា ក៏ចាត់ឲ្យ**ទៀវតាំង**ចាត់ចែងទាហានត្រៀមទុកព្រម រួចលើកទៅជាមួយ **អៀវហ្វ៊ឺ**។

**ម៉ាឈៀវ**លុះដឹងថា **អៀវហ្វ៊ឺ**ទៅប្រាប់**កៀវឃឹម**ឲ្យលើកទ័ពមកនឹងធ្វើអន្តរាយដល់ខ្លួនដូច្នោះក៏ខឹងខ្លាំងណាស់ តាំងតែលើកទាហានចេញពីស្រុកគីជីវទៅជាមួយ**បាំងតេក** និង**ម៉ាតាយ** ប្រាថ្នានឹងចាំរងទ័ព**កៀវឃឹម**។ លុះ**កៀវឃឹម**លើកទាហានទៅដល់កណ្ដាលផ្លូវក៏ប្រទះនឹងទ័ព**ម៉ាឈៀវ** ទើបបរសេះចេញទៅបញ្ឈរនៅមុខទាហានទាំងពួងហើយស្រែកថា អាស្រូវផែនដី ឯងបើចង់តស៊ូនឹងអញក៏ចូលមកចុះ។ **ម៉ាឈៀវ**ខឹងលើសកម្លាំង តាំងតែបរពលចូលវាយប្រកាប់ជាប់ដៃគ្នាសម្លាប់ទាហាន**កៀវឃឹម**ស្លាប់ច្រើនណាស់។ **កៀវឃឹម, អៀវហ្វ៊ឺ**តស៊ូមិនបាន ក៏បំផាយសេះរត់ **ម៉ាឈៀវ**បានទំនងក៏ចេញតាមទៅ។ **ទៀវតាំង**ទាហាន**កៀវឃឹម** ឃើញដូច្នោះ ក៏លើកទាហានស្ទាក់ទ័ពពីក្រោយ។ **កៀវឃឹម**ក្រឡេកមកឃើញក៏ត្រឡប់មុខមកតវិញ។ **ម៉ាឈៀវ**ក៏នៅក្នុងចំណោមទ័ព ចេះតែវាប់រងការពារខ្លួនទៅវិញទៅមក។

ទទួល**ហៃហ្វ៊ឺអៀន**លើកកងទ័ពស្រួចចូលមកប្រសព្វគ្នា ក៏ដេញទាហានឲ្យចូលប្រកាប់ប្រចាក់ជួយ**កៀវឃឹម**។ ទាហានទាំងបីកងក៏ចូលប្រយុទ្ធជុំវិញខ្លួន**ម៉ាឈៀវ** ៗលើសកម្លាំងនឹងតស៊ូពុំឈ្នះ ក៏ស្ទុះបំពារទម្លាយរត់ទៅ ដល់ភ្លឺស្រាង ល្មមទៅដល់ស្រុកគីជីវក៏ហៅឲ្យបើកទ្វារទទួល។ **ទៀវហង, ឡេងខ្វាន់** ដែលនៅក្នុងស្រុកនោះ មិនឲ្យបើកទ្វារទទួល។ **តាំងតែ**ឡើងលើកំពែង ហើយឲ្យទាហានបាញ់ធ្នូចម្រុះចុះមក ហើយស្រែកជេរមកចំពោះមុខ**ម៉ាឈៀវ** ៗឃើញដូច្នោះក៏ឈឺឆ្អលឆេះក្នុងចិត្ត ហាក់បីដូចភ្លើងគរលើដើមទ្រូងធ្លាក់ចុះពីលើសេះដល់បីប្អូនដង មិនដឹងដែលនឹងធ្វើប្រការម្ដេច។

ខណៈនោះ**ហៃហ្វ៊ឺអៀន**ឃុំទាហានលើកទ័ពតាមមកទាន់**ម៉ាឈៀវ** ៗទាហានតិចណាស់ ក៏វាយទម្លាយស្ទុះរត់ទៅ ទទួលប្រទះនឹងទ័ព**កៀវឃឹម**និង**អៀវហ្វ៊ឺ**ស្ទាក់

នៅពីមុខ **ម៉ាឈៀវ**បរសេះពុះពារទម្លាយទាហានទាំងឡាយចេញទៅផុតអស់។ **ទៀវតាំង**ក៏លើកជួនថែមទៅជាក្រោយ ក៏ចោមព័ទ្ធ**ម៉ាឈៀវ**ជុំវិញ កាប់សម្លាប់ទាហានស្លាប់ដេរដាស។ **ម៉ាឈៀវ, ម៉ាតាយ** និង**បាំងតេក**ឃើញទាហានសល់នៅប្រហែលហាសិបនាក់ ក៏បរសេះគេចនាំទាហានទាំងនោះស្ទុះរត់ចេញរួចទៅ តាំងពីថ្ងៃ លុះយប់ទៅដល់ស្រុកឡុកសេ ដើរទៅដល់ក្បែរកំផែង ទាហានក្នុងស្រុកឡុកសេមិនបានសង្កេតព្រោះយប់ងងឹតណាស់ សម្គាល់ថា**កៀវឃើម**ចៅហ្វាយស្រុក លើកត្រឡប់ទៅវិញក៏បើកទ្វារទទួល។ **ម៉ាឈៀវ**ក៏នាំទាហានកន្លងចូលទៅក្នុងស្រុកបាន ហើយដេញកាប់សម្លាប់អ្នកស្រុកស្លាប់ជាច្រើនណាស់ រួចចូលទៅចាប់យកម្តាយ**កៀវឃើម**មកក្រៅផ្ទះ។ មាតា**កៀវឃើម**មិនខ្លាចសេចក្តីស្លាប់ ចង្អុលមុខជេរ**ម៉ាឈៀវ**ថា អាសត្វត្រូវផែនដី អាឯងសម្លាប់អញជាស្រីក៏តាមចិត្តចុះ។ **ម៉ាឈៀវ**ខឹងណាស់ក៏យកគ្រប៊ីកាប់មាតា**កៀវឃើម**ស្លាប់។ លុះព្រឹកឡើង**ហែហ៊្វឺអៀន**ដឹងដំណឹងក៏លើកទាហានដិតតាមមកទៀត។ **ម៉ាឈៀវ**រត់ចេញពីស្រុកឡុកសេទៅ ក៏ជួបប្រទះនឹង**អៀវហ៊្វឺ**លើកទាហានតាមមកក្រោយទៀត **ម៉ាឈៀវ**ក៏បរសេះចូលប្រយុទ្ធនឹង**អៀវហ៊្វឺ** កាប់សម្លាប់ទាហាន**អៀវហ៊្វឺ**ស្លាប់ច្រើនណាស់។ **អៀវហ៊្វឺ**ត្រូវលំពែងពិការធ្ងន់ពន់ប្រមាណក៏មិនបានរត់ចូលតស៊ូនឹង**ម៉ាឈៀវ**ជាសាហ័ស ទទួល**ហែហ៊្វឺអៀន**លើកត្រឡប់តាមពីក្រោយជួយ**អៀវហ៊្វឺ**។ **ម៉ាឈៀវ**ក្រឡេកឃើញទាហានខ្លួនសល់តែប្រាំពីរនាក់ ក៏នាំ**បាំងតេក, ម៉ាតាយ**នូវទាហានទាំងនោះគេចទៅ។

**ហែហ៊្វឺអៀន**បានកម្ចាត់**ម៉ាឈៀវ**បែករត់ទៅហើយ ក៏លើកទាហានទៅប្រាបប្រាមអាណាខេត្តឡុកសេបានរាបទាបជាប្រក្រតីគ្រប់តំបន់ តាំងឲ្យ**កៀវឃើម**នៅរក្សាស្រុកនោះដូចដើម ទើបនាំយក**អៀវហ៊្វឺ**ដែលត្រូវរបួស ឡើងរទេះត្រឡប់ទៅក្រុងហ៊្វូតោ ប្តឹងការឲ្យ**ចូឆូ**ជ្រាបគ្រប់ប្រការ។ **ចូឆូ**ក៏មានសេចក្តីត្រេកអរណាស់ទើបតាំងឲ្យ**អៀវហ៊្វឺ**ជានាហ្មឺនធំ។

ខណៈកាល**ម៉ាឈៀវ**បែកទៅនោះ ក៏ប្រឹក្សានឹង**បាំងតេក, ម៉ាតាយ**ថា ឥឡូវនេះយើងនឹងរកទីអាស្រ័យមិនបានឡើយ នឹងទៅពឹងពាក់លើកស្រុកទិសឯកើតនិងឯលិចក៏សឹងជាដែនតំបន់របស់**ចូឆ្វូ**ទាំងអស់ យើងនឹងនាំគ្នាទៅប្រាស្រ័យនៅនឹង**ទៀវឡូ**ឯស្រុកហាន់តុងចុះ។ លុះប្រឹក្សាគ្នាហើយ **ម៉ាឈៀវ, បាំងតេក** និង**ម៉ាតាយ**ក៏នាំទាហានប្រាំនាក់ចូលទៅនៅក្នុងស្រុកហាន់តុងជាមួយនឹង**ទៀវឡូ** ៗក៏ទទួលរាប់អានស្រឡាញ់ពេញចិត្តណាស់ ទើបនិយាយនឹងទីប្រឹក្សាទាំងពួងថា ឥឡូវ**ម៉ាឈៀវ**មកនៅនឹងយើងហើយ ដែលយើងនឹងគិតធ្វើការទៅខាងមុខនោះឃើញថាស្រួលណាស់ ខាងទិសឯកើតក៏នឹងបានតស៊ូនឹង**ចូឆ្វូ** ខាងទិសឯលិចក៏នឹងគិតយកស្រុកសែឈួន គ្រានេះសត្រូវដែលមានខ្លួនក៏នឹងកោតក្រែងរអែងខ្លាច ព្រោះ**ម៉ាឈៀវ**មានអំណាចខ្លាំងពូកែមកជាកម្លាំងយើងហើយ គួរតែយើងនឹងលើកកូនក្រមុំយើងឲ្យយកគ្នាជាស្វាមីភរិយា នៅនឹងគ្នាតាមប្រវេណី។

**អៀវប៉េក**ហាមឃាត់ថា ដែលលោកនឹងលើកបុត្រីឲ្យជាភរិយា**ម៉ាឈៀវ**នោះ ខ្ញុំបាទមិនពេញចិត្តសោះ ព្រោះ**ម៉ាឈៀវ**នោះអភ័ព្វនឹងរក្សាបុត្រភរិយារបស់ខ្លួនក៏មិនគង់ម្ដងទៅហើយ វេលានេះបើលោកលើកបុត្រីទៅទៀត តទៅមុខក៏គង់នឹងរក្សាបុត្រលោកពុំបានដូចគ្នា គង់នឹងលះបង់ឲ្យអន្តរាយជាប្រាកដពុំខាន សូមឲ្យលោករិះគិតអានសិន។ **ទៀវឡូ**យល់ឃើញត្រូវ ក៏មិនបានលើកកូនក្រមុំឲ្យ**ម៉ាឈៀវ**វិញ។ **ម៉ាឈៀវ**ដឹងថា**អៀវប៉េក**ឃាត់ខាំងរាំងរាដូច្នោះក៏ទាស់តូចិត្តខ្លាំងណាស់ គិតខឹងនឹង**អៀវប៉េក**មិនរសាយ គិតនឹងប្រទូសរ៉ាយឲ្យបានវិញ។ **អៀវប៉េក**ដឹងខ្លួន ក៏ប្រឹក្សានឹង**អៀវសុង**ជាបងថា នឹងជួយកម្ចាត់**ម៉ាឈៀវ**ចេញ។

ឯ**អ៊ុយគួន**ដែលកាន់សំបុត្រមកពីស្រុកសែឈួននោះ លុះទៅដល់ហើយក៏យកសំបុត្រនោះទៅជូន**ទៀវឡូ** ៗបានទទួលមើលឃើញសេចក្ដីថា **ឡៅជៀង**ជម្រាបមក**ទៀវឡូ**បានជ្រាប ដ្បិតឥឡូវនេះ**ឡៅពី**លើកទ័ពមកធ្វើអន្តរាយដល់ស្រុកសែឈួន ហើយ គិតប្រុងនឹងធ្វើការឲ្យទូលំទូលាយតទៅទៀត ឯស្រុកសែឈួន និងស្រុក

ហាន់តុងនោះ ក៏ឧបមាបីដូចបបូរមាត់និងធ្មេញជិតគ្នាណាស់ បើ**ឡៅពី**វាយបានស្រុកសែឈួនហើយ ក៏គង់នឹងរាលដាលមកវាយយកស្រុកហាន់តុងមិនបង្អង់ខានទេ អាណាប្រជានុរាស្ត្រទាំងពួងក៏នឹងបានសេចក្តីក្តៅក្រហាយ ការនេះសូមឲ្យអ្នកជួយលើកទាហានទាំងឡាយទៅជួយកម្ចាត់**ឡៅពី**ចេញ បើសម្រេចបានការហើយ ខ្ញុំនឹងលើកអាណាខេត្តឲ្យអ្នក២០តំបន់។ **ទៀវឡូ**ឃើញសំបុត្រដូច្នោះក៏មានអំណរណាស់ ព្រោះចង់បានអាណាខេត្តសែឈួន ក៏ទទួលពាក្យនឹង**អ៊ុយគួន**ថានឹងលើកទ័ពទៅជួយ។

**យៀមផៅ**ឮដូច្នោះក៏និយាយហាមឃាត់ថា **ឡៅជៀង**និងលោកក៏ជាសត្រូវនឹងគ្នាដែលថាមក ព្រោះភារៈទាល់ខ្លួនហើយ មួយទៀត ការត្រង់នឹងវៀចនោះ ក៏ពាក់កណ្តាលម្នាក់ ក្រែងថា ធ្វើការនោះសម្រេចហើយ នឹងប្រែត្រឡប់មិនព្រមឲ្យអាណាខេត្តមកវិញ នឹងមិនបង់កម្លាំងទទេទៅឬ? សុំលោកកុំអាលជឿស្តាប់ពាក្យសម្តី**ឡៅជៀង**នោះសិន។ ខណៈនោះ**ម៉ាឈៀវ**ក៏ជម្រាប**ទៀវឡូ**ថា ខ្ញុំបាទបានមកប្រាស្រ័យពឹងបុណ្យលោក ក៏នៅមិនទាន់បានធ្វើការអ្វីតបស្នងសងគុណសោះ ឥឡូវ**ឡៅពី**លើកកងទ័ពមកវាយបានតំបន់ហែបាំងគួន ដែលជាគយសំខាន់របស់ស្រុកសែឈួនហើយ វេលានេះខ្ញុំបាទនឹងសុំយកអាសាលើកទាហានទៅធ្វើការច្បាំងចាប់យកខ្លួន**ឡៅពី**សម្លាប់ចេញ នោះ**ឡៅជៀង**ចៅហ្វាយស្រុកសែឈួននឹងមានសេចក្តីត្រេកអរ គង់នឹងលើកអាណាខេត្តដែលឡើង២០តំបន់ជូនលោកជាកំណាន់មិនខាន។ **ទៀវឡូ**ឮដូច្នោះក៏ត្រេកអរណាស់ និយាយនឹង**អ៊ុយគួន**ថា ឲ្យស្រូតត្រឡប់ទៅប្រាប់**ឡៅជៀង**ចុះ ថាយើងនឹងព្រមជួយធុរៈទៅ ត្រាតែអស់កម្លាំង។ **អ៊ុយគួន**ក៏លា**ទៀវឡូ**ត្រឡប់ទៅវិញ។

ខណៈនោះ **ទៀវឡូ**ចាត់ទាហានពីរម៉ឺន ឲ្យ**អៀវប៉េក**កាន់កាប់ទៅជាមួយនឹង**ម៉ាឈៀវ**តែវេលានោះ **បាំងតេក**មានធុរៈឈឺ **ម៉ាឈៀវ**ក៏ចាត់ឲ្យមនុស្សនៅពិភក្តិរក្សា

ស្រុកហាន់តុងលុះបានឫក្សជោគល្អ **ម៉ាឈៀវ**និង**ម៉ាតាយ**ជាប្អូនក៏លើកកងទ័ពចេញពីស្រុកតម្រង់ទៅគយហៃបាំងគួន។

ឯ**ឡៅពី** កាលតាំងនៅស្រុកឡុកសៀ **ហួតចេង**ក៏ប្រាប់**ឡៅពី**ថា ខ្ញុំបាទឲ្យសំបុត្រសម្ងាត់ទៅដល់ស្រុកសែឈួន ដើម្បីនឹងឲ្យធ្វើជាកលសឹកខាងក្នុង នោះអ្នកកាន់សំបុត្រត្រឡប់មកប្រាប់ខ្ញុំបាទវិញថា **តែ-ត**ទីប្រឹក្សា ប្រើទាហានចេញទៅដុតស្បៀងអាហាររបស់អ្នកស្រុកក្រៅ ហើយកៀរគ្រួនាំឆ្លងស្ទឹងប៉ិយស៊ុយមកឲ្យផុតសត្រូវ ហើយបង្គាប់ទាហានដែលនៅរក្សាគយឲ្យនៅត្រួតត្រារក្សាបន្ទាយកុំឲ្យចេញតច្បាំង។ **ឡៅពី** និង**ខុងបេង**ដឹងដូច្នោះក៏ភ័យណាស់ថា កាល**តែ-ត**ឲ្យ**ឡៅជៀង**ធ្វើដូច្នោះ តើយើងនឹងគិតប្រការម្ដេចទៅវិញ? **ហួតចេង**ថា **តែ-ត**នោះមានតម្រិះវិះគិតចំណានណាស់ ប៉ិនប្រសប់ខាងការល្បួងបញ្ឆោតគ្រប់ប្រការ តែខ្ញុំបាទយល់ឃើញថា **ឡៅជៀង**មិនព្រមធ្វើតាមទេ។ លុះកន្លងមកបានមួយថ្ងៃ មានបម្រើមកប្រាប់**ឡៅពី**ថា **ឡៅជៀង**មិនបានធ្វើតាមពាក្យ**តែ-ត**ទេ។

**ឡៅពី**ឮដូច្នោះក៏រសាយសេចក្ដីព្រួយ **ខុងបេង**ក៏ប្រឹក្សានឹង**ឡៅពី**ថា ចាំយើងគិតលើកទ័ពទៅវាយស្រុកគិមកុក បើបានហើយក៏នឹងបានស្រុកសែឈួនដោយងាយ។ **ឡៅពី**យល់ឃើញត្រូវ ក៏ចាត់**អ៊ុយអៀន**និង**ហាងតុង**លើកទាហានចេញទៅជាកងមុខ **ឡៅពី**និង**ខុងបេង**ជាកងហ្លួង លើកទៅតាំងនៅដែនស្រុកគិមកុក ឯ**អ៊ុយហ៊្វិន**ចៅហ្វាយស្រុកគីមកុកដឹង ក៏ចាត់**លីយៀម**លើកទាហានបីពាន់ ចេញទៅបានច្បាំងគ្នានឹង**ហាងតុង**បានហាសិបភ្លែង មិនទាន់ចាញ់ឈ្នះគ្នា **ខុងបេង**ឃើញដូច្នោះក៏វាយឃ្មោះប្រាថ្នានឹងឲ្យ**ហាងតុង**វិលមកវិញ **ហាងតុង**ឮសំឡេងឃ្មោះក៏នាំទាហានត្រឡប់មកវិញ ហើយសួរ**ខុងបេង**ថា ខ្ញុំបាទបានការនឹងចាប់ខ្លួន**លីយៀម**បានហើយ ហេតុម្ដេចក៏លោកវាយឃ្មោះហៅដូច្នោះ?

**ខុងបេង**ថា ត្បិត**លីយៀម**នោះមានកម្លាំងខ្លាំងពូកែណាស់ ដែលអ្នកនឹងច្បាំងតយកជ័យជម្នះតាមកម្លាំងតែម្ដងមិនបានទេ បានជាយើងឲ្យវាយឃ្មោះហៅត្រឡប់

មកប្រាថ្នានឹងធ្វើកលឧបាយយកជ័យជម្នះវិញ។ ក្នុងយប់ថ្ងៃនោះ យើងត្រូវចាត់ទាហានពីរកងឲ្យទៅពួនបង្កប់នៅក្បែរផ្លូវច្រកភ្នំ ដល់ព្រឹកស្អែកអ្នកចេញទៅច្បាំងឲ្យធ្វើជាថយរត់មកក្រោយចូលទៅតាមច្រកភ្នំនោះ **លីយៀម**គង់នឹងដេញតាមទៅ កាលណាបើ**លីយៀម**ដេញហួសទៅហើយ ត្រូវឲ្យទាហានដែលពួនបង្កប់នោះវាយខ្ទប់ចេញមកប្រសព្វគ្នា មុខជានឹងបានជ័យជម្នះដោយងាយ។ **ហាងតុង**យល់ឃើញត្រូវ លុះពេលយប់ក្នុងថ្ងៃនោះ **ខុងបេង**ក៏ឲ្យ**អ៊ុយអៀន**លើកទាហានទៅស្ទាក់នៅក្បែរមាត់ផ្លូវ ហើយបំបែកទាហានពីរកងទៅបង្កប់នៅច្រកភ្នំ។ លុះវេលាព្រឹក**ហាងតុង**ជិះសេះនាំទាហានចេញទៅ។

ឯ**លីយៀម**ឃើញដូច្នោះ ក៏បរសេះចេញមកតច្បាំងនឹង**ហាងតុង**បានដប់ភ្លែង **ហាងតុង**ធ្វើជាថយរត់បញ្ឆោតឲ្យដេញទៅតាមច្រកភ្នំ **លីយៀម**មិនដឹងកល ក៏បំផាយសេះដេញតាមទៅដល់មាត់ផ្លូវច្រកភ្នំ ទទួលនឹកឃើញក្រែងសត្រូវបង្កប់ទាហានចាំនៅទីនោះក៏ញាក់សេះត្រឡប់ថយមកវិញ ឃើញ**អ៊ុយអៀន**លើកទាហានស្ទាក់ពីមុខច្រើនណាស់ លុះនឹងរត់ទៅខាងណាក៏មិនរួច។ ខណៈនោះ**ខុងបេង**ឡើងទៅលើកំពូលភ្នំ ស្រែកចុះមកថា **លីយៀម**ចូរប្រញាប់មកចំណុះចុះចូលយើងដោយល្អទៅ បើមិនស្តាប់យើង ៗនឹងឲ្យទាហានដែលបង្កប់សងខាងផ្លូវបាញ់នឹងធ្នូឲ្យស្លាប់ឥឡូវនេះ។ **លីយៀម**ឮដូច្នោះក៏ភ័យណាស់គិតថា ខ្លួនអញនៅក្នុងចំណោមដ៏ចង្អៀតដូច្នេះ បើនឹងខំរឹងទទឹងក៏គង់មិនរួចជីវិតគួរតែនឹងចំណុះចុះចូល**ខុងបេង**ទៅវិញល្អជាង គិតហើយក៏លោតចុះពីលើសេះ បោះអាវុធពីដៃដោះក្រោះចេញ ហើយឡើងទៅគំនាប់**ខុងបេង**នៅលើកំពូលភ្នំដោយល្អ។

**ខុងបេង**មានសេចក្តីត្រេកអរណាស់ ក៏នាំ**លីយៀម**ចូលទៅគំនាប់**ឡៅពី**ក្នុងបន្ទាយ។ **ឡៅពី**អញ្ជើញឲ្យ**លីយៀម**បរិភោគអាហារហើយថា យើងធ្វើការទាំងនេះប្រាថ្នាតែនឹងទំនុកបម្រុងផែនដីឲ្យបានសេចក្តីសុខ អស់អាណាប្រជាជនប៉ុណ្ណោះ។ **លីយៀម**ក៏ឆ្លើយថា **អ៊ុយហ្វ៊ន**នោះជាបងប្អូននឹង**ឡៅជៀង**ក៏មែន តែខ្ញុំបាទនឹងរំឭកការ

អ្វីក៏តែងជឿស្តាប់ដរាប វេលានេះ ខ្ញុំបាទចង់សុំលោកទៅនិយាយឲ្យ**អ៊ុយហ៊្សួន**មកចំណុះចុះចូលលោកឲ្យបាន។ **ឡៅពី**ឮដូច្នោះក៏ត្រេកអរណាស់ថា បើអ្នកតាំងចិត្តសុចរិតត្រង់នឹងយើងហើយ ក៏ត្រូវស្រូតរូតទៅនិយាយនឹង**អ៊ុយហ៊្សួន**ដោយល្អចុះ។ **លីយៀម**គំនាប់លា**ឡៅពី, ខុងបេង** នាំទាហានទៅដល់ស្រុកគិមកុក ជួបនឹង**អ៊ុយហ៊្សួន**ហើយក៏ប្រាប់រឿងឲ្យ**អ៊ុយហ៊្សួន**ស្តាប់ ហើយថា **ឡៅពី**នោះមានចិត្តអធ្យាស្រ័យមេត្រីស្រឡាញ់រាប់អានអស់អាណាប្រជានុរាស្ត្រស្រួលណាស់ ដែល**ឡៅពី**មកធ្វើការនេះ ប្រាថ្នាតែនឹងទំនុកបម្រុងផែនដីឲ្យបានសេចក្តីសុខប៉ុណ្ណោះ។ បើអ្នកមិនព្រមចំណុះ ខំតែរឹងទទឹងតាំងតច្បាំងទៅ ស្រុកយើងក៏គង់តែអន្តរាយ យើងទាំងឡាយនឹងមិនរួចពីសេចក្តីស្លាប់ក្នុងកណ្តាប់ដៃគេឥតអំពើ។

**អ៊ុយហ៊្សួន**បានឮដូច្នោះ ក៏យល់ឃើញត្រូវផង ទើបនាំទាហានចូលទៅគំនាប់**ឡៅពី**ហើយសូមអញ្ជើញ**ឡៅពី, ខុងបេង**ចូលទៅក្នុងស្រុក។ **ឡៅពី, ខុងបេង**អស់សង្ស័យក៏នាំគ្នាចូលទៅក្នុងស្រុកគិមកុក។ **អ៊ុយហ៊្សួន**ក៏តែងតុរៀបអាហារលៀងអញ្ជើញ**ឡៅពី** និង**ខុងបេង**នូវអស់សេនាទាហានទាំងប៉ុន្មានឲ្យបរិភោគអាហារ លុះលៀងរួចហើយ **ឡៅពី**ក៏ចាត់ចែងទាហាននឹងលើកទៅស្រុកអេកជីវ ទទួលមានបម្រើសេះមកប្រាប់ថា ឥឡូវ**ទៀវឡូ**ប្រើ**ម៉ាឈៀវ, ម៉ាតាយ, អៀវប៉េក**លើកកងទ័ពមកច្បាំងនឹងលោក ឯ**បេងតាត់**និង**ហាក់ជុន**ដែលលោកឲ្យទៅរក្សាគយហែបាំងគួននោះបានតតាំងច្បាំងគ្នាទៅហើយ វេលានេះបើលោកមិនលើកពលទៅជួយឲ្យរហ័សទេ ទីគយនោះនឹងខូចអសារ។ **ឡៅពី**ឮដូច្នោះក៏ស្ពុតក្នុងចិត្ត ទើបប្រឹក្សានឹង**ខុងបេង**ថា លោកនឹងរិះគិតប្រការម្តេច? **ខុងបេង**ថា ខ្ញុំបាទឃើញតែ**តៀវហ៊ុយ**និង**ជូឡុង**ពីរនាក់នេះ ទើបនឹងតទល់កម្លាំងនឹង**ម៉ាឈៀវ, ម៉ាតាយ, អៀវប៉េក**នោះ។

**ឡៅពី**ថា **ជូឡុង**នោះប្រើឲ្យទៅបញ្ចុះបញ្ចូលមនុស្សតាមមាត់ទន្លេ ដែនស្រុកតេងកាំង ក៏នៅមិនទាន់នឹងត្រឡប់មកវិញ នៅតែ**តៀវហ៊ុយ** បើដូច្នោះ ត្រូវឲ្យលោកចាត់ចែងទាហានប្រើ**តៀវហ៊ុយ**ឲ្យលើកទៅជួយឲ្យទាន់ការ។ **ខុងបេង**ថា លោកកុំ

អាលមានប្រសាសន៍ឲ្យខ្ជូរខ្ជាយសិន ទុកឲ្យខ្ញុំនឹងរិះគិតនិយាយនឹង**តៀវហ៊ុយ**ផង។ ខណៈនោះ **តៀវហ៊ុយ**ដឹងដំណឹងថា **ម៉ាឈៀវ**លើកទ័ពមកវាយគយហៃបាំងគួន ក៏ស្រូតចូលទៅស្រុកប្រាប់**ខុងបេង**ថា ឥឡូវ**ម៉ាឈៀវ**លើកទ័ពមកច្បាំងនឹង**បេងតាត់ហាក់ជុន**ហើយ ខ្ញុំនឹងសុំអាសាចេញទៅតស៊ូនឹង**ម៉ាឈៀវ**។ **ខុងបេង**ធ្វើជាមិនឮ ហើយក្លែងថានឹង**ឡៅពី** ដើម្បីបញ្ឈឺចិត្ត**តៀវហ៊ុយ**ថា ឯ**ម៉ាឈៀវ**មានកម្លាំងនឹងថ្វីដៃខ្លាំងពូកែណាស់ ចាំសរសេរសំបុត្រឲ្យបម្រើសេះយកទៅស្រុកកេងជីវឲ្យ**គួនអ៊ូ**មកទើបតកម្លាំងនឹង**ម៉ាឈៀវ**បាន។

**តៀវហ៊ុយ**ឮដូច្នោះខឹងណាស់ថា ខ្លួនខ្ញុំបាទនេះ ក៏មានប្រាជ្ញាស្មារតីនិងថ្វីដៃខ្លះដែរ គ្រា**ចូឆូ**លើកពលមួយរយម៉ឺនតាមទៅប្រទះគ្នានៅស្ពានទៀងវ៉ាន់កៀវ ខ្ញុំបាទក៏បានច្បាំងតទល់បាន ហើយធ្វើឧបាយកលទាល់តែទាហាន**ចូឆូ**ថយទៅវិញ ឯ**ម៉ាឈៀវ**នេះនឹងមានប្រាជ្ញាស្មារតីនូវថ្វីដៃប៉ុន្មាន បានជាលោកនឹកចំពោះទៅដល់លោក**គួនអ៊ូ**តែម្តង? **ខុងបេង**ក្លែងតបថា គ្រា**ចូឆូ**លើកពលមួយរយម៉ឺនតាមមកនោះ អ្នកបានតទល់មែនតែលើសកម្លាំងណាស់ ដែលអ្នកគិតកលឧបាយឲ្យពល**ចូឆូ**ថយទៅនោះ ហាក់តែសត្រូវមិនទាន់គិត បើ**ចូឆូ**ដឹងពិតកាលណា ជីវិតអ្នកនឹងខូច អ្នកកុំអាលប្រមាថមើលងាយឡើយ ព្រោះ**ម៉ាឈៀវ**នេះមានថ្វីដៃខ្លាំងពូកែណាស់ កាលច្បាំងនឹងកងទ័ព**ចូឆូ**នៅតំបន់ស្ទឹងម៉ាស៊ុយនោះ **ចូឆូ**ចាញ់ប្រៀបជាច្រើន ទាល់តែដោះក្រោះ កាត់ពុកមាត់ ចូលទៅពួនព័ទ្ធបន្លំនឹងកូនទាហាន ទើប**ចូឆូ**រត់រួចពី**ម៉ាឈៀវ**ទៅបាន។

**តៀវហ៊ុយ**ថា បើលោកនៅមន្ទិលសង្ស័យ ខ្ញុំបាទនឹងសុំធ្វើសញ្ញាទុក បើខ្ញុំបាទលើកពលទៅមិនបានជ័យជម្នះលើ**ម៉ាឈៀវ**ទេ សូមឲ្យកាត់ក្បាលខ្ញុំបាទចេញចុះ។ **ខុងបេង**ថា បើព្រមទទួលដូច្នេះមែន យើងក៏ល្មមទុកចិត្តបាន។ **តៀវហ៊ុយ**ក៏សរសេរសញ្ញាទុកឲ្យ**ខុងបេង**។ **អ៊ុយអៀន**ថា ខ្ញុំបាទនឹងសុំទៅផង **ខុងបេង**ក៏ឲ្យ**អ៊ុយអៀន**លើកទាហានប្រាំរយជាកងមុខ ឲ្យ**តៀវហ៊ុយ**ជាកងកណ្តាល **ឡៅពី**ជាកងក្រោយ

ហើយ**ខុងបេង**ជម្រាប**ឡៅពី**ថា ខ្ញុំនឹងនៅជួយរក្សាស្រុកគិមកុកសិន បើ**ជូឡុង**មកដល់វេលាណា នឹងនាំគ្នាលើកតាមទៅ។ **ឡៅពី, តៀវហ៊ុយ, អ៊ុយអៀន**ក៏លើកកងទ័ពទៅដល់គយហែបាំងគួន ហើយក៏ឲ្យតាំងបន្ទាយនៅជិតគយនោះ។

**ម៉ាឈៀវ** ក៏ឲ្យ**អៀវប៉េក**បរសេះចេញមកច្បាំងនឹង**អ៊ុយអៀន**បានដប់ភ្លែង **អៀវប៉េក**តកម្លាំងនឹង**អ៊ុយអៀន**ពុំបាន ក៏ញាក់សេះថយរត់ **អ៊ុយអៀន**មានចិត្តកំរើបដោយចង់បានសេចក្ដីគាប់ប្រសើរ ក៏បរសេះដេញតាមទៅជួបនឹង**ម៉ាតាយ**ស្ទាក់ពីមុខ **អ៊ុយអៀន**សម្គាល់ថា**ម៉ាឈៀវ** ក៏បរសេះរំដារចូលច្បាំង**ម៉ាតាយ**បានដប់ភ្លែង **ម៉ាតាយ**ធ្វើជាញាក់សេះរត់។ **អ៊ុយអៀន**បានទំនងស្រួល ក៏បរសេះដេញតាមទៅ **ម៉ាតាយ**បែរមុខមកវិញ បាញ់នឹងធ្នូត្រូវស្មា**អ៊ុយអៀន** ៗញាក់សេះថយមកវិញ **ម៉ាតាយ**ក៏បំផាយសេះតាមទៅមុខបន្ទាយ។ **តៀវហ៊ុយ**ឃើញក៏បរសេះពីបន្ទាយ ទៅស្ទាក់ពីមុខហើយស្រែកគំហកឲ្យ**ម៉ាតាយ**។ **អ៊ុយអៀន**ក៏រត់ចូលបន្ទាយបាន។ **តៀវហ៊ុយ**សួរថា អ្នកនេះឈ្មោះអ្វី? ទើបហ៊ានដេញ**អ៊ុយអៀន**មកដល់មុខបន្ទាយ ឆ្លើយឲ្យឆាប់នឹងបានតស៊ូគ្នាឲ្យឃើញថ្វីដៃ។

**ម៉ាតាយ**ឆ្លើយ យើងឈ្មោះ**ម៉ាតាយ**ប្អូន**ម៉ាឈៀវ**នៅស្រុកសៃលៀង។ **តៀវហ៊ុយ**ថា ខ្លួននេះមិនគួរមកចង់ប្ដូរដៃនឹងយើងទេ បើនឹងតស៊ូច្បាំងគ្នាឥឡូវនេះ ខ្លួនក៏ត្រូវស្លាប់ឥតអំពើ យើងទុកជីវិតឲ្យខ្លួន ៗចូរត្រឡប់ទៅប្រាប់**ម៉ាឈៀវ**ឲ្យចេញមកច្បាំងនឹងយើងទើបគួរ។ **ម៉ាតាយ**ស្ដាប់ដូច្នោះក៏ខឹងខ្លាំងណាស់ ទើបបរសេះចូលទៅច្បាំងនឹង**តៀវហ៊ុយ**បានដប់ភ្លែង **ម៉ាតាយ**ទល់កម្លាំងនឹង**តៀវហ៊ុយ**ពុំបាន ក៏ញាក់សេះរត់។ **តៀវហ៊ុយ**ឃើញបានការដេញតាមទៅ។ **ឡៅពី**ឃើញដូច្នោះក៏វាយឃ្មោះឡើង **តៀវហ៊ុយ**បានឮក៏ញាក់សេះត្រឡប់មក **ឡៅពី**ថា បងដឹងចិត្តថៅនៅវីវរណាស់ ខ្លាចដេញសត្រូវទៅនឹងមានអន្តរាយ បានជាបងវាយឃ្មោះឲ្យត្រឡប់មកវិញ មួយទៀតថៅក៏មានជ័យជម្នះ**ម៉ាតាយ**ហើយ គួរនឹងយកឫក្សទុកម្ដងទៅចុះ ចូរឈប់ឲ្យមានកម្លាំងសប្បាយ ព្រឹកស្អែកសឹមចេញច្បាំង។

លុះព្រឹកឡើង **ឡៅពី**បានឮសំឡេងទាហានស្រែកហ៊ោគឹកកងមកដល់មុខបន្ទាយច្រើនណាស់ **ឡៅពី**ក៏ឡើងលើសើនបន្ទាយទាហានចង្អុលបង្ហាញឲ្យឃើញ**ម៉ាឈៀវ**។ **ឡៅពី**ឃើញរូប**ម៉ាឈៀវ**មាំមួនសមជាទាហាន មុខដូចពណ៌ជាតិហិង្គុរ ពាក់អាវប្រាក់ជិះសេះកាន់លំពែងនៅកណ្ដាលពល ហើយសម្លឹងមើលថា បណ្ដាមនុស្សទាំងពួងនិយាយល្បីឮថា**ម៉ាឈៀវ**មានរូបល្អ ក្លាហានក៏សមដូចជាពាក្យថា **តៀវហ៊ុយ**ឃើញ**ម៉ាឈៀវ**លើកពលមកក៏និយាយនឹង**ឡៅពី**ថា ខ្ញុំបាទនឹងសុំអាសាចេញច្បាំងនឹង**ម៉ាឈៀវ**។ **ឡៅពី**ថា ប្អូនឯងកុំអាលសិន ត្រូវបង្អង់នៅក្នុងបន្ទាយចាំមើលកលការ បើឃើញទាហានអត់អាហារហួសវេលាសឹមចេញទៅច្បាំងចុះ។

ឯ**ម៉ាឈៀវ** មិនបានឃើញ**ឡៅពី**លើកទាហានចេញមកច្បាំង ក៏ឲ្យទាហានទៅស្រែកជៀមដាមជាពាក្យទ្រគោះ។ **តៀវហ៊ុយ**ឮដូច្នោះខឹងណាស់ បីដូចនឹងអណ្ដែតខ្លួនចេញទៅស៊ីសាច់**ម៉ាឈៀវ**ឲ្យអស់តែម្ដង តែនៅខ្លាច**ឡៅពី**ណាស់ ទើបខំអត់សង្កត់ចិត្តទុក។ **ម៉ាឈៀវ**មិនបានឃើញអ្នកឯណាឆ្លើយតបចេញមក ក៏ឲ្យផ្លាស់គ្នាចូលទៅស្រែកឡកចំអកជេរទ្រគោះជាពាក្យអសុរោះផ្សេងៗ ទាល់តែថ្ងៃរសៀល **ឡៅពី**ឃើញ**ម៉ាឈៀវ**អត់អាហារ អស់កម្លាំងចុះហើយ ក៏ចាត់ទាហានប្រាំរយឲ្យ**តៀវហ៊ុយ**ចេញពីក្នុងបន្ទាយទៅ។ **ម៉ាឈៀវ**ឃើញ**តៀវហ៊ុយ**ចេញមក ក៏មានអំណរណាស់ ទើបបក់ទង់ឲ្យទាហានថយមក **តៀវហ៊ុយ**ឃើញដូច្នោះក៏បរសេះចេញទៅមុខទាហាន ហើយស្រែកថា ខ្លួនអញឈ្មោះ**តៀវហ៊ុយ** **ម៉ាឈៀវ**ឯងមិនស្គាល់ដៃអញទេឬ? **ម៉ាឈៀវ**ស្រែកតបថា ខ្លួនអញជាពូជនាហ្មឺនមកជាច្រើនតមកហើយ ធ្វើម្ដេចអញនឹងស្គាល់ឯង ដែលជាជាតិស្រុកស្រែក្រៅទុរយសនោះមិនសមគួរ។

**តៀវហ៊ុយ**ឮដូច្នោះក៏ខឹងណាស់ បរសេះចូលប្រយុទ្ធគ្នានឹង**ម៉ាឈៀវ**បានមួយរយភ្លេង ក៏នៅមិនទាន់ចាញ់ឈ្នះគ្នា។ **ឡៅពី**ឃើញដូច្នោះក៏គន់សម្លឹងមើលថ្វីដៃ**តៀវហ៊ុយ**និង**ម៉ាឈៀវ**ហើយថា អ្នកចម្បាំងទាំងពីរនេះរួសរហ័សណាស់សមជាទាហានខ្លា តែគិតក្រែងថា **តៀវហ៊ុយ**នឹងភ្លាត់ភ្លាំង ក៏វាយឃ្មោះសញ្ញាឲ្យថយ

គ្រឡប់ចូលបន្ទាយ។ **តៀវហ៊ុយ**ឮសំឡេងឃ្មោះក៏ដោះថយវិលមកហើយ ដោះក្រោះចេញ ឈប់សម្រាកមួយស្របក់ ក្រោះក៏មិនពាក់ឡើងសេះត្រឡប់ចេញទៅទៀត ស្រែកដៀមដាមឲ្យ**ម៉ាឈៀវ**ជាពាក្យអសុរោះទ្រគោះ។ **ម៉ាឈៀវ**ខឹងណាស់ ក៏បរសេះចេញទៅប្រយុទ្ធគ្នានឹង**តៀវហ៊ុយ**ម្តងទៀត ស្មៀតអាវុធក៏ប្រកិតជាប់គ្នាជាសន្ធឹកសន្ធាប់ណាស់។

**ឡៅពី**គិតក្រែង**តៀវហ៊ុយ**ថ្លោះការ ក៏ពាក់ក្រោះឡើងសេះទៅឈរនៅមុខទាហានឃើញ**តៀវហ៊ុយ**និង**ម៉ាឈៀវ**ច្បាំងគ្នាប្រហែលមួយរយភ្លែង ក៏វាយឃ្មោះហៅ**តៀវហ៊ុយ**ឲ្យត្រឡប់វិលវិញ។ **ឡៅពី**និយាយថា បងក្រែងថៅនឿយណាស់ បានជាវាយឃ្មោះឲ្យវិលមកឈប់សម្រាកសិន **តៀវហ៊ុយ**ថា ខ្ញុំបាទបានចេញមាត់ទទួលអាសាធ្វើការជូនលោក ដើម្បីនឹងយកជ័យជម្នះលើ**ម៉ាឈៀវ** ឥឡូវនៅមិនទាន់ចាញ់ឈ្នះសោះ លុះនឹងឈប់ទទេក៏នាំឲ្យខាតវេលា ហើយ**តៀវហ៊ុយ**ក៏ខាំធ្មេញញេញមុខនឹងចង់ចេញទៅប្រយុទ្ធគ្នាម្តងទៀត **ឡៅពី**ក៏និយាយហាមឃាត់**តៀវហ៊ុយ**ថា ពេលថ្ងៃនេះក៏ល្ងាចណាស់ហើយ ត្រូវឲ្យចូលទៅឈប់សិនចុះ ព្រឹកស្អែកសឹមចេញទៅតស៊ូគ្នាម្តងទៀត។ **តៀវហ៊ុយ**ថា ខ្ញុំបាទមិនចូលទៅទេបើលោកឃើញថា យប់ងងឹតហើយ ក៏ត្រូវអុជគប់ភ្លើងឡើង ខ្ញុំបាទនឹងចេញទៅច្បាំងនឹង**ម៉ាឈៀវ**ត្រាតែបានជ័យជម្នះ។

ខណៈកាល**ឡៅពី**វាយឃ្មោះហៅ**តៀវហ៊ុយ**ឲ្យថយទៅនោះ **ម៉ាឈៀវ**ក៏ត្រឡប់ចូលមកបន្ទាយ គិតខឹងក្តៅ**តៀវហ៊ុយ**ជាខ្លាំងណាស់ ក៏ពាក់ក្រោះឡើងសេះថ្មី នាំទាហានទៅដល់មុខបន្ទាយ ហើយស្រែកដោយទោសោថា ពេលយប់នេះ **តៀវហ៊ុយ**ត្រូវចេញមកច្បាំងនឹងអញទៀត។ **តៀវហ៊ុយ**ឮដូច្នោះក៏ខឹងណាស់ ប្តូរយកសេះ**ឡៅពី**មកជិះ ហើយនាំទាហានចេញទៅស្រែកថា ពេលយប់នេះបើអញមិនចាប់ខ្លួន**ម៉ាឈៀវ**ឯងឲ្យបានទេ អញក៏មិនវិលត្រឡប់ចូលបន្ទាយវិញឡើយ។

**ម៉ាឈៀវ**ស្រែកតបថា ក្នុងពេលយប់នេះ បើអញមិនមានជ័យជម្នះលើឯងទេ អញក៏មិនវិលចូលបន្ទាយ។

ក្នុងខណៈនោះ ទាហានទាំងសងខាងអុជគប់ភ្លើងឡើងភ្លឺស្វាងបីដូចថ្ងៃ **ម៉ាឈៀវ** និង**តៀវហ៊ុយ**ច្បាំងគ្នាបាន២០ភ្លេង **ម៉ាឈៀវ**ធ្វើជាថយរត់ **តៀវហ៊ុយ**ក៏ញាក់សេះដេញតាមទៅភ្លាម ក៏គិតថា **ម៉ាឈៀវ**មិនទាន់ភ្លាត់ភ្លាំងក្នុងភ្លេងអាវុធត្រង់ណា បើទាញសេះវេះរត់ទៅដូច្នោះ មុខជាធ្វើកលឧបាយអ្វីប្រាកដ **តៀវហ៊ុយ**ក៏គិតវាំងខ្លួនមិនចូលទៅឲ្យជ្រុលការ។ **ម៉ាឈៀវ**ឃើញ**តៀវហ៊ុយ**ដេញចូលមកជិត ក៏លើកដំបងដែកវាយ**តៀវហ៊ុយ** ៗយកលំពែងខ្នាតចេញ ហើយទាញញាក់សេះរត់ **ម៉ាឈៀវ**ក៏ដេញតាមពីក្រោយទៅ។ **តៀវហ៊ុយ**ក៏ត្រឡប់បែរមុខមកវិញ យឹតធ្នូបាញ់ **ម៉ាឈៀវ** ៗក៏យកលំពែងរងទាន់ ព្រួញខ្ទាតចេញ ទទួលដល់ពេលយាមពីរប្លាយ **ម៉ាឈៀវ**ក៏ត្រឡប់ចូលទៅកាន់ប្រជុំទាហាន **តៀវហ៊ុយ**ក៏ត្រឡប់ទៅរក**ឡៅពី**ឯបន្ទាយ។

**ឡៅពី**ក៏បរសេះចេញទៅមុខទាហាន ហើយស្រែកប្រកាសប្រាថ្នានឹងយកចិត្ត **ម៉ាឈៀវ**ថា វេលាក៏យប់ងងឹតណាស់ទៅហើយ ចូរអ្នកត្រឡប់ទៅឈប់សម្រាកក្នុងបន្ទាយសិនចុះ ព្រឹកស្អែកសឹមចេញមកច្បាំងគ្នានឹង**ម៉ាឈៀវ**ទៀត។ **ម៉ាឈៀវ**ឮដូច្នោះក៏នាំទាហានត្រឡប់ចូលបន្ទាយ។ **ឡៅពី**និង**តៀវហ៊ុយ**ក៏វិលចូលមកបន្ទាយវិញ។ លុះព្រឹកឡើង**តៀវហ៊ុយ**ក៏ចាត់ចែងទាហាននឹងចេញទៅច្បាំងនឹង**ម៉ាឈៀវ**ម្តងទៀត។ ទទួលបម្រើសេះមកប្រាប់**ឡៅពី**ថា ឥឡូវ**ខុងបេង**តាមមកដល់ហើយ។ **ឡៅពី**ឮដូច្នោះក៏មានអំណរណាស់ ទើបចេញទៅទទួល**ខុងបេង**ចូលមក។ **ខុងបេង**ថា **ម៉ាឈៀវ**នោះមានថ្វីដៃខ្លាំងពូកែណាស់ បើច្បាំងនឹង**តៀវហ៊ុយ**នេះក៏បីដូចខ្លាពីរតគ្នា គង់តែនឹងភ្លាត់មួយៗមិនខាន ខ្ញុំនឹងសុំធ្វើកលឧបាយឲ្យ**ម៉ាឈៀវ**ចូលមកនៅនឹងលោកដោយស្រួល។ **ឡៅពី**ថា ខ្ញុំបាទឃើញថ្វីដៃ**ម៉ាឈៀវ**ហើយ ខ្ញុំក៏គិតណាស់

ដែរ គឺចង់បានមកធ្វើការជាមួយ ដែលលោកថានេះខ្ញុំពេញចិត្តណាស់ តែលោកនឹងគិតកលឧបាយប្រការម្តេចនឹងឲ្យបានខ្លួន**ម៉ាឈៀវ**ដោយស្រួល។

**ខុងបេង**ថា **ទៀវឡា**នោះមានចិត្តកំរើបនឹងចង់តាំងខ្លួនឡើង ជាស្តេចក្នុងស្រុកហាន់តុង មានទីប្រឹក្សាម្នាក់ឈ្មោះ**អៀវសុង** ឯ**អៀវសុង**នោះជាមនុស្សលោភប្រាថ្នាចង់បានតែរបស់ផ្សេងៗទុកជាប្រយោជន៍របស់ខ្លួន បើដូច្នោះសុំឲ្យលោកចាត់របស់ដែលមានតម្លៃត្រកាលនឹងសំបុត្រឲ្យបម្រើលបចូលទៅឲ្យ**អៀវសុង** ឲ្យ**អៀវសុង**នាំយកសំបុត្រនោះទៅឲ្យ**ទៀវឡា**ជាសេចក្តីថា ខ្លួនលោកលើកកងទ័ពមកនេះនឹងវាយយកស្រុកសែឈ្លួន ប្រាថ្នានឹងជួយសងសឹកដែល**ឡៅជៀង**សម្លាប់មាតា**ទៀវឡា**នោះ បើ**ឡៅជៀង**ចៅហ្វាយស្រុកសែឈ្លួននឹងឲ្យមកសម្រួលពីការអ្វីដល់**ទៀវឡា** ក៏កុំយកជាធុរៈឡើយ បើលោកវាយបានស្រុកសែឈ្លួនហើយ នឹងតាំងចិត្តបម្រុងឲ្យ**ទៀវឡា**ឡើងជាស្តេចក្នុងស្រុកហាន់តុងឲ្យបាន ហើយឲ្យ**ទៀវឡា**មានសំបុត្រទៅហៅខ្លួន**ម៉ាឈៀវ**ឲ្យវិលចូលមកវិញ កាលបើ**ម៉ាឈៀវ**នឹងលើកទ័ពត្រឡប់ទៅវិញនោះ ខ្ញុំនឹងចាត់មនុស្សឲ្យទៅស្កាត់បញ្ចុះបញ្ចូល**ម៉ាឈៀវ**ឲ្យមកនៅធ្វើការជាមួយនឹងលោកឲ្យបាន។

**ឡៅពី**បានស្តាប់មានអំណរណាស់ ទើបតែងសំបុត្រតាមពាក្យ**ខុងបេង**និយាយ ហើយចាត់មាសប្រាក់ និងព្រែយ៉ាងល្អ ដែលជាជំនួន**អៀវសុង**នោះ ឲ្យ**ស៊ុនខៀន**ជាបម្រើនាំចូលទៅតាមផ្លូវកាត់ ទៅឲ្យ**អៀវសុង**ឯស្រុកហាន់តុង។ លុះ**ស៊ុនខៀន**បានទៅដល់ ក៏ចូលទៅគំនាប់**អៀវសុង**ហើយជម្រាបថា របស់មាសប្រាក់ទាំងនេះ**ឡៅពី**ឲ្យខ្ញុំបាទនាំមកជូនលោក លោកចូរឃើញដោយផ្លូវមេត្រីជួយឈឺឆ្អាលយកសំបុត្រនេះចូលទៅឲ្យ**ទៀវឡា**ផង។ **អៀវសុង**ឃើញរបស់ទាំងពួងមានតម្លៃក៏ត្រេកអរណាស់ ព្រោះជាមនុស្សលោភ ទទួលយកហើយក៏នាំខ្លួន**ស៊ុនខៀន**និងសំបុត្រចូលទៅគំនាប់**ទៀវឡា**ហើយជម្រាបថា ឥឡូវ**ឡៅពី**ឲ្យមានសំបុត្រជាផ្លូវមេត្រីមកដល់លោក។ **ទៀវឡា**ទទួលយកសំបុត្រនោះមកមើល លុះដឹងសេចក្តីហើយ

ក៏ថា ខ្លួន**ឡៅពី**គ្រាន់តែជាទាហានខាងក្រៅ ហេតុម្ដេចមកបង្អាចកន្លងថា នឹងជួយទំនុកបម្រុងយើងឲ្យធ្វើស្ដេចបាន លើសកម្លាំងនិងគំនិតគិតនូវយសសក្តិណាស់។

**អៀវសុង**ថា **ឡៅពី**នោះជានាយទាហានក៏មែន តែជាពូជព្រះរាជវង្ស ព្រះចៅ**ហៀនតេ** ៗទ្រង់រាប់អានហៅថាមា ហើយ**ឡៅពី**បានចេញពាក្យថាប៉ុណ្ណេះ ហើយក៏គង់នឹងជួយទំនុកបម្រុងលោកឲ្យឡើងជាស្ដេចបាន **ទៀវឡូ**ឮដូច្នោះក៏មានអំណរណាស់ ព្រោះចិត្តកំរើបទើបឲ្យតែងសំបុត្រហៅខ្លួន**ម៉ាឈៀវ**ឲ្យចូលមកវិញ។ **ស៊ុនខៀន**ក៏លា**ទៀវឡូ**ចេញទៅអាស្រ័យនៅផ្ទះ**អៀវសុង** ប្រាថ្នានឹងចាំស្ដាប់សេចក្ដីដែល**ម៉ាឈៀវ**នឹងត្រឡប់មកវិញឬទេ?

បម្រើសេះដែលទៅហៅ**ម៉ាឈៀវ**នោះ ត្រឡប់មកប្ដឹង**ទៀវឡូ**វិញថា **ម៉ាឈៀវ**ឲ្យជម្រាបលោកថា នឹងសុំធ្វើការសង្គ្រាមឲ្យបានសេចក្ដីគាប់ប្រសើរសិន ទើបនឹងលើកកងទ័ពត្រឡប់វិលវិញ។ **ទៀវឡូ**ក៏ឲ្យបម្រើសេះ ឲ្យទៅហៅ**ម៉ាឈៀវ**ម្ដងទៀត ដល់ពីរគ្រាបីគ្រា **ម៉ាឈៀវ**ក៏នៅតែនិយាយដដែល។ **អៀវសុង**ដឹងសេចក្ដីដូច្នោះ ក៏ចូលទៅជម្រាប**ទៀវឡូ**ថា ឯចិត្ត**ម៉ាឈៀវ**នោះជាមនុស្សអកតញ្ញូអាក្រក់ណាស់ ដែលលោកឲ្យទៅហៅខ្លួនមិនព្រមចូលមកតាមប្រសាសន៍នោះ ខ្ញុំបាទឃើញថា **ម៉ាឈៀវ**នឹងប្រែចិត្តចេញពីលោកជាប្រាកដហើយ គួរឲ្យលោកប្រុងប្រយ័ត្នខ្លួនឲ្យមួនមាំ ហើយ**អៀវសុង**ក៏លាត្រឡប់មកវិញ ទើបប្រើមនុស្សទំនុកទុកចិត្តឲ្យចេញទៅលបស្ដាប់ដំណឹង ហើយឲ្យនិយាយប្រាប់អ្នកស្រុកទាំងពួងថា **ម៉ាឈៀវ**នោះប្រែចិត្តចេញពី**ទៀវឡូ**ហើយ ៗកំពុងគិតនឹងទៅវាយយកស្រុកហ៊ូតោ ប្រាថ្នានឹងសងសឹក**ចូឆូ**ដែលសម្លាប់**ម៉ាថេង**ជាបិតា នោះកិត្តិស័ព្ទនេះក៏រន្ទឺឮទៅដល់**ទៀវឡូ** ៗក៏មិនដឹងលកឧបាយ**អៀវសុង** ប្រុងតែគិតថា **ម៉ាឈៀវ**វាយយកស្រុកសៃឈួនហើយ ក៏នឹងលើកមកវាយយកស្រុកហាន់តុងម្ដងទៀត **ទៀវឡូ**ក៏ឲ្យហៅខ្លួន**អៀវសុង**ចូលទៅនិយាយថា ដែលយើងឲ្យហៅខ្លួន**ម៉ាឈៀវ**មិនព្រមត្រឡប់នោះ អាណាប្រជានុរាស្ត្រក៏ល្បីឮរន្ទឺអស់ហើយ អ្នកនឹងគិតយល់ប្រការម្ដេច។

**អៀវសុង**ថា **ម៉ាឈៀវ**មិនព្រមមកនេះ ត្រូវលោកឲ្យមានសំបុត្រទៅកាត់ទោស**ម៉ាឈៀវ**ទុកជាសេចក្ដីរឹងទទឹង ត្រូវធ្វើការបាន៣ខ៖ ខ១ ឲ្យ**ម៉ាឈៀវ**ខំធ្វើការច្បាំងឲ្យកងទ័ព**ឡៅពី**បែកឲ្យខាងតែបាន ខ២ ឲ្យ**ម៉ាឈៀវ**ខំលើកទៅវាយស្រុកសែឈ្លួនឲ្យខាងតែបាន ខ៣ ទោះបីថា**ឡៅជៀង**រត់ចេញពីស្រុក ក៏ឲ្យ**ម៉ាឈៀវ**ខំដេញតាមចាប់សម្លាប់ចេញហើយកាត់ក្បាលបញ្ជូនមកឲ្យយើង។ សេចក្ដីទាំង៣ខនេះ បើ**ម៉ាឈៀវ**ធ្វើបានក៏នឹងឲ្យបំណាច់រង្វាន់ដល់ខ្នាត បើខ្វះតែខឯណានីមួយត្រូវយកទោសប្រហារជីវិត ហើយឲ្យ**ទៀវអ្ហួយ**ជាប្អូនលោកនិងទាហានទៅតាំងស្កាត់ទ័ពឲ្យគ្រប់កន្លែងគយទាំងបួនអន្លើ ខ្លាចក្រែង**ម៉ាឈៀវ**នឹងមានចិត្តខឹង លើកទ័ពត្រឡប់មកវាយយកស្រុកយើងវិញ កងទ័ពទាំងអស់នេះ ក៏នឹងបានជួយគ្នាការពារពីខាងក្រៅ។ **ទៀវឡូ**យល់ឃើញត្រូវផង ក៏ចាត់ចែងទាហានលើកទៅតាំងនៅទីគយទាំងបួនតំបន់ ហើយសំបុត្រកាត់ទោសឲ្យបម្រើសេះកាន់យកទៅឲ្យ**ម៉ាឈៀវ**សេចក្ដីដូច**អៀវសុង**និយាយនោះ។

ឯ**ម៉ាឈៀវ**លុះឃើញសំបុត្រដូច្នោះហើយ ក៏ប្រឹក្សានឹង**ម៉ាតាយ**ជាប្អូនថា **ទៀវឡូ**ខឹងនឹងយើងមិនលើកកងទ័ពត្រឡប់ទៅវិញតាមសេចក្ដីដើម បានជាកាត់ទោសទុកឲ្យយើងធ្វើការឲ្យបានគ្រប់ទាំង៣ខនេះឲ្យរហូត បើមិនសម្រេចនឹងយកទោសយើងដល់ស្លាប់ ឯការទាំង៣ខនេះ យើងនឹងធ្វើទៅរហូតឬៗ ត្រូវតែគិតលើកទ័ពត្រឡប់ទៅស្រុកហាន់តុងវិញតាមពាក្យ**ទៀវឡូ**ទើបនឹងរួចខ្លួន។ **ម៉ាតាយ**យល់ឃើញត្រូវផង **ម៉ាឈៀវ**នឹងលើកទ័ពត្រឡប់វិលវិញ។

**អៀវសុង**លុះដឹងថា**ម៉ាឈៀវ**លើកកងទ័ពត្រឡប់វិលដូច្នោះ ក៏ចាត់មនុស្សឲ្យដើរទៅបរិហារនិយាយប្រាប់អ្នកស្រុកទាំងពួងថា ឥឡូវ**ម៉ាឈៀវ**គិតនឹងលើកទៅវាយយកស្រុកហាន់តុងហើយ ឥឡូវ**ទៀវឡូ**ឲ្យកេណ្ឌទាហានទៅតាំងស្កាត់ទ័ពថែមទៀត ទាំងចាស់ទាំងថ្មី៨អន្លើ ហើយបង្គាប់កំជាប់ទាហានថា កុំឲ្យទាហាន**ម៉ាឈៀវ**ប្លែកប្លបបន្លំចូលបាន។ ឯ**ម៉ាឈៀវ**នោះ លុះលើកទ័ពត្រឡប់មកវិញ ឃើញទាហាន

**ទៀវឡូ**លើកទៅស្ទាក់គ្រប់គយតាមផ្លូវ នឹងចូលទៅក្នុងស្រុកក៏មិនបាន នឹងថយត្រឡប់មកក្រោយ ក៏ក្រែងនឹង**ទៀវឡូ** រឹតតែមានសេចក្ដីសង្ស័យខ្លាំងទៅទៀត **ម៉ាឈៀវ**មិនដឹងគិតប្រការម្ដេច ក៏មានសេចក្ដីបរិវិតក្កកើតទុក្ខខ្លាំងណាស់។

**ខុងបេង**ដឹងថា **ម៉ាឈៀវ**ជាទុក្ខទោមនស្សដូច្នោះ ក៏មានចិត្តត្រេកអរណាស់ ទើបនិយាយនឹង**ឡៅពី**ថា ឥឡូវ**ម៉ាឈៀវ**នឹងចូលទៅរក**ទៀវឡូ**ក៏មិនបាន នឹងថយត្រឡប់មកវិញក៏បារម្ភ ខ្លាចក្រែង**ទៀវឡូ**សង្ស័យ **ម៉ាឈៀវ**ក៏អស់សេចក្ដីគិតទៅហើយ។ ខ្ញុំនឹងសុំអាសាទៅនិយាយបញ្ចុះបញ្ចូល**ម៉ាឈៀវ** ឲ្យចូលនៅជាមួយនឹងលោកឲ្យទាល់តែបាន។ **ឡៅពី**តបថា ខ្លួនលោកឧបមាបីដូចដួងចិត្តរបស់ខ្ញុំ ដែលលោកនឹងទៅបញ្ចុះបញ្ចូល**ម៉ាឈៀវ**នោះ ខ្លាចនឹងមានសេចក្ដីអន្តរាយអ្វីក៏មិនដឹងឡើយ ឯខ្ញុំនឹងមានសេចក្ដីព្រួយណាស់។ ខណៈកាល**ឡៅពី** និង**ខុងបេង**និយាយគ្នានោះ ទទួលបម្រើសេះកាន់សំបុត្រ**ជូឡុង**ប្ដឹងមកថា **លីអ៊ីន**ពួកស្រុកសែឈ្មួនស្គាល់រាប់អានគ្នាពីដើម ឥឡូវមានចិត្តស្ម័គ្រចូលមកនៅធ្វើការជាមួយនឹងលោក ខ្ញុំបាទក៏ទទួលខ្លួនឲ្យនៅជាមួយនឹងខ្ញុំបាទទៅហើយ។ **ឡៅពី**ឃើញសេចក្ដីសំបុត្រដូច្នោះ ក៏មានអំណរណាស់ ទើបឲ្យទៅហៅយកខ្លួន**លីអ៊ីន**ឲ្យចូលមកហើយសួរថា កាល**ឡៅជៀង**នឹងឲ្យទទួលយើងចូលទៅប្រឹក្សាការសង្គ្រាមផងនោះ ខ្លួនអ្នកបានហាមឃាត់**ឡៅជៀង** មិនឲ្យទទួលយើងចូលទៅ ឥឡូវបែកចិត្តចេញពី**ឡៅជៀង**ស្ម័គ្រមកនៅនឹងយើងវិញនោះ ដោយឃើញហេតុប្រការអ្វី?

**លីអ៊ីន**ឆ្លើយថា ពាក្យបុរាណពោលទុកថា ធម្មតាសត្វបក្សីបក្សាបើនឹងធ្វើសំបុកអាស្រ័យនៅលើដើមឈើណា ក៏ត្រូវឲ្យមើលមែកសន្លឹកដែលមានម្លប់ជិតមាំល្អ សឹមឲ្យសំណាក់នៅ ទើបបានសុខនិរទុក្ខចាកភ័យអន្តរាយទាំងពួង ឥឡូវកើតមកជាមនុស្សប្រុសក៏ត្រូវពិគ្រោះមើលនាយចៅហ្វាយ ដែលមានចិត្តអធ្យាស្រ័យល្អសុចរិតប្រាកដ ទើបលោកឲ្យចូលនៅផង ដើម្បីនឹងជួយឲ្យបានសេចក្ដីសុខតទៅ ដូចខ្លួនខ្ញុំបាទជាបាវទទួលទានបាយក្រហមរបស់នាយចៅហ្វាយហើយ ដូចជា

**ឡៅជៀង**គេក៏មានគុណូបការៈលើខ្លួនខ្ញុំបាទ ខ្ញុំបាទក៏ត្រូវជួយរំឭកហាមឃាត់តាមសតិបញ្ញាដោយសេចក្ដីកតញ្ញូ លុះ**ឡៅជៀង**មិនព្រមស្ដាប់តាមពាក្យខ្ញុំបាទហើយ ខ្ញុំបាទក៏បានសេចក្ដីតូចចិត្តគិតអៀនខ្មាសទៅដែរ បើនឹងមិនប្រែចិត្តគិតសាជាថ្មី ខំតែនៅទៅក៏គង់នឹងមានទុក្ខភ័យដល់ខ្លួន បានជាខ្ញុំបាទចូលមកជ្រកកោននៅនឹងលោកវិញដូច្នេះ ព្រោះបានឮកេរ្តិ៍ឈ្មោះពីរោះពិសាថា លោកមានចិត្តមេត្តាករុណាដោយស័ត្យពិតត្រង់ល្អណាស់ សូម្បីមនុស្សទាំងក្មេងចាស់ក្នុងស្រុកសែឈ្វនក៏គង់ស្រឡាញ់លោកជាច្រើន ការទាំងពួងដែលលោកបំណងនឹងធ្វើក៏គង់បានចម្រើនដូចប្រាថ្នាជាប្រាកដ។

**ឡៅពី**សួរថា ដែលអ្នកតាំងចិត្តមកនៅធ្វើរាជការនឹងយើងនេះ អ្នកនឹងជួយរិះគិតធ្វើការប្រការម្ដេចខ្លះ ដើម្បីឲ្យបានជាប្រយោជន៍ដូចប្រាថ្នានោះ? **លីអ៊ីន**ថា ឥឡូវឮកិត្តិសព្ទថា **ម៉ាឈៀវ**នឹងចង់ចូលទៅរក**ទៀវឡូ**វិញក៏ពុំបាន នឹងថយត្រឡប់មកក្រោយក៏ឲ្យបារម្ភខ្លាច ទើបមិនអាចនឹងរិះគិតយ៉ាងណា ដូចជាទាល់ប្រាជ្ញាទៅហើយ ឯ**ម៉ាឈៀវ**នោះនិងខ្ញុំបាទក៏ធ្លាប់រាប់អាន បានស្គាល់ចិត្តគ្នាមកយូរហើយ ខ្ញុំបាទនឹងចង់សុំយកអាសាចេញទៅបញ្ចុះបញ្ចូល**ម៉ាឈៀវ**ឲ្យប្រែចិត្ត គិតមកនៅធ្វើរាជការនឹងលោកឲ្យទាល់តែបាន។ **ខុងបេង**ថា យើងក៏ខំរកតែអ្នកឯណា ដែលមានសតិបញ្ញានឹងឲ្យទៅនិយាយបញ្ចុះបញ្ចូល**ម៉ាឈៀវ**ជាយូរថ្ងៃមកហើយ មិនទាន់បាន បើអ្នកអាចហ៊ានទទួលធុរៈដូច្នេះក៏ជាការប្រពៃណាស់ ចូរខំប្រឹងរួតរះទៅនិយាយឲ្យបានការចុះ ទើបនឹងបានសេចក្ដីគាប់ប្រសើរតទៅ។

**លីអ៊ីន**ទទួលពាក្យនឹង**ខុងបេង**, **ឡៅពី**ហើយ ក៏ស្រូតចេញទៅដល់កងទ័ព**ម៉ាឈៀវ**ក៏ប្រាប់ពួកទាហានយាមថា ខ្ញុំឈ្មោះ**លីអ៊ីន**នឹងសុំចូលទៅរក**ម៉ាឈៀវ**។ ទាហានក៏ចូលទៅជម្រាបការតាមដំណើរនោះ។ **ម៉ាឈៀវ**ដឹងដូច្នោះទើបថា ឯ**លីអ៊ីន**នោះជាមនុស្សពូកែខាងសម្ដីណាស់ ការដែលមកនេះ ប្រាថ្នានឹងមកបញ្ចុះបញ្ចូលយើងហើយ ទើបរៀបទាហានឲ្យមានកាន់សាស្ត្រាវុធគ្រប់ដៃចំនួន២០នាក់ ហើយក៏

បង្គាប់ថា បើ**លីអ៊ុន**ចូលមកនិយាយការនឹងយើង បើឮថាឲ្យយើងចុះដៃវេលាណា ឲ្យអ្នករាល់គ្នាចូលព្រួតចាប់**លីអ៊ុន**សម្លាប់ចេញទៅចុះ ហើយកាប់ចិញ្ច្រាំសាច់ឲ្យល្អិត លុះបង្គាប់ការរួចហើយ ក៏ប្រើទាហានឲ្យចេញទៅហៅ**លីអ៊ុន**ចូលមក។

**ម៉ាឈៀវ**ក៏សួរ**លីអ៊ុន**ដោយសំឡេងគំហកខ្លាំងថា ខ្លួនមករកយើងវេលានេះដោយត្រូវការអ្វី? **លីអ៊ុន**ឆ្លើយថា យើងមកនេះដើម្បីមកបញ្ចុះបញ្ចូល**ម៉ាឈៀវ**។ អ្នកនឹងបញ្ចុះបញ្ចូលប្រការម្ដេច ត្រូវថាទៅឲ្យល្អចុះ ព្រោះគ្រប៊ីដែលយើងកាន់នេះទើបនឹងសំលៀងថ្មី បើថាមិនត្រូវចិត្តយើង ៗនឹងយកគ្រប៊ីនេះល្បងក្បាលអ្នកលមើល។

**លីអ៊ុន**ឮដូច្នោះក៏អស់សំណើចហើយថា វេលានេះយើងដឹងប្រាកដថាភ័យនឹងមកដល់អ្នកហើយ បានជាយើងមកការពារឲ្យផុតអំពីភ័យនោះ ម្ដេចអ្នកត្រឡប់ថាយកគ្រប៊ីល្បងក្បាលយើងវិញដូច្នោះ ឯគ្រប៊ីរបស់អ្នកនោះ បើទុកជាទើបនឹងសំលៀងថ្មី ក៏មិនគប្បីនឹងសម្លាប់កាត់ក្បាលយើងបានទេ ថប់តែអ្នកដទៃនឹងគេកាត់ក្បាលអ្នកវិញទេដឹង។ **ម៉ាឈៀវ**សួរថា អ្នកឯងដឹងថា នរណានឹងប្រាថ្នាកាត់ក្បាលយើងនោះ? **លីអ៊ុន**តបថា ធម្មតាស្រីរូបល្អ ទោះបីនឹងយកគ្រឿងអំពរដែលទុព្វលភាពមកបំពាក់ក៏មិនមែនធ្វើឲ្យរូបនោះអបលក្ខណ៍ទៅវិញបាន។ បើស្ត្រីនោះមានរូបកាយអាក្រក់សាមាន្យ សូម្បីនឹងយកគ្រឿងប្រដាប់ដ៏ល្អភុំផានមកបំពាក់យ៉ាងណា រូបកាយដែលអាក្រក់នៅជាអាក្រក់តាមធម្មតាទាំងអស់ ពុំនោះដូចដួងព្រះអាទិត្យ បើដល់កំណត់ដើរត្រង់ណា រស្មីក៏ក្ដៅបរិឡាខ្លាំងណាស់ ឬដូចដួងព្រះចន្ទ ដែលរៀងរះស្រឡះពពកក្នុងវេលាថ្ងៃពេញបូណ៌មី ក៏មានរស្មីភ្លឺស្វាងរុងរឿងជ្រះថ្លា បើទៅដល់រនោចកាលណា ក៏តែងអាប់អន់ពន្លឺអស់ទៅតាមធម្មតាលោកដូច្នោះ។ ដូចយ៉ាងខ្លួនអ្នកនៅកំពុងពេញពាល ដូចព្រះចន្ទពេញបូណ៌មី ឬដូចព្រះអាទិត្យកំពុងថ្ងៃត្រង់ ព្រមទាំងរូបអង្គទ្រង់ទ្រាយពណ្ណរាយល្អ សមគួរជាទាហានឯកក្នុងផែនដី គប្បីនឹងរិះគិតធ្វើសឹកសង្គ្រាមតាមដែលមានមកពីអតីត មិនត្រូវគិតលះចោលសោះ។ ឯ

សង្គ្រាមនោះ គឺ**ចូឆ្វ**ឯងដែលនាំសម្លាប់បិតាអ្នក ៗក៏ត្រូវគិតតាំងចិត្តសងសឹកវិញឲ្យបាន ទើបនឹងមានកេរ្តិ៍ឈ្មោះជាមនុស្សកតញ្ញូនឹងបិតា។ ឥឡូវខ្លួនអ្នកធ្លាក់មកនៅក្នុងទីនេះអស់តម្រិះនឹងគិតយកខ្លួនឲ្យរួចហើយ បើនឹងរាទៅរក**ឡៅជៀង**ចៅហ្វាយស្រុកសៃឈួនក៏មិនបាន បើនឹងត្រឡប់ទៅរាប់អាន**ទៀវឡូ**វិញ **ទៀវសុង**ក៏ចេះតែញុះញង់ឲ្យទាស់អធ្យាស្រ័យ។ សព្វថ្ងៃនេះ**ទៀវឡូ**ក៏ប្រើទាហានមកចាំស្ទាក់ផ្លូវនៅគ្រប់តំបន់អស់ហើយ អ្នកនឹងចូលទៅឆ្លើយដោះសារឲ្យ**ទៀវឡូ**ជឿស្ដាប់ឯណាបាន បើគ្មានផ្លូវទៅដូច្នេះ បើអ្នកនឹងរូតរះវាយទម្លាយទ័ព**ឡៅពី**ឲ្យបែកក៏មិនងាយ មួយទៀតក៏មិនបានគាប់ប្រសើរនឹង**ទៀវឡូ** ជានាយចៅហ្វាយថ្មីនោះទេ។ គួរតែនឹងគិតគ្នេរមើលក្នុងខ្លួនឲ្យដឹងថា វេលានេះខ្លួនអ្នកមកនៅក្នុងកណ្ដាលកងភ្លើងដូច្នោះ ត្រូវរិះគិតដកខ្លួនឲ្យរួចពេញជាជាតិទាហានមានប្រាជ្ញា។ ខ្ញុំយល់ឃើញថា ដែលអ្នកដំអឹងរឹងនៅដូច្នេះ កាលគ្រាអ្នកទៅចម្បាំងនៅតំបន់អ៊ុយហោ ចាញ់ប្រៀប**ចូឆ្វ**បែកទៅនោះ ក៏មានសេចក្ដីលំបាកពន់ប្រមាណណាស់។ គ្រានេះទោះបីថាអ្នកនឹងមិនស្លាប់ ក៏គង់បានភពប្រសព្វលើសេចក្ដីអប្បយសលើសជាងពីគ្រាមុននោះទៅទៀត នឹងខំផ្អៀតមើលមុខគេក៏មិនពេញភ្នែក ហេតុនេះ បានជាខ្ញុំគិតសង្វេគមកជួយរំឭកស្មារតីដោយមេត្រីរាប់អាន។

**ម៉ាឈៀវ**ឮដូច្នោះក៏រសាយសេចក្ដីខឹង បោះគ្រប៊ីចេញពីដៃ ហើយក្រោកឡើងគំនាប់**លីអ៊ីន**ថា ដែលអ្នកមករំឭកខ្ញុំដូច្នេះគួរសមណាស់ តែខ្លួននៅក្នុងទីចង្អៀតចង្អល់គិតមិនយល់ច្បាស់ផ្លូវ ដែលនឹងដើរទៅទីណាបានឡើយ។ បើអ្នកមានចិត្តអាណិតខ្ញុំមេត្តាជួយណែនាំបំភ្លឺចុះ ខ្ញុំនឹងទទួលធ្វើតាម។ **លីអ៊ីន**តបថា ខ្ញុំនឹងជួយណែនាំរំឭកឲ្យអ្នកយល់ក៏បានខ្លះដែរ តែថាពួកទាហានរបស់អ្នកកាន់អាវុធឈរប្រចាំនឹងធ្វើអន្តរាយខ្ញុំ ៗនឹងថាការអ្វីបាន។ **ម៉ាឈៀវ**ក៏បណ្ដេញពួកទាហានទាំងនោះឲ្យចេញទៅក្រៅអស់។ **លីអ៊ីន**តបថា **ឡៅពី**នោះចំពោះជាពូជព្រះរាជវង្សព្រះចៅ**ហៀនតេ**ប្រាកដ ប្រកបទាំងចិត្តអធ្យាស្រ័យធូរទូលាយ គិតតែទំនុកបម្រុង

ផែនដីឲ្យបានសេចក្តីសុខតទៅ ដូចជា**ម៉ាថេង**បិតាអ្នកកាលរស់នៅ ៗក្នុងស្រុកហ៊ូតោនោះ ក៏បានពិគ្រោះត្រូវគំនិតគ្នានឹង**ឡៅពី**ថានឹងជួយគ្នាកម្ចាត់**ចូឆូ**ចេញ ព្រោះឃើញថាជាគូសត្រូវរាជសម្បត្តិពិតណាស់ ការនេះក៏គិតពុំទាន់បានសម្រេច ឥឡូវត្រូវអ្នកមកជំពាក់ខ្លួននៅដូច្នេះ បើប្រសិនជាអ្នកនឹងរិះគិតទៅនៅនឹង**ឡៅពី**វិញ ដើម្បីនឹងជួយបំពេញគំនិតគិតធ្វើការបំបាត់**ចូឆូ**ចេញ អ្នកក៏បានរសាយសេចក្តីទុក្ខទោម្នេញនោះអស់ទៅ ទាំងឈ្មោះសំឡេងអ្នកក៏នៅឮល្បីជាប្រាកដទៅមុខទៀត។

**ម៉ាឈៀវ**បានឮដូច្នោះក៏មានអំណរណាស់ ឲ្យហៅខ្លួន**អៀវប៉េក**ដែលជានាយទាហាន**ទៀវឡូ**ចូលមក ហើយក៏ចាប់សម្លាប់មួយរំពេច ហើយកាត់យកក្បាល**អៀវប៉េក**នោះនាំទៅជាមួយនឹង**លីអ៊ុន** និងទាហានទាំងពួងទៅឯទីគយហែបាំងគួន។ ឯ**ឡៅពី**ដឹងថា **ម៉ាឈៀវ**លុះក្នុងឧបាយ**លីអ៊ុន**បានចូលខ្លួនមកជាមួយនឹង**លីអ៊ុន**ដូច្នោះ ក៏មានសេចក្តីត្រេកអរពន់ប្រមាណណាស់ ចេញទៅចាំទទួល**ម៉ាឈៀវ**នាំចូលមក។ **ម៉ាឈៀវ**គំនាប់**ឡៅពី**ហើយថា ដែលខ្ញុំបាទបានមកនៅនឹងលោកជាអ្នកមានសតិបញ្ញាដូច្នេះ ខ្ញុំបាទមានអំណរណាស់ ឧបមាដូចនៅក្នុងទីងងឹត មានគេនាំឲ្យមកដល់ទីដែលភ្លឺ នោះអ្វីជារបស់លោកត្រូវការប្រើខ្ញុំបាទចុះ ខ្ញុំបាទនឹងសុំទទួលយកអាសាធ្វើត្រាតែអស់តម្រិះប្រាជ្ញា និងសតិកម្លាំងផង ជីវិតមិនគិតស្តាយឡើយ។ ខណៈនោះ **ស៊ុនខៀន**ដឹងថា **ម៉ាឈៀវ**ចូលទៅនៅនឹង**ឡៅពី**ហើយ ក៏លា**អៀវសុង**ត្រឡប់ទៅប្តឹង**ឡៅពី**គ្រប់ប្រការ។

**ឡៅពី**បង្គាប់**បេងតាត់** និង**ហាក់ជុន**ឲ្យនៅរក្សាបន្ទាយ ហើយឲ្យរៀបចំទាហានលើកត្រឡប់នឹងវាយយកស្រុកសែឈួន លុះទៅដល់ស្រុកគឹមកុក **ជូឡុង**, **ហាងតុង** ដឹងក៏ចេញមកទទួល**ឡៅពី**ចូលទៅក្នុងស្រុកហើយជម្រាបថា ឥឡូវ**ឡៅជៀង**ប្រើ**ឡៅឃួន**និង**ម៉ាហ័ន**លើកទាហានមកជាច្រើន ខ្ញុំបាទនឹងសុំអាសាចេញទៅកាត់ក្បាលនាយទាហានទាំងពីរមកជូនលោក។ **ឡៅពី**ក៏បើកឲ្យទៅ។ **ជូឡុង**ជិះសេះនាំទាហានចេញពីស្រុកគឹមកុក បានច្បាំងនឹងនាយទាហានទាំងពីរ។ ឯ**ឡៅពី**

នៅក្នុងស្រុក ឲ្យរៀបតុលៀង**ម៉ាឈៀវ**នៅមិនទាន់នឹងសម្រេច ទទួលឃើញ**ជូឡុង**យួរក្បាល**ឡៅយួន**ចូលមកជូន**ឡៅពី**។ **ម៉ាឈៀវ**ឃើញដូច្នោះ ក៏ភ័យស្លុតគិតថា**ជូឡុង**នាយទាហាននេះមានថ្វីដៃរហ័សរហួនណាស់ **ម៉ាឈៀវ**ក៏រិះគិតតែកោតក្រែង**ឡៅពី**ពន់ប្រមាណណាស់ ទើបជម្រាប**ឡៅពី**ថា ឯស្រុកសែឈ្នួននោះ លោកកុំបាច់លើកកងទ័ពទៅឲ្យបានសេចក្ដីលំបាកនឿយព្រួយដល់ទាហានឡើយ។ ខ្ញុំបាទសុំអាសាចូលទៅនិយាយនឹង**ឡៅជៀង** ឲ្យចេញមកចំណុះចូលលោកដោយស្រួល បើ**ឡៅជៀង**រឹងទទឹង ខ្ញុំបាទនឹង**ម៉ាតាយ**ជាប្អូននឹងលើកទាហានទៅវាយយកស្រុកសែឈ្នួនឲ្យបាន។ **ឡៅពី**ឮដូច្នោះក៏មានអំណរណាស់ លុះលៀងអាហារស្រេចបរិបូរហើយ នាយទាហានទាំងពួងក៏លាទៅកាន់ទីសំណាក់។

ខណៈនោះ មានទាហានដែលមកក្នុងកងទ័ព**ឡៅយួន**, **ម៉ាហ័ន**នោះបែករត់ត្រឡប់ទៅប្រាប់**ឡៅជៀង**គ្រប់ប្រការ **ឡៅជៀង**ដឹងដូច្នោះក៏ភ័យខ្លាំងណាស់ ឲ្យបិទទ្វារស្រុកជិតទាំងអស់ ហើយឲ្យទាហានរក្សាសើនបន្ទាយជុំវិញមាំមួនណាស់។ ខណៈនោះ**ម៉ាឈៀវ**ក៏លា**ឡៅពី**លើកកងទ័ពតម្រង់ទៅស្រុកសែឈ្នួន។

ទាហានដែលនៅលើសើនបន្ទាយ ឃើញ**ម៉ាឈៀវ**លើកមកជិតកំផែង ក៏ចូលទៅប្រាប់**ឡៅជៀង**ថា ឥឡូវ**ម៉ាឈៀវ**លើកកងទ័ពមកព័ទ្ធជិតគូកំផែងស្រុកហើយ។ **ឡៅជៀង**ក៏ឡើងទៅមើលលើសើនបន្ទាយ ទទួល**ម៉ាឈៀវ**ក្រឡេកទៅឃើញ ក៏ស្រែកអញ្ជើញ**ឡៅជៀង**ឲ្យងាកមុខចេញមក នឹងសុំនិយាយការផង។

**ឡៅជៀង**ឮហើយ ក៏អើតមុខចេញទៅ ហើយស្រែកថា អ្នកឯងចង់និយាយការអ្វីក៏ឲ្យស្ដីមកចុះ។ **ម៉ាឈៀវ**ថា ពីដើមយើងលើកទាហាន**ទៀវឡូ**ទៅធ្វើសង្គ្រាមនឹង**ឡៅពី**ប្រាថ្នានឹងជួយការពារស្រុកលោក តែ**អៀវសុង**ញុះញង់**ទៀវឡូ**ឲ្យមានសេចក្ដីសង្ស័យនឹងយើង ៗទើបនាំទាហានទៅនៅនឹង**ឡៅពី** ឥឡូវលោកត្រូវរិះគិតជាប្រញាប់ចេញមកចំណុះចុះចូល លើកស្រុកប្រគល់ជូន**ឡៅពី**ដោយល្អចុះ ទើបនឹងផុតសេចក្ដីអន្តរាយមិនមានដល់ខ្លួនលោក ហើយបណ្ដារាស្ត្រក្នុងស្រុក ក៏នឹងបាន

សេចក្ដីសុខតទៅ បើលោកនៅតែរឹងទទឹង យើងនឹងអាសា**ឡៅពី**វាយយកស្រុកសៃឈួនឲ្យទាល់តែបាន។

**ឡៅជៀង**ឮដូច្នោះ ក៏ឲ្យស្លុតស្មារតីភ័យទាល់តែដួលចុះសន្លប់នៅទីនោះ។ ទីប្រឹក្សានិងទាហានទាំងពួងក៏នាំគ្នាគ្រាហ៍ធ្វើឲ្យដឹងស្មារតីឡើងវិញ។ **ឡៅជៀង**ប្រឹក្សានឹងទាហានទាំងពួងថា ការទាំងនេះ យើងមិនបានត្រិះរិះឲ្យរហូតជាមុន ទើបបណ្ដាលឲ្យចាញ់ប្រៀបគេ លុះនឹងប្រឹងក្នុងវេលានេះ ចេះតែស៊ូច្បាំងទៅ ការក៏កាន់តែប្រទាល់ខ្លួនដល់ប៉ុណ្ណោះទៅហើយ យើងអាណិតអាសូរប្រជានុរាស្ត្រ ប្រាថ្នានឹងមិនឲ្យបានសេចក្ដីក្ដៅក្រហាយគិតនឹងចេញទៅសុំចំណុះលើកស្រុកឲ្យ**ឡៅពី** តើអ្នកទាំងអស់គ្នានឹងយល់ឃើញប្រការម្ដេច។ **តាំងហោ**ឆ្លើយថា ទាហានដែលមានក្នុងស្រុកយើងក៏ច្រើនដែរ គិតឃើញចំនួនបីម៉ឺនប្លាយ ទាំងស្រូវអង្ករស្បៀងអាហារក៏បរិបូរល្មមនឹងជប់លៀងទាហានគ្រប់គ្រាន់បានក្នុងរវាងមួយឆ្នាំ ដែលលោកនឹងលើកស្រុកទៅឲ្យ**ឡៅពី**ដោយងាយនោះមិនគួរសោះ។

**ឡៅជៀង**តបថា បិតាយើងនិងខ្លួនយើងបានមកនៅក្នុងស្រុកនេះដល់កំណត់ ២០-៣០ឆ្នាំហើយ បណ្ដារាស្ត្រអ្នកស្រុកក៏មិនដែលបានទុក្ខលំបាកពីព្រោះអ្វី គ្រានេះ**ឡៅពី**លើកកងទ័ពមកធ្វើអន្តរាយអាណាខេត្ត ហើយទន្ទ្រានចូលមកដល់ដែនស្រុកយើង រាស្ត្រទាំងឡាយក៏បានសេចក្ដីក្ដៅក្រហាយគ្រប់បីឆ្នាំមកហើយ ខ្លួនយើងមានចិត្តអាណិតអាណាប្រជានុរាស្ត្រណាស់ បានជារិះគិតនឹងលន់តួចំណុះ**ឡៅពី**។ **ចៅជីវ**ទីប្រឹក្សាឆ្លើយថា លោកគិតនេះត្រូវណាស់ ព្រោះខ្ញុំបាទបានឃើញផ្កាយសម្រាប់ស្រុកសៃឈួននោះបាត់ទៅ មានផ្កាយមួយដួងរះធំឡើងជំនួស មានពន្លឺរស្មីភ្លឺដូចព្រះចន្ទ មានផ្កាយតូចៗចោមរោមជាបរិវារ ចោមរោមច្រើនណាស់ ហើយខ្ញុំបាទបានឮកូនក្មេងក្នុងស្រុកសៃឈួនធ្វើភ្លេងលេងថា បើអ្នកណានឹងចង់ពិសាអាហារថ្មី ចូរចាំម្ចាស់ផែនដីមកឈរស្រុកនេះចុះ ទើបសមតាមសេចក្ដីប្រាថ្នា។

**អ៊ុយគួន, ឡៅប៉ា** បានឮដូច្នោះក៏ខឹងណាស់ កន្ត្រាក់យកគ្រប៊ីមកកាន់គិតនឹងសម្លាប់**ចៅជីវ**ចេញ។ **ឡៅជៀង**ក៏ស្ទុះទៅឃាត់ ទទួលមានបម្រើចូលទៅប្តឹង**ឡៅជៀង**ថា **ខៅចេង**ដែលជាបាឡាត់ខេត្តនោះ លបរត់ចេញទៅនៅខាង**ឡៅពី**ទៅហើយ។ **ឡៅជៀង**បានឮដូច្នោះក៏រឹតតែតូចចិត្តអង្គុយយំ ហើយត្រឡប់ចូលទៅខាងក្នុង។ លុះវេលាព្រឹកឡើងនាយទ្វារចូលមកប្តឹង**ឡៅជៀង**ថា ឥឡូវ**ឡៅពី**លើកកងទ័ពមកពីគយហែបាំងគួនហើយ បោះទ័ពនៅខាងក្រៅស្រុកយើងនេះ ឲ្យ**កាន់យ៉ុង**ចូលមករកលោក។ **ឡៅជៀង**បង្គាប់ឲ្យបើកទ្វារស្រុកទទួលចូលមក នាយទ្វារក៏ចេញបើកទ្វារទទួល។

ឯ**កាន់យ៉ុង**នោះក៏ជិះរទេះចូលទៅដល់កណ្តាលស្រុក **ជិនពី**ឃើញដូច្នោះក៏ខឹងណាស់ កន្ត្រាក់គ្រប៊ីគ្រវែងឡើង ហើយស្រែកទៅ**កាន់យ៉ុង**ថា ខ្លួនឯងជាជាតិថោកទាបហេតុម្តេចទើបហ៊ានជិះរទេះចូលមកដល់កណ្តាលស្រុក ឯងមើលងាយថាស្រុកសែឈ្លួននេះគ្មានមនុស្សល្អទេឬ ទើបព្រហើនដូច្នេះ? **កាន់យ៉ុង**ឮដូច្នោះក៏ចុះពីលើរទេះគំនាប់សួរឈ្មោះគ្នាទៅវិញទៅមក ហើយ**កាន់យ៉ុង**ថា ខ្ញុំបាទជាមនុស្សប្រមាទ ហ៊ានជិះរទេះចូលមកដល់ពាក់កណ្តាលស្រុក អ្នកកុំប្រកាន់ទោសឡើយ។ **ជិនពី**ក៏រសាយកំហឹងទើបនាំ**កាន់យ៉ុង**ចូលទៅជួបនឹង**ឡៅជៀង**។ **កាន់យ៉ុង**ឱនគំនាប់ហើយជម្រាបថា **ឡៅពី**នោះជាមនុស្សមានស្មារតី មានចិត្តអាណិតករុណាបណ្តារាស្ត្រច្រើនណាស់ គួរលោកតាំងចិត្តលំអុតលំឱនដល់**ឡៅពី**ដោយសុចរិត ហើយ**ឡៅពី**ក៏នឹងមិនមានប្រទូសរ៉ាយដល់លោកទេ។

**ឡៅជៀង**ឮដូច្នោះក៏បណ្តាលចិត្តញញើតកោតខ្លាច**ឡៅពី**ខ្លាំងណាស់ ទើបនិយាយជាពាក្យដាច់ថា អ្នករាល់គ្នាកុំបីនិយាយរឹងទទឹងនឹងយើងឡើយ យើងនឹងទំនុកបម្រុងអាណាប្រជានុរាស្ត្រទាំងពួងឲ្យបានសេចក្តីសុខតទៅ ក្នុងគ្រានេះ យើងនឹងចេញទៅលន់តួសុំចំណុំចុះចូល**ឡៅពី** ទើបឲ្យរៀបតុលៀង**កាន់យ៉ុង**ឲ្យបរិភោគអាហារ លុះលៀងរួចហើយ ក៏យកត្រាសម្រាប់ងារនូវអស់របស់ទ្រព្យដែលល្អ

ត្រកាល នាំទាហានចេញទៅគំនាប់**ឡៅពី**ក្នុងបន្ទាយ។ **ឡៅពី**ឃើញដូច្នោះ ក៏ចុះទៅទាញដៃ**ឡៅជៀង**ឲ្យឡើងទៅអង្គុយថ្នាក់លើ **ឡៅពី**យំហើយនិយាយនឹង**ឡៅជៀង**ថា ខ្លួនយើងនេះ មានចិត្តសុចរិតគិតនឹងទំនុកបម្រុងផែនដី ឲ្យបណ្ដារាស្ត្របានសេចក្ដីសុខតទៅ ដែលខំមកធ្វើទាំងម្ល៉េះដោយសេចក្ដីថាំចិត្ត លុះនឹងមិនគិតធ្វើដូច្នេះ ការដែលគិតទុកនោះក៏មិនបានរហូត អ្នកចូរឃើញដល់ផែនដីដែលបានសេចក្ដីក្ដៅក្រហាយនោះចុះ កុំបីប្រកាន់ទោសដល់យើងឡើយ។ **ឡៅជៀង**តបថា ធម្មតាអ្នកដែលទំនុកបម្រុងផែនដីនោះ ទោះដូចម្ដេចក៏ត្រូវតែធ្វើដូចជាលោកទាំងអស់ ខ្ញុំបាទឥតគិតអ្វីសោះឡើយ ហើយក៏លើកត្រាសម្រាប់ងារនោះជូនទៅឲ្យ**ឡៅពី**ព្រមទាំងបណ្ដាការទាំងពួង។ **ឡៅពី**ទទួលហើយ ក៏មានសេចក្ដីសោមនស្សសាទរអរពេកណាស់។ **ឡៅជៀង**ក៏អញ្ជើញ**ឡៅពី**និងបណ្ដាសេនាទាហានចូលទៅក្នុងស្រុក។ ខណៈនោះ មនុស្សម្នាមហាជនទាំងឡាយទាំងពួងបណ្ដាដែលមានក្នុងអំឡុងស្រុកសែឈួនទាំងប៉ុន្មាន បានក្រឡេកឃើញ**ឡៅពី**ចូលទៅ ក៏ស្រុះស្រួលបបួលគ្នាអុជទៀនធូបបូជាព្លីការ**ឡៅពី** តាមលំដាប់មាគ៌ាទាំងសងខាងរៀងទៅ។ **ឡៅពី**នោះលុះក្រឡេកឃើញដូច្នោះក៏មានចិត្តត្រេកអរណាស់ កាលបើយាត្រាទៅដល់ទីគេហដ្ឋាននិយាយការរាជការហើយ ក៏ឃើញទីប្រឹក្សារបស់**ឡៅជៀង**ទាំងប៉ុន្មាន ចូលទៅត្រៀមចាំគំនាប់**ឡៅពី**ទាំងអស់ បាត់តែឈ្មោះ**អ៊ុយគួន១, ឡៅប៉ា១**មិនបានចូលទៅគំនាប់**ឡៅពី**។

ពួកទាហាន**ឡៅពី**ដឹងដូច្នោះ ក៏បបួលគ្នានឹងទៅចាប់**អ៊ុយគួន**និង**ឡៅប៉ា**សម្លាប់ចេញ។ **ឡៅពី**ឮពាក្យទាហាននិយាយគ្នាដូច្នោះក៏ក្ដែងបង្គាប់ថា ឲ្យសម្លាប់ឲ្យអស់ទាំងពូជពង្សវង្សញាតិកានិងស្ម័គ្របក្សពួកកុំឲ្យសល់ ហើយ**ឡៅពី**ក៏ស្រូតតាមទាហានទាំងពួងទៅ លុះទៅដល់មុខផ្ទះ**អ៊ុយគួន, ឡៅប៉ា** **ឡៅពី**ក៏ឃាត់ហាមទាហានទាំងពួងឲ្យបង្អង់ឈប់ហើយក្ដែងស្រែកប្រកាសឲ្យឮច្បាស់ទៅដល់**អ៊ុយគួន, ឡៅប៉ា**ថា ឯ**អ៊ុយគួន** និង**ឡៅប៉ា**នោះ គេជាមនុស្សមានសេចក្ដីស័ត្យពិតត្រង់នឹងនាយ

ចៅហ្វាយណាស់ គួរយើងនឹងចិញ្ចឹមរក្សាទុកតទៅ កុំបីអស់អ្នកទាំងពួងធ្វើអន្តរាយគេឡើយ សូម្បីតែអំបោះមួយសរសៃ ឬម្ជុលមួយ ក៏មិនត្រូវធ្វើឲ្យបាត់របស់គេជាដាច់ខាត បើនរណាមិនស្តាប់ពាក្យយើងហាមឃាត់ទេ យើងនឹងចុះទោសដល់ជីវិត។ **អ៊ុយគួន, ឡៅប៉ា** ឮ**ឡៅពី**ស្រែកប្រកាសដូច្នោះ ក៏ពិគ្រោះគ្នាថា **ឡៅពី**នេះគេជាមនុស្សល្អ មានអធ្យាស្រ័យសុភាពរៀបរយដូចពាក្យគេនិយាយមែនៗ គួរតែយើងនឹងចូលទៅធ្វើរាជការផងចុះ លុះនិយាយហើយក៏នាំគ្នាចេញទៅគំនាប់គោរព**ឡៅពី** ៗក៏ទទួលរួសរាយ ហើយនាំខ្លួន**អ៊ុយគួន, ឡៅប៉ា**ទៅទីលំនៅ រួចក៏តាំងនៅក្នុងទីដដែលតាមដើម។

**ខុងបេង**និយាយនឹង**ឡៅពី**ថា ស្រុកសែឈួនថ្ងៃនេះបានរាបទាបស្រួលបួលហើយ ដែលនឹងឲ្យមានចៅហ្វាយស្រុកពីររូបនោះមិនគួរសោះ គួរតែឲ្យ**ឡៅជៀង**ទៅស្រុកកេងជីវវិញ។ **ឡៅពី**ថា ខ្លួនយើងទើបតែនឹងបានស្រុកសែឈួននេះ បើនឹងឲ្យ**ឡៅជៀង**ទៅនៅស្រុកកេងជីវ មនុស្សទាំងពួងនឹងគរហានិន្ទាថា យើងក្លែងបញ្ឆោត**ឡៅជៀង**ឲ្យខូចស្រុកសែឈួន។

**ខុងបេង**ថា ឯ**ឡៅជៀង**នេះជាមនុស្សមិនចេះដឹងអ្វីសោះ ហើយថែមទាំងខូចចិត្តគំនិតទៅហើយ បើយើងនឹងទុកឲ្យនៅក្នុងស្រុកនេះជាមួយយូរទៅ ខ្លាចមានគេនាំញុះញង់គង់នឹងស្តាប់ជឿពាក្យគេ ខ្លួនលោកក៏គង់នឹងបានសេចក្តីរំខានចិត្តទៅថ្ងៃក្រោយ។ **ឡៅពី**យល់ឃើញត្រូវ លុះកន្លងមកមួយថ្ងៃ **ឡៅពី**ក៏ឲ្យអញ្ជើញ**ឡៅជៀង**ទៅលៀងអាហារហើយនិយាយថា យើងនឹងឲ្យអ្នកទៅនៅឈរស្រុកកងអាន់។ **ឡៅជៀង**ក៏ទទួលប្រសាសន៍។ **ឡៅពី**ក៏ឲ្យធ្វើត្រាតាំង ៗ**ឡៅជៀង**ជាជីវវុយចុងកុនឲ្យនាំគ្រប់គ្រួសារចេញទៅឈរស្រុកកងអាន់ ដែលឡើងស្រុកកេងជីវ។ **ឡៅពី**ប្រគល់ត្រាតាំងឲ្យ**ឡៅជៀង**ហើយថា មាសប្រាក់និងទ្រព្យសម្បត្តិរបស់អ្នកទាំងប៉ុន្មាន ចូរនាំយកទៅទាំងអស់ចុះ។ **ឡៅជៀង**ទទួលយកត្រាសម្រាប់ងារ ហើយក៏នាំគ្រប់គ្រួនិងបក្សពួកទៅនៅស្រុកកងអាន់។

ឯ**ឡៅពី**កាលបានស្រុកសែឈួនហើយ បណ្ដាទីប្រឹក្សានិងសេនាទាហានរបស់**ឡៅជៀង**ទាំងប៉ុន្មាន **ឡៅពី**ក៏តាំងឲ្យធ្វើនាហ្មឺនមុខមន្ត្រីខាងរដ្ឋបាលទាំងអស់ តែ**ហ្លួតចេង**នោះតាំងឲ្យធ្វើបាឡាត់ស្រុកសែឈួន ហើយ**ឡៅពី**ក៏តាំង**ខុងបេង**ជាអាចារ្យធំសម្រាប់ប្រៀនប្រដៅ តាំង**គួនអ៊ូ**ឲ្យជាចៅហ្វាយស្រុកកេងជីវ ឯ**តៀវហ៊ុយ** **ជូឡុង**, **អ៊ុយអៀន**, **ហងតុង**, **ឡៅហង**, **លៀវហ៊្វ**, **ម៉ាចេក**, **ម៉ាលៀង**, **ថៀងអួន**, **អ៊ីថៀ** ទាំងនេះជានាហ្មឺនធំតូចតាមលំដាប់ ហើយឲ្យបំណាច់រង្វាន់ជាច្រើនគ្រប់ៗគ្នា តែ**ជីវឆង**, **គួនប៉េង**ចាត់ឲ្យទៅនៅធ្វើរាជការជាមួយ**គួនអ៊ូ**ឯស្រុកកេងជីវ ហើយ**ឡៅពី**ចាត់មាសប្រាំរយជញ្ជីងប្រាក់មួយពាន់ជញ្ជីង អ៊ីប៉េះប្រាំពាន់ម៉ឺន ព្រែយ៉ាងល្អមួយពាន់ផាប់ ឲ្យទាហាននាំទៅជាបំណាច់**គួនអ៊ូ**ឯស្រុកកេងជីវ ដើម្បីឲ្យចែកបណ្ដាកូនទាហានតាមបំណាច់។

លុះវេលាព្រឹក **ឡៅពី**ឲ្យបើកជង្រុកស្រូវ និងចំណីត្រីសាច់ស្បៀងអាហារចែកអ្នកស្រុក និងរេហ៍ពលតាមសមគួរគ្រប់ៗគ្នា អស់បណ្ដាមនុស្សម្នាមហាជនមុខមន្ត្រីអំឡុងក្នុងស្រុកសែឈួនក៏មានសេចក្ដីសុខ និរទុក្ខចាកភ័យយន្តរាយសប្បាយគ្រប់ៗគ្នា។ **ឡៅពី**ក៏បង្គាប់ថា ដីសួនច្បារស្រែចម្ការ ដែលគ្មានម្ចាស់កាន់កាប់ចុះបញ្ជីជាកម្មសិទ្ធិទេ ត្រូវបែងឲ្យបានជាពន្ធទៅជាសម្រាប់មុខមន្ត្រីតូចធំ ដើម្បីជាកម្លាំងរាជការ។ **ជូឡុង**ឆ្លើយថា ស្រុកសែឈួននេះមានសឹកសង្គ្រាម បណ្ដារាស្ត្រក៏ខ្ចាត់ភ្លាត់ពីភូមិលំនៅ មិនបានធ្វើស្រែចម្ការ ដែលនឹងយកពន្ធពីស្រែចម្ការមកបែងរំលែកចែកឲ្យនាហ្មឺនមុខមន្ត្រីនោះ បណ្ដារាស្ត្រនឹងមានសេចក្ដីក្ដៅក្រហាយណាស់ គួរលោកឲ្យប៉ាវគងប្រាប់រាស្ត្រថា ភូមិលំនៅនិងសួនច្បារស្រែចម្ការរបស់នរណា ក៏ឲ្យមកនៅធ្វើរកទទួលទានតាមដើមចុះ ទើបរាស្ត្រនឹងបានសេចក្ដីសុខតទៅ។ **ឡៅពី**យល់ត្រូវផង ទើបឲ្យប៉ាវគងប្រាប់រាស្ត្រតាមពាក្យ**ជូឡុង**។

**ឡៅពី**និយាយនឹង**ខុងបេង**ថា ច្បាប់របស់ស្រុកសែឈួននោះ យើងត្រូវលើកចោលចេញ ហើយសុំឲ្យលោកតាក់តែងច្បាប់ថ្មីសម្រាប់ស្រុកឡើងវិញ ហើយឲ្យ

ចាត់ទោសមនុស្សដែលប្រព្រឹត្តខុសឲ្យធ្ងន់ជាងច្បាប់ចាស់ ទើបមនុស្សនឹងខ្លាចរអាប្រតិបត្តិតាមស្រុកទេសទើបនឹងបានរាបទាបតទៅ។ **ហ្ហួតចេង**ថា ការគ្រាព្រះចៅ**ហាន់កោចោ**បានសោយរាជសម្បត្តិនោះ ស្ដេចឲ្យតែងច្បាប់កាត់ទោសមនុស្សដែលប្រព្រឹត្តិខុសទុកជាប្រមាណ លុះដល់ព្រះចៅ**ហៀនតេ**គ្រានេះ ទ្រង់ឲ្យតែងច្បាប់កាត់ទោសឲ្យធ្ងន់ជាងច្បាប់ចាស់ បានជាមនុស្សកើតក្ដៅក្រហាយជាចលាចលដូច្នេះ ហេតុនេះ គួរឲ្យលោកត្រិះរិះបន្ថយទោសឲ្យស្រាលទៅវិញ តាមច្បាប់បុរាណនឹងបានសេចក្ដីសុខធូរទូលាយ។

**ខុងបេង**ថា ពាក្យដែលអ្នកនិយាយនេះគួរប្រពៃណាស់ ព្រោះតាំងពីគ្រាព្រះចៅ**ហាន់កោចោ** ដែលធ្វើច្បាប់ទុកនោះ មិនមែនទុកមកដល់ព្រះចៅ**ហៀនតេ**ទេ វេលានោះបណ្ដារាស្ត្រគ្រប់អាណាខេត្តក្នុងប្រទេសចិន ក៏មិនបានសេចក្ដីសុខសោះឡើយ ដូច**ឡៅជៀង**សោតក៏ជាមនុស្សមិនសូវមានតម្រិះវិជ្ជា ដែលនឹងរកអំណាចអាជ្ញាដូចគ្នា តាំងធ្វើជានាហ្មឺនធំ ម្ល៉ោះហើយមនុស្សនោះក៏មានចិត្តកំរើបលះបង់ច្បាប់សម្រាប់ផែនដី មានតែសេចក្ដីកំហែងសង្កត់សង្កិនអាណាប្រជានុរាស្ត្រតាមអំណាចចិត្ត រាស្ត្រក៏បានសេចក្ដីក្ដៅក្រហាយដោយហេតុរឿតអំពើដូច្នោះឯង បានជាត្រូវអន្តរាយខូចស្រុកទេសទៅ គ្រានេះយើងត្រូវលើកច្បាប់ចាស់ចោលចេញ តាំងបទប្បញ្ញត្តិច្បាប់ថ្មីបំពេញឲ្យធ្វើទោសមនុស្ស ដែលប្រព្រឹត្តិខុសនោះមិញឲ្យធ្ងន់របស់ ដើម្បីឲ្យមនុស្សទាំងអស់នោះខ្លាចញញើត នឹងប្រតិបត្តិតាមច្បាប់តទៅ បើនាហ្មឺននិងបណ្ដារាស្ត្រឯណាឃើញនរណាប្រព្រឹត្តខុសអំពីបញ្ញត្តិច្បាប់ ក៏ត្រូវចុះទោសតាមទោសានុទោស បើឃើញនរណាប្រព្រឹត្តសេចក្ដីគាប់ប្រសើ ក៏ត្រូវឲ្យបំណាច់រង្វាន់ឲ្យមានឡើង ទើបនឹងបានថ្កុំថ្កើងស្រុកទេសជាវឌ្ឍនាការតទៅ។ **ហ្ហួតចេង**បានស្ដាប់ក៏គាប់ចិត្តគិតយល់ត្រូវប្រាកដ ឱនគំនាប់**ឡៅពី**និង**ខុងបេង**ទទួលតាមប្រសាសន៍គ្រប់ប្រការ។

**ខុងបេង**ក៏តែងរចនាច្បាប់តាមទម្លាប់ទំនៀមផែនដី នឹងកាត់ទោសឲ្យធ្ងន់ជាងប្រក្រតីបុរាណ ហើយបញ្ជូនទៅឲ្យគ្រប់ខេត្តខណ្ឌ ដែលនៅក្រោមបង្គាប់ទាំងបួនតំបន់ ជាខេត្តសម្រាប់ឡើងស្រុកសែឈ្ងួន ចៅហ្វាយស្រុកទាំងអស់នោះ និងចៅហ្វាយស្រុកសម្រាប់ត្រី-ចត្វា ដែលឡើងតៗជាលំដាប់គ្នាទាំងមួយរយប្លាយតំបន់ក៏ទទួលធ្វើតាមបញ្ញត្តិទាំងអស់ បណ្ដារាស្ត្រគ្រប់ខេត្តខណ្ឌ ក៏បានសេចក្ដីសុខសប្បាយក្សេមក្សាន្តលើសជាងពីដើម។

លុះនៅមកថ្ងៃមួយ **ឡៅពី**ចេញនិយាយរាជការ មានបម្រើស៊ើបការណ៍ចូលទៅប្ដឹងថា ដ្បិតមានបម្រើ**គួនអ៊ូ**, **គួនប៉េង**នឹងចូលមកគំនាប់លោក។ **ឡៅពី**ក៏ឲ្យហៅ**គួនបេង**ចូលទៅ។ **គួនប៉េង**គំនាប់ហើយជម្រាបថា **គួនអ៊ូ**បិតាខ្ញុំបាទ មានសេចក្ដីត្រេកអរព្រះតេជព្រះគុណ ដែលលោកបានឲ្យបំណាច់រង្វាន់ទៅនោះច្រើនណាស់ បានជាប្រើខ្ញុំបាទឲ្យចូលមកជម្រាប ខ១ បិតាខ្ញុំបាទផ្ដាំមកថា ដ្បិតបានឮដំណឹងល្បីទៅដល់ថា **ម៉ាឈៀវ**នោះជាមនុស្សមានថ្វីដៃខ្លាំងពូកែណាស់នឹងរកនរណាស្មើគ្មាន បិតាខ្ញុំបាទនឹងសុំមកតស៊ូកម្លាំងនឹង**ម៉ាឈៀវ**ល្បងមើល។

**ឡៅពី**ឮដូច្នោះភ័យភ្ញាក់ស្មារតី ទើបប្រឹក្សានឹង**ខុងបេង**ថា **គួនអ៊ូ**នឹងចង់មកល្បងថ្វីដៃនឹង**ម៉ាឈៀវ**នោះ បើអ្នកឯណាភ្លាត់ចំណាប់ទន់ថយក៏គង់នឹងជាប់ព្យាបាទគ្នាតទៅ លោកនឹងគិតប្រការម្ដេច? **ខុងបេង**ថា លោកកុំព្រួយ ខ្ញុំនឹងធ្វើសំបុត្រទៅឲ្យ**គួនអ៊ូ**ឲ្យរសាយសេចក្ដីឥច្ឆាព្យាបាទនោះចេញ។ **ឡៅពី**ថា ការនេះបើបង្អង់ឲ្យយូរមុខជា**គួនអ៊ូ**នឹងមកដល់ នាំឲ្យព្រួយរវល់ឡើងទៀត បើដូច្នេះគួរតែលោកធ្វើសំបុត្រផ្ញើទៅឲ្យឆាប់កុំឲ្យ**គួនអ៊ូ**មកដល់មុន។ **ខុងបេង**ក៏ធ្វើសំបុត្រសរសើរលើក**គួនអ៊ូ**គ្រប់ប្រការ រួចច្រកបិទស្រោមប្រគល់ឲ្យ**គួនប៉េង** ៗទទួលហើយក៏លាត្រឡប់ទៅវិញ លុះទៅដល់ស្រុកគេងជីវក៏យកសំបុត្រនោះទៅជូន**គួនអ៊ូ** ហើយពណ៌នាសេចក្ដីឲ្យស្ដាប់គ្រប់ប្រការ។

**គួនអ៊ូ**ទទួលសំបុត្រទៅមើលឃើញសេចក្តីថា **ខុងបេង**ឲ្យពរមក**គួនអ៊ូ**ទីចុងគុនឲ្យបានជ្រាប ព្រោះយើងដឹងថា អ្នកមានសេចក្តីវិតក្កព្រោះ**ម៉ាឈៀវ**នោះមិនគួរទេ ព្រោះថ្វីដៃ**ម៉ាឈៀវ**នោះ ប្រៀបស្មើនឹងថ្វីដៃ**តៀវហ៊ុយ**ប្អូនអ្នក ឯការកលសឹកសង្គ្រាមនោះ ថ្វីដៃអ្នកលើសជាង**ម៉ាឈៀវ**ច្រើនណាស់ ដែលអ្នកនឹងលះបង់ស្រុកកេងជីវទៅល្បងថ្វីដៃគ្នានឹង**ម៉ាឈៀវ**នោះ មិនស្រួលទេ ក្រែងមានសេចក្តីអន្តរាយដល់ស្រុកកេងជីវ ខ្លួនអ្នកក៏ត្រូវមានទោសខុស ព្រោះធ្វេសប្រហែស ការនេះសូមអ្នកត្រិះរិះតាមគួរសិនទើបបាន។ លុះមើលចប់សេចក្តីហើយ **គួនអ៊ូ**ក៏មានសេចក្តីត្រេកអរគិតថា **ខុងបេង**នោះសមជាគ្រូអាចារ្យប្រដៅយើងបានណាស់ ទើបយកសំបុត្រនោះបង្ហាញអស់នាហ្មឺនមុខមន្ត្រីនិងទាហានទាំងពួង ហើយថា ពីដើមយើងគិតវិតក្កព្រោះឮថា **ម៉ាឈៀវ**មានថ្វីដៃខ្លាំងពូកែណាស់ គិតនឹងចង់ទៅល្បងថ្វីដៃមើល ឥឡូវយើងក៏អស់សេចក្តីវិតក្កហើយ។

*លោកអ្នកអានអាចស្វែងរកសៀវភៅផ្សេងទៀតតាមរយៈប្លក៖*

[www.khmerliterature.wordpress.com](http://www.khmerliterature.wordpress.com)

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៥៥

**ចារឹកឡើងទញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ស៊ុនគួន**ដឹងថា **ឡៅពី**បានវាយស្រុកសែឈួន **ស៊ុនគួន**គិតនឹងវាយយកស្រុកកេងជីវវិញ រហូតដល់**ចូឆ្វ**វាយយកបានស្រុកហាន់តុង តាំង**ទៀវឡូ**ឲ្យឈរជាចៅហ្វាយស្រុកដូចដើម។)*

ឯ**ស៊ុនគួន**នោះ លុះដឹងកិត្តិស័ព្ទថា **ឡៅពី**វាយយកបានស្រុកសែឈួនហើយឲ្យ**ឡៅជៀង**ទៅនៅស្រុកកងអាន់ដូច្នោះ ក៏ពិគ្រោះនឹងទីប្រឹក្សាទាំងពួងថា **ឡៅពី**ខ្ចីស្រុកកេងជីវទុកជាទីអាស្រ័យ យើងត្រូវតែឲ្យទារយកស្រុកនោះមកឡើងស្រុកយើងវិញ បើ**ឡៅពី**រឹងទទឹងមិនព្រមឲ្យ យើងនឹងលើកកងទ័ពទៅវាយយកឲ្យខាងតែបាន អ្នកទាំងពួងនឹងយល់ឃើញដូចម្ដេច?

**ទៀវចៀវ**ឆ្លើយថា សឹកសង្គ្រាមទើបនឹងស្ងប់ ពលទាហានក៏កំពុងនឿយហត់ ដែលនឹងលើកកងទ័ពទៅវាយយកស្រុកកេងជីវទៀតនោះ សុំឲ្យលោកឈប់បង្អង់សិន ខ្ញុំបាទនឹងរិះគិតឲ្យ**ឡៅពី**លើកបង្វិលស្រុកកេងជីវឲ្យលោកវិញតាមស្រួល។ **ស៊ុនគួន**សួរថា គំនិតអ្នកនឹងរិះគិតប្រការម្ដេច? **ទៀវចៀវ**ថា ដែល**ឡៅពី**គិតធ្វើការទាំងពួងនោះ ក៏ប្រស្រ័យសេចក្ដីរិះគិតរបស់**ខុងបេង** ឯ**ខុងបេង**នោះជាប្អូន**ជូកាត់កិន** សុំឲ្យលោកយកគ្រប់គ្រួរបស់**ជូកាត់កិន**ដាក់គុកទុក ហើយឲ្យ**ជូកាត់កិន**ទៅនិយាយនឹង**ខុងបេង**ឲ្យបង្វិលស្រុកកេងជីវជូនលោកវិញជាប្រញាប់ ក៏មុខជានឹងបាន។

**ស៊ុនគួន**តបថា **ជូកាត់កិន**នោះជាមនុស្សទៀងត្រង់សុចរិតណាស់ ហើយគ្មានទោសខុសពីអ្វីផង បើយើងនឹងធ្វើទោសដូចពាក្យអ្នកថា កាលណា**ជូកាត់កិន**នឹងចូលចិត្តគិតខឹងនឹងយើង ម្យ៉ាងទៀតមនុស្សទាំងពួងក៏គង់នឹងគរហានិន្ទាយើងទៀត

**ទៀវចៀវ**ថា បើជាលោកនឹងត្រូវធ្វើការនេះ មានតែត្រូវហៅ**ជូកាត់កិន**មកប្រាប់ជាមុនឲ្យដឹងថា ដែលលោកយកគ្រប់គ្រួមកធ្វើទោសនោះគឺកលឧបាយទេ កុំឲ្យតូចចិត្តឡើយ **ជូកាត់កិន**ជាមនុស្សមានសតិបញ្ញា ក៏គង់នឹងយល់តាមអធ្យាស្រ័យលោកមិនខាន។ **ស៊ុនគួន**យល់ឃើញត្រូវ ក៏ឲ្យហៅ**ជូកាត់កិន**មកនិយាយតាមដំណើរឧបាយដែលគិតនោះឲ្យស្តាប់គ្រប់ប្រការ ហើយក៏តែងជាសំបុត្រប្រគល់ឲ្យ**ជូកាត់កិន**យកទៅ ឯគ្រួសារ**ជូកាត់កិន**ទាំងប៉ុន្មានតក៏ឲ្យយកទៅដាក់គុកឃុំទុកទាំងអស់។ **ជូកាត់កិន**ក៏កាន់សំបុត្រនោះលា**ស៊ុនគួន**ចេញទៅស្រុកសែឈួន លុះទៅដល់ហើយក៏ប្រាប់អ្នកចាំទ្វារ។ អ្នកចាំទ្វារក៏ចូលទៅជម្រាប**ឡៅពី**ថា ឥឡូវ**ជូកាត់កិន**នឹងចូលមករកលោក។

**ឡៅពី**ដឹងសេចក្តីសួរ**ខុងបេង**ថា **ជូកាត់កិន**បងលោកដែលមករកយើងក្នុងវេលានេះដោយហេតុអ្វីអេះ? **ខុងបេង**ថា ដែលបងខ្ញុំមកនេះប្រាកដជា**ស៊ុនគួន**ប្រើមកទារយកស្រុកកេងជីវហើយ។ **ឡៅពី**សួរថា បើដូច្នោះលោកនឹងឲ្យនិយាយការនេះថាម្តេច? **ខុងបេង**ក៏ចូលទៅខ្សឹមប្រាប់**ឡៅពី**ឲ្យឆ្លើយតបតាមពាក្យ**ខុងបេង**ពន្យល់សព្វគ្រប់ ហើយ**ខុងបេង**ក៏ចេញទៅគំនាប់ទទួល**ជូកាត់កិន**នាំទៅឈប់ឯផ្ទះទទួលភ្ញៀវ។ **ជូកាត់កិន**ក៏ក្លែងធ្វើជាយំខ្សឹកខ្សួលយូរណាស់ **ខុងបេង**ឃើញដូច្នោះក៏ក្លែងសួរថា អ្នកបងមកឃើញមុខខ្ញុំជាប្អូនហើយ ហេតុម្តេចត្រឡប់ទៅជាយំវិញ គួរតែត្រេកអរសាទរ។ **ជូកាត់កិន**ថា ឥឡូវនេះ**ស៊ុនគួន**ចាប់យកភរិយាបុត្ររបស់បងទៅដាក់គុកអស់ទៅហើយ មុខជានឹងដល់នូវសេចក្តីស្លាប់ទាំងអស់គ្នា។ **ខុងបេង**ថា កើតហេតុទាំងនេះ ព្រោះ**ស៊ុនគួន**ចង់បានស្រុកកេងជីវទៅវិញ បានជាធ្វើដូច្នេះ ហើយធ្វើជាសួរថា ដែលអ្នកបងអញ្ជើញមកនេះ **ស៊ុនគួន**ប្រើមក ឬវត់មកទេ? **ជូកាត់កិន**ថា **ស៊ុនគួន**ប្រើឲ្យបងមក យកទាំងសំបុត្រនេះមកជូន**ឡៅពី**ផង។ **ខុងបេង**ថា បើការតែប៉ុណ្ណេះកុំឲ្យអ្នកបងព្រួយ សឹមយើងនាំគ្នាទៅជួបនឹង**ឡៅពី**

ហើយខ្ញុំនឹងនិយាយឲ្យ**ឡៅពី**បង្វិលស្រុកកេងជីវឲ្យ**ស៊ុនគួន**វិញ។ **ជូកាត់កិន**ឮដូច្នោះ ក៏ត្រេកអរណាស់។

**ខុងបេង**ក៏នាំ**ជូកាត់កិន**ចូលទៅគំនាប់**ឡៅពី** ហើយ**ជូកាត់កិន**ក៏ជូនសំបុត្រនោះទៅឲ្យ**ឡៅពី** ៗទទួលយកសំបុត្រនោះទៅមើលឃើញសេចក្ដីថា ពីដើម**ឡៅពី**បានខ្ចីស្រុកកេងជីវទុកជាទីអាស្រ័យ ឥឡូវដល់សន្យាហើយ ត្រូវឲ្យ**ឡៅពី**បង្វិលស្រុកនោះឲ្យ**ស៊ុនគួន**វិញ។ **ឡៅពី**ឃើញសេចក្ដីដូច្នោះ ក៏ធ្វើជាខឹងច្រឡោតឡើង តាំងតែឆ្លើយតបទៅ**ជូកាត់កិន**តាមពាក្យ**ខុងបេង**ពន្យល់ថា កាលពីថ្ងៃមុន **ស៊ុនគួន**បានលើកប្អូនក្រមុំឲ្យយើងយកធ្វើជាភរិយា យើងក៏បាននាំមកយកទុកនៅស្រុកកេងជីវ លុះយើងលើកទ័ពមកវាយយកស្រុកសៃឈួន **ស៊ុនគួន**ក៏មិនមានកោតក្រែងចិត្ត គិតប្រើឧបាយមកបញ្ឆោតយកភរិយាយើងទៅទុកឯស្រុកកាំងតាំងវិញ ឥឡូវនៅទទូចឲ្យមកពឹងទារយកស្រុកកេងជីវទៀត គឺ**ស៊ុនគួន**គិតធ្វើការទាំងម្ល៉េះដូចជាមិនជាអ្នកធំសោះ ហេតុនេះ គួរយើងលើកទ័ពទៅវាយយកស្រុកកាំងតាំងឲ្យបាន។

**ខុងបេង**បានស្ដាប់ហើយ ក៏ធ្វើជាយំយែកនិយាយនឹង**ឡៅពី**ថា វេលានេះ **ស៊ុនគួន**ឲ្យចាប់ភរិយាបុត្រ និងស្ម័គ្របក្សពួកបងខ្ញុំទៅដាក់គុកទុកទាំងអស់ ប្រាថ្នាតែនឹងទារយកស្រុកកេងជីវឲ្យបាន បើមិនបានក៏នឹងធ្វើអន្តរាយបងខ្ញុំ និងភរិយាបុត្រឲ្យបានសេចក្ដីព្រួយលំបាកដល់នូវជីវិតអន្តរាយ បើបងខ្ញុំបាទស្លាប់ខ្ចាត់ខ្ចាយវេលាណា ខ្លួនខ្ញុំបាទក៏គង់នឹងមរណាវេលានោះជាប្រាកដ។ ហេតុនេះ សូមឲ្យលោកអាណិតអាសូរបង្វិលស្រុកកេងជីវឲ្យ**ស៊ុនគួន**ចុះ ដើម្បីជាផ្លូវសង្គ្រោះឲ្យ**ជូកាត់កិន**និងខ្ញុំបាទ បានគង់ជីវិតនៅមើលឃើញមុខគ្នាតទៅ។ **ឡៅពី**ក៏ធ្វើជាព្រងើយ បែបមិនឮមិនដឹងមិនយល់។ **ខុងបេង**ក៏រឹតតែយំសោកជាទុក្ខទល់អង្វរ**ឡៅពី**យូរណាស់។ **ឡៅពី**ថា ស្រុកកេងជីវនេះមានខេត្តសម្រាប់ឡើងដល់ប្រាំមួយមណ្ឌល យើងនឹងឲ្យខូចដូចម្ដេចបាន តែយើងយោគយល់ដល់មុខទាំងពីរនាក់ដែលទទូចមកនិយាយ

ហើយ យើងត្រូវឲ្យស្រុកទៀងសា១ ស្រុកឡេងឡេង១ និងស្រុកហ៊ុយអៀង១ ទាំងបីតំបន់នេះបែងឲ្យ**ស៊ុនគួន**ពាក់កណ្ដាលចុះ។

**ខុងបេង**ឮដូច្នោះក៏ធ្វើជាត្រេកអររួសរាយនិយាយថា បើលោកមានមេត្តាដូច្នោះហើយ សុំឲ្យឆ្លើយសំបុត្រឲ្យ**ជូកាត់កិន**ទៅដល់**គួនអ៊ូ**ឲ្យដឹងជាមុន នឹងបានបែងស្រុកបីតំបន់នោះឲ្យទៅ**ស៊ុនគួន**។ **ឡៅពី**ក៏ធ្វើសំបុត្រជាសេចក្ដីថា **ឡៅពី**ព្រមលើកស្រុកទៀងសា១, ស្រុកឡេងឡេង១, ស្រុកហ៊ុយអៀង១ ដែលឡើងស្រុកកេងជីវនោះឲ្យទៅជាចំណុះរបស់**ស៊ុនគួន**ចុះ។ លុះតែងសំបុត្រនោះរួចហើយ ក៏ប្រគល់ឲ្យ**ជូកាត់កិន**ហើយថា បើកាលណាអ្នកនឹងទៅរក**គួនអ៊ូ**នោះ ចូរឲ្យលំអុតលំឱននិយាយដោយសុភាព ព្រោះចិត្ត**គួនអ៊ូ**នោះរួសរហ័សណាស់ សូម្បីខ្លួនយើងឯងក៏ក្រែងខ្លាចណាស់ដែរ។ **ជូកាត់កិន**ទទួលប្រសាសន៍ និងសំបុត្រហើយ ក៏លាត្រឡប់ទៅស្រុកកេងជីវ ហើយឲ្យទាហាននាំចូលទៅជួបនឹង**គួនអ៊ូ** ពណ៌នារឿងរ៉ាវឲ្យ**គួនអ៊ូ**ស្ដាប់គ្រប់ប្រការ ជូនទាំងសំបុត្រនោះឲ្យទៅ**គួនអ៊ូ**មើល។

**គួនអ៊ូ**ឃើញសំបុត្រដូច្នោះក៏និយាយថា **ឡៅពី, តៀវហ៊ុយ**និងយើងក៏បានរួមចិត្តជីវិតមួយនឹងគ្នា ប្រាថ្នាធ្វើការដរាបមកបម្រុងនឹងជួយរក្សាផែនដីឲ្យបានសេចក្ដីសុខ អាណាខេត្តទាំងអស់នេះ ក៏សុទ្ធតែជាផែនដីរបស់ព្រះចៅ**ហៀនតេ** តែវេលានេះមានមនុស្សអ្នកមានថ្វីដៃខ្លាំងពូកែច្រើនយល់ឃើញថា ផែនដីកើតចលាចលគ្រប់មណ្ឌលខេត្តខណ្ឌ បានជានាំគ្នារាំងពាំងពារខេត្តខណ្ឌដែន ជាកំណាន់របស់ខ្លួននោះទុកតាមចំណែកៗ ឯធម្មតាធ្វើរាជការ ជាចៅហ្វាយខេត្តខណ្ឌនីមួយៗ នោះក៏ត្រូវតែតាំងចិត្តជាសុចរិតក្នុងរាជការ បើមានព្រះតម្រាស់បង្គាប់មកយ៉ាងណា ក៏ត្រូវឲ្យពិចារណាមើលតាមគួរនិងអធ្យាស្រ័យ បើឃើញត្រូវគួរឲ្យធ្វើតាម បើឃើញទាស់ខុសពីបទគំរាមត្រង់ប្រការណា ត្រូវឲ្យមកប្ដឹងទៅអ្នកកាន់កាប់រាជការជាធំឲ្យបានជ្រាប ឥឡូវ **ឡៅពី**បងយើងនឹងឲ្យបង្វិលស្រុកបីតំបន់ទៅឲ្យ**ស៊ុនគួន**នោះ យើងយល់

ឃើញមិនគួរ យើងមិនព្រមធ្វើតាមបង្គាប់**ឡៅពី**ទេ អ្នកចូរទៅប្រាប់**ស៊ុនគួន**ឲ្យដឹងចុះ។

**ជូកាត់កិន**ឮ**គួនអ៊ូ**ថាដូច្នោះក៏ចេះតែអង្វរថា សូមឲ្យលោកអាណិតឈ្វេងយល់ទៅដល់ខ្ញុំចុះ **ស៊ុនគួន**ឃើញថា ខ្ញុំនិង**ខុងបេង**ជាបងប្អូននឹងគ្នា បានជាគេចាប់យកភរិយាបុត្ររបស់ខ្ញុំទៅដាក់គុកទុក ហើយប្រើខ្ញុំឲ្យនាំសំបុត្រមកទារស្រុកកេងជីវឲ្យបាន បើមិនបានបង្វិលស្រុកនេះឲ្យវិញទេ គេឲ្យសម្លាប់បុត្រភរិយារបស់ខ្ញុំទាំងអស់។ **គួនអ៊ូ**ថា ដែល**ស៊ុនគួន**ធ្វើដូច្នេះជាកលឧបាយបញ្ឆោត ប្រាថ្នានឹងទារយកស្រុកកេងជីវឲ្យបាន។ **ជូកាត់កិន**ថា លោកចរចាដូច្នេះដូចជាមនុស្សមិនចេះគិតអ្វីសោះ។

**គួនអ៊ូ**ឮដូច្នោះខឹងណាស់ ហូតគ្រប៊ីចេញហើយថា បើយើងមិនគិតយល់ដល់**ខុងបេង** ក៏នឹងត្រូវកាត់ក្បាលអ្នកឥឡូវនេះចេញ តាំងពីនេះតទៅ អ្នកកុំមកនិយាយមើលងាយប្រមាថយើងដូច្នេះទៀត បើមិនស្តាប់ទេយើងក៏មិនអត់ឡើយ។ **គួនប៉េង**ឮហើយក៏ចូលទៅអង្វរឃាត់ថា បិតាកុំអាលធ្វើវីវរដូច្នេះឡើយ គួរឃើញយល់ទៅដល់**ខុងបេង**ចុះ។ **គួនអ៊ូ**តបថា **ជូកាត់កិន**នេះព្រហើនមើលងាយយើងពេកណាស់បើកុំតែយើងយោគយល់ទៅដល់**ខុងបេង** នឹងកាត់ក្បាលចេញឥឡូវនេះ។ **ជូកាត់កិន**បានសេចក្តីអប្បយសណាស់ ក៏វិលត្រឡប់ទៅស្រុកសែឈួនវិញ ខណៈនោះទទួល**ខុងបេង**ឃុំនាំទាហានចេញទៅត្រួតគយ។ **ជូកាត់កិន**ក៏ចូលទៅជួបនឹង**ឡៅពី** ហើយយំយែកនិយាយឲ្យ**ឡៅពី**ស្តាប់តាមហេតុ ដែល**គួនអ៊ូ**ប្រុងនឹងសម្លាប់នោះគ្រប់ប្រការ។

**ឡៅពី**តបថា យើងបាន ប្រាប់អ្នកហើយថា ចិត្ត**គួនអ៊ូ**នោះកាចរួសរហ័សណាស់ អ្នកចូរវិលត្រឡប់ទៅប្រាប់**ស៊ុនគួន**ដោយល្អសិនចុះថា សូមឲ្យបង្អង់ទម្រាំយើងលើកទ័ពទៅវាយយកស្រុកហាន់តុង បានវេលាណាយើងនឹងយក**គួនអ៊ូ**ឲ្យទៅឈរធ្វើជាចៅហ្វាយស្រុកហាន់តុង នឹងប្រគល់ស្រុកកេងជីវ ព្រមទាំងស្រុកដែល

ឡើងទាំងប៉ុន្មានឲ្យ**ស៊ុនគួន**វិញទាំងអស់។ **ជូកាត់កិន**មិនដឹងតបថាយ៉ាងណា ក៏លាត្រឡប់វិលទៅស្រុកកាំងតាំងវិញ លុះទៅដល់ហើយក៏ពណ៌នារឿងរ៉ាវឲ្យ**ស៊ុនគួន**ស្តាប់ តាមដែល**ឡៅពី**និង**គួនអ៊ូ**ថា ប្រការម្តេចៗនោះគ្រប់ប្រការ។

**ស៊ុនគួន**ស្តាប់ហើយក៏ខឹងណាស់ថា ដែល**ឡៅពី** និង**គួនអ៊ូ**និយាយឲ្យយ៉ាងម្តេចនោះគឺជាសេចក្តីចេញមកពីគំនិត**ខុងបេង**ជាប្អូនអ្នកឯងទាំងអស់។ **ជូកាត់កិន**ឆ្លើយថា **ខុងបេង**ក៏ជាទុក្ខទោមនស្សអាណិតខ្ញុំបាទណាស់ដែរ បានទាំងជួយអង្វរលន់តួទោស**ឡៅពី** ៗក៏បង្គាប់ទៅ**គួនអ៊ូ**ឲ្យបង្វិលស្រុកបីតំបន់ជូនមកលោក លុះខ្ញុំបាទទៅប្រាប់**គួនអ៊ូ** ៗខឹងប្រកែកមិនព្រមឲ្យ ហើយគិតនឹងសម្លាប់ខ្ញុំបាទទៀត។ **ស៊ុនគួន**ថា គេបានចេញវាចាថានឹងបង្វិលស្រុកបីតំបន់ឲ្យយើងហើយ យើងត្រូវតែចាត់ទាហានដែលមានថ្វីដៃខ្លាំងពូកែទៅឈររក្សាស្រុកទាំងបីតំបន់នោះទុក ដើម្បីនឹងមើលកលការ**គួនអ៊ូ** តើនឹងធ្វើប្រការម្តេច?

**ជូកាត់កិន**ថា លោកគិតនោះគួរប្រពៃណាស់ **ស៊ុនគួន**ក៏បង្គាប់ឲ្យបើកលែងបុត្រភរិយា**ជូកាត់កិន**ដែលឃុំនោះចេញអស់ ហើយចាត់ប្រើទាហានដែលមានថ្វីដៃទៅឈររក្សាស្រុកទាំងបីតំបន់ តែនាយទាហានទាំងបីនាក់ដែលទៅនោះ វិលមកប្តឹង**ស៊ុនគួន**ថា បានលើកគ្នាទៅជិតនឹងដល់ស្រុកទាំងបីអន្លើនោះហើយ **គួនអ៊ូ**លើកពលទៅដេញកម្ចាត់កម្ចាយ មិនព្រមឲ្យចូលទៅក្នុងស្រុកនីមួយៗបាន បើខំបំពានបំពារចូលទៅតាមពេលការឃើញថា **គួនអ៊ូ**នឹងប្រហារជីវិតឲ្យអន្តរាយទាំងអស់គ្នា។

**ស៊ុនគួន**ឮដូច្នោះក៏ខឹងណាស់ ទើបឲ្យរកហៅ**ឡោសុក**ចូលមកសួរថា **ឡៅពី**បានខ្ចីស្រុកកេងជីវទុកប្រាស្រ័យនោះ បានប្តេជ្ញាថាបើកាលណាវាយបានស្រុកសៃឈួនហើយ នឹងបង្វិលស្រុកកេងជីវឲ្យយើងវិញ ខ្លួនអ្នកក៏ចូលជាអ្នកធានាក្នុងរឿងនេះ ឥឡូវ**ឡៅពី**វាយបានស្រុកសៃឈួនហើយ បានចេញសំបុត្រប្រាប់ទៅ**គួនអ៊ូ**ឲ្យបង្វិលស្រុកបីតំបន់ឲ្យយើង ឥឡូវ**គួនអ៊ូ**រឹងទទឹងមិនព្រមឲ្យ ថែមទាំងធ្វើទុក្ខបុកម្នេញដោយរំលោភទៀត ខ្លួនអ្នកជាអ្នកធានាតើធ្វើលេងទេឬ?

**ឡោសុក**ថា ការនេះមិនមែនខ្ញុំបាទនឹងស្ងៀមព្រងើយទេ ដែល**គួនអ៊ូ**ធ្វើដូច្នេះ ខ្ញុំបាទនឹងសុំគិតធ្វើកលឧបាយមួយ មុខជានឹងបានស្រុកកេងជីវដោយងាយ។ **ស៊ុនគួន**សួរថា ឧបាយអ្នកប្រការម្ដេច? **ឡោសុក**ថា ខ្ញុំបាទគិតឲ្យទៅតាំងបន្ទាយនៅមាត់ពាមស្រុកយើង ឲ្យទាហានពួនបង្កប់ចាំគ្រប់ច្រក ហើយឲ្យទៅអញ្ជើញ**គួនអ៊ូ**មកស៊ីលៀង ខ្ញុំបាទនឹងចាប់ខ្លួនសម្លាប់ចេញ។ បើ**គួនអ៊ូ**មិនមកតាមសេចក្ដីខ្ញុំបាទទេ សឹមលោកលើកកងទ័ពចេញទៅច្បាំងយកស្រុកកេងជីវចុះ។

**ស៊ុនគួន**ស្ដាប់យល់ឃើញត្រូវ ក៏ចាត់ចែងទាហានតាមពាក្យ**ឡោសុក**និយាយ។ **ងាំតេក**ថា លោកកុំអាលមាក់ងាយប្រមាថ ព្រោះ**គួនអ៊ូ**នោះមានថ្វីដៃពូកែជាទាហានខ្លា បើមិនសមនឹងសេចក្ដីគិតឧបាយនោះដោយប្រការឯណា ក៏នឹងត្រឡប់អន្តរាយដល់យើងវិញ។ **ស៊ុនគួន**ឮដូច្នោះក៏ខឹងណាស់ថា ចាំកាលណាទើបយកស្រុកកេងជីវឲ្យបាន ហើយបង្គាប់ឲ្យ**ឡោសុក**ធ្វើតាមគំនិតដែលគិតទុកនោះឲ្យសម្រេច។ **ឡោសុក**ទទួលបង្គាប់ហើយក៏លាចេញទៅចាត់រៀបចំទូកចម្បាំង លុះបានព្រមទាំងទាហានយោធាហើយ ក៏ចេញទៅបោះយុថ្កានៅមាត់ពាមឡុកខៅ ហើយឡើងទៅតាំងបន្ទាយលើគោក រួចចាត់ឲ្យ**កាំឡេង១, លីបង១** លើកទាហានទៅពួនបង្កប់គ្រប់រយៈដែលគិតទុកនោះ ហើយឲ្យរៀបតុលៀងអាហារស្រេចកាលណា ក៏ធ្វើសំបុត្រចាត់បម្រើឲ្យទៅអញ្ជើញ**គួនអ៊ូ**មកបរិភោគ ឯបម្រើដែលកាន់សំបុត្រនោះ រើសមនុស្សដែលចេះសម្ដី លុះទៅដល់ស្រុកកេងជីវហើយ ក៏និយាយឲ្យ**គួនប៉េង**យល់តាមសំបុត្រ**ឡោសុក**។

**គួនប៉េង**ក៏នាំអ្នកកាន់សំបុត្រនោះ ចូលទៅគំនាប់**គួនអ៊ូ** ហើយជូនសំបុត្រនោះទៅ**គួនអ៊ូ**ៗ មើលឃើញសេចក្ដីថា **ឡោសុក**សុំអញ្ជើញទៅពិសាលៀងឯបន្ទាយមាត់ពាមឡុកខៅ។ **គួនអ៊ូ**ក៏ប្រាប់អ្នកកាន់សំបុត្រនោះថា ឲ្យស្រួតទៅប្រាប់**ឡោសុក**ចុះចាំព្រឹកស្អែកយើងនឹងទៅ។ បម្រើនោះក៏លា**គួនអ៊ូ**ត្រឡប់ទៅវិញ។ **គួនប៉េង**ជម្រាប

**គួនអ៊ូ**ថា ដែល**ឡោសុក**ឲ្យមកអញ្ជើញបិតាទៅពិសាលៀងនោះ ខ្ញុំបាទឃើញថានឹងជាកលឧបាយទេ ហេតុម្តេចក៏បិតាទទួលថាទៅ?

**គួនអ៊ូ**ឮហើយអស់សំណើច ហើយតបថា ហេតុទាំងនេះ ព្រោះ**ជូកាត់កិន**ទៅប្រាប់**ស៊ុនគួន** បានជា**ឡោសុក**គិតកលឧបាយឲ្យអញ្ជើញយើងទៅស៊ីលៀង ហើយនឹងបានទារយកស្រុកកេងជីវវិញ ដើម្បីឲ្យបានជាកម្មសិទ្ធិរបស់**ស៊ុនគួន** បើយើងនឹងមិនទៅវេលានេះ ពួកស្រុកកាំងតាំងនឹងមើលងាយថាយើងខ្លាច ព្រឹកស្អែកយើងនឹងនាំទាហានតែ២០នាក់ចុះទូករហ័សទៅស៊ីលៀង ដើម្បីនឹងមើលកលការ**ឡោសុក**នឹងខ្លាចញញើតលំពែងដែលយើងកាន់ទៅនេះដែរឬទេ? **គួនប៉េង**ថា ខ្លួនបិតាដូចជាមាសនព្វគុណដែលនឹងកន្លងចូលទៅក្នុងពួកចោរនោះមិនគួរ ខ្ញុំបាទក្រែងស្រុកកេងជីវនេះនឹងកើតអន្តរាយ **ឡៅពី**នឹងសម្គាល់ទោសថា បិតាធ្វេសប្រហែស។

**គួនអ៊ូ**តបថា ចៅកុំវិតក្កឡើយ ឯបិតានេះក៏មានថ្វីដៃល្បីល្បាញទូទៅ សូម្បីទាហាន**ចូឆូ**រាប់សែន ច្រើនហួសប្រមាណ បិតាមានតែសេះមួយ អាចការពារមិនឲ្យព្រួញអាវុធជិតដល់ខ្លួនបាន អាចបរសេះរុករានបំពានចូលទៅចេញមកច្រើនគ្រាច្រើនគ្រឡប់ ឧបមាបីដូចជាគេចូលក្នុងគុម្ពឫស្សី និងចេញមកវិញបានដោយងាយនឹងខ្លាចអ្វីថ្វីដៃទាហានស្រុកកាំងតាំងប៉ុណ្ណោះ បីដូចជាហ្វូងជ្រូកនឹងរកស្វាហាប់គ្មានសោះ បិតាបានចេញវាចាថាទៅហើយនឹងឲ្យខូចសម្តីថ្វី។ **ម៉ាលៀង**ឆ្លើយថា បើលោកនឹងអញ្ជើញទៅ ក៏ត្រូវប្រុងប្រយ័ត្នគិតរវាំងមុខក្រោយកុំឲ្យថ្លោះការ។ **គួនអ៊ូ**ថា ដែលអស់អ្នកមករំឭកគ្រានេះក៏គួរហើយ ខ្លួនយើងនឹង**គួនប៉េង**នឹងនាំទាហានចេញទៅបួនប្រាំរយ ហើយបង្គាប់**គួនប៉េង**ឲ្យត្រួតត្រាទាហានទាំង៥០០ ចុះទូកចម្បាំងដប់ប្រចាំត្រួតមើលការ បើឃើញយើងបោកទង់ចុះវេលាណា ត្រូវបរពលចូលទៅជួយឲ្យរួសរាន់ **គួនប៉េង**ទទួលបង្គាប់ហើយ ក៏ចេញទៅចាត់ចែងទុកជាព្រមតាមពាក្យ**គួនអ៊ូ**បង្គាប់។

លុះបម្រើនាំសំបុត្រនោះវិលទៅដល់បន្ទាយ ក៏និយាយប្រាប់**ឡោសុក**ថា **គួនអ៊ូ**ត្រេកអរទទួលថា នឹងមកពីព្រឹកស្អែក **ឡោសុក**ត្រេកអរណាស់ ទើបប្រឹក្សានឹង **លីបង**ថា ឯ**គួនអ៊ូ**នោះមានថ្វីដៃខ្លាំងពូកែណាស់ នឹងមកស្អែកនេះហើយ យើងនឹងគិតប្រការដូចម្តេច? **លីបង**ថា **កាំឡេង**និងខ្ញុំបាទក៏បានចាត់ចែងទាហានបង្កប់នៅខាងក្រៅជាពីរកង បើឃើញ**គួនអ៊ូ**គ្មានពួកទាហានមកជាមួយជាច្រើនទេ យើងនឹងបញ្ចេញទាហានដែលបង្កប់នោះឲ្យចេញមកត្រឹមតែ៥០នាក់ បើបានការហើយនឹងព្រួតគ្នាចាប់**គួនអ៊ូ**សម្លាប់ចេញ បើ**គួនអ៊ូ**មានទាហានមកផង ខ្ញុំបាទនិង**កាំឡេង**ចាំស្តាប់សំឡេងផាវ បើឮកាលណានឹងឃុំទាហានវាយប្រសព្វខ្ទប់ចាប់ខ្លួន**គួនអ៊ូ**ឲ្យបាន។

**ឡោសុក**យល់ឃើញត្រូវផង លុះដល់ពេលព្រឹកក៏ចាត់ចែងតាមគំនិតដែលគិតទុក ហើយឲ្យទាហានទៅចាំមើល**គួនអ៊ូ**ជាមានទាហានមកជាមួយឬទេ។ បម្រើនោះក៏ត្រឡប់មកប្រាប់**ឡោសុក**វិញថា ឃើញ**គួនអ៊ូ**ចុះទូករហ័សតូចមួយមក មានពួកជើងចែវប្រហែល២០នាក់ និងទង់ក្រហមសម្រាប់**គួនអ៊ូ** ឯ**គួនអ៊ូ**នោះតែងខ្លួនហ៊ឹហាពាក់អាវព្រែកពណ៌ស្វាយ ជូតក្បាលព្រែពណ៌ខៀវ មិនមានពាក់ក្រោះ ឃើញ**ជីវឆង**លីលំពែងអង្គុយអម**គួនអ៊ូ** ឯទាហានដែលមកជាមួយនោះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែប្រហែលប្រាំពីរប្រាំបីនាក់។ **ឡោសុក**ឮហើយក៏ចេញទៅទទួល ឃើញ**គួនអ៊ូ**តែងខ្លួនហ៊ឹហា មានទាហានមកជាច្រើនគ្នា **ឡោសុក**នឹកញញើតក្រែងធ្វើការនោះពុំសម្រេច លុះនាំ**គួនអ៊ូ**ចូលទៅដល់ក្នុងបន្ទាយក៏តាំងគំនាប់គ្នា ហើយ**ឡោសុក**ក៏អញ្ជើញ**គួនអ៊ូ**បរិភោគអាហារ។

ខណៈកាលកំពុងសេពសុរានោះ **ឡោសុក**ក៏ញាប់ញ័រអស់ទាំងខ្លួន មិនហ៊ានទាំងងើបមុខមើល**គួនអ៊ូ**ផង ឲ្យតែមនុស្សបម្រើចាក់ស្រាឲ្យ**គួនអ៊ូ**ផឹក។ **គួនអ៊ូ**ផឹកស្រាភ្លាមក៏មិនបានកោតញញើត តាំងតែនិយាយពីរឿងចម្បាំងហើយក៏សើចរួសរាយសប្បាយ។ **ឡោសុក**ក៏សម្លឹងចុងភ្នែកមើល**គួនអ៊ូ**ឃើញកាន់តែស្រវឹងខ្លាំងក៏តាំង

និយាយថា យើងមានសេចក្ដីមួយខ នឹងសុំប្រារព្ធចរចានឹងលោក។ **គួនអ៊ូ**សួរថា អ្នកនិយាយការអ្វី? **ឡៅសុក**ឆ្លើយថា ពីដើម**ស៊ុនគួន**ឲ្យយើងទារយកស្រុកកេងជីវពីរបីដង ហើយ**ឡៅពី**ចេះតែបណ្ដោះបណ្ដែថា សុំស្រុកកេងជីវទុកជាទីអាស្រ័យសិន បើកាលណាវាយបានស្រុកសែឈ្វួនហើយ នឹងបង្វិលស្រុកកេងជីវឲ្យវិញ។ សេចក្ដីនេះយើងបានរ៉ាប់រងនឹង**ស៊ុនគួន**មាំមួនណាស់ ឥឡូវ**ឡៅពី**វាយបានស្រុកសែឈ្វួនហើយ ដែលនឹងហួងហែងស្រុកកេងជីវទុកនោះក៏មិនគួរសោះឡើយ។ **គួនអ៊ូ**តបថា អ្នកមានសំបុត្រឲ្យបម្រើនាំទៅខ្ញុំ ដើម្បីនឹងឲ្យមកបរិភោគអាហារតែម្យ៉ាងជាការសប្បាយ ឥឡូវត្រូវការអ្វីបានជាប្រារព្ធរឿងស្រុកទេសទៅវិញដូច្នេះ មិនគួរសោះ ត្រូវតែស្ងៀមទៅសិនចុះ។

**ឡៅសុក**ថា ចៅហ្វាយនាយយើងជាធំក្នុងស្រុកកាំងតាំង ក៏មិនគិតនឹងផ្សាយផែនដីឲ្យធំទូលាយទៅទៀត តែនៅមានចិត្តអាណិតលោកនឹង**ឡៅពី**ដែលរត់ពី**ចូឆូ**មក បានជាឲ្យស្រុកកេងជីវនៅជាបណ្ដោះអាសន្ន ឥឡូវត្រូវឲ្យ**ឡៅពី**គិតដល់ផ្លូវមេត្រីរបស់នាយយើងបានជាឲ្យមានសំបុត្រអញ្ជើញលោកមក ដើម្បីនឹងទារយកស្រុកបីតំបន់ ដែល**ឡៅពី**ព្រមឲ្យនាយយើងជាមុនមកហើយនោះ ដែលលោកមកខាំងខាទុកនោះមិនគួរសោះ។

**គួនអ៊ូ**ថា កាលគ្រា**ចូឆូ**លើកទ័ពមកវាយយកស្រុកកាំងតាំងនោះ **ឡៅពី**ក៏ចាត់កេណ្ឌទាហានទៅស្កាត់ច្បាំងនឹងទ័ព**ចូឆូ**ជាច្រើនតំបន់ ទាហានទាំងពួងក៏បានស៊ូនឹងព្រួញធ្នូនិងអាវុធផ្សេងៗ បានសេចក្ដីលំបាកវេទនាគ្រប់គ្នា ប្រាជ្ញាដែលធ្វើការបានជ័យជម្នះ**ចូឆូ**គ្រានោះ មិនពីព្រោះ**ឡៅពី**ប្រើ**ខុងបេង**ទៅជួយទេឬ? ហើយ**ឡៅពី**ក៏បានបង់ខាតស្បៀងអាហារជាច្រើន តែត្រឹមស្រុកកេងជីវប៉ុណ្ណោះ មិនសមគួរជាបំណាច់**ឡៅពី**និងទាហានដែលបានធ្វើការនឿយហត់នោះទេឬ? ហេតុម្ដេចបានជាអ្នកមកបង្ខំតឹងទារស្រុកកេងជីវដដែលៗដូច្នេះ?

**ឡោសុក**ថា កាល**ឡៅពី**និងលោកបែកទ័ពមកពីវាលទៀងប៉ាន់ប៉ោ នាយយើងគិតអាណិតអាសូរបានជាឲ្យស្រុកកេងជីវនៅជាបណ្តោះអាសន្ន ត្រាតែតាំងខ្លួនបានដល់ប៉ុណ្ណោះ ហើយ**ឡៅពី**នោះក៏ជាមនុស្សមានសេចក្តីស័ត្យបានចេញមាត់ថាពីការអ្វីៗ ក៏មិនដែលឲ្យខូចវាចារសោះ ដែលខ្លួនលោកមកនិយាយដូច្នេះ មនុស្សទាំងពួងនឹងកន្លងមើលងាយបាន។ **គួនអ៊ូ**ថា ការទាំងពួងនេះ មិនមែនជាសិទ្ធិដាច់ខាតលើខ្លួនយើងទេ គឺចំពោះលើ**ឡៅពី**ជានាយចៅហ្វាយសម្រេចសេចក្តី តាមតែអ្នកនឹងនិយាយគ្នាចុះ។ **ឡោសុក**ថា យើងដឹងថា ខ្លួនលោកនិង**ឡៅពី**បានប្តេជ្ញាស្បថស្បាន់គ្នា ទុកជាបងប្អូនរួមឧទរជាមួយគ្នា បើនឹងមានការអ្វីមកជារបស់**ឡៅពី** ក៏បីដូចជារបស់លោកដែរ ធុរៈអ្វីជារបស់លោកក៏ដូចជាធុរៈរបស់**ឡៅពី** ហេតុម្តេចលោកមកធ្វើព្រងើយកន្តើយដូច្នេះ? **គួនអ៊ូ**ក៏មិនឆ្លើយតបថាអ្វីៗ **ជីវឆង**ទាហាន**គួនអ៊ូ**ស្រែកថា អាណាខេត្តទាំងអស់នេះសុទ្ធតែរបស់ព្រះចៅ**ហៀនតេ**ទាំងមូល ហេតុអ្វី**ឡោសុក**មកថាស្រុកកេងជីវជារបស់**ស៊ុនគួន**វិញ?

**គួនអ៊ូ**ឮ**ជីវឆង**ស្រែកដូច្នោះក៏ធ្វើជាខឹង ក្រោកចេញមកឲ្យន័យ**ជីវឆង**ដឹងហេតុហើយ ក៏ដណ្តើមយកលំពែងមកកាន់ហើយស្រែកថា យើងនិង**ឡោសុក**កំពុងនិយាយគ្នាពីការស្រុកទេស ហេតុម្តេចខ្លួនគ្រាន់តែជាទាហានសម្រាប់លីលំពែងតាមមកអាចហ៊ានចូលមកនិយាយផងដូច្នេះ ជាការមិនសមគួរសោះ ខ្លួនត្រូវចេញពីទីនេះទៅក្រៅបន្ទាយទៅ។ **ជីវឆង**ដឹងន័យ**គួនអ៊ូ**ដូច្នោះ ក៏ដោះខ្លួនចេញទៅនៅខាងក្រៅ ហើយយកទង់ក្រហមបោកឡើងជាសម្គាល់។

**គួនប៉េង**ឃើញទង់សម្គាល់ដូច្នោះ ក៏បង្ខំទាហានឲ្យចែវទូកចម្បាំងទាំង៨០ ចូលទៅដល់មុខបន្ទាយ ឯ**គួនអ៊ូ**ក៏ធ្វើជាស្រវឹង គ្រវែងលំពែងដៃម្ខាង ដៃម្ខាងកាន់ដៃ**ឡោសុក**ហើយថា អ្នកហៅមកបរិភោគអាហារពេលនេះ ខ្ញុំក៏អរគុណណាស់ហើយ តែហេតុម្តេចក៏បានជាយកការស្រុកកេងជីវមកប្រារព្ធឲ្យរំខាន មិនបានឲ្យសប្បាយទៅវិញដូច្នេះ។ ឥឡូវយើងស្រវឹងជ្រុលបន្តិចទៅហើយ បើមិនគិតដល់ការដែលធ្លាប់

រាប់អានស្រឡាញ់គ្នាមកពីដើម ក៏នឹងបណ្ដាលឲ្យកើតជារឿងទាស់ទែងគ្នាជាធំ ខ្ញុំក៏រម្ងាប់កំហឹងច្រើនណាស់ ពេលនេះសុំលាអ្នកត្រឡប់ទៅវិញសិន ចាំថ្ងៃក្រោយខ្ញុំនឹងសុំអញ្ជើញអ្នកទៅពិសាលៀងខាងខ្ញុំឯស្រុកកេងជីវម្ដងវិញ ហើយក៏ដឹកដៃ**ឡោសុក**ចេញទៅដល់ក្រៅបន្ទាយ។

ឯ**កាំឡ្វេង**និង**លីបង**ដែលឃុំទាហានទៅពួនបង្កប់កនៅក្បែរនោះ លុះក្រឡេកឃើញ**គួនអ៊ូ**កាន់លំពែងម្ខាង ដឹកដៃ**ឡោសុក**ម្ខាងចេញមក លុះនឹងស្ទុះចេញទៅធ្វើអន្តរាយ**គួនអ៊ូ**តាមសញ្ញា ក៏នឹកខ្លាចថា **គួនអ៊ូ**នឹងប្រហារជីវិត**ឡោសុក**ជាប្រាកដ ឯ **គួនអ៊ូ**សោតក៏ដឹកដៃ**ឡោសុក**ទៅដល់មាត់ច្រាំង តាំងតែនិយាយថា យើងអរគុណអ្នកច្រើនណាស់ សុំឲ្យអ្នកនៅជាសុខសប្បាយចុះ ថាហើយក៏គំនាប់លា**ឡោសុក**ទៅក្នុងទូក ឲ្យទាហានបើកក្ដោងចេញទៅដល់ស្រុកកេងជីវ ឯ**ឡោសុក**ក៏ត្រឡប់ចូលក្នុងបន្ទាយវិញ ហើយឲ្យរកហៅ**កាំឡ្វេង** និង**លីបង**ចូលទៅប្រឹក្សាថា យើងគិតធ្វើការប្រទូសរ៉ាយ**គួនអ៊ូ**គ្រានេះ ក៏មិនសមសេចក្ដីគិតសោះ បើដូច្នេះយើងនឹងគិតធ្វើម្ដេចតទៅទៀត? **លីបង**ឆ្លើយថា លោកត្រូវធ្វើសំបុត្រមួយទៅដល់**ស៊ុនគួន**ថា ការដែលគិតធ្វើអន្តរាយ**គួនអ៊ូ**នោះ មិនបានដូចប្រាថ្នាទេ សុំឲ្យរៀបចាត់ចែងលើកទាហានជាព្យុហៈទ័ព ទៅវាយយកស្រុកកេងជីវតែម្ដងទៅចុះ ឯការខាងមាត់កំពង់នេះ ត្រូវឲ្យលោកនៅគ្រប់គ្រងរក្សាកុំឲ្យកើតអន្តរាយ។ **ឡោសុក**យល់ឃើញត្រូវ ក៏តែងសំបុត្រតាមពាក្យ**លីបង**ហើយប្រើបម្រើសេះឲ្យកាន់ចូលទៅឲ្យ**ស៊ុនគួន**ឯស្រុកកាំងតាំង។

**ស៊ុនគួន**ទទួលសំបុត្រមើល ដឹងសេចក្ដីហើយក៏ខឹងខ្លាំងណាស់ ទើបឲ្យកេណ្ឌទាហានអស់ពីក្នុងដែនស្រុកកាំងតាំងត្រៀមទុកស្រេច ដើម្បីនឹងលើកទៅវាយយកស្រុកកេងជីវ ទទួលមានបម្រើសេះពីទិសខាងជើងចូលមកប្ដឹងរាជការថា ឥឡូវ**ចូឆូ**កេណ្ឌទាហានបានប្រមាណបីម៉ឺន នឹងលើកចុះមកវាយយកស្រុកកាំងតាំងហើយ។ **ស៊ុនគួន**ឮដូច្នោះក៏តក់ស្លុតស្មារតី ទើបឲ្យតែងសំបុត្រប្រាប់ខរាជការខាងទិសឯជើងទៅដល់**ឡោសុក**ថា យើងត្រូវលើកទ័ពទៅតាំងទទួលកងទ័ព**ចូឆូ**នៅតំបន់ហាប់ហ៊ុយ

ឲ្យ**ឡោសុក**នៅរក្សាមាត់កំពង់យើងឲ្យមាំមួន ហើយ**ស៊ុនគួន**ក៏ឲ្យទាហានលើកទៅតាំងទល់ទ័ពនៅតំបន់យីស៊ូ តួ**ស៊ុនគួន**ឯងក៏លើកពលទៅតាំងនៅតំបន់ហាប់ហ៊ុយប្រាថ្នានឹងទទួលទ័ព**ចូឆូ**។

ឯ**ចូឆូ**ត្រៀមពលយោធា ព្រមព្រៀងស្រេចកាលណានឹងលើកចេញចាកស្រុកក្រុងទទួល**ប៉ោហាន់**កាន់សំបុត្រមួយច្បាប់យកទៅជូន **ចូឆូ**ទទួលយកទៅមើលឃើញសេចក្ដីថា ខ្ញុំបាទ**ប៉ោហាន់**សូមគំនាប់មហាឧបរាជទីវ៉ុយកុងសូមជ្រាប ព្រោះពាក្យបុរាណពោលទុកថា បណ្ដាទាហានសេនាដែលជាកងទ័ពមេកងនោះ បើនឹងលើកពលទៅធ្វើសង្គ្រាមនៅទីណា តំបន់ណា ត្រូវឲ្យបម្រុងសេនាទាហាននិងគ្រឿងសាស្ត្រាវុធឲ្យព្រមជាតេជៈរាសី ហើយសន្សឹមលើកព្យុហៈចេញទៅជាធម្មតា ចំណែកខាងភ្នាក់ងាររដ្ឋបាលសោត ក៏ត្រូវឲ្យប្រកបចិត្តគិតអធ្យាស្រ័យប្រណីទូទៅដល់អាណាប្រជានុរាស្ត្រឲ្យនៅជាសុខ ហើយត្រូវទំនុកបម្រុងស្រុកទេសទុកជាទីរាសីតេជៈ សេចក្ដីទាំងពីរនេះបើអ្នកណាធ្វើបានទើបនឹងតាំងខ្លួនធ្វើជាធំបានតទៅ ឯអាណាខេត្តទាំងអស់នេះ សុទ្ធតែកើតចលាចលរាល់ថ្ងៃខែ ពុំទាន់ស្ងប់រាបទាបលោកបានចេញទៅបង្ក្រាបបានប្រាំបួនភាគហើយ នៅសល់តែមួយភាគ គឺស្រុកកាំងតាំង និងស្រុកសែឈួន ដូចជាស្រុកកាំងតាំងនោះ ផ្លូវក៏ដាច់ស្រយាលឆ្ងាយព្រោះជាជាយមាត់ទន្លេសមុទ្រផុតស្រុកទាំងពួង ឯស្រុកសែឈួនសោតក៏ជាផ្លូវទៅមកលំបាកណាស់ ព្រោះជាច្រកជ្រោះជ្រលងដងលង្វែកភ្នំច្រើនអន្លើ បើលោកនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំងគ្រានេះ មុខជាពលទាហានបានសេចក្ដីលំបាកណាស់ សុំឲ្យលោកបង្អង់ឈប់បម្រុងសេនាទាហានឲ្យមានកម្លាំងសិនសឹមលើកទៅគង់នឹងបានជ័យជម្នះដោយងាយ។

**ចូឆូ**មើលយល់សេចក្ដីសំបុត្រដូច្នោះហើយ ក៏ឲ្យបញ្ឈប់កងទ័ពទុកមួយអន្លើ ហើយតាំងរិះគិតធ្វើតាមឧបាយនៃសំបុត្រ**ប៉ោហាន់**នោះ ទោះមាននរណាខ្លាំងពូកែក្លាហានក៏ឲ្យយកខ្លួនមកចូលធ្វើការរាជការព្យាបាលរក្សាទុក ក្នុងខណៈនោះមាន

ឈ្មោះ**អងសាន, តោស៊ិប, អ៊ុំខៃ, ឱចាប់** ប្អូននាក់នេះប្រឹក្សាឃើញព្រមគ្នា ក៏ចូលទៅជម្រាបប្តឹង**ចូឆ្វ**ថា ព្រះតេជព្រះគុណជាមនុស្សមានសតិបញ្ញា បានទំនុកបម្រុងស្រុកទេសផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្ត បានប្រាបប្រាមសឹកសត្រូវឲ្យរាបទាបអស់ហើយ គួរនឹងលើកទីជាម្ចាស់**វ៉ុយអេង** គឺស្តេចតាងក្រុមបាន។ **ចូឆ្វ**បានស្តាប់ក៏មិនទាន់តបប្រការម្តេច **ស៊ុនហ៊ីវ**ឮមន្ត្រីទាំងបួននាក់ស្នើសេចក្តីដូច្នោះ ក៏ឆ្លើយទាស់ថា សព្វថ្ងៃនេះលោកក៏បានជាទីវ៉ុយកុងហើយ គឺជាធំលើសមន្ត្រីខ្ញុំរាជការទាំងពួង ដែលអ្នកទាំងបួននាក់សុំឲ្យលោកឡើងជាទីវ៉ុយអេងនោះ លើសនិស្ស័យណាស់។

**ចូឆ្វ**ឮដូច្នោះក៏ខឹងច្រឡោតថា អ្នកឯងមកស្រដីមើលងាយយ៉ាងនេះ នឹងចង់ឲ្យដូច**ស៊ុនហុក**ទៅឬ? **ស៊ុនហ៊ីវ**ឃើញ**ចូឆ្វ**ខឹងដូច្នោះ ក៏មិនហ៊ានតបថាអ្វីទៀត ទើបលាត្រឡប់ថយចេញមក លុះទៅដល់ផ្ទះអាត្មាក៏ឈឺផ្សាទោមនស្សតូចចិត្តណាស់ ចេះតែក្រំចិត្តទាល់តែក្ស័យជីវិតទៅ។ **ចូឆ្វ**ដឹងថា**ស៊ុនហ៊ីវ**អនិច្ចកម្មក៏អាណិតស្តាយណាស់ ឲ្យយករបស់មាសប្រាក់ទៅរៀបធ្វើការសពតាមទម្លាប់ប្រពៃណី ហើយឲ្យហែទៅបញ្ចុះតាមទំនៀម ឯកាដែលប្រុងនឹងឡើងទីជាវ៉ុយអេងនោះ**ចូឆ្វ**ក៏បង្អង់ទៅវិញ។

លុះអំណើះមកថ្ងៃមួយនោះ **ចូឆ្វ**ក៏កាន់គ្រប៊ីចូលទៅទីខាងក្នុងព្រះបរមរាជវាំងព្រះចៅ**ហៀនតេ** និងព្រះនាង**ហុកហៅ**ជាអគ្គមហេសី ក្រឡេកឃើញក៏ស្លុតព្រះទ័យ **ចូឆ្វ**ក៏ទូលន័យថា ឥឡូវ**ស៊ុនគួន**ទៅវាយស្រុកកាំងតាំង និង**ឡៅពី**ទៅវាយស្រុកសែឈួន ទាំងពីរមណ្ឌលនេះរឹងទទឹង ខ្លាំងពូកែមិនបានមកចំណុះចុះចូលស្តាប់បង្គាប់ក្រោមព្រះបាទតាមបុរាណរាជប្រពៃណីជាយូរមកហើយ។ ព្រះចៅ**ហៀនតេ**ទ្រង់ត្រាស់តបថា ការទាំងនេះនឹងមកប្រាប់យើងធ្វើអ្វី នឹងត្រូវការអ្វីក៏ស្រេចតែវ៉ុយកុងចុះ។ **ចូឆ្វ**ឮព្រះវាចារដូច្នោះក៏ខឹងណាស់ ឆ្លើយតបថា ព្រះអង្គទ្រង់មានព្រះបន្ទូលដូច្នោះ ដូចជានាំឲ្យមនុស្សទាំងពួងមានសេចក្តីគរហានិន្ទាដល់ទូលព្រះបង្គំ។ ព្រះចៅ**ហៀនតេ**ត្រាស់ថា ការស្រុកទេសទាំងប៉ុន្មាន បើលោកមិនជួយទំនុកបម្រុង

ទេ ក៏មិនបានសេចក្ដីសុខក្សេមក្សាន្ត ព្រោះផែនដីនេះ ពិតជារបស់យើងមែន តែស្រេចនៅលើលោកចាត់ចែងទាំងអស់ហើយ បើលោកនឹងគិតធ្វើការអ្វីៗ យើងនឹងទទឹងលោកបាន?

**ចូឆ្វ**ឮដូច្នោះក៏រឹតតែខឹងខ្លាំងណាស់ មិនបានគំនាប់លាតាមទំនៀម ក៏វិលត្រឡប់ទៅកាន់ទីលំនៅវិញ។ ខន្ទីទាំងពួងកាលបើឃើញ**ចូឆ្វ**ទៅវិញផុតហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា ទូលព្រះបង្គំជាខ្ញុំបានឮកិត្តិស័ព្ទថា **ចូឆ្វ**នោះគិតនឹងឡើងទីជាស្ដេចតាងក្រុម យូរទៅទូលព្រះបង្គំជាខ្ញុំយល់ឃើញថា មុខជាក្បត់ដណ្ដើមយករាជសម្បត្តិជាប្រាកដពុំខាន។ ព្រះចៅ**ហៀនតេ** និងព្រះនាង**ហុកហៅ**អគ្គមហេសីទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ទ្រង់កន្សែងពិលាប ហើយស្ដេចយាងចូលទៅក្នុងព្រះបន្ទំទាំងពីរព្រះអង្គ។ ព្រះនាង**ហុកហៅ**ក្រាបទូលថា **ហុកអ៊្វន**បិតាខ្ញុំម្ចាស់ ឃើញ**ចូឆ្វ**ធ្វើការរំលោភអាក្រក់ ក៏មានចិត្តក្ដាញ់ក្ដៅពន់ប្រមាណណាស់ គិតតែនឹងសម្លាប់**ចូឆ្វ**ចេញឲ្យបាន ខ្ញុំម្ចាស់នឹងធ្វើសំបុត្រផ្ញើទៅបិតាខ្ញុំម្ចាស់ ឲ្យខំរិះគិតកម្ចាត់វាចេញឲ្យបានឆាប់។

ព្រះចៅ**ហៀនតេ**ត្រាស់ថា ដែលចៅនឹងឲ្យសំបុត្រទៅដល់បិតានោះ យើងខ្លាចក្រែងដូចកាលយើងសរសេរអក្សរនឹងលោហិត ទៅដល់**តាំងស៊ិន**ធ្វើការមិនកំបាំង **ចូឆ្វ**ចាប់បាន ក៏សម្លាប់អស់ទាំងពួកក្រុមជាច្រើននាក់ គ្រានេះបើចៅនឹងធ្វើការក្រែងមិនជិតយើងនឹងនាំគ្នាក្ស័យជីវិតទេដឹងឬ? ព្រះនាង**ហុកហៅ**ទូលថា ព្រះអង្គនិងខ្ញុំម្ចាស់មានជីវិតរស់នៅសព្វថ្ងៃនេះ ឧបមាបីដូចត្រឡាចនៅក្នុងបន្លាមិនមានពេលណាឲ្យសប្បាយនោះគ្មាន បើតេជៈបារមីរបស់ព្រះអង្គនិងខ្ញុំម្ចាស់មានមក ក៏គង់គិតធ្វើការនេះបានរហូតទៅ បើគ្មានបុណ្យវាសនាមកទេ ស្លាប់ជីវិតទៅប្រសើរជាងរស់នៅ ខ្ញុំម្ចាស់ឃើញ**បកស៊ុន**ខន្ទីនោះមានចិត្តសុចរិតទៀងត្រង់ ល្មមនឹងប្រើការបាន នឹងឲ្យកាន់សំបុត្រចេញទៅឲ្យបិតាខ្ញុំម្ចាស់។

ព្រះចៅ**ហៀនតេ**យល់ឃើញត្រូវ ក៏ត្រាស់ឲ្យហៅ**បកស៊ុន**ខន្ទីចូលទៅគាល់ ហើយទ្រង់ព្រះកន្សែងត្រាស់ប្រារព្វរឿងដែលជាទុក្ខនោះឲ្យស្ដាប់ ហើយត្រាស់ថា **ចូឆ្វូ**ធ្វើការអាក្រក់លាមក ទាល់តែបានឡើងយសសក្តិជាទីវុយកុង ហើយនៅមានចិត្តគិតប្រុងនឹងលើកខ្លួនជាទីវុយអេងទៀត ប្រាថ្នានឹងជ្រៀតជ្រែកដណ្តើមយករាជសម្បត្តិរបស់យើង ខ្លួនយើងនឹងអគ្គមហេសីបានសេចក្តីទុក្ខក្តៅ ដូចដេកនៅក្នុងគំនរភ្លើងជានិច្ចនិរន្តរ៍ នឹងគយគន់មើលក៏មិនឃើញមានអ្នកឯណានឹងជួយរួចពីសេចក្តីក្តៅនេះបាន ឃើញតែអ្នកមួយដែលនឹងជួយឲ្យបានសេចក្តីសុខជាស្វាត់ កាន់សំបុត្រទៅដល់**ហុកអ៊្វួន**ដែលជាបិតាព្រះអគ្គមហេសីនៃយើង ដើម្បីនឹងជួយកម្ចាត់**ចូឆ្វូ**ចេញ។

**បកស៊ុន**ឮព្រះបន្ទូលដូច្នោះ ក៏យំខ្សឹកខ្សួលអួលឱរា ក្រាបទូលស្នងព្រះរាជឱង្ការថា ទូលព្រះបង្គំជាខ្ញុំបាននៅជាសុខក្រោមម្លប់ព្រះបរមពោធិសម្ភារព្រះអង្គមកយូរហើយ វេលានេះខ្ញុំនឹងសុំយកជីវិតគិតឆ្លងថ្វាយព្រះតេជព្រះគុណកាន់សំបុត្រចេញទៅឲ្យបាន សូមឲ្យទ្រង់ព្រះអក្សរចុះ។ ព្រះនាង**ហុកហៅ**ក៏សរសេរសំបុត្រតាមរឿងរ៉ាវ ដែលមានសេចក្តីទុក្ខក្តៅគ្រប់ប្រការ ហើយច្រកស្រោមបិទយ៉ាងជិតប្រគល់ឲ្យ**បកស៊ុន** ៗទទួលយកសំបុត្រនោះទៅលាក់ក្នុងផ្នួងសក់ ហើយក៏ថ្វាយបង្គំលាចេញទៅពីក្នុងព្រះបរមរាជវាំងតម្រង់ទៅផ្ទះ**ហុកអ៊្វួន** លុះទៅដល់ហើយក៏ហុចសំបុត្រទៅឲ្យ**ហុកអ៊្វួន** ហើយនិយាយប្រាប់សេចក្តីគ្រប់ប្រការ។

**ហុកអ៊្វួន**ទទួលសំបុត្រទៅមើលដឹងថា លាយលក្ខណ៍អក្សរដៃព្រះនាង**ហុកហៅ**ជាបុត្រ ប្រាប់សេចក្តីទុក្ខក្តៅគ្រប់ប្រការថា ការនេះឃើញតែបិតានឹងជួយរិះគិតការកំបាំង ដើម្បីនឹងកម្ចាត់**ចូឆ្វូ**ចេញ ទើបផែនដីនឹងបានសេចក្តីសុខតទៅ។ **ហុកអ៊្វួន**ដឹងក្នុងសេចក្តីសំបុត្រដូច្នោះក៏និយាយថា សព្វថ្ងៃនេះ**ចូឆ្វូ**កំរើបចិត្តគិតធ្វើការជាធំពន្លឹកពេកណាស់ ទាំងត្រចៀកនិងភ្នែកក៏មានជ្រួតជ្រាបដឹងទូទៅគ្រប់ច្រកល្ហកមិនសូវកំបាំង ដែលយើងនឹងធ្វើការអ្វីជាសេចក្តីស្រាលគំនិតគិតឲ្យជ្រៅល្អិតទេ

ក៏គង់មិនសម្រេច គេចត្រឡប់វ័ណ្ឌព័ន្ធលើខ្លួនវិញមិនខាន។ បើដូច្នោះគួរតែឲ្យសំបុត្រសម្ងាត់ទៅដល់**ឡៅពី** និង**ស៊ុនគួន** ឲ្យលើកកងទ័ពមកធ្វើការខាងក្រៅ **ចូវឆ្វ**ក៏គង់ចេញទៅធ្វើការតទល់ ហើយយើងចាត់មនុស្សដែលមានចិត្តសុចរិតត្រង់នឹងផែនដីទៅធ្វើការជាកលសឹកខាងក្នុងគង់នឹងបានសម្រេចតាមប្រាថ្នា។ **បកស៊ុន**ស្តាប់យល់ឃើញត្រូវ **ហុកអ៊ួន**ក៏តែងសំបុត្រពីរច្បាប់បញ្ជូនឲ្យទៅ**ឡៅពី** និង**ស៊ុនគួន** ហើយសរសេរសំបុត្រប្រាប់រឿងរ៉ាវដែលគិតនោះ ផ្ញើទៅព្រះនាង**ហុកហៅ**ឲ្យក្រាបបង្គំទូលព្រះចៅ**ហៀនតេ**មួយច្បាប់ រួចបិទស្រោមប្រគល់ឲ្យ**បកស៊ុន**។

**បកស៊ុន**ទទួលសំបុត្រនោះមកស៊កលាក់ក្នុងផ្នួងសក់ ហើយលាត្រឡប់ចូលទៅក្នុងព្រះបរមរាជវាំង ខណៈនោះមានស្រីស៊ើបការណ៍របស់**ចូវឆ្វ**នៅក្នុងព្រះបរមរាជវាំងបានដឹងសេចក្តីច្បាស់ក៏ទៅប្រាប់**ចូវឆ្វ** ៗបានដឹងការណ៍ក៏នាំទាហានស្រូតទៅស្ទាក់ចាំ**បកស៊ុន**នៅមាត់ទ្វារព្រះបរមរាជវាំង លុះឃើញ**បកស៊ុន**ដើរចូលមក **ចូវឆ្វ**សួរថា អ្នកឯងទើបមកពីណា? **បកស៊ុន**ឆ្លើយថា ព្រះនាង**ហុកហៅ**ទ្រង់ប្រឈួន ឲ្យខ្ញុំបាទចេញទៅរកពេទ្យហ្ន។ **ចូវឆ្វ**ថា ឯណាមិនឃើញពេទ្យនោះ? **បកស៊ុន**ឆ្លើយកែថា ពេទ្យមកតាមក្រោយ។ **ចូវឆ្វ**ថា ខ្លួនមានពិរុទ្ធហើយ ទើបឲ្យទាហានដោះអាវ**បកស៊ុន**ពិនិត្យមើល ក៏មិនឃើញមានអ្វីជាសម្គាល់ ក៏ឲ្យបើកលែង**បកស៊ុន**ដើរចេញទៅ។ **បកស៊ុន**ដើរចេញទៅបានប្រហែលដប់ព្យាមទទួលខ្យល់ផាត់ធ្លាក់មួកពីលើក្បាល **ចូវឆ្វ**ឃើញដូច្នោះក៏មានសេចក្តីសង្ស័យទើបឲ្យហៅ**បកស៊ុន**ត្រឡប់មកពិនិត្យមើលម្តងទៀត ក៏មិនឃើញមានពិរុទ្ធអ្វី **ចូវឆ្វ**ឲ្យបើកលែងទៅ។ **បកស៊ុន**ភ័យតក់ស្លុតលា**ចូវឆ្វ**ដើរចេញទៅ មួកលើក្បាលក៏របើកធ្លាក់ទៅវិញ ព្រោះភ័យតក្កមាខ្លាំងណាស់ ប្រឹងដើររហ័សទៅឲ្យផុត។ **ចូវឆ្វ**ឃើញប្លែកគិតថា **បកស៊ុន**ប្រហែលមានហេតុអ្វីក្នុងខ្លួនបានជាតក់ស្លុតម្ល៉េះ ក៏ឲ្យហៅមកពិនិត្យមើលម្តងទៀត។ លុះអង្កេតមើលសព្វហេតុទៅ ក៏ឃើញសំបុត្រនៅក្នុងផ្នួងសក់**បកស៊ុន**។ **ចូវឆ្វ**ឲ្យទាហានឃុំខ្លួនទុក ហើយយកសំបុត្រនោះមកហែកស្រោមមើលឃើញសេចក្តីថា ខ្ញុំ**ហុកអ៊ួន**ដែលគិតនឹង

កម្ចាត់**ចូឆ្វូ**ចេញនោះ ចាំគិតធ្វើសំបុត្រទៅបញ្ចុះបញ្ចូល**ឡៅពី** និង**ស៊ុនគួន**ឲ្យលើកកងទ័ពមកសិន ទើបនឹងគិតការនោះបានរហូត។

**ចូឆ្វូ**ឃើញសេចក្តីសំបុត្រដូច្នោះក៏ខឹងណាស់ ឲ្យទាហាននាំ**បកស៊ុន**ទៅឯផ្ទះ ហើយក៏ឃុំខ្លួន**បកស៊ុន**ទុក នាំទាហានបីពាន់ទៅព័ទ្ធផ្ទះ**ហុកអ៊្វិន** ចាប់ខ្លួន**ហុកអ៊្វិន**និងគ្រប់ស្ម័គ្របក្សពួកទាំងអស់យកទៅដាក់គុកទុក ហើយរឹបយកទ្រព្យរបស់អស់រលីងពីក្នុងផ្ទះក្រៅផ្ទះ ពួកទាហានក៏រើឃើញសំបុត្រព្រះនាង**ហុកហៅ**នៅលើផ្ទះ**ហុកអ៊្វិន**យកទៅជូន**ចូឆ្វូ** ៗទទួលយកទៅមើលឃើញសេចក្តីខឹងណាស់ ប្រើទាហានឲ្យទៅព័ទ្ធចាប់បណ្តាវង្សាគណៈញាតិបងប្អូនព្រះនាង**ហុកហៅ**យកទៅដាក់គុកទាំងអស់។ លុះវេលាព្រឹក **ចូឆ្វូ**ប្រើ**អេកលី**ឲ្យលើកទាហានបីរយនាក់ កាន់គ្រឿងសាស្ត្រាវុធគ្រប់ដៃ ហើយចូលទៅប្រុងនឹងយកត្រាសម្រាប់ព្រះអគ្គមហេសី។ ខណៈនោះព្រះចៅ**ហៀនតេ** ទ្រង់ស្តេចយាងចេញមកកាន់ទីប្រជុំខុនម៉ឺនមន្ត្រី ទតព្រះនេត្រឃើញ**អេកលី**លើកទាហានចូលមកសន្ធឹកសន្ធាប់ដូច្នោះ ក៏ទ្រង់ត្រាស់សួរថា អ្នកឯងចូលមកនេះដោយមានការអ្វី? **អេកលី**ទូលថា **វុយកុង**ប្រើទូលបង្គំជាខ្ញុំចូលមកយកត្រាសម្រាប់ទីព្រះអគ្គមហេសី។

ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្តាប់ស្តុតព្រះទ័យ ទ្រង់ព្រះតម្រិះថា ការដែលគិតនោះប្រហែលជាដឹងដល់**ចូឆ្វូ**ហើយ បានជាកើតហេតុដូច្នេះ ទ្រង់មានព្រះបរិវិតក្កទុក្ខទោសមនស្សពន់ប្រមាណណាស់ មិនបានត្រាស់ថាប្រការម្តេចសោះ។ **អេកលី**ក៏នាំទាហានចូលទៅដល់ល្វែងក្នុង ហើយស្រែកប្រកាសថា ស្រីបម្រើឯណាដែលបានរក្សាត្រាសម្រាប់ទីអគ្គមហេសីនោះ ចូរយកត្រាប្រគល់ឲ្យយើងជាប្រញាប់តាមបង្គាប់**វុយកុង**។ ស្រីបម្រើដែលសម្រាប់រក្សាត្រាបានឮដូច្នោះក៏ភ័យតក់ស្លុតក្នុងចិត្ត ទើបយកត្រានោះប្រគល់ឲ្យ**អេកលី** ៗបានត្រាហើយ ក៏នាំទៅប្រគល់ឲ្យ**ចូឆ្វូ**។

ខណៈនោះព្រះនាង**ហុកហៅ**ឃើញទាហាន**ចូឆ្វូ**ទៅស្រែកកំហែងទារយកត្រាសម្រាប់ទីព្រះអគ្គមហេសីដូច្នោះ ក៏ភ័យខ្លាំងណាស់ ទើបគិតថា សេចក្តីដែលគិត

ឲ្យសំបុត្របិតានោះប្រហែល**ចូឆ្វ**ដឹងប្រាកដហើយ ៗព្រះនាងក៏ចូលទៅពួនក្នុងព្រះដំណាក់មួយអន្លើហើយបង្គាប់ឲ្យចាក់សោពីក្នុង និងក្រៅ ប្រាថ្នាមិនឲ្យអ្នកឯណាចូលទៅធ្វើអន្តរាយបាន។

**ចូឆ្វ**ក៏ប្រើ**ហ្សូហ៊ឹម**ឲ្យនាំទាហានប្រាំរយ ចូលទៅចាប់ព្រះនាង**ហុកហៅ**។ **ហ្សូហ៊ឹម**កាលចូលទៅដល់ល្វែងក្នុង ក៏សួរស្រីបម្រើទាំងពួងថា ព្រះនាង**ហុកហៅ**នៅឯណា? បណ្តាស្រីខាងក្នុងបានឮដូច្នោះក៏ភ័យខ្លាំងណាស់ឆ្លើយថា ព្រះនាង**ហុកហៅ**រត់ទៅពួនឯណាមិនដឹងទេ។ **ហ្សូហ៊ឹម**នាំទាហានចូលទៅរើរកមើលគ្រប់ទីកន្លែង ក៏មិនប្រទះឃើញសោះ លុះក្រឡេកមើលដំណាក់មួយខ្ទង់បិទទ្វារជិតប្លែកណាស់ ក៏ឲ្យទាហានបុកទម្លាយចូលទៅ។ **ហ្សូហ៊ឹម**ចូលទៅតាមឃើញព្រះនាង**ហុកហៅ**នៅពួនក្នុងដំណាក់នោះ ក៏ចូលទៅចាប់សក់ដឹកកន្ត្រាក់អូសចេញមកពីក្នុងដំណាក់។ ព្រះនាង**ហុកហៅ**ភ័យខ្លាំងណាស់ ក៏ស្រែកទួញអង្វរថា លោកចូរអាណិតខ្ញុំ កុំឲ្យខ្ញុំដល់នូវសេចក្តីស្លាប់ឡើយ។ **ហ្សូហ៊ឹម**ថា យើងជាបម្រើគេធ្វើតែតាមបង្គាប់នាយចៅហ្វាយ សូមនាង**ហុកហៅ**ទៅអង្វរ**វុយកុង**ចុះ។ ហើយក៏ដឹកសក់អូសកន្ត្រាក់ព្រះនាងចេញពីក្នុងដំណាក់ ទៅដល់មុខព្រះលាន។

ព្រះចៅ**ហៀនតេ**ឃើញដូច្នោះស្លុតព្រះទ័យខ្លាំងណាស់ ហើយស្តេចចេញទៅឱបព្រះអគ្គមហេសីទ្រង់ព្រះកន្សែងសោកាពិលាប។ ព្រះនាង**ហុកហៅ**ក៏ទ្រង់ព្រះកន្សែងទូលតបថា ជីវិតខ្ញុំម្ចាស់ វេលានេះមុខជាមិនរួចឡើយ។ ព្រះចៅ**ហៀនតេ**ត្រាស់ប្រលោមថា ពេលវេលានេះជាកម្មវេរារបស់យើង តាមមកទាន់ហើយ កុំថាឡើយតែជីវិតចៅដែលត្រូវស្លាប់នោះ ទោះជីវិតយើងនេះក៏មិនដឹងថានឹងមានសេចក្តីអន្តរាយនោះនឹងមកដល់ពេលណា។ **ហ្សូហ៊ឹម**ឃើញដូច្នោះក៏ស្រែកគំហកថា **វុយកុង**ឲ្យមកយកខ្លួនព្រះអគ្គមហេសីចេញទៅជាប្រញាប់ ហេតុម្តេចព្រះអង្គមកទ្រង់ព្រះកន្សែងឲ្យយូរការដូច្នេះ ទោសនោះមិនធ្លាក់ទៅលើមនុស្សបម្រើទេឬ? ថាហើយក៏ឲ្យទាហានអូសទាញកន្ត្រាក់នាំព្រះនាងចេញ។

ព្រះចៅ**ហៀនតេ**ទតឃើញ ក៏រឹតតែទ្រង់ព្រះកន្សែងពន់ពេកណាស់ មុខគួរឲ្យអាសូរព្រះមហាក្សត្រ ដែលរាជសម្បត្តិមកកើតវិបត្តិដូច្នេះ លុះទ្រង់ក្រឡេកទៅឃើញ**អេកលី** ដែល**ចូឆ្វ**ប្រើឲ្យយកគ្រាសម្រាប់ទីព្រះអគ្គមហេសីនោះត្រឡប់ចូលមកគាល់ ក៏ត្រាស់សួរ**អេកលី**ថា ស្រុកទេសយើងពីដើមមកមានកើតហេតុដូច្នេះទេ? អ្នកឯងដែលឃើញខ្លះឬទេ? **អេកលី**ក៏មិនបានទូលតបថាប្រការម្ដេច។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់ព្រះកន្សែងទាល់តែដួលសន្លប់នៅទីនោះ។ **អេកលី**ឃើញដូច្នោះក៏ប្រើខន្ទីឲ្យចូលទៅគ្រាហ៍ ព្រះអង្គបានដឹងព្រះស្មារតីឡើងវិញ ហើយអញ្ជើញស្ដេចឲ្យទៅខាងក្នុង។

ខណៈនោះ**ហួហ៊ីម**ក៏នាំព្រះនាង**ហុកហៅ**ទៅជូន**ចូឆ្វ** ៗក៏សួរថា ខ្លួនអញឧស្សាហ៍រិះគិតបំបាត់សឹកសត្រូវចម្រូងចម្រាសក្នុងព្រះនគរឲ្យរាបទាប ហេតុអ្វីខ្លួនឯងដែលបានតែសេចក្ដីសុខក៏នៅមិនគាប់ចិត្តទៀត? ឯងជាមនុស្សមិនដឹងគុណ គិតទុរយសទ្រុស្តគុណអញ គប់គិតគ្នានឹងអាពុកប៉ងធ្វើទុក្ខឲ្យអញវិនាសវិញដូច្នេះ បើអញនឹងទុកឲ្យឯងនៅតទៅទៀត គង់នឹងប្រទូសរ៉ាយអញពុំខាន។ ថាហើយក៏ឲ្យទាហានយកដំបងសំពងវាយដំ ទាល់តែព្រះនាង**ហុកហៅ**អនិច្ចកម្មក្នុងខណៈនោះ។ ហើយឲ្យទាហានទៅចាប់ព្រះរាជបុត្រព្រះនាង**ហុកហៅ**ទាំងពីរព្រះអង្គ ដែលកើតពីព្រះចៅ**ហៀនតេ**នោះនាំទៅប្រហារជីវិតបង់។ លុះវេលាយប់ **ចូឆ្វ**ក៏នាំយកខ្លួន**ហុកអ៊្វិន** និង**បកស៊ុន** នូវបណ្ដាគ្រប់បក្សពួកទាំងប៉ុន្មាន ហើយនិងបងប្អូនសាច់សន្ដានព្រះនាង**ហុកហៅ**ទៅប្រហារជីវិតទាំងអស់។

ខណៈនោះ ព្រះចៅ**ហៀនតេ**តាំងពីបានទៅគង់នៅក្រុងហ៊្វូតោចំនួន១៩ឆ្នាំ (ពុទ្ធសករាជ ៧៥៧) វេលានោះព្រះអង្គទ្រង់សោកាល័យព្រះអគ្គមហេសី នូវព្រះរាជបុត្រទាំងពីរព្រះអង្គគ្រប់ពេលវេលា មិនបានស្រង់មិនបានសោយព្រះក្រយាជាយូរថ្ងៃ **ចូឆ្វ**ដឹងដូច្នោះក៏ចូលទៅគាល់ហើយទូលថា ព្រះអង្គកុំទ្រង់ព្រះវិតក្កសោះឡើយ ដូចជាខ្លួនទូលបង្គំនេះពីដើមរៀងមកបានទូលទុកថា នឹងជួយទំនុកបម្រុងផែន

ដឹតទៅ បើនរណាប្រព្រឹត្តខុសត្រូវក៏ត្រូវធ្វើតាមគុណ និងទោស ទូលព្រះបង្គំមិនបានគិតថាចិត្តពីរសោះ តាំងចិត្តស្មោះថានឹងជួយទំនុកបម្រុងព្រះអង្គដោយសុចរិតប្រាកដ ឥឡូវនេះទូលព្រះបង្គំក៏នៅមានបុត្រីម្នាក់ មានប្រាជ្ញាឆ្លៀវឆ្លាតប្រកបដោយអធ្យាស្រ័យទៀងត្រង់ល្អ ទូលព្រះបង្គំនឹងថ្វាយព្រះអង្គ។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ក៏មិនបានរឹងទទឹងទាស់អធ្យាស្រ័យ ព្រមទទួលតាមពាក្យ**ចូឆូ**ទូលនោះគ្រប់ប្រការ។

ខណៈនោះ ព្រះចៅ**ហៀនតេ**ទ្រង់ក្នុងក្រុងហ៊ូតោ២០ឆ្នាំ (ពុទ្ធសករាជ៧៥៨) ជាទេសកាលខែមាឃចូលឆ្នាំចិន **ចូឆូ**ក៏រៀបតុបតែងបុត្រីនាំចូលទៅថ្វាយព្រះចៅ**ហៀនតេ** ហើយតាំងបុត្រីនោះពេញជាទីអគ្គមហេសី បណ្ដានាហ្មឺនសព្វមុខមន្ត្រីព្រះចៅ**ហៀនតេ** ក៏កោតខ្លាចអំណាច**ចូឆូ**ទាំងអស់ នឹងរកអ្នកឯណាមួយអាចពិតទូលពោលទទឹងទាស់ដោយប្រការម្ដេចៗក៏គ្មាន។ **ចូឆូ**ក៏រឹតតែកំរើបចិត្តគិតធ្វើអាក្រក់ផ្សេងៗ តាមអំពើចិត្តឥតកោតញញើតព្រះចេស្ដា។

ថ្ងៃមួយ**ចូឆូ**ឱ្យហៅនាហ្មឺនមុខមន្ត្រីចូលទៅប្រជុំប្រឹក្សាថា យើងបានបម្រុងសេនាទាហានក៏មានកម្លាំងបរិបូរហើយ ឥឡូវយើងលើកទ័ពទៅវាយយកស្រុកសែឈ្នួននិងស្រុកកាំងតាំង អ្នកទាំងអស់គ្នានឹងយល់ឃើញដូចម្ដេច? **កាសៀង**ឆ្លើយថា សុំលោកឱ្យហៅខ្លួន**ចោយិន**និង**ហែហ៊្សូទុន**ឱ្យចូលមកប្រឹក្សាការរាជការសិន បើឃើញបានការហើយ សឹមលោកលើកកងទ័ពទៅចុះ។ **ចូឆូ**យល់ឃើញត្រូវផង ក៏ប្រើបម្រើឱ្យស្រូតរូតទៅហៅខ្លួន**ចោយិន**និង**ហែហ៊្សូទុន** ដែលនៅស្រុកស៊ុងយុងឱ្យចូលមក។

ឯ**ចោយិន**និង**ហែហ៊្សូទុន**ដឹងការណ៍ ក៏ស្រូតរូតចូលទៅដល់ក្រុងហ៊ូតោ តែ**ចោយិន**ចូលទៅដល់មុន។ ខណៈនោះ**ចូឆូ**សេពសុរាស្រវឹងក៏ចូលទៅដេកខាងក្នុង ទទួល**ចោយិន**ឡើងទៅនឹងចូលទៅគំនាប់**ចូឆូ** **ខៅធូ**កាន់លំពែងយាមនៅខាងក្រៅ កាលឃើញ**ចោយិន**ចូលទៅដល់ ក៏ឃាត់ហាមថា អ្នកកុំអាលចូលទៅ។ **ចោយិន**ឮ

ដូច្នោះខឹងណាស់ថា ខ្លួនអញជាក្មួយសាលោហិតរបស់មហាឧបរាជ ខ្លួនគ្រាន់តែជានាយទាហានទេ ហេតុម្ដេចអាចហ៊ានមកហាមឃាត់អញដូច្នេះ? **ខៅធូ**តបថា អ្នកឯងជាក្មួយ**វុយកុង**ក៏មែន តែ**វុយកុង**ចាត់ប្រើឱ្យខ្លួនចេញទៅឈរខេត្តក្រៅទៅហើយ ខ្លួនយើងជានាយទាហាននៅរក្សាអង្គខាងក្នុង អ្នកឯងមកពីស្រុកឆ្ងាយ យើងនឹងបណ្ដោយឱ្យចូលទៅតែម្ដងម្ដេចបាន! **ចោយិន**ត្រឡប់គិតឃើញត្រូវ ក៏ថយចេញទៅនៅខាងក្រៅវិញ។

ក្នុងខណៈដែល**ចោយិន**និង**ខៅធូ**ប្រកែកគ្នានោះ **ចូឆ្វូ**នៅមិនទាន់ដេកលក់ទេ បានឮសម្ដី**ខៅធូ**និយាយដូច្នោះ ឃើញត្រូវតាមទម្លាប់ទំនៀម ក៏សរសើរ**ខៅធូ**ថា មានតម្រិះប្រាជ្ញាជាមនុស្សទៀងត្រង់ លុះ**ហែហ៊្វូទុន**មកដល់ទៀត **ចោយិន** និង**ហែហ្វូទុន**ក៏ចូលទៅគំនាប់**ចូឆ្វូ** ៗមានសេចក្ដីត្រេកអរណាស់ ទើបប្រឹក្សានឹង**ចោយិន**និង**ហែហ៊្វូទុន**ថា យើងគិតនឹងលើកកងទ័ពទៅវាយស្រុកកាំងតាំង ហើយនិងស្រុកសែឈ្វូន អ្នកទាំងពីរនឹងយល់ឃើញដូចម្ដេច?

**ហែហ៊្វូទុន**ឆ្លើយថា ស្រុកកាំងតាំងនោះ សុំឱ្យលោកបង្អង់ទុកសិនចុះ ព្រោះស្រុកហាន់តុងបីដូចជាដើមផ្លូវស្រុកសែឈ្វូន សុំឱ្យលោកលើកទ័ពទៅវាយយកស្រុកហាន់តុងឱ្យបានសិន សឹមលើកទៅវាយយកស្រុកសែឈ្វូន គង់នឹងបានដោយងាយ ឯកាខាងស្រុកកាំងតាំងវិញ សឹមគិតជាក្រោយតទៅ។ **ចូឆ្វូ**យល់ឃើញត្រូវផង ក៏ឱ្យកេណ្ឌប្រមូលទាហានបានជាច្រើន ហើយឱ្យ**ហែហ៊្វូអៀន**និង**ទៀវខាប់**ជាមេកងទ័ពមុខ **ចូឆ្វូ**ជាមេទ័ពហ្លួង ឱ្យ**ចោយិន**និង**ងហែហ៊្វូទុន**ជាមេកងទ័ពក្រោយឱ្យនាំស្បៀង លុះបានឫក្សជ័យមង្គល ក៏រៀបពលយោធាចេញពីក្រុងហ៊្វូតោតម្រង់ទៅស្រុកហាន់តុង។

ខណៈនោះ មានបម្រើសេះដឹងការណ៍ ក៏ស្រូតទៅប្រាប់**ទៀវឡូ**ចៅហ្វាយស្រុកហាន់តុង ៗដឹងហើយក៏ប្រឹក្សានឹង**ទៀវអ្វួយ**ថា **ចូឆ្វូ**លើកទ័ពមកគ្រានេះយើងនឹងគិតការពារប្រការម្ដេច? **ទៀវអ្វួយ**ថា ឯស្រុកហាន់តុងនេះជាទីចង្អៀតចង្អល់

មានតែគយអេងប៉េងគួនជាទីប្រជុំផ្លូវសំខាន់ បើប្រសិនជាខូចទីគយនោះហើយ ស្រុកហាន់តុងក៏នឹងខូចទៅឯង។ ឯមុខគយអេងប៉េងគួននោះ មានភ្នំជាម្ខាង ព្រៃកជាម្ខាង សូមឱ្យលោកចាត់ទាហានជាពីរកងទៅតាំងបន្ទាយឱ្យមាំមួននៅទីនោះ ដើម្បីនឹងចាំទទួលកងទ័ព**ចូឆូ**ទើបនឹងបាន ឯខ្លួនលោកត្រូវនៅរក្សាការពារស្រុកទុកឱ្យមាំមួន។

**ទៀវឡូ**ស្តាប់យល់ឃើញត្រូវ ក៏ចាត់ឱ្យ**ទៀវអ្វូន**និង**អៀវហៀម, អៀវងុង** លើកទាហានជាច្រើនបន្ទាយរក្សាគយអេងប៉េងគួននោះ។ នាយទាហានទាំងបីនាក់ក៏នាំទាហានទៅដល់ទីនោះ **ទៀវអ្វូន**ក៏នៅរក្សាទីគយនោះ **អៀវហៀម, អៀវងុង**ក៏នាំទាហានចេញផ្លូវឆ្ងាយប្រហែលប្រាំមួយរយសិន ឱ្យតាំងបន្ទាយរយទ័ពនៅទាំងសងខាងផ្លូវចម្ងាយប្រាំរយបន្ទាយ ហើយត្រួតត្រារក្សាពលយោធា និងការពារបន្ទាយជាមាំមួនណាស់។

ឯ**ហែហ៊ួអៀន**និង**ទៀវខាប់**ដែលជានាយទ័ពមុខនោះ លុះលើកពលទៅដល់ប្រទល់មុខគ្នា ដឹងថាទាហាន**ទៀវឡូ**ចេញមកតាំងបន្ទាយរាយតាមមុខគយ ក៏ឈប់ទ័ពឱ្យតាំងបន្ទាយនៅឆ្ងាយពីគ្នាប្រមាណមួយរយហាសិបសិន។ ក្នុងពេលយប់នោះ ទាហាន**ហែហ៊ួអៀន**និង**ទៀវខាប់**នឿយណាស់ ក៏ដាក់ឈប់សម្រាកកម្លាំង តាំងតែធ្វេសប្រហែសប្រមាថពុំសូវគិតយាមល្បាតជាមាំមួន ជួនយប់ជ្រៅដល់យាមមួយប្លាយ **អៀវហៀម, អៀវងុង**ដឹងថាកងទ័ព**ចូឆូ**លើកទ័ពមកតាំងនៅជិតគ្នាដូច្នោះ ក៏ប្រឹក្សាគ្នាថា ទ័ពមុខ**ចូឆូ**ទើបនឹងមកដល់ទាហានកំពុងនឿយហត់ណាស់ ខ្លះក៏ដេកលក់ដេរដាស យើងត្រូវរកឱកាសចេញទៅប្លន់បន្ទាយគង់នឹងបានជ័យជម្នះជាប្រាកដ។ លុះគិតស្រេចក៏ចាត់ចែងបែងទាហានលបចេញទៅ យកភ្លើងដុតឆេះសន្ធោរសន្ធៅគ្រប់បន្ទាយ**ហែហ៊ួអៀន** និង**ទៀវខាប់**នោះ ហើយក៏បរពលចូលគ្រលុករុកបំពារជុំវិញ បន្ទាយបានបែកធ្លាយប្រកាប់សម្លាប់ទាហាន**ហែហ៊ួអៀន**និង**ទៀវខាប់**ស្លាប់ជាច្រើនណាស់ ឯ**ហែហ៊ួអៀន, ទៀវខាប់** នូវទាហានដែលមិនបានដឹង

ខ្លួនក៏បែកប្រពាក់ប្រពួនខ្ចាត់ខ្ចាយរត់ទៅក្រោយបណ្ដោយទៅ ចូលទៅពណ៌នាប្រាប់**ចូឆ្វ**គ្រប់ប្រការ។

**ចូឆ្វ**ដឹងដូច្នោះខឹងណាស់ថា ខ្លួនឯងបានធ្វើសឹកសង្គ្រាមជាមួយនឹងយើងរៀងមកជាយូរហើយ មិនគួរឡើយនឹងធ្វេសប្រមាថ គួរគិតឲ្យដឹងបទបាទតាមទម្លាប់ លើកទ័ពទៅដល់យល់ថា ទាហានកំពុងនឿយហត់ ត្រូវឲ្យដាក់យាមល្បាតក្រវែលប្រុងប្រយ័ត្នការឲ្យមាំមួនឲ្យណាស់ វេលានេះខ្លួនមកធ្វើល្មើសធ្វេសប្រហែស ហេតុការណ៍ឲ្យបរាជ័យដល់សត្រូវដូច្នេះ ទោសខ្លួនជាទម្ងន់ធ្ងន់ពន់ប្រមាណណាស់ ថាហើយក៏បង្គាប់ឲ្យចាប់ខ្លួន**ហៃហ៊្វអៀន**និង**ទៀវខាប់**ទៅសម្លាប់ ទីប្រឹក្សាទាំងអស់នាំគ្នាចូលទៅគំនាប់សុំទោស។ **ចូឆ្វ**អត់សន្ដោសលើកទោសឲ្យ ហើយលើកទ័ពស្រូតចូលទៅទៀត ឯផ្លូវដែលធ្វើដំណើរទ័ពទៅនោះ ជាច្រកជ្រោះជ្រលងភ្នំទុរគមញាតស្បាតណាស់ បណ្ដាពលយោធាក៏យាត្រាទៅដោយលំបាកពន់ពេក។ **ចូឆ្វ**ថា យើងមិនបានដឹងសោះថា ផ្លូវមកស្រុកនេះដាច់ស្រយាលលំបាកដូច្នេះសោះ ប្រសិនបើដឹងយ៉ាងនេះ យើងមិនលើកទ័ពមកទេ។ ហើយឲ្យមានចិត្តគិតព្រួយក្រែងសត្រូវយកទាហានមកពួនបង្កប់នៅទីនោះ។ **ខៅធូ**និង**ស៊ីឡុង**ឮដូច្នោះ ក៏ចូលទៅខ្សឹបប្រាប់**ចូឆ្វ**ថា **វ៉ុយកុង**កុំមានប្រសាសន៍ដូច្នេះ បើទាហានទាំងអស់ដឹងនឹងនាំឲ្យព្រួយចិត្ត ពុំបានគិតនឹងខំធ្វើការ។ **ចូឆ្វ**យល់ឃើញត្រូវផង លុះដើរឆ្លងទៅដល់កន្លែងបន្ទាយចាស់ដែល**ហៃហ៊្វអៀន** និង**ទៀវខាប់**តាំងទុក ហើយភ្លើងឆេះអស់ **ចូឆ្វ**បោះទ័ពនៅទីនោះឲ្យកជាបន្ទាយរាយចម្រូងឡើងវិញ លុះធ្វើរួចក៏កំជាប់នាយទាហានឲ្យប្រុងប្រយ័ត្នត្រួតត្រា រក្សាផ្លាស់ប្ដូរយាមល្បាតក្រវែលមិនឲ្យធ្វេសប្រហែស។

លុះវេលាព្រឹក **ចូឆ្វ**ក៏ជិះសេះនាំ**ខៅធូ, ស៊ីឡុង**ចេញពីបន្ទាយទៅដល់ទីភ្នំមួយ ក៏ឡើងទៅលើកំពូលភ្នំនោះ សម្លឹងមើលទៅឃើញសត្រូវតាំងទ័ពនៅគយជាមាំមួនណាស់ មើលទៅច្រកផ្លូវដែលនឹងចូលទៅតតាំងច្បាំងគ្នា ក៏ជាកន្លែងលំបាក នឹងយកជ័យជម្នះដោយក្រ។ និយាយមិនទាន់ផុតមាត់ ស្រាប់តែឮសំឡេងផាវ និងសន្ធឹក

ស្រែកហ៊ោគឹកកងរំពង ចូលមកទាំងសងខាងផ្លូវ **ចូឆូ**ភ័យណាស់ក៏និយាយថា យើងនឹងតតាំងច្បាំងយ៉ាងម្ដេច? **ខៅធូ**ឆ្លើយថា លោកកុំព្រួយ តែខ្លួនខ្ញុំបាទមួយក៏ទទួលអាសាច្បាំងបាន មិនមានឲ្យអន្តរាយដល់លោកទេ។ ហើយក៏និយាយនឹង**ស៊ីឡុង**ថា ឲ្យនាំ**វុយកុង**ត្រឡប់ទៅបន្ទាយវិញចុះ។ ខណៈនោះ**អៀវហៀម, អៀវងុង**ក៏បរសេះនាំទាហានចេញមកពីសងខាងផ្លូវ **ខៅធូ**ក៏ចាប់ដាវញាក់សេះចូលប្រយុទ្ធគ្នា។ **អៀវហៀម, អៀវងុង**តទល់កម្លាំងពុំបាន ក៏ញាក់សេះនាំទាហានថយរត់ទៅ។

ឯ**ហែហ៊ួអៀន** និង**ទៀវខាប់**បានឮសំឡេងហ៊ោកញ្ជៀវគឹកកងក៏នាំទាហានផងឆ្លងតាមទៅដើម្បីនឹងជួយ**ចូឆូ** លុះទៅដល់មាត់ផ្លូវក្រឡេកឃើញ**ស៊ីឡុង**នាំ**ចូឆូ**ចុះពីលើភ្នំមកវិញ ក៏ស្រួតទៅទទួលដោយសេចក្តីត្រេកអរ។ ឯ**ខៅធូ**ក៏តាមមកពីក្រោយបណ្តោយគ្នា។ **ចូឆូ**ក៏ម៉ឺម្នានាំទាហានចូលទៅក្នុងបន្ទាយវិញ គិតតែតាំងនៅក្នុងបន្ទាយនោះពេញហាសិបថ្ងៃ ហើយ**ចូឆូ**ក្លែងនិយាយថា យើងលើកកងទ័ពមកធ្វើការគ្រានេះ ពលទាហានមានសេចក្តីលំបាកណាស់ ឃើញថានឹងវាយយកស្រុកហាន់តុងមិនបានទេ ត្រូវតែគិតលើកទ័ពត្រឡប់ទៅក្រុងវិញស្រួលជាង។ **កាសៀង**ឆ្លើយថា លោកលើកកងទ័ពមកគ្រានេះ នៅមិនទាន់បានច្បាំងតាំងតទល់គ្នាជាមាំមួនសោះ បានប្រទះគ្នាតែចុងដៃចុងជើង នៅមិនទាន់ឃើញថ្វីដៃទាហានស្រុកហាន់តុងនៅឡើយ ហេតុម្ដេចលោកនឹងចង់លើកកងទ័ពត្រឡប់ទៅវិញ?

**ចូឆូ**ខិនខ្សឹបប្រាប់ថា យើងឃើញទាហានស្រុកហាន់តុងចេញមកតាំងបន្ទាយមាំមួនមិនមានប្រមាទ យើងលើកកងទ័ពត្រឡប់ទៅវិញនោះ ព្រោះចង់ឲ្យឮកិត្តិសព្ទនេះទៅដល់សត្រូវខាងនោះ បើឮហើយក៏គង់នឹងប្រមាទមិនខាន បើយើងឃើញបានចំណាប់វេលាណា នឹងបានលើកទាហានទៅព័ទ្ធវាយទម្លាយយកបន្ទាយគយអេងប៉េងគួន ក៏នឹងបានដោយងាយ។ **កាសៀង**ឮដូច្នោះក៏សរសើរថា សេចក្តីត្រិះរិះរបស់**វុយកុង**នេះប្រពៃណាស់ បីដូចជាទេវតា។

**ចូឆូ**និយាយនឹង**ទៀវខាប់**និង**ហែហ៊ូអៀន**ថា ទោសកំហុសរបស់អ្នកទាំងពីរនេះជាទម្ងន់គ្រាមុនម្តងហើយ គ្រានេះយើងនឹងឲ្យទៅធ្វើការម្តងទៀតដើម្បីកែខ្លួន បើធ្វើការម្តងទៀតមិនបានការ យើងត្រូវឲ្យប្រហារជីវិតចេញ **ទៀវខាប់** និង**ហែហ៊ូអៀន**ក៏ទទួលថា បើលោកនឹងប្រើឲ្យទៅធ្វើការអ្វីៗ ខ្ញុំបាទក៏សុំទទួលយកអាសាធ្វើការនោះឲ្យបានការ។ **ចូឆូ**ថា អ្នកឯងទាំងពីរនាក់ត្រូវនាំទាហានញែកគ្នាព័ទ្ធទៅតាមផ្លូវ តាមក្រោយបន្ទាយអេងប៉េងគួន ខ្លួនយើងនឹងលើកទៅវាយពីមុខបន្ទាយ។ **ទៀវខាប់, ហែហ៊ូអៀន**ទទួលបង្គាប់ហើយក៏ចេញទៅចាត់ការជាស្រេច។

ឯ**អៀវងុង**ក៏ប្រឹក្សានឹង**អៀវហៀម**ថា វេលានេះខ្ញុំបាទឮកិត្តិស័ព្ទថា **ចូឆូ**ប្រុងនឹងលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញហើយ ត្រូវតែលើកទាហានតាមទៅវាយពីក្រោយមុខជានឹងបែកធ្លាយជាប្រាកដ។ **អៀវហៀម**តបថា អ្នកឯងគិតកំរើបដូច្នេះមិនត្រូវទេ ព្រោះ**ចូឆូ**នោះចំណានក្នុងកលសឹកសង្គ្រាមណាស់ រមែងចេះល្បួងបញ្ឆោតវៀចជាត្រង់ ត្រង់ជាវៀច ដែលនឹងជឿតាមកិត្តិស័ព្ទយកជាប្រាកដនោះខ្ញុំមិនយល់ផងទេ។ **អៀវងុង**មិនស្តាប់ប្រញាប់ចាត់ចែងទាហានទាំងប្រាំរយបន្ទាយទើបយកអ្នករក្សាបន្ទាយនោះសុទ្ធតែមនុស្សឈឺនិងពិការ ហើយលើកពលយោធាដែលមាំមួនទៅតាំងពីយាមពីរប្លាយ ក្នុងពេលនោះមេឃចុះអ័ព្ទងងឹតណាស់ នឹងមើលផ្លូវព្រៃក៏មិនឃើញច្បាស់ **អៀវងុង**គិតបារម្ភខ្លាចក៏បញ្ឈប់ទ័ពតាំងបន្ទាយនៅកណ្តាលផ្លូវ។

**ហែហ៊ូអៀន**លើកទាហានព័ទ្ធពីក្រោយមកក្នុងយប់នោះ មេឃងងឹតណាស់បានឮសំឡេងមនុស្សនិងសេះសន្ធឹកសន្ធាប់ក៏គិតថា ប្រហែលទាហានស្រុកហាន់តុងមកពួនបង្កប់នៅទីនេះទេដឹង ក៏បង្ខំលើកទាហានស្រូតទៅឲ្យផុត ឯកងទ័ព**ហែហ៊ូអៀន**នោះមិនបានលើកតម្រង់ទៅត្រង់គយទេ ប៉ុន្តែវង្វេងផ្លូវសំដៅទៅបន្ទាយ**អៀវងុង**នោះ លុះទៅដល់បន្ទាយនោះហើយ ទទួលមេឃស្រឡះ អស់ពួកទាហាន**អៀវងុង**ដែលនៅក្នុងបន្ទាយស្មានថា**អៀវងុង**លើកទ័ពមកវិញ ក៏នាំគ្នាបើកទ្វារ

ទទួល។ **ហែហ៊្វអៀន**ក៏លើកទាហានចូលទៅក្នុងបន្ទាយ ដើរត្រួតពិនិត្យមើលគ្រប់បន្ទាយទាំងប្រាំរយ ឃើញទាហានទាំងនោះសុទ្ធតែមនុស្សឈឺពិការ **ហែហ៊្វអៀន**ក៏ឲ្យយកភ្លើងដុតបន្ទាយទាំងអស់នោះឆេះឡើង ពួកទាហានទាំងនោះក៏រត់រួចទៅខ្លះ ក្រៅពីនោះក៏ស្លាប់នឹងភ្លើងឆេះ ត្រូវប្រហារដោយគ្រឿងសាស្ត្រាវុធស្លាប់ជាច្រើនណាស់។

**អៀវហៀម**ឃើញពន្លឺភ្លើងឆេះឡើងគ្រប់បន្ទាយ**អៀវឌុង**ក៏លើកទាហានទៅជួយ **ហែហ៊្វអៀន**ឃើញដូច្នោះក៏បរសេះចូលទៅប្រយុទ្ធគ្នានឹង**អៀវហៀម**បានបួនភ្លូង **អៀវហៀម**ទ្រាំកម្លាំងពុំបានក៏ញាក់សេះនាំទាហានរត់ចូលបន្ទាយ ទទួលឃើញ**ទៀវខាប់**នៅក្នុងបន្ទាយពេញទាំងអស់ **អៀវហៀម**បកប្រាស់ត្រឡប់នាំទាហានរត់តម្រង់តាមផ្លូវសំដៅទៅស្រុកឡាំតេង។

ឯ**អៀវឌុង**ឃើញពន្លឺភ្លើងឆេះឡើងគ្រប់បន្ទាយដូច្នោះ ក៏នឹកគិតថា មុខជាកងទ័ព**ចូឆ្វូ**លបដុតជាពិតប្រាកដហើយ លុះនឹងថយត្រឡប់ទៅក្រោយ ខ្លាចទ័ព**ចូឆ្វូ**នឹងលើកដេញតាម ម្ល៉ោះហើយចេះតែអល់អែកនៅទីនោះ ទទួលទាហាន**ចូឆ្វូ**លើកវាយប្រសប់ខ្ទប់ពេញមកទាំងបីផ្លូវ **អៀវឌុង**ទាល់ច្រកក៏លះបង់ទាហាន បរសេះដោះយកតែខ្លួនរត់យកតែឯង ប្រទះនឹង**ទៀវខាប់**ក៏ចូលប្រកាប់គ្នាជាសន្ធឹកណាស់។ **ទៀវខាប់**ក៏លើកលំពែងឡើងចាក់ត្រូវ**អៀវឌុង**ធ្លាក់ពីលើសេះស្លាប់។ ខណៈនោះ ទាហាន**អៀវឌុង**ដែលបែករត់ទៅ ក៏យកសេចក្ដីនោះទៅអធិប្បាយប្រាប់**ទៀវអ្លួយ**គ្រប់ប្រការ។ **ទៀវអ្លួយ**ឮដូច្នោះក៏ភ័យណាស់ លះចោលបន្ទាយនោះ ហើយនាំទាហានរត់ត្រឡប់ទៅស្រុកហាន់តុងវិញ។

ខណៈនោះ **ចូឆ្វូ**ក៏លើកទាហានទ័ពហ្លួងចូលទៅក្នុងបន្ទាយអេងប៉េងគួន ឯ**ទៀវអ្លួយ**នោះ កាលរត់ត្រឡប់ទៅក៏ជួបប្រទះនឹង**អៀវហៀម** ទើបនាំគ្នាចូលទៅក្នុងស្រុកហាន់តុង ហើយ**ទៀវអ្លួយ**និយាយប្រាប់**ទៀវឡូ**ថា ខូចបន្ទាយមុខគយទាំងឆ្វេងស្ដាំនោះ ព្រោះ**អៀវឌុង**, **អៀវហៀម**ធ្វេសប្រហែសណាស់ ខ្ញុំបាទឃើញសឹកលើស

កម្លាំងនឹងទប់ពុំឈ្នះ បានជាលះបង់ចោលបន្ទាយរត់ចូលមកជម្រាបការឲ្យលោកជ្រាប។

**ទៀវឡ**ឮដូច្នោះខឹងណាស់ បង្គាប់ឲ្យចាប់ខ្លួន**អៀវហៀម**ទៅសម្លាប់ចេញ **អៀវហៀម**ឆ្លើយដោះសាថា ទោសខ្ញុំបាទនោះខុសណាស់មែនហើយ តែថាមានទម្ងន់មិនស្មើនឹង**អៀវងុង**ទេ ព្រោះដើមហេតុ**អៀវងុង**លើកទ័ពទៅវាយបន្ទាយ**ចូឆូ**។ ខ្ញុំបាទបាននិយាយហាមឃាត់ **អៀវងុង**មិនស្ដាប់ ចេះតែទទូចលើកទៅទាល់តែសត្រូវកន្លងចូលមកដុតបន្ទាយឆេះអស់ ខ្ញុំបាទឃើញពន្លឺភ្លើងឆេះឡើងសន្ធឹកណាស់ ក៏លើកទាហានទៅជួយ លុះថយមក ទាហាន**ចូឆូ**ក៏លើកគ្នាមកវាយដណ្ដើមយកបន្ទាយបាន ដែលទោសខ្ញុំបាទខុសនោះ ស្រេចនៅលោកមេត្តាទុកជីវិតចុះ នឹងបានធ្វើការកែខ្លួនម្ដងទៀត បើក្រោយៗខ្ញុំបាទលើកទ័ពទៅហើយ បែរជាចាញ់ត្រឡប់វិញដូចគ្នានេះ សូមឲ្យលោកសម្លាប់ចុះ។ **ទៀវឡ**ក៏ព្រមអនុញ្ញាតលើកទោស ហើយកេណ្ឌទាហានពីរម៉ឺនប្រគល់ឲ្យ**អៀវហៀម** លើកទៅវាយកងទ័ព**ចូឆូ**ដណ្ដើមយកបន្ទាយនោះវិញ។ **អៀវហៀម**ក៏នាំទាហានទាំងពីរម៉ឺននោះលើកចេញទៅដល់ស្រុកឡាំតេង ហើយបោះទ័ពតាំងបន្ទាយនៅទីនោះ។

**ចូឆូ**ក៏ប្រើ**ហែហ៊ូអៀន**នាំទាហានពីរពាន់នាក់ជាកងមុខ ហើយចេញពីបន្ទាយធំទៅមុន មានបម្រើសេះស៊ើបដំណឹងត្រឡប់ទៅប្រាប់**ហែហ៊ូអៀន**ថា ឥឡូវនេះ **អៀវហៀម**លើកកងទ័ពមកតាំងបន្ទាយដែនស្រុកឡាំតេងច្រើនណាស់។ **ហែហ៊ូអៀន**ឮដូច្នោះ ក៏ឲ្យបោះទ័ពតាំងបន្ទាយនៅទីនោះ **អៀវហៀម**ដឹងថា **ហែហ៊ូអៀន**លើកទ័ពហ្លួងចូលមកតាំងបន្ទាយនៅដូច្នោះ ក៏ប្រើ**ឈៀងគី**លើកទាហានចេញទៅនឹងច្បាំងតយុទ្ធនឹង**ហែហ៊ូអៀន** ៗឃើញដូច្នោះ ក៏លើកទាហានចេញទៅត្រៀមចាំនៅមុខបន្ទាយ ហើយបរសេះចូលទៅប្រយុទ្ធគ្នានឹង**ឈៀងគី**បានបីភ្លែង **ហែហ៊ូអៀន**ក៏យកដាវកាប់ត្រូវ**ឈៀងគី**ដាច់ពាក់កណ្ដាលខ្លួនជាពីរកំណាត់ស្លាប់។

**អៀវហៀម**ឃើញ**ឈៀងគី**ស្លាប់ក៏ខឹងណាស់ លោតឡើងសេះចេញទៅតស៊ូនឹង**ហែហ៊ួអៀន**បានសាមសិបភ្លែង នៅមិនទាន់ចាញ់ឈ្នះ **ហែហ៊ួអៀន**ធ្វើជាញាក់សេះថយរត់ទៅក្រោយ **អៀវហៀម**មិនដឹងកលក៏ដេញបណ្ដោយតាមទៅ **ហែហ៊ួអៀន**ញាក់សេះត្រឡប់មក កាប់ត្រូវ**អៀវហៀម**ធ្លាក់ពីលើសេះស្លាប់ ទាហានទាំងពួងក៏បាក់បែកខ្ចាត់ខ្ចាយអស់ទៅ។

មានបម្រើសេះទៅប្រាប់**ចូឆូ**ថា **ហែហ៊ួអៀន**មានជ័យជម្នះហើយ **ចូឆូ**ក៏មានចិត្តសោមនស្សណាស់ ទើបលើកទ័ពហ្លួងកន្លងចូលទៅតាំងបន្ទាយនៅជិតស្រុកហាន់តុង។ **ទៀវឡូ**ដឹងដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា **អៀវហៀម**ក៏ដល់នូវសេចក្ដីស្លាប់ទៅហើយ ឥឡូវ**ចូឆូ**ក៏លើកទ័ពហ្លួងកន្លងចូលមកជិតស្រុកយើងណាស់ អ្នកទាំងអស់គ្នានឹងជួយរិះគិតប្រការម្ដេច? **ងៀមផា**ថា **ម៉ាឈៀវ**នោះប្រែចិត្តចេញពីលោកហើយ នៅតែ**បាំងតេក** ព្រោះឈឺទៅផងមិនបាន ឯ**បាំងតេក**នោះមានថ្វីដៃខ្លាំងពូកែណាស់ ទាំងចិត្តក៏សុចរិតពិតត្រង់ ខ្ញុំបាទបានឮសម្ដីនិយាយសរសើរគុណលោកថា កាល**ម៉ាឈៀវ**រត់បែកពី**ចូឆូ**មកទីពឹងបុណ្យលោកនៅទីនោះ **បាំងតេក**ក៏បានសេចក្ដីសុខ ដោយសារគិតធ្វើការតបស្នងសងគុណលោកមិនដាច់ពីមាត់ បើដូច្នេះគួរតែលោកឲ្យហៅខ្លួន**បាំងតេក**មកប្រើការ ឲ្យលើកពលយោធាចេញទៅតនឹង**ចូឆូ**ទើបបាន។

**ទៀវឡូ**ឮដូច្នោះក៏មានចិត្តសោមនស្សណាស់ ឲ្យបម្រើទៅហៅ**បាំងតេក**មកឲ្យបំណាច់រង្វាន់ជាច្រើន ហើយថា យើងត្រូវឲ្យអ្នកចេញទៅច្បាំងនឹងទាហាន**ចូឆូ**បានទេ? **បាំងតេក**ឆ្លើយថា ខ្ញុំបាទនឹងសុំធ្វើការតបស្នងសងគុណលោកត្រាតែអស់ជីវិតចុះ។ វេលានោះ **ទៀវឡូ**ក៏ចាត់ទាហានឲ្យ**បាំងតេក**មួយម៉ឺន។ **បាំងតេក**ក៏លា**ទៀវឡូ**នាំទាហានចេញទៅ លុះទៅដល់ប្រទល់ទ័ពគ្នា ក៏ឲ្យតាំងបន្ទាយជាមាំមួន ហើយ**បាំងតេក**ក៏ឡើងសេះនាំទាហានទៅដល់មុខបន្ទាយ**ចូឆូ** ហើយស្រែកចំអកបញ្ឈឺចិត្តឲ្យ**ចូឆូ**ជាពាក្យអាស្រូវភាសផ្សេងៗ។ **ចូឆូ**បានឮដូច្នោះក៏សួរទាហានថា

ទាហាន**ទៀវឡូ**នោះឈ្មោះអ្វី? មានទាហានម្នាក់ស្គាល់ច្បាស់ប្រាប់ថា ឈ្មោះ**ប៉ាំងតេក**។

**ចូឆូ**ឮដូច្នោះ ក៏នឹករឭកឡើងបានថា **ប៉ាំងតេក**នោះមានថ្វីដៃខ្លាំងពូកែណាស់ គឺជាទាហាន**ម៉ាឈៀវ** កាលគ្រាច្បាំងគ្នានៅតំបន់ស្ទឹងអ៊ុយហោ ដែលមកនៅនឹង**ទៀវឡូ**នេះព្រោះសេចក្ដីប្រចាំចិត្ត ឯ**ម៉ាឈៀវ**ក៏រត់ចូលទៅនៅនឹង**ឡៅពី**ឯស្រុកសែឈ្លួនទៅហើយ យើងត្រូវរិះគិតយកខ្លួន**ប៉ាំងតេក**មកទុកធ្វើការជាមួយផង។ ថាហើយក៏បង្គាប់ទាហានទាំងពួងថា **ប៉ាំងតេក**នោះមានកម្លាំង និងថ្វីដៃខ្លាំងពូកែណាស់ បើអ្នករាល់គ្នានឹងចេញទៅច្បាំងនោះ ទោះបី**ប៉ាំងតេក**នោះនឹងចាញ់ប្រៀបយ៉ាងណា ក៏កុំធ្វើអន្តរាយឲ្យដល់ក្ស័យជីវិតឡើយ ចូរប្រយ័ត្នគិតតដៃឲ្យល្មមតែ**ប៉ាំងតេក**ថយកម្លាំងចុះ ហើយនឹងរកឧបាយចាប់ខ្លួនឲ្យបានទាំងរស់ នាំមកឲ្យយើងឲ្យបាន។

**ទៀវខាប់**ទទួលប្រសាសន៍ហើយ ក៏ឡើងសេះចេញទៅច្បាំងនឹង**ប៉ាំងតេក**បានប្រាំភ្លែង **ទៀវខាប់**ក៏ថយរត់ចូលបន្ទាយ **ហែហ៊ួអៀន**ក៏បរសេះចូលច្បាំងនឹង**ប៉ាំងតេក**បានប្រាំពីរភ្លែង **ហែហ៊ួអៀន**ក៏ថយសេះរត់ត្រឡប់មកក្រោយវិញ។ **ខៅធូ**ក៏បរសេះរំដារចេញទៅច្បាំងនឹង**ប៉ាំងតេក**បានហាសិបភ្លែង **ខៅធូ**ក៏ញាក់សេះថយត្រឡប់មកវិញ។ **ប៉ាំងតេក**បានជ័យជម្នះអស់ពួកទាហាន**ចូឆូ**ទាំងបួននាយ ហើយក៏នាំទាហានចូលទៅក្នុងបន្ទាយវិញ។

ឯនាយទាហាន**ចូឆូ**ទាំងបួននាក់ក៏នាំគ្នាស្ញើថា **ប៉ាំងតេក**នោះចំណានក្នុងការសង្គ្រាមណាស់។ **ចូឆូ**ក៏មានសេចក្ដីត្រេកអរ ទើបប្រឹក្សាប្រាថ្នានឹងចង់ដឹងគំនិតនាយទាហានទាំងបួននាក់នោះ នឹងគិតប្រការម្ដេច ទើបនឹងយកខ្លួន**ប៉ាំងតេក**ឲ្យមកនៅនឹងយើងបាន? **កាសៀង**ឆ្លើយថា ខ្ញុំបានដឹងថា **ទៀវឡូ**នោះមានទីប្រឹក្សាម្នាក់ឈ្មោះ**អៀវសុង** ឯ**អៀវសុង**នោះជាមនុស្សលោភទ្រព្យសម្បត្តិណាស់ ប្រាថ្នាតែនឹងរកទ្រព្យយកមកទុកជាប្រយោជន៍ខ្លួន សុំឲ្យលោកគិតចាត់ចែងរករបស់ទ្រព្យឲ្យនាំ

យកទៅឲ្យ**អៀវសុង** ឲ្យ**អៀវសុង**គិតញុះញង់**ទៀវឡូ**ថា **បាំងតេក**នោះមិនមានចិត្តនឹងគិតច្បាំងទេ គិតតែនឹងប្រែចិត្តក្បត់ពី**ទៀវឡូ** ៗក៏គង់នឹងមានសេចក្តីសង្ស័យនឹង**បាំងតេក**រួចសឹមលោកគិតតទៅគង់នឹងបានខ្លួន**បាំងតេក**ដោយងាយ។

**ចូឆូ**ថា អ្នកគិតដូច្នេះត្រូវណាស់ តែយើងនឹងឲ្យនរណានាំរបស់ទាំងនោះចូលទៅឲ្យ**អៀវសុង**ក្នុងស្រុកហាន់តុងនោះបាន? **កាសៀង**ថា ពេលព្រឹកស្អែកបើឃើញ**បាំងតេក**ចេញមកច្បាំង ឲ្យលោកធ្វើជាចោលបន្ទាយរត់ចេញទៅ **បាំងតេក**ក៏គង់នឹងចូលទៅក្នុងបន្ទាយនោះ ហើយលោកត្រូវរកមនុស្សណាដែលចេះនិយាយស្ដីមាំមួនឲ្យយកមាសប្រាក់មកផែជាផែនបន្ទះ ឲ្យបម្រើលាក់ទុកក្នុងដៃអាវហើយបង្គាប់ថាបើទាហាន**បាំងតេក**បែកត្រឡប់ចូលទៅក្នុងស្រុកវិញ ក៏ឲ្យបម្រើនោះបន្លំចូលទៅជាមួយ នឹងបានយករបស់ទាំងនោះទៅឲ្យ**អៀវសុង** ដល់ពេលយប់កាលណាសឹមលោកលើកទាហានចូលប្លន់បន្ទាយ **បាំងតេក**ក៏គង់នឹងបែកធ្លាយរត់ចូលទៅក្នុងស្រុកវិញ។ **ចូឆូ**យល់ឃើញត្រូវផងក៏ចាត់ទាហានដែលមានប្រាជ្ញាម្នាក់ឲ្យធ្វើតាមពាក្យ**កាសៀង** ហើយឲ្យ**ស៊ីឡុង**និង**ខៅធូ**ជាកងបញ្ចោត ឲ្យ**ទៀវខាប់**និង**ហែហ៊ូអៀន**លើកទាហានទៅពួនបង្កប់នៅសងខាងផ្លូវ។ នាយទាហានទាំងបួននាក់ ក៏ធ្វើតាមពាក្យ**ចូឆូ**បង្គាប់គ្រប់ប្រការ។

ឯ**បាំងតេក**នោះ លុះឃើញ**ខៅធូ**និង**ស៊ីឡុង**លើកទាហានចូលទៅ ក៏នាំទាហានចូលប្រយុទ្ធនឹង**ខៅធូ**, **ស៊ីឡុង**ក្នុងកណ្ដាលទ័ព។ **ស៊ីឡុង**និង**ខៅធូ**ក៏ធ្វើជាថយត្រឡប់ទៅវិញ មិនបានចូលបន្ទាយ។ **បាំងតេក**ក៏លើកពលពារទម្លាយតាមទៅដល់មុខបន្ទាយ**ចូឆូ** ៗក៏នាំទាហានរត់ចេញពីបន្ទាយ **បាំងតេក**ក៏លើកទាហានចូលទៅក្នុងបន្ទាយ រើសបានគ្រឿងសាស្ត្រាវុធនិងស្បៀងអាហារជាច្រើនណាស់ **បាំងតេក**មានចិត្តកំរើបឲ្យតាំងតុរៀបទុក លុះពេលកណ្ដាលយប់ក៏នាំទាហានទាំងពួងស៊ីផឹកនៅក្នុងបន្ទាយទ្រហឹងអឺងកង។

ឯ**ស៊ីឡុង**និង**ខៅធូ**ក៏នាំទាហានចូលពីខាងទិសឯជើង **ហែហ្សឺអៀន**នាំទាហានចូលពីទិសឯកើត **ទៀវខាប់**នាំទាហានចូលពីទិសខាងជើង ជាបីប៉ែក ទុកតែទិសឯត្បូងបើកចំហព្រោះជាផ្លូវនឹងចូលទៅឯស្រុកហាន់តុង។ លុះបានឮស្គរផាវជាសម្គាល់កាលណា ក៏នាំគ្នាដុតបន្ទាយឲ្យឆេះឡើងជាបីអន្លើ ហើយបរពលចូលលុកក្នុងបន្ទាយនោះ។

ខណៈនោះ **បាំងតេក**តទល់ពុំឈ្នះ ក៏នាំទាហានរត់ចេញទៅតាមទ្វារទិសខាងត្បូងចូលទៅក្នុងស្រុកហាន់តុងវិញ។ ទាហាន**ចូឆ្វូ**ម្នាក់ដែលបន្លំនៅក្នុងបន្ទាយនោះក៏ចូលតាមទៅដល់ស្រុកហាន់តុងផង។ លុះទៅដល់ហើយ ក៏ទៅរក**អៀវសុង**យកគ្រឿងមាសប្រាក់នោះទៅគំនាប់ជម្រាបថា ត្បិត**ចូឆ្វូ**ជាទី**វុយកុង**ដឹងដំណឹងថា លោកមានតម្រិះប្រាជ្ញាជាទីអធ្យាស្រ័យគ្នានឹង**ទៀវឡូ** សុំឲ្យលោកស្មោះសរជួយរិះគិតញុះញង់ឲ្យ**ទៀវឡូ**មានសេចក្ដីសង្ស័យនឹង**បាំងតេក** ឯផ្លូវមេត្រីរបស់លោកនិង**វុយកុង**នោះ គង់នឹងមានតទៅមុខទៀត។

**អៀវសុង**ឃើញមាសនិងប្រាក់ ក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណណាស់ ប្រាប់មកទាហាននោះថា អ្នកឯងវិលទៅប្រាប់**ចូឆ្វូ**ថា ការដែលប្រាថ្នាមកទាំងប៉ុន្មានយើងនឹងជួយរិះគិតឲ្យបានដូចចិត្តទាំងអស់។ ទាហាននោះក៏លាទៅប្រាប់**ចូឆ្វូ**គ្រប់ប្រការ។ **ចូឆ្វូ**ដឹងដូច្នោះក៏អរណាស់។

ឯ**អៀវសុង**ក៏ចូលទៅញុះញង់**ទៀវឡូ**ថា **បាំងតេក**នោះចេញទៅវាយបន្ទាយ**ចូឆ្វូ**បានរបស់ទ្រព្យច្រើនណាស់ លុះនឹងខំនៅច្បាំងនឹង**ចូឆ្វូ**តទៅ ខ្លាចក្រែងលោកដឹងការណ៍ថាបានរបស់ទ្រព្យទុក **បាំងតេក**ក៏ក្លែងធ្វើជាចោលបន្ទាយបែកធ្លាយរត់ត្រឡប់មកវិញ ប្រាថ្នាតែនឹងយករបស់នោះមិញ មកលាក់ទុកជាប្រយោជន៍ខ្លួន។

ខណៈនោះ ទទួល**បាំងតេក**ទៅគំនាប់**ទៀវឡូ** ហើយពណ៌នាសេចក្ដីដែលបានធ្វើការបែករត់មកឲ្យ**ទៀវឡូ**ស្ដាប់គ្រប់ប្រការ។ **ទៀវឡូ**បានឮហើយ ក៏ពិគ្រោះមើលឃើញសមប្រកបនឹងពាក្យ**អៀវសុង**និយាយ ក៏មានសេចក្ដីខឹងខ្លាំងណាស់ បង្គាប់

ទាហានឲ្យយកខ្លួន**បាំងតេក**ទៅសម្លាប់ចេញ។ **ងៀមផៅ**ចូលទៅអង្វរសូមទោស **ទៀវឡូ**ក៏និយាយនឹង**បាំងតេក**ថា យើងព្រមលើកទោសខ្លួនតាម**ងៀមផៅ**សុំម្តងចុះ តែពេលព្រឹកស្អែកនេះត្រូវនាំទាហានចេញទៅច្បាំងទៀត បើគ្មានជ័យជម្នះលះបង់បន្ទាយរត់ចូលមកដូចម្តងនេះយើងនឹងឲ្យកាត់ក្បាលខ្លួនចេញជាប្រាកដ។ **បាំងតេក**ស្តាប់ហើយក៏មានសេចក្តីត្រេកអរណាស់ ទទួលបង្គាប់**ទៀវឡូ**ហើយលាថយចេញទៅចាត់ចែងទាហានត្រៀមបម្រុងការ។

ឯ**ចូឆូ**នោះ លុះដល់ពេលយប់ស្ងាត់ ក៏ចាត់ប្រើ**ទៀវខាប់**និង**ហែហ៊្សអៀន**លើកទាហានទៅពួនបង្កប់នៅលើកកំពូលភ្នំទាំងសងខាង ហើយឲ្យទាហានឡើងទៅជីករណ្តៅមួយជ្រៅ ហើយយកដីគ្របពីលើមាត់រណ្តៅ លុញឲ្យស្អាតមិនឲ្យក្រឡេកយល់ លុះដល់ពេលទៀបភ្លឺស្រាងក៏ចាត់ទាហានឲ្យទៅទម្លាយកំពែងស្រុក ឯខ្លួន**ចូឆូ**និងទាហានប្រមាណដប់បួន ដប់ប្រាំនាក់ ក៏ឡើងទៅលើកកំពូលភ្នំដែលជីករណ្តៅទុកនោះ។

លុះព្រឹកឡើង **បាំងតេក**លើកទាហានបើកទ្វារស្រុកចេញទៅ តាំងតែចោមរោមវាយទម្លាយកងទ័ព**ចូឆូ**។ **ខៅចូ**ឃើញដូច្នោះក៏បរសេះចូលច្បាំងនឹង**បាំងតេក**ជាប់ដៃគ្នាទៅវិញទៅមក ហើយធ្វើជាថយរត់ទៅក្រោយ **បាំងតេក**ឃើញបានចំណាច់ក៏ប្រញាប់បរសេះដេញតាមទៅដល់កំពូលភ្នំ។

**ចូឆូ**នៅលើកំពូលភ្នំខ្ពស់ត្រដែត ឃើញ**បាំងតេក**ដេញ**ខៅចូ**ឡើងមក ក៏ស្រែកស្តីទៅ**បាំងតេក**ថា ស្រុកហាន់តុងបីដូចជានៅក្នុងកណ្តាប់ដៃយើងអស់ហើយ ហើយ**ទៀវឡូ**នោះបីដូចកូនមាន់ យើងនឹងចូលកាច់ទម្លាយឲ្យបានឥឡូវនេះ បើស្រុកហាន់តុងបានយើងហើយ ខ្លួនអ្នកឯងក៏គង់នឹងស្លាប់អសារឥតការ ហេតុនេះអ្នកគួរតែមានប្រាជ្ញាចូលមកលន់តួចំណុះយើងដោយស្រួលបួលទៅចុះ ទើបនឹងរួចពីសេចក្តីស្លាប់។

**បាំងតេក**បានឮដូច្នោះក៏គិតថា បើប្រសិនជាយើងនឹងចាប់ទាហានដល់រាប់រយនាក់នាំទៅឲ្យ**ទៀវឡូ** ក៏មិនស្មើនឹងចាប់ខ្លួន**ចូវឆូ**តែមួយនោះឡើយ គិតហើយក៏ញាក់សេះឡើងទៅកំពូលភ្នំដោយមិនដឹងកលឧបាយ ទទួលឮស្គរផាវ សេះនោះក៏ស្ទុះទៅចំមាត់រណ្ដៅ។ **បាំងតេក**ក៏ធ្លាក់ពីលើសេះចុះទៅក្នុងរណ្ដៅ។ ពួកទាហាន**ចូវឆូ**ក៏ស្ទុះស្រចូលទៅព័ទ្ធចាប់ខ្លួន**បាំងតេក** ចងបានហើយនាំទៅឲ្យ**ចូវឆូ**។

**ចូវឆូ**ឃើញដូច្នោះ ក៏ក្លែងធ្វើជាឃាត់ហាមទាហានទាំងអស់នោះកុំឲ្យវីវរឡើយ។ **ចូវឆូ**ចុះទៅពីលើសេះ ស្រាយចំណង**បាំងតេក**ចេញអស់ ហើយសួរថា ខ្លួនអ្នកនឹងព្រមនៅធ្វើការជាមួយនឹងយើងតទៅឬ? យើងនឹងទុកអាយុជីវិត។ **បាំងតេក**ក៏នឹកគិតតែក្នុងចិត្តថា ចិត្ត**ចូវឆូ**នេះមិនមានអាឃាតព្យាបាទនឹងយើងសោះ ឯ**ទៀវឡូ**នោះជាមនុស្សចិត្តស្រាលត្រចៀកស្រាល គ្មានពិគ្រោះពិចារណាឲ្យដឹងការណ៍ច្បាស់ប្រាកដ រកឲ្យឃើញខុសនិងត្រូវសោះ។ គិតហើយក៏ឆ្លើយថា ខ្លួនខ្ញុំបាទជាសត្រូវខ្លាំងនឹងលោក ៗចាប់ខ្លួនបានមិនសម្លាប់នោះ ព្រះគុណជាទម្ងន់មិនមានទីបំផុត ខ្ញុំសូមផ្ញើអាយុជីវិតនឹងលោក សូមចូលធ្វើរាជការតបស្នងព្រះតេជព្រះគុណ ត្រាតែអស់ជីវិត។

**ចូវឆូ**បានស្ដាប់ហើយក៏មានអំណរណាស់ ទើបរកសេះមួយមកឲ្យ**បាំងតេក**ជិះ ហើយក៏នាំចូលទៅក្នុងបន្ទាយ រួចឲ្យរៀបតុលៀងអាហារ ហើយឲ្យបំណាច់ប្រាក់មាសដល់**បាំងតេក**ជាច្រើន។ លុះវេលាព្រឹកឡើង **ចូវឆូ**ក៏ប្រើទាហានឲ្យយកជើងជណ្ដើរនិងចង្កៀងទៅដាក់ភ្ជាប់នឹងកំពែងស្រុក ឯទាហានដែលនៅលើសើនបន្ទាយក៏បាញ់ធ្នូចម្រុះចូលមក ហើយចោលទម្លាក់ដុំថ្មមកត្រូវទាហាន**ចូវឆូ**របួសពិការស្លាប់ជាច្រើន ពួកទាហាន**ចូវឆូ**ក៏យកស្លាន់ធ័រ និងរំសេវមកលាយគ្នាដាក់ជាឈ្នួនក្នុងដុំដី ហើយចោលចូលទៅលើដំបូលផ្ទះ ឈ្នួននោះក៏ឆេះរាលដាលគ្រប់ដំបូលផ្ទះរបស់អ្នកស្រុកពេញពាសឡើង។ ពួកអ្នកស្រុកទាំងអស់គ្នាក៏នាំគ្នាលត់បាន។

**ទៀវឡូ**ដឹងថា **បាំងតេក**ប្រែចិត្តក្បត់ចូលទៅខាង**ចូឆ្វូ**ហើយ ក៏ប្រឹក្សានឹងទាហានទាំងពួងថា វេលានេះ**បាំងតេក**ចេញជាក្បត់នឹងយើងទៅនៅខាង**ចូឆ្វូ**ហើយ **ចូឆ្វូ**ក៏លើកទ័ពមកដល់ជើងកំផែងទៀត តើអ្នករាល់គ្នានឹងជួយគិតប្រការម្ដេច? **ទៀវអ្វួយ**ឆ្លើយថា ការដែលនឹងការពារស្រុកទុកឲ្យបាននោះមុខជាមិនកើតទេ គួរតែដុតបំផ្លាញភូមិស្រុកទាំងនេះឲ្យវិនាសអស់ចេញ កុំឲ្យ**ចូឆ្វូ**បានរបស់ទ្រព្យអ្វីឡើយ ហើយខ្លួនលោកក៏ត្រូវនាំគ្រប់គ្រួ និងពលទាហានរត់ទៅនៅស្រុកប៉ាតុងវិញ។ **អៀវសុង**ឆ្លើយថា ដែលនឹងធ្វើតាមពាក្យ**ទៀវអ្វួយ**នោះមិនគួរទេ បើប្រសិនជារត់ចេញទៅនៅស្រុកប៉ាតុង ក៏គង់មិនរួចពីដៃ**ចូឆ្វូ**សុំឲ្យលោកចេញទៅលន់តួសុំចំណុំចុះចូលដោយល្អទៅវិញស្រួលជាង។

**ទៀវឡូ**បានស្ដាប់**ទៀវអ្វួយ**និង**អៀវសុង**ថាខុសដំណើរសេចក្ដីគ្នាដូច្នោះ ក៏មិនអស់សង្ស័យ មិនដឹងនឹងយកសម្ដីខាងណា ហើយថា កាលពីដើមយើងគិតនឹងតាំងខ្លួននោះប្រាថ្នានឹងជួយទំនុកបម្រុងអាណាប្រជានុរាស្ត្រឲ្យបានសេចក្ដីសុខ។ ឥឡូវនេះមានកម្មជាហេតុឲ្យទុក្ខមក បណ្ដាលឲ្យទាល់ខ្លួនដល់ទីនៅហើយ បើនឹងដុតបំផ្លាញទ្រព្យរបស់និងស្បៀងអាហារសម្រាប់ស្រុកចេញមិនគួរ ៗតែនាំគ្នារត់ចេញទៅផុតអំពីភ័យអន្តរាយចុះ។ លុះដល់ពេលយាមពីរប្លាយ **ទៀវឡូ**ក៏នាំគ្រប់គ្រួនិងស្ម័គ្របក្សពួករត់ចេញតាមផ្លូវទ្វារទិសខាងត្បូង តម្រង់ទៅស្រុកប៉ាតុង។ **ចូឆ្វូ**ដឹងដូច្នោះ ក៏មិនបានឲ្យទាហានដេញតាម**ទៀវឡូ**នោះទេ។ លុះព្រឹកឡើង **ចូឆ្វូ**ក៏នាំទាហានទាំងពួងចូលទៅក្នុងស្រុកហាន់តុង **ចូឆ្វូ**ឃើញឃ្លាំងនិងជង្រុកចាក់សោជាប់ ក៏បង្គាប់ទាហានឲ្យពុះទម្លាយទ្វារចូលទៅ ឃើញរបស់ទ្រព្យនៅច្រើនណាស់។ **ចូឆ្វូ**ក៏បង្កើតចិត្តសង្វេគអាណិតគិតថា **ទៀវឡូ**នោះជាមនុស្សទៀងត្រង់ មិនបានធ្វើអន្តរាយរបស់ទ្រព្យក្នុងស្រុកឲ្យវិនាស រត់យកតែខ្លួនទៅពួនក្នុងទីដទៃ សមដូចពាក្យបុរាណពោលទុក។ **ចូឆ្វូ**ក៏តែងជាសំបុត្រមានទំនុកទំនៀមតាមធម៌ល្អ បញ្ចុះបញ្ចូល

ចិត្ត**ទៀវឡូ**ឲ្យវិលមកចំណុះចុះចូលតាមស្រួលទៅចុះ។ **ចូវឆ្វ**ថា មិនបានប្រកាន់ទោសពៃរ៍អ្វីទេ បម្រើក៏កាន់សំបុត្រនោះទៅឲ្យ**ទៀវឡូ**ឯស្រុកប៉ាតុង។

**ទៀវឡូ**បានយល់សេចក្ដីក្នុងសំបុត្រដូច្នោះ ក៏ចេះតែគិតខ្លាចក្រែង**ចូវឆ្វ**ធ្វើកលឧបាយបញ្ឆោត ទើបប្រឹក្សានឹង**ទៀវអ្លួយ**ជាប្អូនតាមសេចក្ដីសំបុត្រ**ចូវឆ្វ**នោះ។ **ទៀវអ្លួយ**ថា ឯចិត្ត**ចូវឆ្វ**នោះប្រកបដោយកលឧបាយបញ្ឆោតច្រើនប្រការណាស់ ដែលនឹងចូលទៅលន់តួនោះ ខ្ញុំបាទមិនយល់ផងទេ សុំឲ្យគិតតែរក្សាស្រុកប៉ាតុងទុកឲ្យគង់ទៅចុះ បើ**ចូវឆ្វ**លើកទ័ពតាមមកនឹងបានតទល់ច្បាំងគ្នាជាមាំមួន។ **ទៀវឡូ**ក៏ទទួលស្ដាប់ពាក្យ**ទៀវអ្លួយ**ជាប្អូន។ **អៀវសុង**ក៏លបធ្វើសំបុត្រស្ងាត់ ប្រើបម្រើនាំទៅឲ្យ**ចូវឆ្វ**ឯស្រុកហាន់តុង។

**ចូវឆ្វ**ទទួលសំបុត្រនោះទៅមើល ឃើញសេចក្ដីថា ខ្ញុំបាទ**អៀវសុង**សូមគំនាប់មកដល់**វុយកុង**បានជ្រាប ដែល**ទៀវឡូ**រឹងទទឹងមិនព្រមចូលមកលន់តួលោកនោះ ព្រោះ**ទៀវអ្លួយ**ជាប្អូននាំរឹងទទឹង សូមឲ្យលោកនាំទ័ពទៅវាយស្រុកប៉ាតុងចុះ ខ្ញុំបាទនឹងទទួលយកកលសឹកខាងក្នុង។ **ចូវឆ្វ**ឃើញសេចក្ដីសំបុត្រដូច្នោះក៏មានអំណរណាស់ ទើបចាត់ចែងកងទ័ពលើកទៅតាំងនៅជិតស្រុកប៉ាតុង។

ឯ**ទៀវឡូ**លុះដឹងថា **ចូវឆ្វ**លើកទ័ពទៅដល់ក៏ប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវ**ចូវឆ្វ**លើកទ័ពមក យើងនឹងគិតការពារប្រការម្ដេច? **ទៀវអ្លួយ**ថា ខ្ញុំបាទនឹងសុំអាសាលើកទ័ពចេញទៅច្បាំងនឹង**ចូវឆ្វ** ហើយ**ទៀវអ្លួយ**ក៏ចាត់ចែងទាហានលើកចេញទៅ។

**ចូវឆ្វ**ឃើញដូច្នោះ ក៏ប្រើ**ខៅធូ**ចេញទៅតនឹង**ទៀវអ្លួយ**បានប្រាំភ្លែង **ខៅធូ**ក៏យកលំពែងចាក់ត្រូវ**ទៀវអ្លួយ**ធ្លាក់ពីលើសេះស្លាប់។ ទាហានទាំងពួងក៏បែករត់ទៅប្រាប់**ទៀវឡូ** ៗដឹងដូច្នោះក៏ភ័យស្លុតស្មារតី ទើបកេណ្ឌទាហានឡើងរក្សាសើនបន្ទាយជាមាំមួន។ **អៀវសុង**ឃើញដូច្នោះទើបក្លែងភេទនិយាយនឹង**ទៀវឡូ**ថា ដែលនឹងស្ងៀមនៅដូច្នេះមិនស្រួលទេ ព្រោះសត្រូវមកតាំងនៅព័ទ្ធជុំវិញស្រុកហើយ ខ្ញុំ

បាទនឹងសុំរក្សាស្រុកទុក ឯខ្លួនលោកត្រូវចេញទៅធ្វើសង្គ្រាមនឹង**ចូឆ្វ**ទើបសមគួរជាជាតិទាហាន ទាំងឈ្មោះសំឡេងលោកក៏នឹងល្បីតទៅមុខវែងឆ្ងាយ។

**ទៀវឡូ**មិនដឹងកលឧបាយ ក៏រៀបទាហានលើកចេញ ឯទាហានដែលចេញទៅជាមួយនឹង**ទៀវឡូ**នោះ ក៏ត្រឡប់វិលទៅនៅរក្សាគ្រប់គ្រួក្នុងស្រុកវិញទាំងអស់។ **ទៀវឡូ**ឃើញដូច្នោះក៏រឹតតែភ័យណាស់ ទើបញាក់សេះបែរត្រឡប់រត់ទៅដល់ជើងកំផែងស្រុក **ចូឆ្វ**ឃើញដូច្នោះក៏លើកទាហានដេញតាមទៅ។

**អៀវសុង**នៅលើសើនបន្ទាយ ឃើញ**ទៀវឡូ**រត់ត្រឡប់មកក៏ឲ្យទាហានបិទទ្វារស្រុកជិតនឹងចូលពុំបាន **ចូឆ្វ**ឃើញក៏ស្រែកទៅ**ទៀវឡូ**ថា ខ្លួនអ្នកឯងនឹងដល់នូវសេចក្តីស្លាប់គ្រានេះហើយ បើប្រសិនជាចូលមកលន់តួចុះចូលយើងតាមសុភាពយើងក៏ទុកជីវិតឲ្យរស់នៅតទៅ។ **ទៀវឡូ**ឮដូច្នោះក៏លោតចុះពីលើសេះបោះអាវុធចេញពីដៃ ហើយដើរចូលទៅគំនាប់**ចូឆ្វ** ៗក៏មានចិត្តអាណិតអាសូរណាស់ ទើបនាំ**ទៀវឡូ**ចូលទៅក្នុងស្រុកប៉ាតុង ហើយតាំង**ទៀវឡូ**ឲ្យធ្វើជាចៅហ្វាយស្រុកប៉ាតុង បណ្តាទាហានរបស់**ទៀវឡូ**នោះ**ចូឆ្វ**ក៏តាំងឲ្យធ្វើការធំតូច តាមគុណបំណាច់។

**ចូឆ្វ**ប្រាបប្រាមអាណាខេត្ត ដែលឡើងស្តាប់បង្គាប់ស្រុកហាន់តុងនោះរាបទាបទាំងអស់ហើយ ក៏ចែកបំណាច់រង្វាន់ពលទាហានតាមសមគួរ ហើយឲ្យគេហៅខ្លួន**អៀវសុង**ចូលទៅប្រាប់ថា ខ្លួនអ្នកឯងជាមនុស្សលោភសក្ការៈអកតញ្ញូនិរគុណពេកណាស់ ឃើញតែត្រឹមរបស់ទ្រព្យជាមុខ គួរឬមកប្រែចិត្តក្បត់**ទៀវឡូ**ដែលមានគុណលើខ្លួន បើយើងនឹងចិញ្ចឹមរក្សាខ្លួនជាពួកផងតទៅមុខទៀត ខ្លួនក៏គង់នឹងប្រែចិត្តគិតប្រទូសរ៉ាយដល់យើង ទៅចូលខាងសត្រូវដូចជាគ្រាឥឡូវនេះដែរ។ ថាហើយក៏ប្រើទាហានចាប់យកខ្លួន**អៀវសុង**ទៅចងផ្គាង កាត់ក្បាលសម្លាប់បង់ ហើយយកក្បាលដោតផ្គាលមិនឲ្យអ្នកទាំងពួងយកតម្រាប់តាម។ កាល**ចូឆ្វ**ប្រាបប្រាមស្រុកហាន់តុងនិងអាណាខេត្តដែលឡើងទាំងប៉ុន្មាននោះ មនុស្សទាំងពួងក៏សន្មតហៅទីដែននោះថាតាំងឈ្នួន គឺជាផ្លូវដាច់ស្រយាលខាងទិសបូព៌។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៥៦

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**សុម៉ាអ៊ី**ពន្យល់ឲ្យ**ចូឆូ**លើកទ័ពទៅវាយយកស្រុកសែឈួន **ចូឆូ**មិនព្រមរហូតដល់**ចូឆូ**ឲ្យសម្លាប់ពួកនាហ្មឺនក្នុងស្រុកហ៊ូតោ ដែលជួយលត់ភ្លើងពួកក្បត់សាមសិបនាក់។)*

**ខណះនោះ** **សុម៉ាអ៊ី**បានចូលទៅនៅនឹង**ចូឆូ**តាំងពីនៅស្រុកហ៊ូតោ **ចូឆូ**ឲ្យ**សុម៉ាអ៊ី**ជាសមុហបញ្ជីកូនទាហាន។ **សុម៉ាអ៊ី**ចូលទៅគំនាប់**ចូឆូ**ហើយថា គ្រានេះ**វុយកុង**លើកទ័ពមកវាយបានស្រុកហាន់តុងហើយ ខ្ញុំបាទឮកិត្តស័ព្ទថា **ឡៅពី**បានស្រុកសែឈួនហើយបណ្ដេញ**ឡៅជៀង**ចេញពីស្រុកទៅ អាណាប្រជានុរាស្ត្រទាំងពួងដែលនៅក្នុងស្រុកសែឈួននោះ នៅមិនទាន់ជាប្រក្រតីនឹង**ឡៅពី**ទេ ដែលលោកលើកទ័ពមកដល់ទីនេះហើយ ក៏ជាផ្លូវដាច់ស្រយាលឆ្ងាយណាស់ បើនឹងលើកទ័ពត្រឡប់ទៅវិញក៏មិនគួរសោះ កាលណាឡើយនឹងបានលើកមកទៀត សូមឲ្យលោកលើកទៅវាយយកស្រុកសែឈួនឲ្យបានក្នុងគ្រានេះតែម្ដងទៅ រួចសឹមលើកត្រឡប់ទៅវិញ។

**ចូឆូ**ឮដូច្នោះ ក៏ធ្វើជាដកដង្ហើមធំហើយថ្លែងថា ធម្មតាកើតមកជាមនុស្សនេះកាលដើមនឹងគិតថារកតែមួយ លុះបានរួចហើយក៏គិតកំរើបចិត្តនឹងរកឲ្យបានពីរតឡើងទៅព្រោះសេចក្ដីលោភ ដូចជាបានស្រុកហាន់តុងហើយថែមទាំងចង់បានស្រុកសែឈួនទៀត ស្រុកទាំងនេះសុទ្ធតែផ្លូវដាច់ស្រយាល់ឆ្ងាយណាស់។

**ឡៅហ្គូ**ថា ដែល**សុម៉ាអ៊ី**និយាយនេះគួរប្រពៃណាស់ បើលោកនឹងបង្អង់ទុកឲ្យយូរទៅ **ខុងបេង**គង់នឹងមានសតិបញ្ញាវិះគិតបញ្ចុះបញ្ចូលបណ្ដារាស្ត្រក្នុងស្រុក

សែឈ្លួនឲ្យមានចិត្តប្រក្រតីស្រួលទៅ ទាំង**គួនអ៊ូ**, **តៀវហ៊ុយ**, **ជូឡុង** សឹងតែជាទាហានឯក និងទាហានក្រៅពីនេះក៏មានសេចក្ដីអនេកណាស់ បើលោកនឹងលើកទៅវាយយកជាក្រោយដោយសេចក្ដីលំបាក។ **ចូឆូ**តបថា យើងលើកមកគ្រានេះ ផ្លូវក៏ដាច់ស្រយាលឆ្ងាយណាស់ ប្រការមួយទៀត បានស្រុកហាន់តុងហើយ ទាហានក៏កំពុងនឿយហត់ ដែលនឹងលើកទៅវាយស្រុកសែឈ្លួនទៀតនោះ យើងមិនទាន់ឃើញផងទេ។ ហើយក៏តាំងបម្រុងសេនាទាហាននៅក្នុងស្រុកប៉ាតុង។

ឯអស់អាណាប្រជានុរាស្ត្រក្នុងស្រុកសែឈ្លួន និងអាណាខេត្តដែលឡើងទាំងប៉ុន្មាន លុះបានដឹងកិត្តិស័ព្ទថា **ចូឆូ**លើកកងទ័ពមកវាយយកស្រុកហាន់តុងបានដូច្នោះ ទាំងអស់គ្នានោះក៏នាំគ្នារន្ធត់ភិតភ័យខ្លាច**ចូឆូ**ពន់ប្រមាណ ក្រែង**ចូឆូ**នឹងរុករានទន្ទ្រានលើកទ័ពទៅវាយយកស្រុកសែឈ្លួនទៀត។ **ឡៅពី**ដឹងថាបណ្ដារាស្ត្រទាំងពួងតក់ស្លុតភិតភ័យខ្លាចដូច្នោះ ក៏ពិគ្រោះសួរ**ខុងបេង**ថា បណ្ដារាស្ត្រក្នុងស្រុកយើងខ្លាច**ចូឆូ**នឹងលើកទ័ពមកធ្វើអន្តរាយ ដូច្នេះលោកនឹងត្រិះរិះគិតប្រការម្ដេច?

**ខុងបេង**ថា នេះលោកកុំព្រួយចិត្តឡើយ ខ្ញុំនឹងគិតកលឧបាយមិនឲ្យ**ចូឆូ**លើកទ័ពមកធ្វើអន្តរាយដល់ស្រុកយើង នឹងឲ្យលើកទ័ពត្រឡប់ទៅវិញ។ **ឡៅពី**សួរថា លោកនឹងគិតប្រការម្ដេច? **ខុងបេង**ថា ឯ**ចូឆូ**នោះរមែងខ្លាចញញើត**ស៊ុនគួន**ជាដរាប បានជាឲ្យ**ហែហ៊្ហូទុន**និង**ទៀវលៀវ**នៅឈរស្រុកហាប់ប៉ា កាល**ចូឆូ**លើកកងទ័ពមកវាយយកស្រុកហាន់តុងនោះ ក៏យក**ហែហ៊្ហូទុន**មកផង មួយនេះសូមឲ្យលោកចាត់ប្រើបម្រើណាដែលមានតម្រិះប្រាជ្ញាឲ្យទៅនិយាយនឹង**ស៊ុនគួន**ថា **ឡៅពី**នឹងឲ្យស្រុកកាំងហែ ស្រុកទៀងសា ស្រុកហ៊ុយអៀង មកជូនលោក ហើយញុះញង់ឲ្យ**ស៊ុនគួន**លើកទ័ពទៅវាយយកស្រុកហាប់ប៉ា បើ**ចូឆូ**ដឹងវេលាណា ក៏នឹងកង្វល់រវល់ចិត្តគិតលើកទ័ពទៅជួយគ្នាជាប្រាកដ។

**ឡៅពី**ថា លោករំពឹងឃើញនរណាដែលនឹងប្រើឲ្យកាន់សំបុត្រទៅនិយាយការនឹង**ស៊ុនគួន**នោះ? **អ៊ីចៀ**ឆ្លើយទទួលខ្លួនថា ខ្ញុំបាទសុំយកអាសាកាន់សំបុត្រទៅ

និយាយការនោះឲ្យបាន។ **ឡៅពី**ក៏តែងសំបុត្ររួចប្រគល់ឲ្យ**អ៊ីចៀ**ហើយថែមផ្ដាំពាក្យក្រៅថា បើអ្នកឯងទៅដល់ត្រូវនិយាយប្រាប់**គួនអ៊ូ**ឲ្យយល់សេចក្ដីជាមុន។ **អ៊ីចៀ**ទទួលសំបុត្រហើយក៏លា**ឡៅពី**ស្រូតតម្រង់ទៅស្រុកកេងជីវ ដល់ហើយក៏ពណ៌នាសេចក្ដីប្រាប់**គួនអ៊ូ** តាមដែល**ចូវឆូ**លើកទ័ពទៅវាយយកស្រុកហាន់តុង ឥឡូវ **ឡៅពី**ប្រើខ្ញុំឲ្យកាន់សំបុត្រទៅឲ្យ**ស៊ុនគួន**។ និយាយហើយក៏លា**គួនអ៊ូ**ទៅស្រុកកាំងតាំង កាលចូលទៅដល់ក៏ប្រាប់អ្នកចាំទ្វារថា ខ្ញុំជាបម្រើ**ឡៅពី**នាំសំបុត្រមកជូន**ស៊ុនគួន**។ អ្នកចាំទ្វារក៏ចូលទៅជម្រាប**ស៊ុនគួន**។ **ស៊ុនគួន**ដឹងដូច្នោះ ក៏ឲ្យហៅខ្លួន**អ៊ីចៀ**ចូលទៅ ហើយសួរថា **ឡៅពី**ប្រើមកដោយហេតុអ្វី? **អ៊ីចៀ**ក៏ជូនសំបុត្រនោះទៅឲ្យ**ស៊ុនគួន**ហើយជម្រាបថា កាល**ជូកាត់កិន**ទៅនិយាយការពីស្រុកកេងជីវនោះ **ឡៅពី**ក៏ទទួលថានឹងបង្វិលស្រុកបីតំបន់ជូនលោក តែពាក្យនោះក៏ខុសទៅហើយ ឥឡូវ**ឡៅពី**ព្រមបង្វិលស្រុកកាំងហែ ស្រុកទៀងសា ស្រុកហ៊ុយអៀង ជូនលោកវិញ។ បានជាផ្ញើសំបុត្រនេះមកជូនលោកជាសម្គាល់ ឯស្រុកកេងជីវ ស្រុកឡេងឡេង និងស្រុកឡាំងគុននោះគង់នឹងបង្វិលជូនលោកដែរ តែនៅជាប់កិច្ចបន្តិច ព្រោះ**ចូវឆូ**លើកកងទ័ពទៅវាយស្រុកហាន់តុង **គួនអ៊ូ**នៅមិនទាន់មានទីអាស្រ័យ បានជាខ្ចីឲ្យ**គួនអ៊ូ**នៅសិន ឯស្រុកហាប់ប៉ាដែល**ចូវឆូ**ចាត់មនុស្សឲ្យទៅឈររក្សានោះ ទាហានក៏ស្តួចស្តើង សូមឲ្យលោកលើកកងទ័ពទៅវាយយកចុះ បើលោកលើកកងទ័ពទៅវាយយកវេលាណា ក៏គង់តែ**ចូវឆូ**នឹងលើកកងទ័ពមកជួយ **ឡៅពី**បានតម្រុយនឹងលើកកងទ័ពទៅវាយយកស្រុកហាន់តុងខាងនោះ បើ**ឡៅពី**បានស្រុកហាន់តុងចំពោះហើយ ក៏នឹងឲ្យ**គួនអ៊ូ**ទៅនៅស្រុកហាន់តុង ឯស្រុកកេងជីវ ស្រុកឡេងឡេង ស្រុកឡាំងគុន ទាំងបីនោះក៏នឹងបានមកជារបស់លោកវិញ។

**ស៊ុនគួន**ឮដូច្នោះក៏ហែកស្រោម ហូតសំបុត្រមកមើល ឃើញសេចក្ដីត្រូវគ្នានឹងពាក្យ**អ៊ីចៀ**និយាយ ហើយក៏ឲ្យ**អ៊ីចៀ**ទៅឈប់ស្នាក់ឯផ្ទះទទួលភ្ញៀវជាបណ្ដោះអាសន្ន **ស៊ុនគួន**ក៏យកសំបុត្រនោះទៅប្រជុំប្រឹក្សានឹងនាហ្មឺនទាំងពួង។ **ទៀវចៀវ**ថា

ដែល**ឡៅពី**ឲ្យសំបុត្រមកនេះជាកលឧបាយ ព្រោះខ្លាច**ចូវឆូ**នឹងលើកទ័ពមកវាយយកស្រុកសែឈួន តែថាបើទោះជាកលឧបាយយ៉ាងណាក្តី ក៏គង់ជាគប្បីបានប្រយោជន៍ដល់យើងពីរប្រការ។ ប្រការមួយយើងបានស្រុកបីតំបន់ ប្រការពីរយើងបានស្រុកហាប់ប៉ាផង ទោះបីជា**ឡៅពី**នឹងមានចិត្តកំរើបល្បួងបញ្ឆោតយើងបានក៏តាមការចុះ ត្រូវតែគិតធ្វើតាមសំបុត្រឲ្យបាន។

**ស៊ុនគួន**យល់ឃើញត្រូវ ក៏ឲ្យហៅខ្លួន**អ៊ីថៀ**ចូលមក ហើយនិយាយថា អ្នកឯងត្រូវស្រូតប្រញាប់ទៅប្រាប់**ឡៅពី**ចុះ ថាយើងព្រមលើកទ័ពទៅវាយស្រុកហាប់ប៉ាហើយ។ **អ៊ីថៀ**ទទួលប្រសាសន៍ហើយក៏លាចេញទៅ។ ខណៈនោះ**ផៀផៅ**, **អ៊ុយតាយ**, **ហាន់តុង** ចេញទៅត្រួតគយល្បាតពុំទាន់ប្រឡប់វិលមកវិញ។ **ស៊ុនគួន**ក៏ប្រើ**ឡោសុក**ទៅទទួលយកស្រុកទាំងបីតំបន់ ហើយនិងត្រាសម្រាប់ទីចៅហ្វាយស្រុកនោះ ឯ**ស៊ុនគួន**ក៏នាំទាហានទៅតាំងនៅមាត់ពាមកំពង់ឡុកខៅ ហើយរក**កាំឡេង**, **លីបង**, **ឡេងថង**ទៅប្រជុំគ្នាខណៈនោះ **កាំឡេង**និង**លីបង**ទៅដល់មុន។

**ស៊ុនគួន**ក៏ប្រឹក្សាថា ឥឡូវ**ចូវឆូ**លើកទ័ពទៅវាយស្រុកហាន់តុង ឯយើងនឹងគិតលើកទ័ពទៅវាយស្រុកហាប់ប៉ា តើអ្នករាល់គ្នានឹងយល់ឃើញដូចម្តេច? **លីបង**ឆ្លើយថា **ចូវឆូ**ប្រើ**ជូកុង**ឲ្យទៅឈប់ស្រុកលោកាំង **ជូកុង**ទៅតាំងទ័ពនៅស្រុកអួនសៀ ឥឡូវជាទេសកាលស្រូវភោជសាលីទុំ **ជូកុង**ឲ្យច្រូតស្រូវភោជសាលីសន្សំទុកក្នុងស្រុកហាប់ប៉ា សូមឲ្យលោកលើកទ័ពទៅវាយយកស្រុកអួនសៀឲ្យបានជាមុនសិន រួចសឹមលើករំលងទៅវាយយកស្រុកហាប់ប៉ាជាក្រោយ នឹងបានដោយងាយ។

**ស៊ុនគួន**យល់ឃើញត្រូវ ក៏តាំងចាត់ចែងទាហានបានដប់ម៉ឺនឲ្យ**កាំឡេង**, **លីបង**ជានាយកងទ័ពមុខ **ជីវឃឹម** និង**ភូជៀង**ជានាយកងទ័ពក្រោយ **ជីវថាយ**, **តាន់ប៊ូ**, **តាំងស៊ិត**, **ស៊ីសេង** បួននាយទុកក្នុងកងទ័ពហ្លួងជាមួយ**ស៊ុនគួន**។ លុះចាត់ទ័ពរួចហើយ **ស៊ុនគួន**ក៏លើកឆ្លងត្រើយទៅឡើងតាមផ្លូវតម្រង់ទៅស្រុកហៃជីវ

ហើយលើកជាក្បួនទ័ពគោកទៅលុះទៅជិតស្រុកអ្នួនសៀហើយ ក៏ឲ្យបោះទ័ពតាំងបន្ទាយនៅទីនោះ។

ឯ**ជូកុង**ដឹងថា **ស៊ុនគួន**លើកកងទ័ពមកដូច្នោះ ក៏ឲ្យប្រមូលទាហានឡើងរក្សាសើនបន្ទាយយ៉ាងមាំមួន ហើយចាត់បម្រើនាំសំបុត្រទៅដល់**ទៀវលៀវ**ដែលនៅស្រុកហាប់ប៉ា។ **ស៊ុនគួន**នាំទាហានទៅត្រួតមើលកំផែងស្រុកអ្នួនសៀ បើឃើញទីត្រង់ណាស្តើងចន្លោះស្រួល នឹងប្រមូលទាហានឲ្យបំពានទម្លាយវាយចូលស្រុកនោះតែម្តង។ នោះពួកទាហានដែលរក្សាសើនបន្ទាយ ឃើញ**ស៊ុនគួន**នាំទាហានដើរត្រួតមើលដូច្នោះ ក៏នាំគ្នាបាញ់ធ្នូចម្រុះសំដៅទៅជាច្រើន។

**ស៊ុនគួន**មានបារម្ភ ក៏នាំទាហានចូលបន្ទាយវិញ ហើយប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតច្បាំងយ៉ាងម្តេចទើបនឹងបានស្រុកអ្នួនសៀនោះ? **តាំងស៊ិន**ឆ្លើយថា ឲ្យប្រមូលទាហានជីកយកដីមកគរធ្វើជាភ្នំឲ្យខ្ពស់ស្មើនឹងកំផែងស្រុកជុំវិញ ហើយឲ្យទាហានបាញ់ធ្នូឲ្យធ្លាក់ចូលទៅដូចគ្រាប់ភ្លៀង ទាហានដែលនៅលើសើនខាងក្នុង គង់នឹងដោះខ្លួនចេញអស់ រួចយើងត្រូវយកបង្គោងនិងជើងជណ្តើរពាក់ឡើងជុំវិញឲ្យព្រមគ្នា គង់នឹងពារទម្លាយយកស្រុកនោះដោយងាយបាន។ **លីបង**និយាយនឹង**តាំងស៊ិន**ថា ដែលនឹងធ្វើការតាមគំនិតអ្នកនោះយូរណាស់ មុខជាកងទ័ពស្រុកហាន់ប៉ាមកជួយទាន់ វេលានោះទាហានរបស់យើងកំពុងថ្មោងកម្លាំង ត្រូវតែលើកពារទម្លាយវាយឲ្យបែកក្នុងពេលមួយតែម្តងទៅ ទើបនឹងបានស្រុក**អ្នួនសៀ**នោះ រួចនឹងបានលើករំលងទៅវាយយកស្រុកហាប់ប៉ាទៀត។

**ស៊ុនគួន**យល់ឃើញត្រូវ លុះដល់ពេលយាមបីយប់ ក៏បង្គាប់ឲ្យទាហានដាំបាយស៊ីជាស្រេច រួចលើកឆ្លងគូស្រុកសម្រុកចូលទៅវាយទម្លាយទ្វារពារកំផែង សំឡេងមនុស្ស និងគងឃ្មោះក៏លាន់ឮសន្ធឹកគគ្រឹកគគ្រេង ហាក់បីដូចនឹងផ្អើលក្រឡាប់ផែនដី ឯទាហានដែលនៅលើសើនបន្ទាយខាងក្នុង ក៏ប្រុងតែបាញ់ធ្នូចម្រុះចុះមក ព្រួញធ្លាក់ហាក់បីដូចគ្រាប់ភ្លៀង **កាំឡេង** និង**លីបង** ដែលជានាយទាហានកង

មុខឃើញដូច្នោះ ក៏បង្គំទាហានឲ្យយកជើងជណ្ដើរនិងបង្គោងពាក់លើកំផែង ប្រវារឡើងទៅតដៃគ្នាលើសើន ទាំងខ្លួន**កាំឡេង**ក៏ឡើងតាមបង្គោងទៅដល់ពាក់កណ្ដាលកំផែង ហើយយកច្រវាក់ចោលបំពាក់ទៅលើកំផែងប្រតោងឡើងទៅច្បាំង ចាក់កាប់សម្លាប់គ្នានៅលើសន្លឹកសីមាខ្នងកំផែងនោះ។

ឯ**ជូកុង**ក៏ឲ្យទាហានយកដុំថ្ម និងគ្រួសខ្សាច់ចាប់សាចចុះទៅមិនឈប់ **កាំឡេង**ក៏គ្រវែងច្រវាក់ទៅត្រូវ**ជូកុង**ជ្រួលចុះ ពួកទាហានដែលនៅលើសើននោះ ក៏ស្ទុះទៅគ្រាហ៍លើកឡើង **កាំឡេង**និងទាហានពីក្រោមក៏ប្រវារឡើងទៅបាន ហើយក៏យកគ្រប៊ីនិងដាវលំពែងព្រួតចាក់កាប់សម្លាប់**ជូកុង**នៅទីនោះ ពួកទាហាន**ជូកុង**ទាំងប៉ុន្មានក៏នាំគ្នាចំណុះចុះចូល**កាំឡេង**ទាំងអស់។

ឯ**ទៀវលៀវ**កាលទទួលសំបុត្រ**ជូកុង**ដឹងដំណឹងហើយ ក៏រៀបចាត់ចែងទាហានលើកទៅជួយស្រុកអួនសៀ លុះទៅដល់កណ្ដាលផ្លូវដឹងដំណឹងថា **ស៊ុនគួន**វាយយកស្រុកអួនសៀហើយ **ទៀវលៀវ**ក៏លើកទ័ពត្រឡប់ទៅស្រុកហាប់ប៉ាវិញ។

ខណៈនោះ**ឡេងថង**ក៏លើកទាហានស្រូតតាម**ស៊ុនគួន**ទៅ លុះទៅដល់ ទទួល**ស៊ុនគួន**វាយបានស្រុកអួនសៀហើយ **ស៊ុនគួន**ក៏នាំ**ឡេងថង**និងទាហានទាំងអស់ចូលទៅស្រុកអួនសៀ ហើយឲ្យចែកបំណាច់រង្វាន់ដល់ទាហានតាមលំដាប់ រួចឲ្យរៀបតុលៀងអាហារពួកទាហាននិងនាហ្មឺនទាំងពួង។ **ស៊ុនគួន**ថា យើងមកវាយបានស្រុកអួនសៀគ្រានេះ **កាំឡេង**មានសេចក្ដីគាប់ប្រសើរច្រើនជាងគេ ព្រោះចូលវាយទម្លាយស្រុកបានមុន ត្រូវឲ្យ**កាំឡេង**អង្គុយស៊ីលៀងត្រង់ទីកន្លែងមន្ត្រីជាន់ខ្ពស់។

ខណៈនោះ ទីប្រឹក្សានិងទាហានទាំងពួងក៏អង្គុយស៊ីលៀងព្រមគ្នា **ឡេងថង**ឃើញ**កាំឡេង**អង្គុយកន្លែងជាន់ខ្ពស់ជាងនាយទាហានទាំងពួង ក៏រឹតតែមានសេចក្ដីគ្នាន់ខ្នាញ់ណាស់ ព្រោះ**កាំឡេង**សម្លាប់បិតារបស់ខ្លួនសូន្យជីវិតទៅ ចេះតែសម្លឹងចុងភ្នែកមើល**កាំឡេង** ហើយនិយាយនឹងនាយទាហានទាំងពួងថា យើងនឹងឡើងរាំគ្រប៊ីឲ្យអ្នករាល់គ្នាមើល ហើយ**ឡេងថង**ក៏ឡើងរាំកណ្ដាលទីប្រជុំនោះ។

**កាំឡេង**ឃើញដូច្នោះក៏គិតថា **ឡេងថង**នេះក៏មានចិត្តអាឃាតព្យាបាទមិនដាច់សោះ ដែលរាំគ្រប៊ីនោះ បំណងនឹងប្រទូសរ៉ាយយើងជាប្រាកដ យើងក៏ត្រូវតែរាំដើម្បីនឹងការពារខ្លួនវិញ។ គិតហើយក៏ថា **ឡេងថង**រាំតែម្នាក់ឯងនោះ មិនសូវល្អមើលទេ យើងចេះរាំកាន់លំពែងផ្គូពីរស្ទាត់ជាងអ្នកឯង យើងនឹងរាំឲ្យអ្នករាល់គ្នាមើល ថាហើយក៏ក្រោកឡើងរាំ។ **លីបង**ឃើញ**កាំឡេង** និង**ឡេងថង**រាំលំពែងនិងគ្រប៊ីតគ្នាដូច្នោះ ក៏គិតថា នាយទាហានទាំងពីរនាក់នោះមានចិត្តគិតតែព្យាបាទគ្នាមិនដាច់សោះ ចាំយើងនឹងការពារកុំឲ្យមានសេចក្តីអន្តរាយដល់គ្នានឹងគ្នា គិតហើយក៏និយាយប្រកាសប្រាប់នាហ្មឺនទាំងអស់ថា ខ្លួនយើងចំណានស្ទាត់ខាងរាំខែល យើងនឹងរាំឲ្យអ្នករាល់គ្នាមើល ថាយើងក៏ក្រោកឡើងរាំកណ្តាលចន្លោះ**កាំឡេង** និង**ឡេងថង** ប្រាថ្នាមិនឲ្យអ្នកទាំងពីរប្រទូសរ៉ាយគ្នា។ ទាហានម្នាក់ឃើញដូច្នោះ ក៏នាំសេចក្តីនោះទៅប្តឹង**ស៊ុនគួន** ៗឮភ្លាមក៏ភ័យស្លុត រត់ទៅកាន់ទីប្រជុំមន្ត្រីទាំងនោះក្រឡេកទៅឃើញ**កាំឡេង**និង**ឡេងថង**កំពុងរាំអាវុធតគ្នាទាំងសងខាង ឃើញ**លីបង**រាំជាកណ្តាល។ **កាំឡេង**និង**ឡេងថង**ឃើញ**ស៊ុនគួន**មកដល់ ក៏ភ័យណាស់ បោះអាវុធចេញពីដៃទាំងពីរនាក់ ហើយលុតជង្គង់ចុះគំនាប់**ស៊ុនគួន** ៗក៏និយាយប្រាប់**ឡេងថង**ថា ហេតុដែលអ្នកឯងចាប់ចិត្តគិតព្យាបាទ**កាំឡេង**នោះ យើងក៏បានសុំឲ្យលើកចោលពីគ្រាមុនទៅហើយ ហេតុម្តេចក៏នាំមកបណ្តាលឲ្យកើតឡើងក្នុងគ្រានេះទៀត? **ឡេងថង**មិនឆ្លើយតបថាអ្វីសោះ ចេះតែអង្គុយយំ។

**ស៊ុនគួន**ក៏និយាយលួងលោមផ្គួមចិត្ត**ឡេងថង**ថា ខ្លួនអ្នកឯងនិង**កាំឡេង**នេះឧបមាដូចត្រីនៅក្នុងអន្លង់ជាមួយគ្នា គួរតែតាំងចិត្តចងមេត្រីនឹងគ្នា ធ្វើរាជការជាមួយគ្នាដោយប្រក្រតីទៅចុះ ទើបប្រសើរកេរ្តិ៍ឈ្មោះវែងឆ្ងាយ។ **ឡេងថង**ក៏ស្ងៀមមិនស្តី។ **ស៊ុនគួន**ក៏ឲ្យត្រួតត្រាមើលសេនាទាហានគ្រប់គ្រងត្រៀមទុកព្រម។ លុះវេលាព្រឹក **ស៊ុនគួន**ក៏លើកទ័ពចូលទៅជិតស្រុកហាប់ប៉ា ហើយឲ្យតាំងបន្ទាយនៅទីនោះ។

ខាង**ទៀវលៀវ**ក៏ប្រមូលពលទាហានឡើងរក្សាលើបន្ទាយជាមាំមួន មិនបានប្រហែសធ្វេស លុះដឹងថា **ស៊ុនគួន**លើកកងទ័ពទៅតាំងបន្ទាយជិតស្រុកហាប់ប៉ាហើយ **ទៀវលៀវ**ក៏គិតនឹងលើកពលចេញទៅតស៊ូច្បាំងនឹង**ស៊ុនគួន** ទទួលទាហានចូលទៅប្រាប់**ទៀវលៀវ**ថា **ចូឆូ**ឲ្យយកហិបតូចមួយមកជូនលោក។ **ទៀវលៀវ**ទទួលយកហិបនោះមកពិនិត្យមើល ឃើញសរសេរស្លាកបិទថា បើកាលណាមានសឹកសង្គ្រាមលើកមកញាំញីស្រុកហាប់ប៉ា ហើយតទល់ដល់នូវសេចក្តីលំបាកប្រការម្តេច ឲ្យបើកយកសំបុត្រក្នុងហិបនោះមកមើល ហើយឲ្យធ្វើតាមចុះ។

ខណៈនោះ **ទៀវលៀវ**ក៏ប្រឹក្សានឹង**លីទៀន**, **ង៉ាក់ជិន**ថា ដែលនឹងចេញទៅតស៊ូនឹង**ស៊ុនគួន**នោះ ក៏នៅមិនទាន់ព្រមព្រៀងគ្នា **ទៀវលៀវ**ក៏បើកហិបចេញ ហើយយកសំបុត្រ**ចូឆូ**មកមើលឃើញសេចក្តីថា បើ**ស៊ុនគួន**លើកទ័ពមកវាយស្រុកហាប់ប៉ាវេលាណាឲ្យ**ទៀវលៀវ** និង**លីទៀន**លើកទាហានចេញទៅតនឹង**ស៊ុនគួន** ឲ្យ**ង៉ាក់ជិន**នៅរក្សាស្រុកលុះ**ទៀវលៀវ**មើលហើយ ក៏យកសំបុត្រនោះឲ្យទៅ**លីទៀន**, **ង៉ាក់ជិន**មើល។

**លីទៀន**, **ង៉ាក់ជិន**ឃើញសេចក្តីសំបុត្រហើយ ក៏និយាយនឹង**ទៀវលៀវ**ថា បើសំបុត្រ**វុយកុង**ឲ្យមកដូច្នេះ លោកនឹងរិះគិតប្រការម្តេច? **ទៀវលៀវ**ថា **ស៊ុនគួន**ដឹងថា**វុយកុង**លើកទ័ពទៅវាយស្រុកហាន់តុង **ស៊ុនគួន**មានចិត្តកំរើប ទើបលើកទ័ពមកវាយស្រុកយើង ៗត្រូវតែលើកទាហានចេញទៅតច្បាំងយកជ័យជម្នះ**ស៊ុនគួន**ឲ្យបានម្តងសិន ដើម្បីឲ្យទាហានខាងយើងមានចិត្តកំរើបខំធ្វើការតទៅមុខទៀត រួចសឹមយើងគិតការតាមការតទៅ។ **លីទៀន**ឮដូច្នោះក៏ស្ងៀម តែ**ង៉ាក់ជិន**ឆ្លើយតបនឹង**ទៀវលៀវ**ថា **ស៊ុនគួន**លើកទាហានមកគ្រានេះច្រើនណាស់ ទាហានខាងយើងតិចដែលនឹងលើកចេញទៅនោះ មុខជានឹងតទល់នឹង**ស៊ុនគួន**មិនបាន គួរឲ្យគិតរក្សាស្រុកឲ្យគង់នៅសិន ដើម្បីកុំឲ្យសត្រូវចូលមកក្នុងស្រុកបាន។

**ទៀវលៀវ**ថា ដែលនឹងគិតរក្សាស្រុកនៅតែស្ងៀមដូច្នេះ នឹងមិនខុសពីក្នុងសំបុត្របណ្ដាំ**វុយកុង**ឲ្យមកនេះទេឬ? នរណានឹងនៅក៏នៅចុះ ខ្ញុំម្នាក់ឯងនឹងលើកទាហានចេញធ្វើការសង្គ្រាមនឹង**ស៊ុនគួន**។ ថាហើយក៏បង្គាប់ឲ្យចាត់ចែងទាហាន **លីទៀន, ង៉ាក់ជិន**ក៏និយាយនឹង**ទៀវលៀវ**ថា បើដូច្នោះខ្លួនយើងត្រូវរួមសុខទុក្ខខុសត្រូវជាមួយគ្នា យើងនឹងសុំចេញទៅផង នឹងឲ្យតែទាហាននៅរក្សាស្រុកក៏បាន។

**ទៀវលៀវ**ឮដូច្នោះក៏អរណាស់ និយាយនឹង**លីទៀន**ថា វេលាយាមបីយប់នេះ អ្នកឯងត្រូវឲ្យទាហានព័ទ្ធចេញទៅទម្លាយស្ពាន “សៀវកៀវ” ខាងទិសទក្សិណឲ្យអស់ចេញកុំឲ្យសត្រូវឆ្លងទៅមកបាន ហើយនាំទាហានទៅពួនបង្កប់នៅតំបន់សៀវកៀវនោះ ចាំស្កាត់វាយទ័ព**ស៊ុនគួន** លុះដល់ព្រឹកឡើង យើងនិង**ង៉ាក់ជិន**លើកទាហានចេញទៅចោមវាយថែមទៀត **លីទៀន**យល់ឃើញត្រូវ ក៏លើកទាហានចេញទៅធ្វើតាមពាក្យ**ទៀវលៀវ**បង្គាប់។ លុះព្រឹកព្រហាមស្រាង **ទៀវលៀវ**ក៏ឲ្យ**ង៉ាក់ជិន**លើកទាហានជាកងបញ្ឆោត ឯខ្លួន**ទៀវលៀវ**លើកទាហានចេញទៅពួនបង្កប់ចាំខ្ទប់វាយប្រសព្វគ្នា។

ខណៈនោះ **ស៊ុនគួន** និង**ឡេងថង**ក៏លើកកងទ័ពកន្លងចូលទៅ ឯ**កាំឡេង**និង**លីបង**ដែលជាកងមុខនោះ លុះឃើញ**ង៉ាក់ជិន**លើកទាហានចេញមកពីក្នុងបន្ទាយ **កាំឡេង**ក៏បរសេះចូលតច្បាំងនឹង**ង៉ាក់ជិន**បានដប់ភ្លែង **ង៉ាក់ជិន**ធ្វើជាញាក់សេះថយរត់ ចូលទៅតាមមាត់ផ្លូវសៀវកៀវ ហើយស្រូតបរសេះវេះទៅតាមផ្លូវបែក **លីបង**ឃើញបានចំណាប់ស្រួល ក៏បរពលចូលទៅជាជំនួយ ពីក្រោយ **ស៊ុនគួន**ឃើញដូច្នោះក៏បំបោលសេះដេញទាហានតាមទៅទៀត រហូតដល់កន្លែងដែល**ទៀវលៀវ**ពួនបង្កប់ទ័ព ទទួលឮសូរផាវជាសញ្ញា ឮសូរហ៊ោកញ្ជ្រៀវជាគឹកកង ឃើញ**លីទៀន**នៅខាងឆ្វេង នាំទាហានចេញមកវាយប្រសព្វជាច្រើន ឃើញ**ទៀវលៀវ**នៅខាងស្ដាំ នាំទាហានចេញមកវាយខ្ទប់ប្រសព្វគ្នាទាំងសងខាង ចូលប្រកាប់សម្លាប់ទាហានជាច្រើនណាស់ ទាហានទាំងនោះក៏ប្រាសរត់ខ្ចាត់ខ្ចាយបែកប្រពាក់ប្រពូន **ស៊ុនគួន**ក៏

បរាជ័យភ័យតក់ស្លុតមហិមា ឯ**កាំឡេង**និង**លីបង**ក៏ដេញ**ង៉ាក់ជិន**ជ្រុលហួសទៅ នឹងឲ្យទាហានបរសេះបំពានវិលមកក្រោយឲ្យហៅគ្នាទៅជួយ ក៏ទើសនឹងទាហាន**ទៀវលៀវ**ចេញមករាំងស្កាត់ជាប់តាន់តាប់ច្រើនណាស់។

ខណៈនោះ**ស៊ុនគួន**ក៏នៅសល់ទាហានពីស្លាប់ប្រហែលបីរយនាក់ **ឡេងថង**ក៏និយាយនឹង**ស៊ុនគួន**ថា លោកចូរឆ្លងតាមស្ពានទៅឲ្យដល់ត្រើយម្ខាងជាប្រញាប់ចុះ ទើបរួចពីអន្តរាយ និយាយមិនទាន់ផុតមាត់ ទទួល**ទៀវលៀវ**លើកទាហានដេញ**ឡេងថង**តាមពីក្រោយទៅទៀត **ស៊ុនគួន**ក៏បំបោលសេះរត់ឆ្លងតាមស្ពានថ្មទៅត្រើយខាងលិច ឃើញចុងស្ពាននោះដាច់គ្មានតំណទៅដល់ត្រើយចម្ងាយប្រហែលប្រាំមួយហត្ថទៅដប់ហត្ថ **ស៊ុនគួន**ភ័យស្លុតស្មារតីគិតថា គ្រានេះមុខជាមិនរួចជីវិតនឹងសត្រូវនេះឡើយ ហើយក៏ញាក់សេះថយមកក្រោយវិញ ក៏ថយមកមិនបាន ព្រោះទាហាន**ទៀវលៀវ**ដេញតាមស្ពានពីក្រោយទៅដល់ត្រើយពីខាងកើត ហើយមានទាហានម្នាក់ដែលតាមទៅជាមួយ ក៏រំឭកស្មារតី**ស៊ុនគួន**ថា លោកញាក់បរសេះទៅមុខទៅ លុះទៅដល់កណ្ដាលស្ពាន ឲ្យលោកបង្ខំបំផាយសេះឲ្យវាស្ទុះលោតឆ្លងត្រង់ស្ពានដាច់ទើបដល់ផែនដី។ **ស៊ុនគួន**ក៏មានស្មារតីយល់តាម តាំងតែវាយបំផាយសេះទៅ សេះនោះក៏ស្ទុះអស់ទំហឹងប្រឹងលោតទៅដល់ផែនដីត្រើយម្ខាង ទទួល**ស៊ីឡេង**និង**តាំងស៊ិត**ជិះទូកតូចមួយចូលទៅដល់ទីនោះ ក៏បង្ខំទាហានឲ្យចែវទូកទៅទទួល**ស៊ុនគួន**ចុះទូកបាន។ **ឡេងថង**ដែលនៅពីក្រោយ ក៏ទទួលរងតស៊ូនឹង**ទៀវលៀវ** ៗក៏កាប់ទាហាន**ឡេងថង**ស្លាប់អស់ទាំងបីរយនាក់។

ឯ**កាំឡេង**និង**លីបង**បានឮស្នូរទាហានហ៊ោកញ្ជៀវពីក្រោយគឹកកងដូច្នោះ ក៏នាំទាហានចូលបម្រុងទៅជួយ**ស៊ុនគួន** ទទួលប្រទះនឹង**លីទៀន** ក៏តាំងប្រយុទ្ធគ្នានៅយូរណាស់ **ង៉ាក់ជិន**ក៏នាំទាហានលបត្រឡប់ចូលពីក្រោយ ឃើញ**លីទៀន** និង**កាំឡេង**, **លីបង**កំពុងប្រកាប់គ្នា ក៏ស្ទុះចូលទៅជួយ**លីទៀន** ៗនិង**ង៉ាក់ជិន**ក៏កាប់សម្លាប់ទាហាន**កាំឡេង**ស្លាប់ជាច្រើនណាស់ **ឡេងថង**អស់ពលសល់នៅតែខ្លួនម្នាក់

ឯង ឯខ្លួននោះក៏ត្រូវរបួសដោយអាវុធមុតដាច់ជាច្រើនអន្លើលើសកម្លាំងនឹងទ្រាំតពុំឈ្នះ ក៏ប្រាសត្រឡប់សេះស្ទុះបំបោលទៅ **ទៀវលៀវ**ក៏ដេញទៅដល់ចុងស្ពានប្រទះនឹង**លីបង**, **កាំឡេង**និងទាហានប្រហែលដប់បួន ដប់ប្រាំនាក់ ទាំងអស់គ្នានោះក៏លោតចុះពីលើសេះ លោតចុះទៅក្នុងទឹកស្ទឹងប្រឹងហែលទៅ **ស៊ុនគួន**ឃើញដូច្នោះ ក៏ឱ្យថយទូកចេញទៅទទួលទាំងអស់គ្នាឱ្យឡើងមកលើទូក ហើយក៏ឱ្យចែវតម្រង់ទៅកំពង់យីស៊ូដែនស្រុកកាំងតាំង ហើយឱ្យតាំងបន្ទាយនៅលើគោក។

ខណៈកាល**ស៊ុនគួន**បែកទ័ពទៅនោះ ទាហាននិងអ្នកស្រុកកាំងតាំងទាំងស្រីទាំងប្រុសក៏ចេះតែញញើតខ្លាចថ្វីដៃ**ទៀវលៀវ**ជាប់ក្នុងចិត្ត សូម្បីកូនក្មេងដែលលេងនឹងគ្នាហើយយំ បើមានគេបន្លាចហើយចេញឈ្មោះ**ទៀវលៀវ**វេលាណា ក្មេងនោះក៏ខ្លាចតក្កមាមិនហ៊ានយំសោះ។ **ស៊ុនគួន**វេលានោះ ក៏មានសេចក្ដីទោមនស្សតូចចិត្តណាស់ តាំងតែបញ្ចុះបញ្ចូលពលទាហានប្រាថ្នានឹងទៅសងសឹក**ទៀវលៀវ**វិញ ហើយឱ្យសំបុត្របកទៅដល់**ឡោសុក**សេចក្ដីថា ឱ្យ**ឡោសុក**ប្រញាប់បញ្ជូនទាហានឱ្យទៅដល់ ដើម្បីនឹងលើកទៅវាយយកស្រុកហាប់ប៉ាទៀត នឹងចាប់យកខ្លួន**ទៀវលៀវ**ឱ្យបានសម្លាប់ចេញ។

ឯ**ទៀវលៀវ**នោះ លុះមានជ័យជម្នះ**ស៊ុនគួន**ហើយ ក៏លើកទាហានត្រឡប់ចូលទៅស្រុកវិញ ចេះតែគិតបារម្ភខ្លាចក្រែង**ស៊ុនគួន**បែកទៅគ្រានេះ នឹងកេណ្ឌទាហានមកបំពេញទ្វេឡើងជាច្រើន នឹងសងសឹកយើងវិញមិនលែង ឯទាហានក្នុងស្រុកហាប់ប៉ានេះក៏មានតិចផង មុខជាតស៊ូនឹង**ស៊ុនគួន**មិនបាន គួរនឹងប្ដឹងទៅ**ចូឆូ**ឱ្យលើកទ័ពមកជួយ គិតហើយក៏ធ្វើសំបុត្រប្ដឹងជូនដំណឹងរាជការទៅដល់**ចូឆូ** តាមដែលមានជ័យជម្នះ**ស៊ុនគួន**នោះគ្រប់ប្រការ ហើយថា វេលានេះក៏នៅមានបារម្ភក្រែង**ស៊ុនគួន** នឹងលើកកងទ័ពទៅទៀត ព្រោះទាហានក្នុងស្រុកហាប់ប៉ានោះស្ដួចស្ដើងណាស់ សូមឱ្យ**វុយកុង**លើកទ័ពទៅជួយ។ លុះតែងសំបុត្រហើយក៏ប្រើ**ស៊ីថែ**

ឲ្យកាន់ទៅ។ **ស៊ីថៃ**នោះ លុះទៅដល់ស្រុកហាន់តុងហើយ ក៏យកសំបុត្រនោះទៅជូន**ចូឆ្វ**។

**ចូឆ្វ**ទទួលសំបុត្រមើលដឹងសេចក្តីហើយ ក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតប្រការម្តេច? **ឡៅហ្វ**ថា ដែលនឹងលើកកងទ័ពទៅវាយយកស្រុកសៃឈ្នួននោះត្រូវបង្អង់ឈប់សិនចុះ ព្រោះ**ឡៅពី**ប្រុងប្រៀបទាហានមានត្រៀមទុកជាច្រើនណាស់ ប្រុងនឹងការពារស្រុកសៃឈ្នួនមិនឲ្យអន្តរាយ ឯស្រុកហាប់ប៉ានោះក៏ជាមណ្ឌលមួយធំ បើលោកលះបង់មិនគិត **ស៊ុនគួន**ជាបច្ចាមិត្តនឹងលើកកងទ័ពទៅវាយយកទទេជាអសារ។ បើបែកស្រុកនោះកាលណា ក៏គង់នឹងក្តៅរំជួលទៅដល់ក្រុងហ៊្វូតោទៀត។ ហេតុនេះសូមឲ្យលោករៀសរវៃ លើកទៅជួយស្រុកហាប់ប៉ាជាប្រញាប់ចុះទើបនឹងស្រួល។ **ចូឆ្វ**ក៏ទទួលថាត្រូវទើបនិយាយថា ភ្នំតេងគុនសាន់ និងភ្នំបងថៅង៉ៀម ពីរតំបន់នេះជាមាត់ច្រកស្រុកហាន់តុងត្រូវឲ្យ**ហែហ៊្វូអៀន** ឃុំទាហាននៅរក្សាត្រង់ភ្នំតេងគុនសាន់ ឲ្យ**ទៀវខាប់**នៅរក្សាត្រង់មាត់ច្រកផ្លូវភ្នំបងថៅង៉ៀម ហើយក៏ចាត់ចែងទាហានបានសែសិបម៉ឺន **ចូឆ្វ**ក៏លើកទៅដល់ស្រុកហាប់ប៉ា ហើយនាំ**ទៀវលៀវ, លីទៀន** និង**ង៉ាក់ជិន**លើករំលងចូលទៅត្រង់ដែនតដែនស្រុកកាំងតាំង តាំងបន្ទាយនៅទីនោះ។

បម្រើសេះក៏នាំយកសេចក្តីចូលទៅប្តឹង**ស៊ុនគួន**ថា ឥឡូវ**ចូឆ្វ**លើកកងទ័ពប្រហែល៤០ម៉ឺន មកបោះបន្ទាយនៅព្រំប្រទល់ដែនស្រុកហាប់ប៉ានិងស្រុកយើងហើយ។ **ស៊ុនគួន**ឮដូច្នោះក៏ភ័យខ្លាំងណាស់ ទើបចាត់ប្រើ**តាំងស៊ិត** និង**ស៊ីសេង**ឲ្យនាំទូកចម្បាំងហាសិបចេញទៅរាំងទ័ពនៅមាត់ពាមយីស៊្វ ប្រើ**តាន់ប៊្វូ**ឲ្យនាំទាហានទៅយាមល្បាតតាមក្បែរមាត់ទន្លេ។ **ទៀវចៀវ**ក៏និយាយនឹង**ស៊ុនគួន**ថា វេលានេះ**ចូឆ្វ**ទើបនឹងលើកពលមកដល់ ពលកំពុងនឿយហត់ គួរនឹងលើកទ័ពទៅខ្ទប់វាយឲ្យទាហាន**ចូឆ្វ**ថយកម្លាំងចុះ ទើបធ្វើការនឹងមានជ័យជម្នះតទៅ។ **ស៊ុនគួន**យល់ឃើញត្រូវ ទើបសួរនាយទាហានទាំងអស់ថា នរណានឹងអាសាចេញទៅធ្វើការតាមពាក្យ

**ទៀវចៀវ**បាន? **ឡេងថង**ឆ្លើយទទួលអាសាថា ខ្ញុំបាទនឹងសុំទាហានបីរយនាក់លើកទៅប្លន់បន្ទាយន**ចូឆ្វូ**ឲ្យបាន។ **កាំឡេង**ឆ្លើយថា **ឡេងថង**នឹងយកទាហានបីរយនោះច្រើនណាស់ ខ្ញុំបាទនឹងសុំតែទាហានមួយរយនាក់ លើកទៅធ្វើការយកជ័យជម្នះឲ្យបាន។

ខណៈនោះ**កាំឡេង** និង**ឡេងថង**ប្រកែកគ្នាមិនទាន់ព្រមចុះសម្រុងគ្នា **ស៊ុនគួន**ក៏និយាយនឹង**កាំឡេង**ថា ឯគំនិតនឹងរិះគិត និងថ្វីដៃទាហាន**ចូឆ្វូ**នោះជ្រៅទូលាយខ្លាំងពូកែណាស់ អ្នកកុំមើលងាយឡើយ ត្រូវឲ្យ**ឡេងថង**ទៅចុះ ថាហើយក៏ចាត់ចែងទាហានឲ្យ**ឡេងថង**បីពាន់នាក់។ **ឡេងថង**ក៏លា**ស៊ុនគួន** លើកទាហានចេញទៅដល់ព្រំប្រទល់ដែនស្រុកហាប់ប៉ា ក៏ប្រទះនឹង**ទៀវលៀវ**ជាមេកងទ័ពមុខខាង**ចូឆ្វូ**។ **ទៀវលៀវ**ក៏បរសេះរាំលំពែងចូលប្រយុទ្ធគ្នានឹង**ឡេងថង**បានហាសិបភ្លួង នៅមិនទាន់ឈ្នះគ្នា។

ឯ**ស៊ុនគួន**កាលប្រើ**ឡេងថង**ចេញទៅនោះ ក៏គិតបារម្ភក្រែង**ឡេងថង**នឹងថ្លោះការដោយទាហាន**ចូឆ្វូ** ទើបប្រើ**លីបង**លើកទាហានជំនួយទៅបម្រុងជួយ **លីបង**ក៏លើកចេញទៅជួបនឹង**ឡេងថង** ក៏នាំគ្នាតម្រង់ទៅបន្ទាយយីស៊ូ **កាំឡេង**និយាយជម្រាប**ស៊ុនគួន**ថា ពេលកណ្ដាលយប់នេះ ខ្ញុំបាទសុំតែទាហានមួយរយនាក់ទៅប្លន់បន្ទាយ**ចូឆ្វូ**ឲ្យបាន បើខូចទាហានតែម្នាក់ក្តី សុំកុំឲ្យលោកលើកសេចក្តីគាប់ប្រសើរឲ្យខ្ញុំបាទឡើយ។

**ស៊ុនគួន**ឮដូច្នោះក៏អរណាស់ ព្រោះធ្លាប់បានឃើញថ្វីដៃ**កាំឡេង**មកហើយ ទើបចាត់ទាហានសេះដែលមានថ្វីដៃមួយរយនាក់ និងស្រាហាសិបឪទិន សាច់ពពែដប់ជញ្ជីងឲ្យ**កាំឡេង** ៗក៏ប្រើមនុស្សរែកស្រានិងរបស់ផ្សេងៗ ហើយនាំទាហានទៅឯបន្ទាយ **កាំឡេង**ក៏យកផ្តិលប្រាក់ដងស្រាផឹកអស់ពីរផ្តិល ហើយស្រែកប្រកាសប្រាប់ទាហានទាំងពួងថា វេលានេះចៅហ្វាយយើងប្រើឲ្យទៅប្លន់បន្ទាយ**ចូឆ្វូ** អស់អ្នករាល់គ្នាត្រូវជួយពួតដៃធ្វើការនោះឲ្យពេញកម្លាំង និងសតិបញ្ញា ទើបនឹងបាន

ជ័យជម្នះ។ ទាហានទាំងមួយរយនាក់បានស្ដាប់ឮដូច្នោះក៏នាំគ្នាគិតថា បើគ្នាយើងតែមួយរយនាក់ដូច្នេះ នឹងអាចទៅប្លន់បន្ទាយ**ចូឆ្វ**បានឬ ហើយក៏ដាក់មុខជ្រប់ជាទុក្ខគ្រប់គ្នា។

**កាំឡេង**ឃើញដូច្នោះក៏ខឹងណាស់ ហូតគ្រប៊ីកាន់លើកឡើងហើយថា ខ្លួនយើងជាទាហានឯក មិនបានស្រឡាញ់ជីវិតប៉ុន្មានទេ អស់ឯងរាល់គ្នាសុទ្ធតែជាកូនទាហានទេតើហេតុម្ដេចខ្លាចស្លាប់ខ្លាំងម្ល៉េះ? វេលានេះ បើនរណានៅរួញរាញញើតមិនស្មើចិត្តនឹងធ្វើការទេ យើងនឹងយកគ្រប៊ីនោះកាត់ក្បាលចេញ។ ទាហានទាំងនោះឮពាក្យ**កាំឡេង**និយាយដូច្នោះក៏ខ្លាចទាំងអស់គ្នា នាំគ្នាឆ្លើយទទួលថា យើងខ្ញុំទាំងអស់គ្នានឹងសុំយកអាសាទៅប្លន់បន្ទាយ**ចូឆ្វ**ឱ្យបាន។ **កាំឡេង**មានអំណរណាស់ ទើបយកសាច់ពពែនិងស្រានោះចែកឱ្យទាហានទាំងអស់គ្នាស៊ីផឹកតាមសប្បាយ។

លុះដល់ពេលព្រលប់ **កាំឡេង**ឱ្យយករោមក្ងានមកដោតនៅមួកទាហានទាំងអស់ជាសម្គាល់ ហើយឱ្យតែងខ្លួនពាក់ក្រោះចងសេះត្រៀមទុកព្រម លុះដល់ពេលយាមមួយ **កាំឡេង**ក៏ឡើងសេះកាន់លំពែងនាំទាំហានទាំងអស់ទៅពួនបង្កប់នៅលើកំពូលភ្នំមួយអន្លើលុះបានចំណាប់ហើយ ក៏នាំទាហានពារទម្លាយបន្ទាស្រែកហ៊ោចូលទៅចោមវាយបន្ទាយ**ចូឆ្វ** ហើយយកភ្លើងអុជបន្ទាយនោះឆេះឡើងច្រើនតំបន់ ពួកទាហាន**កាំឡេង**ទាំងមួយរយនាក់នោះ ក៏ដេញកាប់សម្លាប់ទាហាន**ចូឆ្វ**ស្លាប់ជាច្រើនណាស់។ **ចូឆ្វ**និងពួកទាហានក៏ភ័យភ្ញាក់តក់ស្លុតបែកព្រាត់ព្រាយធ្លាយបន្ទាយជាជ្រួលច្របល់ ខ្លះលោតទៅជល់ដួលទង្គិចទង្គុកបុកជាន់គ្នាស្លាប់របួសពិការនឹងគ្រារាប់ពុំបាន។

វេលានោះ **ស៊ុនគួន**ក៏ចាត់ប្រើ**ជីវថាយ**ឱ្យនាំទាហានជាជំនួយ**កាំឡេង**ទៅប្រាថ្នានឹងបានជួយ**កាំឡេង** ៗឃើញ**ចូឆ្វ**នឹងទាហានរត់បែកធ្លាយពីក្នុងបន្ទាយទៅ ហើយឃើញទាហានទាំងមួយរយនោះមិនមានអន្តរាយ ក៏នាំគ្នាវិលចេញពីក្នុងបន្ទាយ ទៅជួបប្រទះនឹង**ជីវថាយ**ក៏នាំគ្នាត្រឡប់មកវិញ។ ខណៈនោះ**ចូឆ្វ**រត់ចេញ

ទៅប្រមូលពលទាហានបានព្រមព្រៀងហើយ គិតនឹងលើកដិតដោយពីក្រោយ**កាំឡេង**មកវិញ ក៏នឹកបារម្ភខ្លាច**ស៊ុនគួន**ពួនបង្កប់ទាហានទុក ទើបមិនហ៊ានចេញមុខលើកតាម ត្រៀមតែទាហានបម្រុងក្នុងទីនោះ។

ឯ**កាំឡេង**និង**ជីវថាយ** ក៏នាំគ្នាវិលមកជិតបន្ទាយ ទទួលភ្លឺស្រាងឡើង **ស៊ុនគួន**ដឹងដំណឹងថា **កាំឡេង**ទៅប្លន់បន្ទាយ**ចូឆូ**បានបែកធ្លាយក៏សប្បាយចិត្តណាស់ ទើបឲ្យទាហានគោះគងទូងភេរីវាយឃោះប៉ោអឹងកង **ស៊ុនគួន**ក៏ចេញទៅទទួល**កាំឡេង**ដល់ក្រៅបន្ទាយ។ **កាំឡេង**ឃើញ**ស៊ុនគួន**ចេញទៅទទួល ក៏លោតចុះពីលើសេះ ចូលទៅគំនាប់**ស៊ុនគួន** ៗក៏ចូលទៅចាប់ដៃ**កាំឡេង**នាំត្រឡប់ចូលទៅក្នុងបន្ទាយហើយថា អ្នកបានទទួលអាសាគ្រានេះ ធ្វើឲ្យអាសត្រូវកញ្ជាស់ប្រាសចោលបន្ទាយ ភ័យវាយមាយស្មារតី ហើយខូចបង់ទាហានរបស់វាជាក្រៃលដូច្នោះ ឈ្មោះរបស់អ្នកក៏ប្រាកដល្បីឮរន្ទឺតទៅមុខវែងឆ្ងាយណាស់ ខ្លួនយើងមិនមែនមិនស្រឡាញ់អ្នកនោះក៏ទេ តែគិតថានឹងឲ្យទាហានទាំងពួងបានឃើញថ្វីដៃអ្នកឲ្យច្បាស់ប្រាកដ យើងក៏បានឲ្យ**ជីវថាយ**នាំទាហានជំនួយទៅបម្រុងជួយហើយ។ **ស៊ុនគួន**ក៏យកដារយ៉ាងល្អមួយរយ ឲ្យជាបំណាច់រង្វាន់**កាំឡេង** ៗទទួលគំនាប់យករបស់ទាំងនោះហើយ ក៏យកទៅចែកឲ្យទាហានទាំងមួយរយនាក់។ **ស៊ុនគួន**ឃើញដូច្នោះក៏រឹតតែមានសេចក្ដីត្រេកអរ ហើយថា **ចូឆូ**បាន**ទៀវលៀវ**ទុកជាទាហានឯក យើងក៏បាន**កាំឡេង**ទុកជាទាហានឯក ល្មមនឹងតស៊ូជាមួយ**ទៀវលៀវ**បានដែរ។

លុះវេលាព្រឹក **ចូឆូ**ក៏ប្រើ**ទៀវលៀវ, លីទៀន** និង**ង៉ាក់ជិន**ឲ្យនាំទាហានទៅស្រែកជេរបញ្ឈឺចិត្តនៅមុខបន្ទាយ**ស៊ុនគួន**។ **ឡេងថង**បានឮដូច្នោះក៏គិតថា ខ្លួនអញជាហរិគ្នានឹង**កាំឡេង** វេលានេះ**កាំឡេង**ធ្វើការបានសេចក្ដីគាប់ប្រសើរច្រើនគ្រា ដូច្នេះគួរតែអញនឹងយកអាសាចេញទៅច្បាំងគ្នានឹង**ទៀវលៀវ** ដើម្បីនឹងបានសេចក្ដីគាប់ប្រសើរស្មើនឹង**កាំឡេង**ឲ្យបាន។ គិតហើយក៏ចូលទៅនិយាយនឹង**ស៊ុនគួន**ថា ខ្ញុំ

បាទនឹងសុំអាសាចេញទៅច្បាំងឲ្យ**ទៀវលៀវ**បរាជ័យឲ្យបាន។ **ស៊ុនគួន**ក៏ចាត់ទាហានឲ្យ**ឡេងថង**ប្រាំពាន់នាក់ ហើយ**ឡេងថង**ក៏នាំទាហានចេញចាកបន្ទាយ។

វេលានោះ **ស៊ុនគួន**ក៏នាំទាហាន និង**កាំឡេង**ចេញទៅ ប្រាថ្នានឹងមើលកលការ**ឡេងថង**ច្បាំងនឹង**ទៀវលៀវ**។ **ឡេងថង**ឡើងសេះចេញទៅមុខបន្ទាយ ឃើញ**លីទៀន**និង**ង៉ាក់ជិន**បញ្ឈរសេះអម**ទៀវលៀវ**ទាំងឆ្វេងស្តាំ។ **ឡេងថង**ស្រែកថា **ទៀវលៀវ**ដែលមកស្រែកជេរបញ្ឈឺចិត្តហើយ ត្រូវតែចេញមុខមកតស៊ូគ្នាឲ្យឃើញថ្វីដៃ។ **ទៀវលៀវ**ឮដូច្នោះក៏ប្រើ**ង៉ាក់ជិន**ឲ្យឡើងសេះចេញទៅច្បាំងនឹង**ឡេងថង**បានហាសិបភ្លែងមិនទាន់ចាញ់ឈ្នះគ្នា។

ខណៈនោះ **ចូឆ្វ**ក៏លើកទាហានជូនតាមទៅទៀត ឃើញ**ង៉ាក់ជិន**និង**ឡេងថង**ច្បាំងជាប់ដៃគ្នា **ចូឆ្វ**ក៏បង្គាប់**ចូហ៊ីវ**ឲ្យលបយកធ្នូបាញ់**ឡេងថង**ប្រាថ្នានឹងជួយ**ង៉ាក់ជិន**។ **ចូហ៊ីវ**លើកធ្នូបាញ់ទៅត្រូវសេះ**ឡេងថង**។ សេះនោះក៏ភ្ញាក់ស្ទុះច្រឡោតឡើង **ឡេងថង**ក៏របូតធ្លាក់ពីលើសេះដួលទៅលើផែនដី។ **ង៉ាក់ជិន**ឃើញបានចំណាប់ក៏បំបោលសេះចូលទៅលើកលំពែងឡើងនឹងចាក់**ឡេងថង** ទទួល**កាំឡេង**យឹតធ្នូបាញ់ទៅ ត្រូវកំផ្លៀង**ង៉ាក់ជិន**ធ្លាក់ពីលើសេះ។ ទាហានទាំងសងខាងក៏ស្ទុះចូលទៅជួយគ្នានាំយក**ង៉ាក់ជិន**និង**ឡេងថង**ចេញពីក្នុងទីចម្បាំងបាន។

**ស៊ុនគួន**និយាយប្រាប់**ឡេងថង**ថា កាលអ្នកឯងធ្លាក់ពីលើសេះ **ង៉ាក់ជិន**ស្ទុះទៅលើកលំពែងប្រុងនឹងចាក់អ្នកឯងហើយ បើកុំតែ**កាំឡេង**យឹតធ្នូបាញ់**ង៉ាក់ជិន**ធ្លាក់ពីលើសេះទាន់ កុំអីអ្នកឯងនឹងស្លាប់ដោយលំពែង**ង៉ាក់ជិន**មិនខានទេ។ **ឡេងថង**ឮដូច្នោះក៏ក្រោកឡើងគំនាប់**កាំឡេង**ហើយថា អ្នកបានជួយឲ្យគង់ជីវិតគ្រានេះ គុណរបស់អ្នកជាទម្ងន់នឹងរកអ្វីប្រៀបមិនស្មើបានទេ។ ដែលខ្ញុំមានចិត្តគិតអាឃាតព្យាបាទអ្នកមកពីដើមនោះ ខ្ញុំសូមអភ័យទោសចុះ ពីថ្ងៃនេះទៅ ខ្ញុំសូមតាំងចិត្តលំអុតលំឱនដល់អ្នកជាដរាប។ **កាំឡេង**ឮដូច្នោះក៏សោមនស្សណាស់ ទាំងពីរនាក់ក៏តាំង

អធិដ្ឋានស្បថស្បាន់ថា យើងទាំងពីរតាំងពីថ្ងៃនេះទៅ ត្រូវទុកគ្នាជាមិត្តមេត្រីអស់សេចក្ដីសង្ស័យនឹងគ្នាហើយ។

ឯ**ចូឆ្វ**នោះ លុះត្រឡប់ចូលទៅក្នុងបន្ទាយវិញ ក៏ឲ្យពេទ្យថែរក្សារបួសព្រួញ **ង៉ាក់ជិន** ហើយគិតថា ត្រូវចាត់ទាហានចេញទៅព័ទ្ធវាយបន្ទាយ**ស៊ុនគួន**ជាប្រាំផ្លូវ ទើបមានជ័យជម្នះបាន។ លុះព្រឹកឡើង **ចូឆ្វ**ក៏លើកទាហានជាកងកណ្ដាល ឲ្យ**ទៀវលៀវ** និង**លីទៀន**នាំទាហានម្នាក់មួយម៉ឺនលើកញែកគ្នាទៅតាមក្បែរមាត់ទន្លេជាពីរផ្លូវ ឲ្យ**ស៊ីឡុង** និង**បាំងតេក**លើកទាហានម្នាក់មួយម៉ឺនញែកគ្នាទៅតាមក្បែរជើងភ្នំជាពីរផ្លូវ លុះចាត់ចែងរួចហើយ **ចូឆ្វ**និងនាយទាហានទាំងបួនកង ក៏នាំទាហានចេញទៅព្រមគ្នា។

ឯ**តាំងស៊ិត** និង**ស៊ីសេង**ក៏លើកទាហានទូកច្បាំងទៅនោះ លុះឃើញកងទ័ព**ចូឆ្វ**លើកប្រពាក់ប្រពូនមក ឃើញពួកកូនទាហានក្នុងទូកចម្បាំងនោះ មុខស្លេកស្លាំងភ័យស្លុតទាំងអស់គ្នា **ស៊ីសេង**ថា ធម្មតាជាជាតិទាហានស៊ីបៀវត្សរ៍លោកហើយ បើមានសង្គ្រាមមកក៏ត្រូវតាំងចិត្តគិតតែច្បាំងមិនត្រូវកោតញញើតឡើយ។ ដូចជាអ្នករាល់គ្នាទាំងអស់នេះ គ្រាន់តែឃើញសត្រូវមកពីចម្ងាយ ក៏ឲ្យមានសេចក្ដីតក់ស្លុតដូច្នេះនឹងធ្វើជាទាហានដូចម្ដេចកើត! ឥឡូវយើងត្រូវតែចេញតស៊ូនឹងសត្រូវ ហើយបើរណារួញរាញញើត យើងនឹងកាត់ក្បាលចេញ ហើយនាំទាហានបីរយចុះទូកតូចឡើងទៅលើឆ្នេរខ្សាច់ ហើយក៏ចូលទៅប្រកាប់ប្រចាក់គ្នាជ្រួលច្របល់នឹងទាហាន**លីទៀន**។

**តាំងស៊ិត**នៅក្នុងទូកចម្បាំងឃើញដូច្នោះ ក៏ឲ្យទាហានគោះគងទូងភេរីហ៊ោស្រែកបន្លឺស័ព្ទខ្ទរខ្ទារ ទទួលផ្លាក់ខ្យល់ព្យុះសង្ឃរាសន្ធឹកណាស់ សំឡេងឮលាន់ទាំងរលកសមុទ្រក៏បោកបែកផ្កាត្រែង ផ្សែងចុះអ័ព្ទងងឹតគ្រប់ទិសទាំងពួង ឯបណ្ដាទូកចម្បាំងទាំងអស់ក៏លោតរលកផ្អៀងក្រឡាប់ដូចជានឹងលិចចុះ ពួកទាហានទាំងអស់

នោះក៏ភ័យតក់ស្លុតខ្លាចទូកនឹងលិច ក៏ស្ទុះរត់ជ្រួលច្របល់ប្រាថ្នានឹងចុះទូកតូចទៅឡើងលើឆ្នេរខ្សាច់ ឲ្យរួចពីសេចក្ដីស្លាប់។

**តាំងស៊ិត**ឃើញដូច្នោះក៏នឹកខឹងខ្លាំងណាស់ ហូតគ្រប៊ីចេញដេញកាប់សម្លាប់ទាហានអស់ប្រហែលដប់បួន ដប់ប្រាំនាក់ ហើយស្រែកប្រកាសថា ចៅហ្វាយរបស់យើងប្រើឲ្យចេញមកវាំងទ័ព ទទួលផ្កាក់ខ្យល់ព្យុះយ៉ាងខ្លាំងដល់ប៉ុណ្ណេះ អ្នករាល់គ្នាក៏គិតរត់ឡើងគោក បើខំតែចចេសឡើងទៅ យើងនឹងកាប់សម្លាប់ឲ្យអស់។

ខណៈនោះខ្យល់ព្យុះក៏មិនស្ងប់ រឹតតែបក់បោកមកខ្លាំងណាស់ រលកក៏កាន់តែខ្លាំងឡើង ទូកចម្បាំងដែលបោះយុថ្កាក្នុងទន្លេនោះក៏របើកដាច់ខ្សែច្រវាក់លិចបាត់ជាច្រើន។ ទូកដែល**តាំងស៊ិត**ជិះនោះក៏លិចបាត់ទៅទៀត **តាំងស៊ិត**ក៏ខំតែហែលទឹកទាល់តែអស់កម្លាំងលង់ទឹកស្លាប់ ទាហានទាំងពួងក៏លង់ស្លាប់ជាច្រើន។

ឯ**តាន់ប៉ូ** ដែលជាកងក្រវែលឃើញ**បាំងតេក**នាំទាហានមកតាមជើងភ្នំ **តាន់ប៉ូ**ក៏បរពលចូលប្រកាប់ជាប់ដៃគ្នាជាជ្រួលច្របល់។ ខណៈនោះ**ស៊ុនគួន**ដឹងការ ក៏ឡើងសេះនាំ**ជីវថាយ**និងទាហានស្រូតរូតទៅ ឃើញ**ស៊ីសេង**និង**លីទៀន**លើកទាហានចូលច្បាំងគ្នា **ស៊ុនគួន**ក្រែងទាហាន**ស៊ីសេង**តិច មិនធួននឹងការពារខ្លួនបានក្រែងថ្លោះការ **ស៊ុនគួន**និង**ជីវថាយ**ក៏លើកទាហានចូលទៅជួយ**ស៊ីសេង** ច្បាំងនឹងទាហាន**ចូឆូ**ជាជ្រួលច្របល់។ **ទៀវលៀវ**និង**ស៊ីឡុង**ឃើញដូច្នោះ ក៏លើកទាហានវាយខ្ទប់ ប្រសព្វព័ទ្ធ**ស៊ុនគួន**ទៅក្នុងចំណោម។ **ចូឆូ**នៅលើភ្នំក្រឡេកឃើញបានចំណាប់ ក៏បង្គាប់**ខៅធូ**ឲ្យចុះទៅជួយ ដើម្បីមិនឲ្យ**ស៊ុនគួន**ជួយគ្នាបាន។ ខណៈកាលច្បាំងគ្នាជាជ្រួលច្របល់នោះ **ជីវថាយ**និង**ស៊ុនគួន**ក៏ឃ្លាតព្រាត់ពីគ្នា **ជីវថាយ**បរបំបោលសេះស្កាត់រុករក**ស៊ុនគួន**ចេញទៅដល់មាត់ទ្វារទន្លេក្រៅ ទើបស្រែកសួរទាហានថា ឃើញចៅហ្វាយយើងនៅឯណា? មានទាហានម្នាក់ចង្អុលប្រាប់ថា ឃើញ**ស៊ុនគួន**នៅខាងនោះ។ **ជីវថាយ**ក៏បំបោលសេះពុះទម្លាយកងទ័ពចូលទៅប្រទះនឹង**ស៊ុនគួន** ហើយថា លោកខំបំបោលសេះតាមខ្ញុំបាទមកចុះ ខ្ញុំបាទនឹងនាំចេញឲ្យផុតពីចំណោមទ័ព

សត្រូវ។ **ស៊ុនគួន**ទទួលប្រុងប្រៀបខ្លួនហើយ **ជីវថាយ**ក៏យកសេះបង្រុះកងទ័ព**ចូវឆូ**ចេញទៅដល់មាត់ទន្លេ លុះក្រឡេកមកក្រោយមិនឃើញ**ស៊ុនគួន**ក៏ភ័យស្លុតស្មារតីត្រឡប់បរសេះពុះពារកងទ័ព ទៅក្នុងចំណោមធំវិញក៏ប្រទះនឹង**ស៊ុនគួន**។ **ជីវថាយ**ក៏ថាឲ្យលោកស្រួតប្រញាប់បរសេះតាមខ្ញុំបាទឲ្យទាន់ចុះ។ **ស៊ុនគួន**ថា យើងតាមអ្នកចេញទៅអម្បាញ់មិញនេះសត្រូវបាញ់ធ្នូមកខ្លាំងណាស់ បានជាព្រាត់ឃ្លាតឃ្លា។ **ជីវថាយ**ថា បើដូច្នោះឲ្យលោកបរសេះទៅមុខខ្ញុំបាទចុះ ខ្ញុំបាទនឹងការពារពីក្រោយមិនឲ្យព្រួញមកត្រូវបាន។ **ស៊ុនគួន**បរសេះទៅមុខ**ជីវថាយ** ៗបរពីក្រោយ ហើយយកដាវគ្រវីកាត់ព្រួញមិនឲ្យមកជិតបាន។ លុះចេញទៅដល់មាត់ទន្លេ ទទួល**លីបង**នាំទាហានចែវទូកចម្បាំងមកដល់ ក៏ទទួលយក**ស៊ុនគួន**ឲ្យចុះទូកជាមួយនឹង**ជីវថាយ**និងទាហានប្រហែលជាសែសិបទៅហាសិបនាក់ចុះទូក។ **ស៊ុនគួន**ក៏សរសើរថ្វីដៃ**ជីវថាយ**ដែលបានពុះពារទម្លាយកងទ័ព**ចូវឆូ**ចូលចេញទៅមកជាច្រើនសា តែយើងនៅគិតព្រួយដល់**ស៊ីសេង** ដែលនៅក្នុងចំណោមទ័ព**ចូវឆូ**នោះ មិនដឹងជាយ៉ាងណាឡើយ នរណាឡើយនឹងអាចចូលទៅជួយយក**ស៊ីសេង**ឲ្យបាន។ **ជីវថាយ**ទទួលថា ខ្ញុំបាទសុំអាសាចូលទៅម្តងទៀត ថាហើយក៏ចាប់លំពែងលោតចេញពីក្នុងទូក ឡើងសេះពុះទម្លាយកងទ័ព**ចូវឆូ**ទៅ ក៏ប្រទះនឹង**ស៊ីសេង**នៅក្នុងចំណោមទ័ព ហើយក៏ត្រឡប់នាំគ្នាពារកងទ័ព**ចូវឆូ**ចេញមកវិញ។ ខណៈនោះ**ជីវថាយ**និង**ស៊ីសេង**ត្រូវរបួសដោយអាវុធមុតរលុះសាច់អស់ទាំងខ្លួនជាច្រើនអន្លើ។ **លីបង**នៅក្នុងទូកចម្បាំង ក៏ឲ្យទាហានបាញ់ធ្នូតម្រង់ទៅជួយការពារ**ជីវថាយ**និង**ស៊ីសេង** អ្នកទាំងពីរក៏ដោះខ្លួនលោតចុះមកក្នុងទូកបាន។

ឯ**តាន់ប៊ូ**ច្បាំងនឹង**បាំងតេក**ជាប់ដៃគ្នាជាយូរណាស់ ទាហានទាំងសងខាងក៏ពិការស្លាប់ជាច្រើន **តាន់ប៊ូ**អស់កម្លាំងព្រាត់សេះរត់ទៅក្រោយ **បាំងតេក**ក៏ដេញបណ្តោយទៅ **តាន់ប៊ូ**បំផាយសេះរត់ទៅតាមច្រកជើងភ្នំជាទីចង្អៀតមួយអន្លើ មែក

ឈើដែលឃួរនៅក្បែរផ្លូវក៏ផ្តក់ក្រើសជាប់ **តាន់ប៊ូ**ត្រឡប់ងាកខ្លួនឲ្យរបូតពីមើកឈើពុំទាន់ ទទួល**បាំងតេក**ដេញទៅទាន់ ក៏យកដាវកាប់**តាន់ប៊ូ**ធ្លាក់ពីលើសេះស្លាប់។

**ចូឆ្វ**ក្រឡេកទៅឃើញ**ស៊ុនគួន**រត់ចុះទូក ក៏លើកទាហានចុះតាមទៅដល់ក្បែរមាត់ទន្លេ **ស៊ុនគួន**និង**លីបង**ឃើញដូច្នោះ ក៏ឲ្យទាហានចុះទូកចម្បាំងបាញ់ធ្នូតម្រង់ទៅជាច្រើន។ ទទួល**ឡុកស៊ុន**ជាកូនប្រសា**ស៊ុនសេក**នាំទូកចម្បាំងនិងបញ្ចុះទាហានប្រមាណដប់ម៉ឺនបើក្តោងមកដល់ ក៏ឲ្យទាហានទាំងនោះបាញ់ធ្នូឡើងទៅព្រមគ្នា ព្រួញក៏ធ្លាក់ទៅបីដូចគ្រាប់ភ្លៀង ហើយ**ឡុកស៊ុន**ក៏នាំទាហានឡើងពីទូកទៅលើគោកចូលទៅតតាំងច្បាំងនឹងទាហាន**ចូឆ្វ** ៗនឿយអស់កម្លាំងណាស់ក៏ថយចូលបន្ទាយ។ ទាហាន**ឡុកស៊ុន**បានឃើញសព**តាន់ប៊ូ** ក៏នាំទៅឲ្យ**ស៊ុនគួន** ៗមានសេចក្តីអាណិតអានាថពន់ប្រមាណណាស់ គិតនឹកដល់**តាំងស៊ិត**ដែលលិចទូកលង់ទឹកស្លាប់ **ស៊ុនគួន**ក៏បង្គាប់ទាហានឲ្យយកអួនទៅអូសដឹកយកសព**តាំងស៊ិត**បាន ហើយក៏ឲ្យរង្វាន់ទាហានជាមាសប្រាក់ ហើយឲ្យនាំយកសព**តាន់ប៊ូ** និង**តាំងស៊ិត**ហែទៅបញ្ចុះទុកឯស្រុកកាំងតាំង។

**ស៊ុនគួន**ក៏នាំទូកចម្បាំងត្រឡប់ទៅបន្ទាយយីស៊ូ ហើយ**ស៊ុនគួន**ក៏គិតដល់សេចក្តីគាប់ប្រសើររបស់**ជីវថាយ** ទើបឲ្យរៀបតុលៀងអាហារ **ស៊ុនគួន**ក៏ចាក់ស្រាឲ្យ**ជីវថាយ**ផឹកផ្ទាល់ដៃ ទើបស្រដីទៅកាន់**ជីវថាយ**ថា ខ្លួនអ្នកបានតាំងចិត្តសុចរិតត្រង់នឹងយើងក្នុងគ្រានេះ គឺស៊ូប្តូរជីវិតមិនគិតស្លាប់ អាចចូលទៅប្រកាប់ពុះទម្លាយកងទ័ព**ចូឆ្វ** ប្តូរជីវិតអាចទាក់យកជីវិតខ្ញុំឲ្យចេញរួចមកបាន អ្នកក៏មានគុណនឹងខ្ញុំរកអ្វីប្រៀបផ្ទឹមពុំត្រឹមស្មើ ឧបមាដូចខ្ញុំស្លាប់ទៅហើយក្នុងចំណោមទ័ព**ចូឆ្វ** អ្នកទៅនាំយកសពខ្ញុំមកជប់ប្រោះឲ្យរស់វិញ។ ខ្ញុំសុំតាំងឲ្យអ្នកត្រួតបង្គាប់លើទាហានស្រុកកាំងតាំងពាក់កណ្តាល ឯខ្លួនអ្នកនិងខ្ញុំនោះត្រូវតែស្មោះត្រង់ស្រឡាញ់គ្នាជាបងប្អូនដូចរួមផ្ទៃជាមួយចុះ ហើយឲ្យ**ជីវថាយ**ដោះអាវចេញ ឃើញរបួសដោយអាវុធសុះអស់ទាំងខ្លួន។ ទាហានទាំងពួងឃើញក៏គ្រវីក្បាលទាំងអស់គ្នា។

**ស៊ុនគួន**សួថា របួសនេះត្រូវនឹងអាវុធត្រង់ទីណា? **ជីវថាយ**ថា របួសនេះត្រូវនឹងអាវុធកាលខ្ញុំបាទចូលទៅរកលោក របួសនេះត្រូវនឹងគ្រប់កាលបែកភ្លាត់បាត់លោកទៅ។ **ជីវថាយ**ប្រាប់របួសអស់គ្មានសល់ត្រង់ណា។ **ស៊ុនគួន**ក៏ចាក់ស្រាឲ្យផឹកម្តង ទាល់តែ**ជីវថាយ**ស្រវឹងដេកលក់ទៅ **ស៊ុនគួន**ក៏ឲ្យទាហានគ្រាហ៍យកខ្លួន**ជីវថាយ**ដាក់លើរទេះ ហើយឲ្យយកសប្បធន់មកបាំងពីលើ**ជីវថាយ**ឲ្យបរជូនទៅដល់បន្ទាយ។

ខណៈនោះ **ចូឆូ**និង**ស៊ុនគួន**ទើបតែធ្វើសង្គ្រាមនឹងគ្នាចំនួនមួយខែប្លាយ។ **ទៀវចៀវ**និយាយនឹង**ស៊ុនគួន**ថា តាំងពីលោកធ្វើសង្គ្រាមនឹង**ចូឆូ**មកក៏បានជាងមួយខែហើយ ទាហានទាំងសងខាងក៏ស្លាប់វិនាសជាច្រើនណាស់ ឯ**ចូឆូ**នោះក៏ចំណានស្ទាត់ក្នុងការសង្គ្រាមណាស់។ លោកនឹងគិតយកជ័យជម្នះមិនងាយនឹងបានទេ។ បើចេះតែតតាំងច្បាំងគ្នាទៅទៀត មុខជានឹងខូចខាតទាហានច្រើនណាស់ ការនេះគួរតែលោករកមនុស្សឲ្យចេញទៅនិយាយនឹង**ចូឆូ**ថា បើដល់ឆ្នាំខែកំណត់ហើយ យើងនឹងតែងគ្រឿងបណ្ណាការនាំទៅគំនាប់តាមទំនៀម។ **ស៊ុនគួន**យល់ឃើញត្រូវ ក៏ប្រើ**ប៉ោជិត**ជាបម្រើឲ្យទៅក្នុងបន្ទាយ**ចូឆូ** ៗក៏ហៅខ្លួនចូលទៅសួរ **ប៉ោជិត**គំនាប់ហើយជម្រាបថា **ស៊ុនគួន**ប្រើខ្ញុំបាទមកជម្រាបលោកថា ដែលនឹងតតាំងគ្នាតទៅនោះឃើញថា ទាហានទាំងសងខាងនឹងវិនាសអន្តរាយច្រើនណាស់ មិនជាប្រយោជន៍អ្វីទេ គួរតែលោកនឹងលើកកងទ័ពត្រឡប់ទៅវិញសិន បើដល់កំណត់ឆ្នាំ សឹមតែងគ្រឿងបណ្ណាការទៅឡើងលោកតាមទំនៀមប្រពៃណីតាមទីធំ និងតូច។

**ចូឆូ**តបថា ខ្លួនយើងជាចាស់ យសស័ក្តិក៏ធំជាងចៅហ្វាយនាយអ្នកឯង ចៅហ្វាយនាយអ្នកឯងនៅក្មេងជាងយើង ដែលនឹងឲ្យយើងលើកទ័ពត្រឡប់ទៅមុននោះ យើងក៏មានសេចក្តីអៀនខ្មាសណាស់ ចូរអ្នកឯងវិលទៅប្រាប់**ស៊ុនគួន**ចៅហ្វាយអ្នកឯងចុះថា ឲ្យលើកទ័ពត្រឡប់ទៅស្រុកមុនយើង សឹមយើងលើកទ័ពត្រឡប់ទៅវិញជាក្រោយ។ **ប៉ោជិត**ក៏លា**ចូឆូ**មកវិញប្រាប់**ស៊ុនគួន** ៗបានស្តាប់ឲ្យ

**ជីវថាយ**និង**ជីវឃឹម**នៅរក្សាបន្ទាយយីស៊ូ ហើយ**ស៊ុនគួន**ក៏លើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ។ ឯ**ចូឆូ**ក៏ឲ្យ**ទៀវលៀវ**និង**ចោយិន**នៅរក្សាបន្ទាយហាប់ប៉ា ហើយ**ចូឆូ**ក៏លើកទ័ពត្រឡប់ទៅស្រុកហ៊ូតោវិញ។

លុះកន្លងមកយូរថ្ងៃ ទីប្រឹក្សានិងសេនាទាហានច្រើននាក់ បានទៅជួបជុំជំនុំប្រឹក្សាយល់ព្រមគ្នានឹងតាំង**ចូឆូ**ជាម្ចាស់វុយអេង។ **ស៊ុនតាំ**បានឮទីប្រឹក្សាពិគ្រោះយល់ព្រមគ្នាដូច្នោះក៏ឆ្លើយថា ដែលអស់អ្នកទាំងឡាយនឹងចង់តាំង**ចូឆូ**ជាម្ចាស់វុយអេងនោះ ខ្ញុំមិនទាន់យល់ឃើញផងទេ។ មន្ត្រីទាំងពួងឮដូច្នោះក៏ឆ្លើយឡើងថា អ្នកឯងមិនដឹងទេឬ? កាលគ្រា**ស៊ុនហុក**រឹងទទឹងពីជាន់មុននោះ ក៏លុះដល់នូវសេចក្ដីស្លាប់អសារឥតការ។ **ស៊ុនតាំ**ឮដូច្នោះក៏ខឹងខ្លាំងណាស់ថា គ្រានេះអស់អ្នកបានចំណាប់ហើយ នឹងចង់ធ្វើអ្វីដល់ខ្លួនខ្ញុំក៏ត្រូវធ្វើទៅចុះ។ ទាហានម្នាក់ឮ**ស៊ុនតាំ**និយាយដូច្នោះ ក៏នាំហេតុនេះទៅជម្រាប**ចូឆូ**។

**ចូឆូ**បានស្ដាប់ហើយ ក៏បង្គាប់ឲ្យយកខ្លួន**ស៊ុនតាំ**ទៅដាក់គុកទុក។ **ស៊ុនតាំ**មានចិត្តឈឺក្ដៅផ្សាជេរប្រមាថ**ចូឆូ**ជាពាក្យទ្រគោះអសុរោះផ្សេងៗគ្រប់វេលា។ ភូឃុំក៏នាំហេតុទៅប្ដឹង**ចូឆូ** ៗឮដូច្នោះក៏ខឹងណាស់ បង្គាប់ឲ្យចងក**ស៊ុនតាំ**ឲ្យទាល់តែដាច់ខ្យល់ស្លាប់។

ក្នុងសម័យនោះព្រះចៅ**ហៀនតេ**ទៅគង់ក្នុងស្រុកហ៊ូតោបាន២១ឆ្នាំ ព.ស ៧៥៩ឆ្នាំ ក្នុងខែជេស្ឋខាងខ្នើតនោះ ពួកនាហ្មឺននិងសេនាទាហានទាំងឡាយដែលមានចិត្តស្រឡាញ់**ចូឆូ**ក៏រួមគំនិតគិតព្រមគ្នាតែងរឿងរ៉ាវ ក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ជាសេចក្ដីថា ដ្បិត**វុយកុង**នេះមានសេចក្ដីគាប់ប្រសើរ បានធ្វើរាជការប្រាបប្រាមបច្ចាមិត្តដែលគិតប្រទូសរ៉ាយផែនដីបានរាបទាបជាច្រើនមកហើយ សូមព្រះរាជទានតាំង**វុយកុង**ឲ្យឡើងស័ក្ដិជាម្ចាស់**វុយអេង**តាំងពីថ្ងៃនេះតទៅ។

ព្រះចៅ**ហៀនតេ** បានទ្រង់ព្រះសណ្ដាប់សេចក្ដីដែលមន្ត្រីទាំងឡាយទូលដូច្នោះ ក៏ត្រាស់បង្គាប់ឲ្យ**ចេងអ៊ីវ**តែងព្រះរាជឱង្ការត្រាតាំង**វុយកុង**ឡើងជាម្ចាស់

**វុយអេង** មានកិត្តិយសជិះរថមាសទឹមសេះបីគូ មានគ្រឿងតែងតួហែហមតាមរបៀបប្រៀបស្មើនឹងម្ចាស់ផែនដី។ **ចេងអ៊ីវ**ក៏ខ្ទាននាមតាមព្រះតម្រាស់ប្រទានទៅឲ្យ**ចូឆ្វូ**។

**ចូឆ្វូ**បានទទួលព្រះរាជឱង្ការត្រាស់តាំងដូច្នោះ ក៏បង្កើតចិត្តសោមនស្សពន់ប្រមាណណាស់គិតថា ស្រុកង៉ៀបគុននោះជាព្រំប្រទល់ដែន គួរតែសាងឲ្យរុងរឿងទុកជាទីទស្សនាដើម្បីជាកេរ្តិ៍យសតទៅខាងមុខ។ គិតហើយក៏ចាត់ភ្នាក់ងារមេការឲ្យចេញទៅកសាងដំណាក់ឃ្លាំងវង់កំផែងចិញ្ចែងចិញ្ចាច មានជីកគូស្នាមភ្លោះសើនឲ្យខ្ពស់ស្រឡះជុំវិញមើលទៅត្រង់រលេញហាក់បីដូចជាទីក្រុងក្នុងស្រុកហ្លួង វេលាទៅមកនឹងមកជាទីអាស្រ័យសំណាក់ ពួកភ្នាក់ងារក៏កេណ្ឌគ្នាទៅធ្វើការនៅស្រុកង៉ៀបគុនតាមបង្គាប់។

ឯ**ចូឆ្វូ**នោះមានបុត្របួននាក់គឺ៖ **ចូភី១, ចូជៀង១, ចូស៊ិត១, ចូហ៊ឹម១** ឯ**ចូស៊ិត**នេះមានសតិបញ្ញាចេះតែងកាព្យឃ្លោង **ចូឆ្វូ**មានចិត្តស្រឡាញ់**ចូស៊ិត**ជាងបុត្រទាំងបីនាក់ បើ**ចូឆ្វូ**នឹងចេញទៅធ្វើសង្គ្រាមវេលាណា បើមិនបានយកបុត្រណាទៅផងបានទេ ក៏មិនមានបុត្រណានឹងអាចតាម មានតែ**ចូភី១**យំតាមបិតា ឯ**ចូជៀង**និង**ចូហ៊ឹម**នៅស្ងៀម តែ**ចូស៊ិត**នោះកាន់ពិតតែងកាព្យឃ្លោងសរសើរកិត្តិយសបិតា ហើយឲ្យពរផ្សេងៗជាច្រើន។

**ចូឆ្វូ**ឃើញដូច្នោះក៏គិតថា **ចូស៊ិត**មានតម្រិះប្រាជ្ញាក៏មែន តែចិត្តច្រើនភ្លើនហួស ឯ**ចូភី**នេះមានគំនិតមារយាទមាំមួន បើនឹងធ្វើការអ្វីក៏គិតដោយជ្រៅទូលាយ។ **ចូឆ្វូ**ក៏គិតថា វេលានេះខ្លួនអញក៏កាន់តែចាស់ជរាហើយ នឹងតាំង**ចូភី**ឬ**ចូស៊ិត**ជំនួសអញតទៅ តែគិតមិនដាច់ស្រេចសោះ វេលានោះ**ចូឆ្វូ**ក៏ប្រឹក្សានឹងមន្ត្រីទាំងពួងថា យើងចង់តាំងបុត្រយើងឲ្យធ្វើជាធំជំនួសខ្លួនយើងតទៅ តើអស់អ្នករាល់គ្នានឹងយល់ឃើញឈ្មោះណាល្មមជាជំនួសយើងបាន? **កាសៀង**ឆ្លើយថា រឿងនេះមិនចាំបាច់ពិគ្រោះនិងប្រឹក្សាទេ សូមឲ្យលោកនឹកមើលដល់រឿង**អ៊្វិនសៀវ** និង**ឡៅពៀវ**នោះ

ចុះ។ **ចូឆូ**សើចហើយថា អ្នកនិយាយនេះគួរប្រពៃណាស់ **ចូឆូ**ក៏តាំង**ចូភី**ជាបុត្រច្បងនោះ ឲ្យមានក្រុមឡើងស្ដាប់បង្គាប់ហៅថាម្ចាស់**ឈីជូ**។

លុះដល់ខែកត្តិកភ្នាក់ងារដែលទៅធ្វើការសាងស្រុកងៀបគុននោះ ប្ដឹងជូនដំណឹងឲ្យទូលម្ចាស់**វុយអេង**ថា ការដែលកសាងវាំងកំផែងនោះរួចជាស្រេចហើយ **ចូឆូ**ឮដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ បង្គាប់ឲ្យចាត់ចែងទាហាន និងរបៀបខាងក្នុងព្រមព្រៀងហើយ ក៏លើកកងទ័ពជាព្យុហយាត្រាតាមក្បួន ហែហមអមដំណើរទៅដល់ស្រុកងៀបគុន ហើយឲ្យមានចុតហ្មាយប្រាប់ទៅអាណាខេត្ត ឲ្យចាត់រកដើមឈើមានផ្កា និងផ្លែដាំជាលម្អជាច្រើន ហើយតែងសំបុត្រមួយច្បាប់ទៀតទៅដល់**ស៊ុនគួន**ចៅហ្វាយស្រុកកាំងតាំងសេចក្ដីថា ព្រះចៅ**វុយអេង**មានព្រះទ័យប្រាថ្នាផ្លែក្រូចក្នុងស្រុកកាំងតាំង ឲ្យ**ស៊ុនគួន**ខំរិះគិតនាំទៅថ្វាយ បម្រើសេះក៏នាំសំបុត្រនោះទៅដល់ស្រុកកាំងតាំង ហើយយកទៅឲ្យ**ស៊ុនគួន**។

**ស៊ុនគួន**ទទួលមើលដឹងសេចក្ដីហើយ ក៏ចាត់ឲ្យមន្ត្រីភ្នាក់ងាររកផ្លែក្រូចបានហាសិបហាប ហើយចាត់ឲ្យរែកសែងនាំចូលទៅថ្វាយ លុះបម្រើនោះទៅដល់ពាក់កណ្ដាលផ្លូវ ពួកអ្នកជើងសែងឈប់សម្រាកកម្លាំងនៅក្បែរជើងភ្នំមួយអន្លើ ក៏ក្រឡេកឃើញមនុស្សប្រុសម្នាក់ចេញពីក្នុងរូងភ្នំ មានជើងនោះខ្វិនម្ខាង ភ្នែកស្រលៀងរូបរាងវិកលប្លែក តែជាមនុស្សវិសេសស្លៀកពាក់ខៀវ ពាក់មួកត្បាញដោយផ្ដៅ លុះដើរមកដល់ជិត ក៏សួរអ្នកជើងស្នែងថា អស់អ្នករាល់គ្នាសែងក្រូចទៅណា បានជានាំគ្នាមកឈប់នៅទីនេះ? ពួកជើងស្នែងទាំងនោះក៏ពណ៌នាសេចក្ដីឲ្យស្ដាប់ ហើយថា យើងខ្ញុំសែងរែកមកពីស្រុកឆ្ងាយនឿយអស់កម្លាំងណាស់ ឈប់សម្រាកឲ្យបាត់នឿយហត់បន្តិចនឹងលើកទៅទៀត។ **ចៅជូ**ថា យើងជួយរែកឲ្យម្នាក់ៗឈប់ឲ្យល្ហមមានកម្លាំង។ ថាហើយ**ចៅជូ**ក៏ចូលទៅរែកផ្លែក្រូចនោះឲ្យទៅម្នាក់ៗមួយហាប។ ក្នុងមួយហាបចម្ងាយបានហាសិបសិន ទាំងហាសិបហាបបាន

ចម្ងាយផ្លូវពីរពាន់ប្រាំរយសិន (៩០០គ.ម) ពួកជើងស្នែងទាំងអស់នោះក៏សោមនស្សត្រេកអរណាស់។

**ចៅជូ**ក៏និយាយនឹងពួកជើងស្នែងទាំងនោះថា បើអស់អ្នកទៅដល់ព្រះចៅ**វុយអេង**ហើយឲ្យជួយទូលឲ្យខ្ញុំផងចុះថា ខ្ញុំឈ្មោះ**ចៅជូ**ពួកស្រុកជាមួយគ្នានឹងព្រះចៅ**វុយអេង** ថាហើយ**ចៅជូ**ក៏ដើរចូលទៅក្នុងព្រៃ អស់ពួកជើងស្នែងទាំងពួងក៏នាំគ្នារែកសែងផ្លែក្រូចនោះទៅទៀត ទាំងអស់គ្នាក៏ចេះតែពិភាល់សង្ស័យថា ពីដើមយើងរែកផ្លែក្រូចមកធ្ងន់ណាស់ លុះដល់អាចារ្យ**ចៅជូ**ជួយត្រឹមណា ផ្លែក្រូចនេះក៏ត្រឡប់ជាស្រាលខុសអំពីដើមឆ្ងាយណាស់ លុះទៅដល់ស្រុកង៉ៀបគុនក៏យកផ្លែក្រូចចូលទៅថ្វាយ។

ព្រះចៅ**វុយអេង**ឃើញផ្លែក្រូចក៏សោមនស្ស ព្រោះឃើញថា**ស៊ុនគួន**ទទួលចំណុះដោយសុចរិត ទើបយកផ្លែក្រូចនោះមកហែកមើលជាច្រើនគូមិនឃើញមានសាច់សោះ ឃើញតែសំបកទទេ។ **ចូឆូ**សង្ស័យណាស់ ទើបសួរពួកជើងស្នែងទាំងនោះថា ហេតុម្តេចបានជាផ្លែក្រូចនេះដូច្នេះ? ពួកជើងស្នែងទូលតបថា កាលទូលព្រះបង្គំជាខ្ញុំរែកមកឈប់ពាក់កណ្តាលផ្លូវ មានអាចារ្យម្នាក់ឈ្មោះ**ចៅជូ**មកជួយផ្លាស់អម្រែករែក ឲ្យម្នាក់ចម្ងាយហាសិបសិន គ្រប់ទាំងហាសិបនាក់ ហើយ**ចៅជូ**នោះផ្តាំមកឲ្យក្រាបបង្គំទូលដោយគោរព ព្រោះបានស្គាល់ទ្រង់មកពីដើម។

**ចូឆូ**ឮដូច្នោះក៏នៅសង្ស័យ ទទួលអ្នកយាមទ្វារចូលទៅទូលថា **ចៅជូ**នឹងចូលមកគាល់។ **ចូឆូ**ក៏ឲ្យហៅ**ចៅជូ**ចូលទៅ ពួកជើងស្នែងទាំងអស់ឃើញក៏ស្រែកឡើងព្រមគ្នាថា អាចារ្យ**ចៅជូ**នេះហើយ ដែលជួយអម្រែកយើងរាល់គ្នានោះ។ **ចូឆូ**ឮដូច្នោះក៏សួរ**ចៅជូ**ថា ខ្លួនបានរៀនវិជ្ជាមកពីណាបានជាក្លែងយកសាច់ផ្លែក្រូចអស់នៅសល់តែសំបកទទេមកឲ្យយើងដូច្នេះ? **ចៅជូ**ថា ធម្មតាក្រូចនឹងគ្មានសាច់នោះមិនមែនទេ បើលោកសង្ស័យនឹងសុំបកថ្វាយទត។ ហើយ**ចៅជូ**ក៏យកក្រូចនោះបកឃើញមានសាច់ធម្មតា ក្អែកនរណាក៏មើលទៅឃើញទាំងអស់។

**ចូឆ្វ**ឃើញដូច្នោះក៏ចាប់យកក្រូចមកហែកមើលខ្លះ ក៏គ្មានសាច់សោះមានតែសំបក រឹតតែមានសេចក្ដីសង្ស័យ ទើបអញ្ជើញ**ចៅជូ**ឲ្យមកអង្គុយហើយថា ហេតុម្ដេចទើបក្រូចដូច្នេះ? **ចៅជូ**ថា ទូលព្រះបង្គំនឹងសុំស្រានូវគ្រឿងលៀងមកបរិភោគសិន ទើបនឹងទូលឲ្យបានជ្រាប។ **ចូឆ្វ**ក៏យកសុរាមកឲ្យ**ចៅជូ**ផឹកអស់ប្រាំឌីទិន ក៏គ្មានស្រវឹងទើបឲ្យយកពពែមួយមកពិឃាតយកសាច់ឲ្យស៊ីក៏មិនឆ្អែត។

**ចូឆ្វ**ឃើញដូច្នោះក៏សួរថា អ្នករៀនវិជ្ជានេះមកពីសំណាក់គ្រូឯណា បានជាចេះធ្វើកលផ្ដេសផ្ដាសដូច្នេះ? **ចៅជូ**ទូលថា កាលទូលបង្គំកាន់សីលនៅភ្នំងូពីសាន់ដែនក្នុងស្រុកសែឈួនបានសាមសិបឆ្នាំ ទេព្ដាយកតម្រាមកឲ្យទូលបង្គំបីច្បាប់៖ ទីមួយ ឈ្មោះធៀនទុក, ទីពីរឈ្មោះតេទុន, ទីបីឈ្មោះយិនទុន។ ឯច្បាប់ធៀនទុននោះ សម្រាប់ហៅខ្យល់ និងភ្លៀង និងឥទ្ធិឫទ្ធិហោះទៅបានតាមអាកាស ច្បាប់តេទុននោះទោះបីនឹងប្រើដុំថ្ម សិលាឬជ្រែកភ្នំចេញក៏បាន ច្បាប់យិនទុននោះ បើចង់បំបាំងកាយឬ ប្រើអាវុធឲ្យទៅធ្វើអន្តរាយអ្នកឯណាក៏បាន យ៉ាងដូចខ្លួនលោកបានភប់នឹងយសស័ក្ដិដ៏ប្រសើរហើយ តែមិនបានចេះដឹងវិជ្ជានេះ គួរតែលះយសស័ក្ដិសម្បត្តិទៅកាន់សីលនៅក្នុងព្រៃភ្នំក្រុំថ្មជាមួយនឹងទូលបង្គំចុះ នឹងបានរៀនវិជ្ជាទាំងបីច្បាប់នេះ ទុករក្សាខ្លួនឲ្យស្ងាត់។

**ចូឆ្វ**ថា វិជ្ជាទាំងអម្បាលនេះ យើងក៏មានចិត្តស្រឡាញ់ចង់រៀនណាស់ តែនឹងទៅពុំបាន ព្រោះមានកិច្ចការពីស្រុកទេសច្រើនប្រការណាស់ គ្មាននរណានៅនឹងទទួលភារៈជាជំនួសយើង។ **ចៅជូ**ឮហើយក៏អស់សំណើចថា **ឡៅពី**ចៅហ្វាយស្រុកសែឈួនមានតម្រិះប្រាជ្ញា ហើយជាពូជព្រះរាជវង្សព្រះចៅ**ហៀន**តេស្រាប់ ហេតុម្ដេចលោកមិនហៅមកប្រាប់ឲ្យទទួលរាជការស្រុកទេសជាជំនួសលោកទៅ? បើលោករឹងទទឹងមិនធ្វើតាមពាក្យយើង ៗនឹងសម្ដែងវិជ្ជាប្រើអាវុធឲ្យកាត់ក្បាលលោកចេញ។

**ចូឆ្វ**ព្ជូច្ឆោះក៏ខឹងណាស់ ស្រែកបង្គាប់ទាហានថា អាដែងនេះពួក**ឡៅពី** វាក្លែងចូលមកស៊ើបការណ៍ក្នុងស្រុកយើង ៗត្រូវចាប់ខ្លួនវាទុក ទាហាន**ចូឆ្វ**ប្រហែលសាមសិបនាក់ ក៏ស្ទុះស្រូចូលទៅព័ទ្ធចាប់ចង**ចៅជូ**បាន ហើយវាយដំច្រំធាក់តប់គ្រប់គ្នា ប្រហារដោយគ្រឿងអាវុធផ្សេងៗ **ចៅជូ**ធ្វើជាធ្មេចភ្នែកហើយសើចក្អាកក្អាយ **ចូឆ្វ**ក៏ឱ្យយកច្រវាក់មកដាក់ហើយចាក់សោរវឹតរួតជើងដៃ**ចៅជូ**ឱ្យខ្ជាប់ រួចឱ្យទាហាននៅយាមរក្សាជាច្រើន លុះពេលព្រឹកឡើង ភូឃុំទៅមើលឃើញច្រវាក់និងសោរដែលនៅរង្វង់កងដដែល តែមិនបានទៅជាប់នឹងជើងដៃ**ចៅជូ** ៗដេកនៅជាប្រក្រតី។ ភូឃុំក៏នាំសេចក្ដីទៅជម្រាប**ចូឆ្វ**គឺ៖ ព្រះចៅ**វុយអេង**។

**ចូឆ្វ**បានស្ដាប់ក៏បង្គាប់ឱ្យឃុំឃាំង**ចៅជូ**ទុកអស់ប្រាំពីរថ្ងៃ បង្អត់បាយនៅក្នុងគុកនោះ ភូឃុំក៏គិតថា **ចៅជូ**អត់បាយទឹកដល់ទៅប្រាំពីរថ្ងៃ នឹងមិនស្លាប់ទៅហើយឬ? ក៏បើកទ្វារគុកចូលទៅមើល ឃើញ**ចៅជូ**អង្គុយសើចសប្បាយ ភូឃុំឆ្ងល់ណាស់ ក៏ទៅទូលព្រះចៅ**វុយអេង**តាមរឿងហេតុនោះ។ **ចូឆ្វ**ក៏ឱ្យយកខ្លួន**ចៅជូ**ចេញមក ហើយសួរថា នឹងធ្វើយ៉ាងម៉េចទើបខ្លួននឹងដល់នូវសេចក្ដីស្លាប់? **ចៅជូ**ថា ទោះបីនឹងបង្អត់អាហារយើងឱ្យដល់ដប់ឆ្នាំ យើងក៏មិនស្លាប់ បើនឹងឱ្យស៊ីសាច់ពពែមួយពាន់ក្នុងមួយថ្ងៃ យើងក៏បរិភោគអស់បានគ្មានអន្តរាយ។

**ចូឆ្វ**ព្ជូច្ឆោះក៏អស់គំនិតគិត មិនដឹងបើនឹងធ្វើការម្ដេច នឹងឱ្យ**ចៅជូ**ដល់នូវសេចក្ដីស្លាប់បាន។ ខណៈនោះជាថ្ងៃនក្ខត្តឫក្សល្អ **ចូឆ្វ**រៀបនឹងឡើងដំណាក់ថ្មី ឱ្យប្រមូលនាហ្មឺនមុខមន្ត្រីតូចធំមកបរិភោគលៀងអាហារ **ចៅជូ**ក៏ក្រោកទៅឈរនៅមុខតុកណ្ដាលទីប្រជុំមុខមន្ត្រី ហើយស្រដីទៅកាន់**ចូឆ្វ**ថា លោកមានយសស័ក្តិធំដល់ទីនេះហើយ នឹងត្រូវការប្រាថ្នារករបស់អ្វីជាវិសេសទៀតដែរឬទេ? **ចូឆ្វ**ក្លែងឆ្លើយថា របស់អ្វីៗក៏មានសព្វគ្រប់អស់ហើយ ឃើញខ្វះតែថ្លើមមករ យើងចង់បានមកអាស្រ័យ ចូរអ្នកទៅរកមកឱ្យយើងចុះ។

**ចៅជូ**បានស្តាប់ដូច្នោះក៏អស់សំណើចហើយថា ឲ្យយកពិតមកឲ្យយើងៗនឹងសរសេរវេលានោះ **ចៅជូ**ក៏កាន់ពិតគូររូបមករភ្ជាប់នឹងជញ្ជាំង ហើយក៏យកដៃបោសលុបចេញ ពោះមករនោះក៏បែកធ្លាយ **ចៅជូ**ក៏ចាប់លូកយកថ្លើមមករមកបានជូនទៅឲ្យ**ចូឆូ** លោហិតមករក៏នៅប្រឡាក់ជាប់ស្រស់ៗ មើលឃើញច្បាស់ទាំងអស់គ្នា។ **ចូឆូ**ស្រែកគំហកហើយថា យើងមិនជឿទេ ខ្លួនមកធ្វើក្លែងកលឧបាយយកថ្លើមដទៃមកលាក់ទុកក្នុងដៃអាវ។ **ចៅជូ**តបថា លោកមិនជឿក៏វាហីទៅចុះ ឥឡូវជាទេសកាលខែមិគសិរផុតរដូវផ្កាឈើ ផ្លែឈើទាំងពួង បើលោកចង់ត្រូវការប្រាថ្នាផ្កាឈើអ្វី ខ្ញុំម្ចាស់នឹងរកមកជូន។

**ចូឆូ**ថា យើងត្រូវការចង់បានផ្កាឈើប៉ោតាន់ អ្នកឯងទៅរកមកឲ្យយើងឥឡូវនេះ។ **ចៅជូ**ក៏យកផើងដាក់ដីមក ហើយសែគស្រោចទឹកតែមួយរំពេច ដើមប៉ោតាន់ក៏លូតលាស់ដុះឡើងប៉ិចលេចផ្កាមួយគូ **ចៅជូ**ក៏លើកផើងដើមឈើនោះទៅឲ្យ**ចូឆូ**ៗនិងមន្ត្រីទាំងពួងឃើញប្លែកដូច្នោះ ក៏សម្លឹងមើលមុខគ្នាស្លាំងកាំងទាំងអស់។ **ចូឆូ**ថា ធម្មតាដើមប៉ោតាន់នេះកម្រណាស់ បើនរណានឹងដាំដើមផ្កាដទៃៗឲ្យគ្រប់មួយរយដើមសិន ទើបយកដើមប៉ោតាន់នោះទៅបណ្តុះជាកណ្តាលទើបរស់ ឯដើមផ្កាទាំងមួយរយនោះក៏ត្រឡប់ប្រែផ្កាទៅចូលនឹងដើមប៉ោតាន់នេះអស់ទៅ ហើយ**ចូឆូ**ក៏អញ្ជើញ**ចៅជូ**ចូលទៅស៊ីលៀងជាមួយនឹងនាហ្មឺនមុខមន្ត្រីទាំងពួង។

ខណៈកាល**ចៅជូ**ផឹកស្រាស៊ីបាយនោះ ក៏និយាយថា ធ្វើម្តេចនឹងបានខ្ចីស្រស់មកស៊ីក្លែមស្រា? **ចូឆូ**ថា អ្នកឯងមានវិជ្ជាចេះដឹងត្រូវធ្វើខ្ចីឲ្យបាន។ **ចៅជូ**ក៏យកថាសមួយមកហើយដោះអាវចេញយកទៅរុំថាសនោះទុកមួយស្របក់ ទើបបើកឡើងក៏ឃើញខ្ចីស្រស់ពេញថាសនោះ ហើយលើកយកទៅឲ្យ**ចូឆូ** ៗក្រឡេកទៅឃើញសំបុត្រមួយច្បាប់ទម្លាក់ទុកនៅលើថាស មានការខ្ទងថា**បាំងតេក** ហើយ**ចូឆូ**ក៏ចាប់លើកឡើងមើល ទើបគិតថា សំបុត្រច្បាប់នេះរបស់យើងតែងឯង យើងហែកចោលពីគ្រា**ទៀវសុង** ដែលមកពីស្រុកសៃឈួនអស់ហើយ ហេតុម្តេចទើបត្រឡប់

មកនៅល្អដូចដែលដូច្នេះ មុខគួរឲ្យឆ្ងល់ពេកណាស់។ **ចៅជូ**ក៏ចាប់យកពែងលើកឡើងចាក់ស្រាហុចជូនទៅឲ្យ**ចូឆ្ន**ហើយថា អញ្ជើញព្រះចៅ**រុយអេង**សោយស្រានេះព្រះជន្មវស្សានឹងយឺនបានមួយរយឆ្នាំ។

**ចូឆ្ន**ថា ត្រូវអ្នកឯងផឹកមុនយើងសិន។ **ចៅជូ**ក៏ទាញយកស្នៀតសក់មកខណ្ឌពាក់កណ្ដាលពែងស្រា ហើយលើកឡើងនឹងផឹកចូលទៅ ហើយពែងស្រាក៏ទទេម្ខាងមានស្រានៅត្រឹមស្នៀតសក់ខណ្ឌម្ខាង ហើយក៏ហុចជូនទៅឲ្យ**ចូឆ្ន**។

**ចូឆ្ន**ឃើញប្លែកដូច្នោះ ក៏គំហកឲ្យ**ចៅជូ** ៗក៏យកពែងស្រាចោលទៅលើ**ចូឆ្ន** ពែងនោះក៏ក្លាយទៅជាសត្វក្រៀលទំលើក្បាល**ចូឆ្ន**។ នាហ្មឺនមុខមន្ត្រីទាំងពួងឃើញប្លែកដូច្នោះក៏តក់ស្លុតក្នុងចិត្តណាស់ នាំគ្នាឡើងមើលសត្វនោះ លុះក្រឡេកចុះមក ក៏បាត់ខ្លួន**ចៅជូ**ទៅ ក៏រឹតតែសង្ស័យក្រៃពេកណាស់។ មានមនុស្សចូលមកស្រែកថា **ចៅជូ**រត់ចេញទៅក្រៅទ្វារហើយ។ **ចូឆ្ន**ថា **ចៅជូ**នោះចេះធ្វើកលផ្ដេសផ្ដាសដោយមន្តអាគមផ្សេងៗ បើយើងស្ងៀមមិនយកវាចេញ វាក៏គង់ធ្វើអន្តរាយយើងវិញ ក៏ប្រើ**ខៅធូ**លើកទាហានបីរយនាក់ ឲ្យតាមទៅចាប់ខ្លួន**ចៅជូ**។

**ខៅធូ**លើកទាហានស្រូតតាមទៅដល់កណ្ដាលព្រៃ ឃើញ**ចៅជូ**ដើរជាប្រក្រតីធម្មតា**ខៅធូ**និងទាហានក៏បំផាយសេះទៅមួយស្របក់ ទាល់តែសេះនោះអស់កម្លាំងក៏មិនទាន់ ឃើញ**ចៅជូ**នៅដើរជាប្រក្រតីដូចដែល លុះទៅដល់ភ្នំមួយអន្លើ មានក្មេងឃ្វាលពពែមួយហ្វូងនៅវាល **ចៅជូ**ក៏ចូលទៅក្នុងហ្វូងពពែនោះ **ខៅធូ**យឺតធ្នូបាញ់តម្រង់ទៅជាច្រើនព្រួញ **ចៅជូ**ក៏បាត់ខ្លួនទៅ។ **ខៅធូ**ខឹងណាស់ក៏ចាប់ពពែទាំងហ្វូងនោះសម្លាប់អស់ ខ្មោចពពែក៏នៅគរត្រៀបត្រា រួចនាំទាហានត្រឡប់យកសេចក្ដី ទៅក្រាបទូលព្រះចៅ**រុយអេង**គ្រប់ប្រការ។

ឯក្មេងគង្វាលពពែនោះ លុះឃើញពពែស្លាប់អស់ក៏ជាទុក្ខទោមនស្សអង្គុយយំ ស្រាប់តែឮសំឡេងមនុស្សក្នុងក្បាលពពែស្រែកមកថា កុំយំថ្វីឡើយ ចូរយកក្បាលពពែផ្គុំភ្ជាប់គ្នាទៅវិញចុះ ពពែរបស់ឯងទាំងអស់នោះគង់តែរស់ឡើងវិញទេ។

ក្មេងគង្វាល់ពពែបានឮក៏ភ័យស្លាំងស្លុតស្មារតី គិតថាខ្មោចបិសាចលងក៏យកដៃខ្ទប់មុខយំ ហើយរត់ចេញ។ **ចៅជូ**ក៏ចេញពីក្នុងក្បាលពពែប្រាថ្នានឹងឲ្យពពែនោះរស់ឡើង ក៏តាមទៅហៅក្មេងគង្វាលពពែថា ឯងវិលទៅយកក្បាលពពែផ្គុំនឹងខ្លួនវាវិញចុះ ពពែទាំងអស់នឹងរស់ឡើងវិញដូចដើម។ ក្មេងនោះក្រឡេកទៅឃើញ**ចៅជូ**ក៏រសាយសេចក្ដីខ្លាច ទើបត្រឡប់ទៅលើក្បាលពពែនោះ ផ្គុំនឹងខ្លួនក៏រស់ឡើងវិញទាំងអស់។

កាលពីដើម ពពែញីគ្មានស្នែងនិងពុកមាត់ទេ លុះក្មេងគង្វាលពពែវាលើកក្បាលទៅផ្គុំតនឹងខ្លួនមិនបានពិចារណាឲ្យដឹងថាញីឈ្មោលប្រាកដ គឺយកក្បាលឈ្មោលទៅផ្គុំនឹងពពែញី យកក្បាលញីទៅផ្គុំនឹងខ្លួនឈ្មោលក៏មាន បានជាពពែញីមានស្នែងនិងពុកមាត់រហូតដល់សព្វថ្ងៃនេះ។ កាលបើពពែនោះរស់ឡើងវិញហើយ **ចៅជូ**ក៏បាត់ខ្លួនទៅ។ ក្មេងគង្វាលពពែក៏ភ័យខ្លាំងណាស់ កៀងហ្វូងពពែវិលទៅផ្ទះវិញ ហើយនាំព័ត៌មាននោះទៅប្រាប់ចៅហ្វាយនាយម្ចាស់ពពែក ៗដឹងហើយ ក៏ចូលទៅទូលព្រះចៅ**វុយអេង**តាមរឿងហេតុគ្រប់ប្រការ។

**ចូឆូ**ជាព្រះចៅ**វុយអេង**ដឹងដូច្នោះ ក៏ឲ្យជាងគូររូបភាព**ចៅជូ**តាមលក្ខណៈស្រលៀងភ្នែកខាងស្ដាំ ជើងម្ខាងពិការ ហើយតែងសំបុត្របញ្ជូនរូប**ចៅជូ**ទៅគ្រប់ខេត្តឡើងទាំងអស់ថា បើភ្នាក់ងារខេត្តណាបានឃើញប្រទះមនុស្សមានរូបដូចគំនូរនេះ ឲ្យចាប់ខ្លួនបញ្ជូនចូលទៅនឹងបានឲ្យបំណាច់រង្វាន់ច្រើន។ នោះបណ្ដាអាណាខេត្តទាំងប៉ុន្មានបានឃើញមនុស្សនិងលក្ខណៈដូចគំនូរនោះ ក៏ចាប់បញ្ជូនទៅឲ្យ**ចូឆូ**ក្នុងខេត្តមួយៗមានប្រាំបួននាក់ខ្លះ ដប់នាក់ខ្លះ គ្រប់ខេត្តទាំងអស់បានចំនួនបីរយប្លាយនាក់។

**ចូឆូ**ឃើញមនុស្សទាំងបីរយប្លាយដូចរូប**ចៅជូ**គ្មានខុស ក៏បង្គាប់ទាហានឲ្យឃុំនាំចេញទៅក្រៅស្រុក ហើយចងមនុស្សទាំងបីរយប្លាយនោះដោយចំណាង ហើយឲ្យយកឈាមជ្រូក និងឈាមសត្វឯទៀតៗមកស្រោចមកសាចលើមនុស្សទោស

ទាំងនោះ ដើម្បីឲ្យមន្តអាគម**ចៅជូ**នោះសាបរលាបអស់ទៅ ហើយឲ្យទាហានប្រហារជីវិតកាត់ក្បាលទាំងបីរយប្លាយនាក់នោះអស់គ្មានសល់។ មនុស្សទាំងនោះក៏អង្គុយនៅតែខ្លួនទទេអត់ក្បាល ឯឈាមនោះបាញ់ឡើងទៅលើអាកាស ក្លាយទៅជាមនុស្សជិះក្រៀលប្រហែលបីរយប្លាយនាក់ ក្រៀលនោះក៏ហើរវេរានៅលើអាកាស មនុស្សនោះក៏ទះដៃស្រែកចំអកឲ្យ**ចូឆ្លូ**អឹងកង។ **ចូឆ្លូ**ឃើញដូច្នោះក៏ខឹងណាស់ បង្គាប់ទាហានឲ្យយឹតធ្នូបាញ់តម្រង់ទៅ។

ខណៈនោះ ក៏បណ្ដាលឲ្យកើតជាខ្យល់ព្យុះសង្ឃរាខ្លាំងណាស់ គួចយកផង់ធូលីហុយទ្រលោមគ្រឡប់ងងឹតអ័ព្ទអស់ទាំងទិសទី។ ឯរូបមនុស្សដែលសម្លាប់នោះក៏ក្រោកឡើងដើរតែខ្លួនដៃយួរក្បាលរត់ជ្រួលច្របល់ទៅវាយតប់**ចូឆ្លូ** ៗក៏ដួលចុះ។ នាហ្មឺនក្រមការឃើញដូច្នោះក៏ភ័យស្លុតស្មារតី យកដៃខ្ទប់មុខស្រែកឆោឡោអឹងកង លុះស្ងប់ខ្យល់ព្យុះ ខ្មោចមនុស្សទាំងពួងក៏សូន្យបាត់អស់ទៅ ឯ**ចៅជូ**ក៏រស់នៅ ចេញពីស្រុកងៀបគុនទៅទីឯទៀត។

ពួកនាហ្មឺនក្រមការ ក៏ជួយគ្នាគ្រាហ៍យក**ចូឆ្លូ**ត្រឡប់ចូលទៅក្នុងដំណាក់ ហើយ**ចូឆ្លូ**នោះក៏ចាប់ឈឺធ្ងន់ពន់ប្រមាណ មានឈ្មោះ**ខៅជី**ដែលជាហោរាទៅសួរអាការរោគ**ចូឆ្លូ**ចេញមកពីស្រុកហ៊្វូតោ **ចូឆ្លូ**ក៏ឲ្យហៅ**ខៅជី**ចូលទៅសួរថា អ្នកចូរមើលគ្រោះថ្នាក់ឲ្យយើងជានឹងល្អ ឬអាក្រក់យ៉ាងណា? **ខៅជី**ថា លោកម្ចាស់ស្គាល់**គួនឡូ**ឬទេ? ឯ**គួនឡូ**នោះជាអ្នកចេះតម្រាមើលចំណានជាងខ្ញុំបាទច្រើនណាស់។ **ចូឆ្លូ**ក៏សួរថា **គួនឡូ**នោះវិសេសយ៉ាងណាខ្លះ?

**ខៅជី**ថា **គួនឡូ**នោះជាអ្នកស្រុកប៉េងងួន កាលពីក្មេងរមែងផឹកស្រា ហើយរៀនមើលឫក្សជតាលុះធំឡើងបានតម្រា**ជីវកុង**មកទុក បានជាចេះស្ទាត់ខាងវិជ្ជាមើលគ្រោះថ្នាក់ឈឺថ្កាត់ ទោះបីស្លាប់ក៏អាចនឹងដឹងបាន។ កាលគ្រាមួយ**អងគី**ចៅហ្វាយស្រុកអាន់ប៉េងនោះប្រពន្ធមានជំងឺឈឺក្បាល កូននោះមានជំងឺឈឺក្នុងដើមទ្រូងជាដរាប ក៏ឲ្យហៅ**គួនឡូ**ទៅមើលពិគ្រោះ មើលហើយថា កន្លែងលំនៅរបស់

លោកនេះគេកប់ខ្មោចពីរ ខ្មោចមួយកាន់លំពែង ខ្មោចមួយកាន់ធ្នូ។ ខ្មោចដែលកាន់លំពែងនោះ ជញ្ជាំងផ្ទះលោកសង្កត់ពីលើក្បាល ទើបបណ្ដាលឱ្យប្រពន្ធលោកឈឺក្បាល ឯកូនលោកដែលឈឺក្នុងដើមទ្រូងនោះ ព្រោះហេតុថា សពដែលកាន់ធ្នូនៅក្រោមជើងសសរ។ **អងគឺ**ឱ្យរើជញ្ជាំងផ្ទះហើយ ឱ្យជីកចុះទៅជម្រៅប្រហែលបួនហត្ថ ឃើញសពទាំងពីរនោះដូចពាក្យ**គួនឡ**ទាយ **គួនឡ**ក៏ឱ្យរើឡើងយកខ្មោចនោះនាំទៅបញ្ចុះនៅទីដទៃ ភរិយានិងបុត្រនោះក៏ជាជំងឺអស់ទៅ។ មានស្រីម្នាក់បាត់គោទៅរក**គួនឡ**មើល **គួនឡ**ទាយថា គោមានអាចោរកំណាចប្រាំពីរនាក់លួចនាំទៅទុកឯត្រើយម្ខាង ឥឡូវវាសម្លាប់ស៊ីទៅហើយ នៅតែឆ្អឹងនិងស្បែកចោលទុកនៅក្បែររបងផ្ទះវា។ ស្រីនោះក៏ឆ្លងទៅមើលឃើញស្បែកនិងឆ្អឹងគោប្រាកដ ទើបអើតមើលទៅឃើញអាចោរកំណាចប្រាំពីរនាក់កំពុងស៊ីសាច់គោក្លែមស្រា ស្រីនោះក៏ចូលទៅប្ដឹង**ឡៅពី**ចៅហ្វាយស្រុកផេងងួនគួន។ **ឡៅពី**ក៏ទៅចាប់អាកំណាចប្រាំពីរនាក់បានមកពិចារណាទទួលសត្យហើយក៏សួរទៅស្រីម្ចាស់គោថា ហេតុអ្វីបានជាខ្លួនដឹងថាអាចោរអស់នេះលួចគោខ្លួនទៅ? ស្រីនោះថា **គួនឡ**ជាគ្រូទាយបានជាដឹង។ **ឡៅពី**ក៏ឱ្យហៅ**គួនឡ**ទៅពិសោធន៍ គឺក្លែងយកត្រាពីក្នុងហិប ទើបយករោមមាន់ដាក់ពេញក្នុងហិបនោះ រួចលើកចេញមកឱ្យ**គួនឡ**ទាយថារបស់អ្វីនៅក្នុងហិបនោះ? **គួនឡ**ទាយថា រោមមាន់ក្រហមប៉ុណ្ណេះ រោមមាន់ខ្មៅប៉ុណ្ណេះ រោមមាន់សប៉ុណ្ណេះ។ **ឡៅពី**បើកហិបចេញរាប់មើល ក៏ត្រូវប្រាកដដូចពាក្យទំនាយ។ **ឡៅពី**រាប់អាន**គួនឡ**តាំងទុកជាទីប្រឹក្សា។

លុះនៅយូរមក ថ្ងៃមួយ**គួនឡ**ចេញដើរទៅលេងឃើញក្មេងកំឡោះម្នាក់រូបស្អាតកំពុងភ្ជួរស្រែ **គួនឡ**ពិចារណាមើលក៏ដឹងថា ក្មេងនោះនឹងដល់សេចក្ដីស្លាប់ ទើបសួរក្មេងនោះថា ឯងឈ្មោះអ្វី? យើងមានសេចក្ដីអាណិត ដ្បិតឃើញរូបភាពស្អាតបាត ខ្លួនឯងជិតស្លាប់ហើយ ខ្វះតែបីថ្ងៃទៀតនឹងស្លាប់។ ក្មេងកំឡោះនោះបានស្ដាប់ក៏ប្រាប់ថា ឈ្មោះ**ទៀវងាន់** ហើយសួរមកវិញថា លោកឈ្មោះអ្វី? ហេតុម្ដេច

បានជាដឹងថាខ្ញុំនឹងស្លាប់ក្នុងរវាងបីថ្ងៃទៀតនោះ? **គួនឡ**ឆ្លើយថា យើងឈ្មោះ**គួនឡ** ដែលយើងដឹងនោះ ព្រោះឃើញរោមកាច (សែម) រោមចិញ្ចើមឡើងច្រាងបានជាយើងប្រាប់ឲ្យដឹង។ **ទៀវងាន់**ភ័យស្លុតស្មារតី ក៏រត់ទៅប្រាប់ឪពុកតាមពាក្យ**គួនឡ**ទំនាយ។ អាពុក**ទៀវងាន់**ក៏ភ័យរលះរលាំងនាំកូននោះទៅជួប**គួនឡ** ហើយសួរថា លោកចេះដឹងវិសេស ចូរជួយអនុគ្រោះកូនខ្ញុំបាទឲ្យរួចពីទុក្ខភ័យក្នុងគ្រានេះម្តងចុះ។ **គួនឡ**ឆ្លើយថា យើងនឹងជួយមិនកើតទេ ព្រោះកំណត់អាយុគេកើតស្លាប់តាមឧបនិស្ស័យមកស្រាប់។ ឪពុក**ទៀវងាន់**ក៏អង្គុយយំហើយសំពះអង្វរថា ខ្ញុំបាទមានកូនតែមួយនេះ គិតថានឹងបានធ្វើខ្មោចលើកូននេះ ឥឡូវត្រឡប់ឲ្យមានកម្មដូច្នេះ ខ្ញុំបាទមិនចង់នៅឲ្យឃើញមុខនរណាទេ។ លោកមានវិជ្ជាចេះដឹង សូមអាណិតមេត្តាជួយខ្ញុំបាទដោយឧបាយកែខៃយ៉ាងណា នឹងបានតអាយុកូននេះឲ្យបានទាន់ចុះ ដើម្បីនឹងបានជាទីសង្ឃឹមតទៅ។

**គួនឡ**ឮដូច្នោះ ក៏ឲ្យមានសេចក្តីប្រណីអាណិតណាស់ ប្រាប់ថា បើអ្នកនឹងចង់តអាយុកូនអ្នក ចូរយកស្រាមួយដប និងសាច់មួយដុំឡើងទៅលើភ្នំឡាំសាន់ មានដើមឈើធំមួយដើម មានថ្មសិលាមួយផ្ទាំងធំជាគ្រែនៅក្រោមដើមឈើនោះ បើឡើងទៅឃើញមនុស្សចាស់ពីរនាក់ ម្នាក់ពាក់អាវស ម្នាក់ពាក់អាវក្រហម អង្គុយលេងចត្រង្គនៅលើថ្មសិលានោះ ដល់ពេលថ្ងៃត្រង់អ្នកចូរយកស្រានិងសាច់គោនោះទៅឲ្យមនុស្សពីរនាក់នោះស៊ី ហើយអង្វរសុំអាយុកូនតទៅចុះ បើមនុស្សចាស់ទាំងពីរនាក់នោះនឹងសួរថា នរណាប្រាប់បានជាដឹង? អ្នកកុំបីប្រាប់ចេញឈ្មោះយើងឡើយ។ អាពុក**ទៀវងាន់**បានស្តាប់ក៏ធូររសាយក្នុងចិត្ត ទើបអញ្ជើញ**គួនឡ**ទៅឯផ្ទះខ្លួន ហើយក៏ឲ្យរៀបអាហារលៀងតាមគួរសម ក្នុងពេលយប់នោះក៏ឃាត់**គួនឡ**ឲ្យនៅដេកមួយយប់។

លុះព្រឹកឡើង **ទៀវងាន់**ក៏យកស្រាមួយដបនិងសាច់មួយដុំ កាន់ឡើងទៅលើភ្នំឡាំសាន់ ចម្ងាយផ្លូវប្រហែលហាសិបសិន (២ គ.ម) ក៏ឃើញដើមឈើធំមួយ

មានមនុស្សចាស់ពីរនាក់អង្គុយលើថ្មសិលាក្រោមម្លប់ដើមនោះ កំពុងលេងចត្រង្គ **ទៀវងាន់**ក៏ចូលទៅក្រាបសំពះហើយលើកស្រាសាច់នោះជូនទៅ ក៏មិនបាននិយាយថាអ្វី។ លុះដល់ថ្ងៃត្រង់**ទៀវងាន់**ក៏ចាក់ស្រាហើយហែកបេះសាច់នោះដាក់ចំពោះមុខ។ មនុស្សចាស់ទាំងពីរនាក់ក៏ចេះតែលេងចត្រង្គព្រងើយទៅ ហើយនាំគ្នាផឹកស្រានោះទាល់តែអស់។ **ទៀវងាន់**ឃើញដូច្នោះ ក៏អង្គុយយំសំពះអង្វរថា ខ្ញុំបាទសូមតអាយុតទៅ លោកទាំងពីរចូរមេត្តាអនុគ្រោះខ្ញុំបាទឲ្យទានចុះ។ មនុស្សចាស់ដែលអាវក្រហមឮដូច្នោះក៏ភ្ញាក់ស្មារតីហើយស្រដីថា **គួនឡូ**ប្រាកដជាប្រាប់ទើបគេដឹង។ ទើបប្រឹក្សាគ្នាថា យើងបានស៊ីផឹករបស់គេហើយ បើមិនជួយសង្គ្រោះគេក៏មិនសមគួរ។ មនុស្សដែលពាក់អាវសនោះក៏យល់ឃើញតាម ទើបយកបញ្ជីមនុស្សក្នុងដៃអាវចេញមក មើលឃើញឈ្មោះ**ទៀវងាន់**នោះដល់កំណត់ស្លាប់ក្នុងវាងអាយុ១៩ឆ្នាំ ទើបនិយាយថា អាយុរបស់អ្នកឯងគ្រប់១៩ឆ្នាំហើយ នៅខ្វះតែពីរថ្ងៃទៀតនឹងស្លាប់ យើងនឹងជួយបំពេញទូរលេខ១ខាងដើម ឲ្យទៅជាលេខ៩វិញ គឺត្រូវតអាយុទៅមុខបាន៩៩ឆ្នាំទើបស្លាប់។ ហើយសរសេរលេខ៩ដាក់ក្នុងបញ្ជី ទើបផ្តាំឲ្យទៅប្រាប់**គួនឡូ**ថា ការទាំងអស់កុំឲ្យអ្នកឯណាដឹងទូទៅឡើយ ហើយមនុស្សចាស់ទាំងពីរនាក់នោះ ក៏ក្លាយទៅជាសត្វហើរចេញពីលើថ្មនោះបាត់ទៅ។

**ទៀវងាន់**មានសេចក្តីសោមនស្សត្រេកអរពន់ប្រមាណណាស់ ក៏ត្រឡប់ទៅប្រាប់អាថ៌សេចក្តីទាំងពួងដល់**គួនឡូ**គ្រប់ប្រការ ហើយសួរ**គួនឡូ**ថា មនុស្សចាស់ទាំងពីរនាក់គឺអ្វី? **គួនឡូ**ប្រាប់ថា ដែលពាក់អាវក្រហមនោះគឺទេព្តាខាងត្បូងសម្រាប់កាន់បញ្ជីមនុស្សទាំងពួងយកកំណើត ដែលពាក់អាវសនោះគឺ ទេព្តាខាងជើងសម្រាប់កាន់បញ្ជីមនុស្សទាំងពួងដែលដល់កំណត់អាយុនឹងស្លាប់។ លុះប្រាប់ប៉ុណ្ណោះហើយក៏ហាមថា ខ្លួនអ្នកឯងផុតរួចអំពីទុក្ខភ័យហើយ មិនត្រូវសាកសួរអ្វីតទៅទៀតទេ។ **គួនឡូ**ក៏លាអាពុក**ទៀវងាន់**ទៅកាន់ទីលំនៅវិញ។ តាំងពីនោះមក **គួនឡូ**ខ្លាចស្លាប់មិនបានរៀនវិជ្ជាចេះដឹងតទៅទៀតឡើយ។ ទើប**ខៅជី**និយាយថា

ឥឡូវនេះ**គួនឡួ**នៅក្នុងស្រុកផេងងួនគួន សូមឲ្យលោកទៅហៅខ្លួនមកមើល ទើបនឹងដឹងច្បាស់ថាគ្រោះល្អ ឬអាក្រក់។

**ចូឆ្វ**បានស្តាប់រឿងរ៉ាវដូច្នោះក៏មានចិត្តត្រេកអរណាស់ ទើបចាត់បម្រើឲ្យទៅឯស្រុកផេងងួនគួនរកខ្លួន**គួនឡួ** នាំចូលទៅហើយ**ចូឆ្វ**ឲ្យមើលគ្រោះថាល្អ ឬអាក្រក់ធ្ងន់ឬស្រាល? **គួនឡួ**ពិគ្រោះមើលក៏ឃើញថា ដែលលោកឈឺនេះ ព្រោះមានមនុស្សមានតម្រិះវិជ្ជាមន្តធ្វើកលបំបិទបំបាំង កុំព្រួយអ្វីឡើយ មិនមានអន្តរាយទេ ឯជំងឺនេះជាអស់ទៅហើយ។ **ចូឆ្វ**ឮហើយក៏គិតឃើញមែន ហើយសួរថា អ្នកចូរមើលពីស្រុកទេស តើនឹងល្អ ឬអាក្រក់ប្រការម្តេច? **គួនឡួ**ក៏ទំនាយជាពាក្យកាព្យឃ្លោងថា៖

ហ្វូងជ្រូកស៊ីកសៀតជ្រៀតជ្រកព្រៃ ខ្លាខ្លាំងវាងវៃមានជ័យឈ្នះ
ដេញជ្រូកជ្រកជ្រៀតខ្នាតស្រឡះ ពុំអាចមកប៉ះពាលនឹងខ្លា។
នៅកើតសឹកសាមសង្គ្រាមធំ ប្រឹបភ្នំកេងភុនសានបព្វតា
ខ្លួនលោកនឹងខាតខូចហត្ថា ខាងឆ្វេងឲ្យអសារសូន្យសោះ។
បើនឹងរំពឹងក្នុងតម្រា ថាជាសេនាឯកបង្អស់
ពុំនោះបងប្អូនលោកដោយស្មោះ សុំលោកពិគ្រោះគិតឲ្យមាំ។

**ចូឆ្វ**ថា ពាក្យទំនាយរបស់អ្នកនេះ ឃើញថាជាការចំណានណាស់ យើងនឹងតាំងអ្នកជាហោរាធ្វើការក្នុងរាជការ។ **គួនឡួ**ថា ខ្លួនខ្ញុំបាទនេះជាមនុស្សមានវាសនាតិចណាស់ មានចិត្តប្រាថ្នាចង់នៅតែក្នុងរូងភ្នំក្រំថ្មជាទីរហោឋាន បង្ក្រាបបានតែលើពួកខ្មោចបិសាចព្រៃ ដែលនឹងចេញខ្លួនមកនៅក្នុងទីប្រជុំជននោះ បុណ្យមិនមានមិនអាចប៉ានមកទេ។ **ចូឆ្វ**ថា អ្នកចូរមើលដួងជតាយើង ថានឹងមានបុណ្យឡើងទៅទៀតឬទេ?

**គួនឡួ**ថា ខ្លួនលោកមានបុណ្យឡើងដល់ព្រះចៅ**វុយអេង**ស្មើនឹងព្រះចៅ**ហៀនតេ**ម្ចាស់ផែនដី ដែលនឹងឲ្យមើលឡើងទៅទៀតនោះ អស់តម្រាហើយ។ **ចូឆ្វ**ថា អ្នកចូលមើលនាហ្មឺនមុខមន្ត្រីទាំងអស់ ដែលអង្គុយក្នុងទីនេះ តើនរណានឹងល្អ

អាក្រក់ម្ដេចខ្លះ? **គួនឡូ**សើចហើយថា បណ្ដានាហ្មឺនទាំងពួងនោះ គឺសុទ្ធតែជាអ្នកមានតម្រិះប្រាជ្ញា គួរជាខ្ញុំរាជការទាំងអស់បានហើយ។

**ចូឆូ**ថា ចូរឲ្យអ្នកពិគ្រោះមើលទៀត ជាស្រុកសែឈ្មួននិងស្រុកកាំងតាំងនោះនឹងតាំងនៅជាប្រក្រតីទៅឬយ៉ាងម៉េច? **គួនឡូ**ពិគ្រោះមើលហើយថា ស្រុកកាំងតាំងនោះ នឹងរួចទីប្រឹក្សាឯកម្នាក់ ឯ**ឡៅពី**ចៅហ្វាយស្រុកសែឈ្មួននោះ ក៏លើកកងទ័ពទៅវាយយកបានស្រុកហាន់តុង ដែលនឹងថាជាប្រក្រតីនោះមិនទាន់ប្រាកដទេ។ **ចូឆូ**មិនជឿ ទទួលមានបម្រើសេះស្រុកហាប់ប៉ានាំសំបុត្រមកប្ដឹងថា **ឡោសុក**ទីប្រឹក្សាឯកស្រុកកាំងតាំងនោះទទួលអនិច្ចកម្មទៅហើយ។ មានបម្រើសេះមួយទៀតនាំសំបុត្រពីស្រុកហាន់តុងមកប្ដឹងថា **ឡៅពី**ចៅហ្វាយស្រុកសែឈ្មួន ប្រើ**តៀវហ៊ុយ**និង**ម៉ាឈៀវ**ទៅនៅរក្សាស្រុកប៉ាសេមុខជានឹងចូលទៅវាយយកស្រុកហាន់តុង។

**ចូឆូ**ឮដូច្នោះក៏ខឹងណាស់ តាំងឲ្យចាត់ពលទាហាននឹងលើកទៅជួយស្រុកហាន់តុង ក៏ឲ្យ**គួនឡូ**មើលឫក្សពារពេលានឹងលើកកងទ័ពទៅ។ **គួនឡូ**មើលហើយថា ដែលនឹងលើកទៅក្នុងគ្រានេះមិនទាន់ស្រួលទេ ព្រោះប្រជួននឹងចូលឆ្នាំថ្មីមកផង ហើយក្នុងស្រុកហ៊ូតោនោះនឹងកើតអគ្គិភ័យជាធំខ្លាំងណាស់។ **ចូឆូ**ឮដូច្នោះក៏បញ្ឈប់ទ័ពទៅវិញ ទើបចាត់ពលប្រាំម៉ឺន ឲ្យ**ចូហង**លើកទៅជួយ**ហែហ៊ូអៀន** និង**ទៀវខាប់**ដែលនៅរក្សាស្រុកហាន់តុងឲ្យគង់មាំមួន។ ចាត់**ហែហ៊ូទុន**ឲ្យនាំពលបីម៉ឺនជាកងប្រចាំជូនទៅមកសំបុត្រប្ដឹងជាដំណឹងរាជការក្នុងស្រុកហ៊ូតោកុំឲ្យដាច់វេលា ហើយចាត់**អងប៊ិត**ជាអ្នកបង្គាប់បញ្ជារេហ៍ពលក្នុងទីក្រុងហ៊ូតោ។

**សុម៉ាអ៊ី**នាយបញ្ជីក៏ទូលព្រះចៅ**វុយអេង**ថា ដែលនឹងឲ្យ**អងប៊ិត**បង្គាប់បញ្ជាទាហានក្នុងក្រុងហ៊ូតោនោះមិនគួរទេ ព្រោះ**អងប៊ិត**រមែងផឹកស្រាជ្រុលហួសប្រមាណ មានតែរឹងរូសប្រទូសនឹងអ្នកទាំងពួងជាដរាប។ **ចូឆូ**ថា **អងប៊ិត**នេះធ្លាប់ជាភៀនកម្សត់កម្រជាប់ធ្វើការនឹងយើងតាំងពីដើមយូរមកហើយ ចិត្តថ្លើមក៏ទៀងត្រង់សុចរិត បានជាយើងគិតចាត់ឲ្យទៅធ្វើការបង្គាប់បញ្ជាទាហានក្នុងក្រុងហ៊ូតោ

គួរនឹងទុកចិត្តបាន ថាហើយក៏ចាត់នាយទាហានទាំងបីនាក់ឲ្យនាំពលលើកចេញទៅតាមបង្គាប់**ចូឆ្វ** ឯ**អងប៊ិត**នោះ លុះលើកពលទៅដល់ក្រុងហ៊្វូតោហើយ ក៏តាំងទីប្រថាប់នៅទិសខាងកើត។

ខណៈនោះ ព្រះចៅ**ហៀនតេ**ទៅគង់នៅក្រុងហ៊្វូតោបាន២៣ឆ្នាំ ព.ស ៧៦១ លុះដល់ខែមាឃចូលឆ្នាំថ្មី ឈ្មោះ**កេងជី**ពីដើមជានាហ្មឺននៅក្រោមបង្គាប់**ចូឆ្វ** បានលឿនទីជាមន្ត្រីក្នុងព្រះបរមរាជវាំង មានចិត្តស្វាមីភក្តិនឹងព្រះចៅ**ហៀនតេ**ណាស់ **កេងជី**នេះមានសម្លាញ់ម្នាក់ជានាហ្មឺនឈ្មោះ**អ៊ុយឡុង**។ **កេងជី**ក៏អញ្ជើញ**អ៊ុយឡុង**ទៅប្រឹក្សាក្នុងទីស្ងាត់ថា **ចូឆ្វ**វាធ្វើការជាមិត្តប្រទូសនឹងម្ចាស់ផែនដី ដោយអំណាចខ្លាំងណាស់ ឥឡូវវាតាំងខ្លួនជាម្ចាស់**វុយអេង** បំណងនឹងដណ្តើមរាជសម្បត្តិព្រះចៅ**ហៀនតេ**ជាប្រាកដ យើងនឹងគិតឲ្យផែនដីនៅជាសុខក្សេមក្សាន្ត បានជាទីតបស្នងឆ្លងព្រះតេជព្រះគុណព្រះមហាក្សត្រ។ អ្នកត្រូវជួយគិតដូចម្តេច ដើម្បីនឹងកម្ចាត់**ចូឆ្វ**ចេញបាន?

**អ៊ុយឡុង**ឆ្លើយថា ខ្ញុំមានសម្លាញ់ស្និទ្ធម្នាក់ឈ្មោះ**គិមហាន់** ជាពូជឧបរាជមកពីដើម ឯ**គិមហាន់**នេះក៏បានចេញវាចានឹងខ្ញុំមកពីយូរមកហើយថា **ចូឆ្វ**នោះជាមិត្តទ្រុស្តផែនដី គប្បីតែនឹងគិតកម្ចាត់ចេញឲ្យស្រឡះទៅ តែនឹងរកច្រកផ្លូវនៅពុំទាន់មានឱកាសនោះ ឯ**គិមហាន់**នោះគេជាភឿនសម្លាញ់នឹង**អងប៊ិត** ដែល**ចូឆ្វ**ចាត់មកឲ្យឈរត្រួតត្រារក្សាស្រុកហ៊្វូតោនេះ បើដូច្នេះយើងនឹងទៅញុះញង់**គិមហាន់**ឲ្យទៅបញ្ចុះបញ្ចូលបបួល**អងប៊ិត**ឲ្យចូលគំនិតនឹងយើង បើប្រសិនជា**អងប៊ិត**ចូលគំនិតផងវេលាណា ការដែលគិតក៏នឹងសម្រេចបានដោយងាយ។

**កេងជី**ថា **គិមហាន់**នេះជាភឿនសម្លាញ់នឹង**អងប៊ិត**ពិតមែនណាស់ តែការនេះក្រែង**គិមហាន់**មិនទៅនិយាយ ព្រោះ**អងប៊ិត**ជាមនុស្សជំនិតរបស់**ចូឆ្វ**។ **អ៊ុយឡុង**ថា យើងនឹងនាំគ្នាទៅនិយាយមើលកលការ**គិមហាន់**សិន ថាហើយក៏នាំគ្នាទៅឯផ្ទះ**គិមហាន់** ៗឃើញក៏ចេញមកទទួល**កេងជី** និង**អ៊ុយឡុង** ឡើងទៅអង្គុយខាងល្វែង

ក្នុងទីស្ងាត់ គំនាប់គ្នាតាមសមគួរ **អ៊ុយឡុង**តាំងនិយាយជាឧបាយថា យើងមករកអ្នកវេលានេះ ព្រោះប្រាថ្នានឹងចង់ដឹងសេចក្ដីមួយ តែក្រែងចិត្តអ្នកមិនស្មោះសរអាណិត។ **គិមហាន់**ឆ្លើយថា ការអ្វីឲ្យអ្នកស្រដីទៅចុះ។

**អ៊ុយឡុង**ថា ខ្ញុំហើយនឹងអ្នកធ្លាប់ស្គាល់គ្នាជាភឿនសម្លាញ់មកយូរហើយ ឯខ្លួនអ្នកក៏ជាមិត្តសម្លាញ់នឹង**អងប៊ិត** ឥឡូវខ្ញុំគិតឃើញថា ព្រះចៅ**វុយអេង**នឹងបានគ្រងរាជសម្បត្តិជំនួសព្រះចៅ**ហៀនតេ**ពិតប្រាកដហើយ ឯ**អងប៊ិត**សោតក៏ជាខ្ញុំរាជការចាស់ គង់នឹងស្នើសេចក្ដីគាប់ប្រសើរ តាំងឲ្យអ្នកបានជានាហ្មឺនធំ ដែលខ្លួនខ្ញុំមករកអ្នកនេះប្រាថ្នានឹងឲ្យអ្នកជួយទំនុកបម្រុងផែនដី។

**គិមហាន់**បានស្ដាប់ក៏ខឹងណាស់ ស្ទុះក្រោកឡើងស្រែកគំហកឲ្យ**អ៊ុយឡុង**ទទួលមនុស្សបម្រើឆ្នុងតែលើកមកជូន **គិមហាន់**ក៏ចាប់យកប៉ាន់តែបោះចោលទៅហើយថា នឹងយកតែមកឲ្យផឹកយកប្រយោជន៍អ្វី។ **អ៊ុយឡុង**ឃើញដូច្នោះក៏ធ្វើជាខឹងស្រដីថែមថា ខ្លួនខ្ញុំគិតថា អ្នកបានខ្ពង់ខ្ពស់ឡើង ទើបឧស្សាហ៍បែរមុខមករកអ្នកប្រាថ្នានឹងផ្ញើខ្លួនតទៅ នៅមិនទាន់បានដឹងការអ្វី ស្រាប់តែមាក់ងាយប្រមាថធ្វើបង្អាប់មុខកណ្ដាលជំនុំ ឲ្យអាប់យសដល់មនុស្សបាវព្រាវអ្នកដូច្នេះ គួរឲ្យឈឺចិត្តណាស់។

**គិមហាន់**ថា មិនមែនខ្ញុំនឹងមិនគិតដល់អ្នកនោះក៏ទេ តែខ្ញុំតូចចិត្តព្រោះអ្នកដឹងថា **ចូឆូ**ជាសត្រូវរាជសម្បត្តិប្រាកដ ហើយមកលើកសរសើរវាថាជាល្អប្រពៃវិញមួយទៀត ខ្លួនអ្នកក៏ជាខ្ញុំព្រះចៅ**ហៀនតេ**ដូចគ្នា ហេតុម្ដេចមិនគិតតបស្នងសងគុណព្រះមហាក្សត្រឲ្យប្រាកដកេរ្ដិ៍ឈ្មោះទុក ដែលនឹងមកតាំងចិត្តគិតពឹងបុណ្យ**ចូឆូ**នោះ ខ្ញុំមិនគួរនឹងរាប់មុខទុកអ្នកជាមិត្តសម្លាញ់ទៅទៀតសោះ។

**អ៊ុយឡុង**និង**កេងជី**ឃើញដូច្នោះក៏គិតថា **គិមហាន់**នោះមានចិត្តកតញ្ញូនឹងព្រះចៅ**ហៀនតេ**ពិតប្រាកដណាស់។ **អ៊ុយឡុង**ថា ខ្លួនខ្ញុំបាននាំ**កេងជី**មកនេះ ប្រាថ្នានឹងជួយទំនុកបម្រុងអ្នកគិតកម្ចាត់**ចូឆូ**ចេញ ដើម្បីនឹងជួយគ្នាការពារផែនដីថ្វាយព្រះ

មហាក្សត្រតទៅ លុះនិយាយប្រាប់អ្នកដោយការពិតក៏គិតខ្លាច បានជាក្លែងឧបាយនិយាយលចិត្តមើលសិន។ វេលានេះក៏ឃើញចិត្តអ្នកសុចរិតពិតត្រង់ហើយ អ្នកចូររម្ងាប់កំហឹងទៅចុះ។

**គិមហាន់**ថា ជីតាជីដូន និងបិតាមាតាខ្ញុំ ក៏ទទួលទានបៀវត្សជាខ្ញុំរាជការតៗ មករហូតដល់ខ្លួនខ្ញុំ ៗឬនឹងធ្វើក្បត់ទៅចូលខាងអាសត្រូវរាជសម្បត្តិនោះ? ដែលអ្នកទាំងពីរគិតដូច្នេះ ខ្ញុំក៏ត្រូវចិត្តដើម្បីនឹងកម្ចាត់វាចេញ តែអ្នកនឹងរិះគិតដូចម្ដេច ទើបនឹងសម្រេចតាមប្រាថ្នា? **អ៊ុយឡុង**ថា ខ្ញុំគិតនឹងកម្ចាត់**ចូឆ្វ**ចេញដរាប តែនឹងរិះរកកលឧបាយយ៉ាងណាក៏នៅមិនទាន់រកប្រាជ្ញានោះឃើញ។

**គិមហាន់**ថា ខ្លួនខ្ញុំជាមិត្តសម្លាញ់នឹង**អងប៊ិត**ក៏ពិតមែន តែនឹងទុកចិត្តវាមិនបាន ខ្ញុំគិតនឹងធ្វើកលឧបាយសម្លាប់**អងប៊ិត**ចេញ ហើយដណ្ដើមយកត្រាសម្រាប់ងារនេះមកទុក នឹងបានបង្គាប់បញ្ជាលើទាហានទៅ ហើយខ្ញុំនឹងតែងជាព្រះរាជតម្រាស់ព្រះចៅ**ហៀនតេ**ទៅដល់**ឡៅពី** ឲ្យលើកទ័ពមកវាយយកស្រុកងៀបគុន យើងនឹងលើកទាហានទៅធ្វើជាកលសឹក វាយប្រសព្វពីក្នុងចេញមក ឃើញថានឹងចាប់**ចូឆ្វ**បានដោយងាយ។

**អ៊ុយឡុង**និង**កេងជី**ឮដូច្នោះក៏មានអំណរណាស់ ទះដៃសើចហើយថា អ្នកគិតដូច្នេះល្អណាស់។ **គិមហាន់**ថា ខ្ញុំមានមិត្តសម្លាញ់ពីរនាក់ទៀត ឯឈ្មោះទាំងពីរនាក់នោះ មានចិត្តឈឺក្ដៅក្រហាយនៅច្រើនណាស់ ព្រោះ**ចូឆ្វ**សម្លាប់ឪពុកវានិងបងប្អូន យើងនឹងបបួលឈ្មោះទាំងពីរមករួមគំនិតគ្នា។ **កេងជី**សួរថា ពីរនាក់នោះឈ្មោះអ្វី? **គិមហាន់**ប្រាប់ថា បងឈ្មោះ**កៀតម៉ៅ** ប្អូនឈ្មោះ**កៀតបុក** ជាកូន**កៀតប៉ឹង**ជាពេទ្យដែល**ចូឆ្វ**សម្លាប់ជាមួយនឹង**តាំងស៊ិន**។ **កៀតម៉ៅ**, **កៀតបុក**រត់ចេញទៅនៅស្រុកក្រៅ ឥឡូវចូលមកលាក់ខ្លួនពួនអាត្មានៅស្រុកហ៊ូតោក្រៅទីក្រុង បើយើងឲ្យទៅបបួលមុខជានឹងចូលមកធ្វើការផងមិនខាន ព្រោះមានកិច្ចព្យាបាទ**ចូឆ្វ**ជាប់ជានិច្ច។

**អ៊ុយឡុង**, **កេងជី**យល់ឃើញត្រូវផង **គិមហាន់**ក៏កំណត់ថ្ងៃឱ្យ**អ៊ុយឡុង**, **កេងជី**មកព្រមគ្នា ហើយឱ្យបម្រើស្រួតទៅហៅខ្លួន**កៀតម៉ៅ**, **កៀតបុក**ឱ្យចូលមក **គិមហាន់**ក៏ប្រាប់ថា តាមគំនិតដែលគិតនោះឱ្យស្តាប់គ្រប់ប្រការ។ **កៀតម៉ៅ**, **កៀតបុក** បានស្តាប់ហើយក៏យំសោកាល័យ ហើយថា ជីតាខ្ញុំស្លាប់ក៏ព្រោះ**ចូឆូ** ព្រះចៅ**ហៀនតេ**បានសេចក្តីក្តៅក្រហាយក្នុងព្រះរាជហឫទ័យណាស់ក៏ព្រោះ**ចូឆូ** បើអ្នកគិតដូច្នេះខ្ញុំអរណាស់ សូមប្តូរជីវិតនឹងធ្វើការផង ហើយស្បថស្បាន់ថា ខ្លួនខ្ញុំទាំងបងប្អូននឹងសុំសម្លាប់**ចូឆូ**ចេញឱ្យបាន។

**គិមហាន់**ថា អ្នកកុំព្រួយឡើយ ខ្ញុំនឹងជួយរិះគិតកម្ចាត់**ចូឆូ**ជាសត្រូវផែនដីឱ្យបាន ហើយឱ្យសញ្ញាថា បើដល់ខែមាឃ១៥កើត ជាទំនៀមអ្នកស្រុកគ្រប់ផ្ទះសម្បែងអុជទៀនសប្បាយដល់ពេលអាធ្រាត្រសុទ្ធតែល្បែងមហោស្រព ខ្លួនយើងនឹងចូលទៅរក**អងប៊ិត** ហើយយើងនឹងនាំទាហានជាស្ម័គ្របក្សពួក ទៅពួនបង្កប់ជាពីរកង បើឃើញពន្លឺភ្លើងដែលយើងអុជឡើងវេលាណា ឱ្យអ្នករាល់គ្នាលបដុតៗទៅ ហើយឱ្យនាំបក្សពួកវាយប្រសព្វចូលមកឱ្យដល់ទីឈ្នួន**អងប៊ិត** អ្នកចូលតាមយើងទៅក្នុងព្រះបរមរាជវាំង យើងនឹងអញ្ជើញស្តេចព្រះចៅ**ហៀនតេ**ឱ្យយាងឡើងទៅគង់លើកំពូលប្រាសាទទងហងឡៅ យើងនឹងប្រឹក្សានឹងមន្ត្រីទាំងពួងតាមគំនិតដែលគិតទុក ហើយឱ្យ**កៀតម៉ៅ**, **កៀតបុក** ដែលនៅក្រៅកំផែងដុតភ្លើងឡើង ហើយនាំបក្សពួកវាយប្រសព្វចូលទៅ ឱ្យស្រែកប្រកាសដល់ទាហានទាំងពួងថា ដែលធ្វើការនេះនឹងកម្ចាត់សត្រូវរាជសម្បត្តិចេញ នរណាសុចរិតទៀងត្រង់នឹងផែនដី ក៏ឱ្យចេញមកជួយ ហើយយើងនឹងក្រាបទូលព្រះចៅ**ហៀនតេ** ឱ្យមានព្រះតម្រាស់ទៅដល់អាណាប្រជានុរាស្ត្រទាំងពួង ឱ្យតាំងចិត្តរួមគំនិតធ្វើការជាមួយគ្នា ហើយនិងឱ្យមានព្រះតម្រាស់ត្រាស់បង្គាប់ទៅដល់**ឡៅពី** ឱ្យលើកកងទ័ពមកជួយ យើងនឹងលើកទៅចាប់**ចូឆូ**ឯស្រុកង៉ៀបកុន ឯការទាំងអម្បាលនេះ យើងត្រូវធ្វើជា

ការរហ័ស បើនឹងលះទុកឲ្យយូររំលងឆ្នាំក៏នឹងនាំអន្តរាយដល់ខ្លួនយើងដូចកាល**តាំងស៊ិន**មិនខាន។

លុះប្រឹក្សាយល់ឃើញព្រមគ្នាទាំងប្រាំនាក់ហើយ ក៏ចាក់ឲ្យហូរលោហិតចេញលាយនឹងស្រាតាំងសច្ចាស្បថគ្នា រួចផឹកទាំងអស់គ្នាក្នុងខណៈនោះ។ រួច**អ៊ុយឡុង, កេងជឺ, កៀតម៉ៅ, កៀតបុក** ក៏លា**គិមហាន់**ត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួន ឯ**អ៊ុយឡុង, កេងជឺ**ចាត់ចែងបាវព្រាវបានម្នាក់ៗចំនួនបីរយប្លាយ និងគ្រឿងសាស្ត្រាវុធត្រៀមទុក ឯ**កៀតម៉ៅ, កៀតបុក**នោះ បបួលបានពួកភៀនជាងបីរយនាក់កាន់អាវុធគ្រប់ដៃ លើកគ្នាទៅពួនបង្កប់នៅក្នុងព្រៃក្បែរទីក្រុង ធ្វើបែបជាលើកគ្នាដេញសត្វ ដើម្បីមិនឲ្យគេមន្ទិលសង្ស័យ។

ឯ**គិមហាន់**នោះ លុះដល់ថ្ងៃ១៤កើត ក៏ចូលទៅរក**អងប៊ិត**គំនាប់គ្នា ហើយក៏និយាយនឹង**អងប៊ិត**ថា សព្វថ្ងៃនេះ ស្រុកក៏សុខសាន្តសប្បាយដោយសារបុណ្យព្រះចៅ**វុយអេង** ទ្រង់បានប្រាបប្រាមសត្រូវរាបទាបអស់ហើយ ព្រឹកស្អែកជាថ្ងៃចូលឆ្នាំថ្មី ទម្លាប់អ្នកស្រុកប្រុសស្រីត្រូវអុជគោមនិងទៀនធូបបូជា បណ្ដានាហ្មឺនសព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រធ្លាប់លេងមហោស្រពល្បែងតាមទំនៀមបុរាណ សូមឲ្យអ្នកជួយប៉ាវគងឲ្យអស់បណ្ដារាស្ត្រលេងតាមទម្លាប់សព្វទីលំនៅទីចុះ នឹងបានជាទីរុងរឿងថ្កើងព្រះចេស្ដា។ **អងប៊ិត**ក៏យល់ឃើញត្រូវ ទើបចាត់ប្រើទាហានឲ្យចេញទៅប៉ាវគងប្រាប់គ្រប់សព្វទីលំនៅបណ្ដារាស្ត្រឲ្យធ្វើតាមទម្លាប់ចូលឆ្នាំ។

លុះដល់ថ្ងៃ១៥កើត ពេលយប់កណ្ដាលអាធ្រាត្រ អស់អ្នកស្រុកក៏អុជគោមតាមលំដាប់ផ្ទះសម្លេងស្វាងរុងរឿងពេញទូទាំងទីក្រុង អស់បណ្ដានាហ្មឺនមុខមន្ត្រីធំតូច និងចាស់ប្រុសស្រីក៏ដើរលេងឈូឆរជាទីត្រេកអរសប្បាយ ខ្លះលេងភ្លេងតូរ្យតន្ត្រី ចាប៉ី ទ្រ តាមមហោស្រពល្បែងទាំងឡាយ លាន់ឮខ្ទរខ្ទាយពេញទីក្រុង **អងប៊ិត**ឃើញដូច្នោះក៏សោមនស្សត្រេកអរណាស់ ឲ្យតែងតុលៀងអាហារនៅទីឈ្ឈួននោះ។

ខណៈនោះ **គិមហាន់**ក៏នាំបក្សពួកទៅពួនបង្កប់នៅប្របទ្វារព្រះបរមរាជវាំង ទិសខាងកើត **អ៊ុយឡុង, កេងជី** និង**កៀតម៉ៅ, កៀតបុក** ក៏នាំបក្សពួកទៅពួនបង្កប់នៅតាមកន្លែងដែលមត់សញ្ញា។ លុះដល់ពេលយាមពីរវេលាណា **គិមហាន់** ក៏តាំងដុតភ្លើងជាច្រើនតំបន់ **អ៊ុយឡុង**ឃើញដូច្នោះ ក៏តាំងដុតតទៅ ហើយដេញកាប់មនុស្សម្នាជាជ្រួលច្របល់ **កៀតម៉ៅ, កៀតបុក**ដែលនៅក្រៅកំផែងឃើញដូច្នោះ ក៏ដុតភ្លើងវាយគងឃ្មោះបង្រុះចូលមកជាពីរផ្លូវ ហើយស្រែកប្រកាសប្រាប់ដល់បណ្ដាអ្នកស្រុកទាំងពួងថា យើងនឹងកម្ចាត់សត្រូវផែនដី នរណានឹងចូលខាងយើង ត្រូវស្រូតរូតមកជួយធ្វើការចុះ អស់នាហ្មឺនដែលមានចិត្តគិតគុំគួន**ចូឆ្វ**ទាំងប៉ុន្មាន ក៏នាំចូលមកជាច្រើន។

ឯ**អងប៊ិត**ឃើញពន្លឺភ្លើងឆេះឡើងជាច្រើនតំបន់ ហើយរាលដាលមកដល់ជិតទីឈ្នួនដូច្នោះក៏ភ័យណាស់ ស្ទុះឡើងបរសេះចេញពីទីនោះប្រទះនឹង**កេងជី** ក៏ចូលប្រយុទ្ធគ្នាជាចលាចល **អងប៊ិត**នោះត្រូវព្រួញអាវុធមុតអស់ទាំងខ្លួន ធ្លាក់ពីលើសេះ ហើយក៏លោតឡើងវិញ ថែមត្រូវព្រួញនិងអាវុធទៀត ក៏ធ្លាក់ពីលើសេះបួនប្រាំដង **អងប៊ិត**ឃើញលើសកម្លាំងនឹងទ្រាំតស៊ូពុំបាន ក៏បំផាយសេះរត់ទៅដល់មុខផ្ទះ **គិមហាន់** ហើយស្រែកហៅ**គិមហាន់**។

ឯភរិយារបស់**គិមហាន់**ឮដូច្នោះក៏សម្គាល់ថា**គិមហាន់**ជាប្ដី ទើបរត់ចេញទៅបើកទ្វារហើយសួរថា បានក្បាល**អងប៊ិត**មកហើយឬអ្វី? **អងប៊ិត**ឮដូច្នោះភ័យស្លុតស្មារតីគិតថា កើតហេតុទាំងនេះព្រោះ**គិមហាន់**ឯងបណ្ដាលឡើង នឹងធ្វើយើងឲ្យវិនាសអន្តរាយ ហើយក៏បរសេះបង្ហួសទៅ ប្រទះនឹង**ចោហ៊ីវ**លើកទាហានមកប្រហែលមួយពាន់ **អងប៊ិត**ក៏ប្រាប់ព័ត៌មានឲ្យដឹង **ចោហ៊ីវ**ឮហើយក៏នាំទាហានស្រូតប្រញាប់ទៅ ឃើញភ្លើងឆេះរាលជាប់ទៅដល់ទ្វារព្រះរាជវាំងជាច្រើនអន្លើ ហើយឆេះរាលឆ្លងចូលទៅទ្វារក្បែរ**ហងឡៅ** ក៏ឲ្យទាហានចូលទៅជួយលត់ភ្លើងជាជ្រួលច្របល់។

ឯព្រះចៅ**ហៀនតេ**ក៏ក្រោកគេចវេះដោះពីភ្លើង វិលចូលព្រះរាជវាំង ស័ព្ទសំឡេងមនុស្សាក៏ស្រែកលាន់រំពងទាំងក្រុង ថាយើងនឹងកម្ចាត់ពួកសត្រូវរាជសម្បត្តិចេញ ដើម្បីនឹងទំនុកបម្រុងព្រះចៅ**ហៀនតេ**ឲ្យបានគង់នៅជាសុខតទៅ។ ខណៈនោះ បណ្ដាបងប្អូន និងបក្សពួក**ចូឆ្វ**ក៏ប្រជុំគ្នាជាពួកៗ មកប្រចាំការរក្សាតាមរាជវាំងគ្រប់អន្លើ។

ឯ**ហែហ៊្វទុន** ដែល**ចូឆ្វ**ប្រើឲ្យមកចាំមើលហេតុការណ៍ខាងក្រៅស្រុកនោះ លុះឃើញពន្លឺភ្លើងឆេះឡើងក្នុងក្រុងសន្ធឹកសន្ធាប់ណាស់ ក៏ឲ្យទាហានមួយកងទៅជួយការពាររំលត់ភ្លើងនោះ ឲ្យទាហានមួយកងទៀតនៅរក្សាពីក្រៅ **ចោហ៊ីវ**ឃើញទាហាន**ហែហ៊្វទុន**លើកចូលទៅក៏ត្រេកអរណាស់ បណ្ដេញទាហានរបស់ខ្លួនឲ្យចូលទៅជួយលត់ភ្លើង ឯពួក**ចូឆ្វ**ដែលលបលួចដុតភ្លើងឆេះផ្ទះសម្បែងនោះ ក៏កាប់សម្លាប់គ្នាស្លាប់ជាច្រើនណាស់ ទាល់តែភ្លឺស្វាង។

ឯ**អ៊ុយឡុង**និង**កេងជី**នោះ ពួកម៉ាកក៏កាន់តែរលោះអស់ទៅ នឹងរកអ្នកឯណាបញ្ចូលជាពួកបំពេញឡើងគ្មាន មានបាវម្នាក់រត់មកប្រាប់ថា ពួក**ចូឆ្វ**ព្រួតគ្នាសម្លាប់**គិមហាន់**, **កៀតម៉ៅ**និង**កៀតបុក**ស្លាប់អស់ទៅហើយ **អ៊ុយឡុង**និង**កេងជី**ក៏ភ័យស្លុតស្មារតី នាំបាវព្រាវដែលសល់ទាំងប៉ុន្មាន បំពារបំពានទម្លាយភ្លើងរត់ទៅមាត់ទ្វារក្រុង ប្រទះនឹង**ហែហ៊្វទុន**លើកទាហានមកព័ទ្ធវាំងខាំងនៅពីមុខណែនណាន់ **ហែហ៊្វទុន**ឃើញប្លែក ក៏ឲ្យទាហានដេញកាប់សម្លាប់បាវព្រាវ**អ៊ុយឡុង**និង**កេងជី**ស្លាប់អស់នៅតែ**អ៊ុយឡុង**និង**កេងជី**ពីរនាក់ **ហែហ៊្វទុន**ឲ្យចាប់បាន យកទៅឃុំទុកក្នុងគុកយ៉ាងខ្ជាប់ខ្ជួន ហើយនាំទាហានទៅជួយលត់ភ្លើងដែលឆេះនោះរលត់អស់ទៅ ទើបនាំយកខ្លួន**អ៊ុយឡុង**, **កេងជី**មកពិចារណា សួរបានសេចក្ដីហើយក៏ឲ្យទាហានទៅចាប់គ្រប់គ្រួនិងបងប្អូនញាតិសន្ដាន**អ៊ុយឡុង**, **កេងជី**, **កៀតម៉ៅ**, **កៀតបុក**, **គិមហាន់**មកដាក់គុកទាំងអស់ ទើប**ហែហ៊្វទុន**ចាត់បម្រើសេះឲ្យកាន់សំបុត្រទៅទូលព្រះចៅ**វុយអេង**តាមហេតុនេះគ្រប់ប្រការ។

**ចូឆ្វ**ដឹងការណ៍តាមសំបុត្រហើយ ក៏ឲ្យចុតហ្នាយតបទៅវិញសេចក្ដីថា ឲ្យ**ហៃហ្វ៊ុទុន**សម្លាប់**អ៊ុយឡុង**និង**កេងជីវ** ហើយនិងស្ម័គ្របក្សពួកគ្រួសារញាតិកាអាកំណាចទាំងអម្បាលនោះឲ្យអស់កុំឲ្យសល់ ហើយឲ្យ**ហៃហ្វ៊ុទុន**យកខ្លួនបណ្ដានាហ្មឺនធំតូចទាំងប៉ុន្មាន ដែលមានក្នុងក្រុងហ៊្វូតោបញ្ជូនទៅឯ**ចូឆ្វ**នៅស្រុកង៉ៀបកុន ដើម្បីនឹងពិចារណាឯង។

**ហៃហ្វ៊ុទុន**ទទួលបង្គាប់តាមចុតហ្នាយ ក៏ឲ្យយកអាកំណាចដែលមានឈ្មោះទាំងប្រាំនាក់និងស្ម័គ្របក្សពួកគ្រប់គ្រួញាតិសន្ដានទៅប្រហារជីវិតទាំងអស់ ឯ**អ៊ុយឡុង**និង**កេងជី**ក៏មិនបានកោតញញើតនឹងសេចក្ដីស្លាប់សោះ ចេះតែទ្រគោះជេរ**ចូឆ្វ**មិនឈប់មាត់ ទាល់តែទាហានចុះដាវប្រហារជីវិតតែម្ដង ហើយ**ហៃហ្វ៊ុទុន**ក៏ឲ្យចាប់អស់នាហ្មឺនមុខមន្ត្រីទាំងធំតូច បណ្ដាដែលមានក្នុងក្រុងហ៊ុំតោនោះ បញ្ជូនទៅឲ្យ**ចូឆ្វ**ឯស្រុកង៉ៀបកុន។

**ចូឆ្វ**ក៏ឲ្យយកខ្លួននាហ្មឺនមុខមន្ត្រីទាំងអស់នោះ ទៅប្រជុំនៅមុខព្រះលាន ហើយឲ្យយកទង់ពណ៌ក្រហមដោតម្ខាង យកទង់សដោតម្ខាង ចម្ងាយពីគ្នាប្រហែលដប់សិន ហើយ**ចូឆ្វ**និយាយថា កាលអាចោរកំណាចទាំងប្រាំនាក់ គប់គិតគ្នាដុតផ្ទះសម្បែងអ្នកស្រុកក្នុងក្រុងហ៊្វូតោឆេះឡើងនោះ អស់អ្នកឯងរាល់គ្នា តើអ្នកឯណាបានទៅជួយលត់ភ្លើងខ្លះ បើនរណាជួយលត់ត្រូវទៅអង្គុយខាងទង់ក្រហម នរណាដែលមិនបានទៅជួយលត់ទេ ឲ្យទៅអង្គុយខាងទង់ស។

នាហ្មឺនមុខមន្ត្រីទាំងអស់ លុះបានឮ**ចូឆ្វ**ថាដូច្នោះ ក៏នាំគ្នាគិតថា **ចូឆ្វ**ឲ្យធ្វើដូច្នេះ ប្រាថ្នានឹងយកទោសអ្នកដែលមិនបានទៅជួយលត់ភ្លើង ទើបនាំគ្នាទៅកាន់ទង់ក្រហមដល់បួនភាគប្រាំ ឯនាហ្មឺនដែលមានចិត្តទៀងត្រង់មិនបានទៅជួយលត់ភ្លើងនោះ ក៏នាំគ្នាទៅខាងទង់សប្រហែលមួយភាគ។

**ចូឆ្វ**ឃើញដូច្នោះក៏ថា បណ្ដាអ្នកដែលទៅជួយលត់ភ្លើងនោះ គឺមិនមែនទៅដោយសុចរិតទេ ទៅព្រោះចូលគំនិតគ្នានឹងអាក្បត់ ប្រាថ្នានឹងរួមបញ្ចូលគ្នាមក

ប្រទូសរ៉ាយយើងប្រាកដ។ ថាហើយក៏ឲ្យចាប់ខ្លួននាហ្មឺនដែលទៅនៅខាងទង់ក្រហមប្រហែលបីរយប្ដាយនាក់ទៅប្រហារជីវិតនៅក្បែរមាត់ទន្លេសៀងហោ ឯនាហ្មឺនដែលទៅនៅខាងទង់សនោះ **ចូឆ្វ**ថា អ្នកទាំងអស់នេះសុទ្ធតែមានចិត្តសុចរិតត្រង់នឹងយើង ក៏ឲ្យបំណាច់រង្វាន់តាមសមគួរ ហើយឲ្យគង់ស័ក្តិយសនៅដូចដែលឲ្យវិលត្រឡប់ទៅនៅធ្វើការរាជការឯក្រុងហ៊្វូតោវិញ។

ខណៈនោះ មានសំបុត្រ**ចោហ៊ីវ**ប្ដឹងមក**ចូឆ្វ**សេចក្ដីថា **អងប៊ិត**នោះត្រូវអាវុធមានរបួសជាច្រើនអន្លើ របួសនិងព្រួញកំរើបខ្លាំង ក៏ទទួលអនិច្ចកម្មទៅហើយ **ចូឆ្វ**ដឹងដូច្នោះក៏មានចិត្តអាណិតណាស់ ទើបបើកមាសប្រាក់ឲ្យទៅតែងការសព**អងប៊ិត**បញ្ចុះទុកក្នុងក្រុងហ៊្វូតោ ហើយឲ្យតែងសំបុត្រទៅតាំង**ចោហ៊ីវ**ឲ្យបង្គាប់បញ្ជាទាហានទាំងពួងក្នុងក្រុងហ៊្វូតោ ឲ្យ**ចុងអ៊ីវ**ជាមហាឧបរាជ **ហ៊្វូហ៊ឹម**ជាបាឡាត់ឧបរាជ ឯទីនាហ្មឺនដែលគ្មានខ្លួននោះ ក៏ចាត់ទាហានធំ តូចតាំងឡើងតាមថ្នាក់ និងគុណបំណាច់តាមតំណែង។

**ចូឆ្វ**គិតថា **គួនឡូ**ចំណានក្នុងក្បួនទំនាយពិតប្រាកដណាស់ ក៏ចាត់មាសប្រាក់និងរបស់ទ្រព្យមានតម្លៃឲ្យជាបំណាច់រង្វាន់**គួនឡូ** ៗគំនាប់ទទួលហើយថា ខ្លួនខ្ញុំបាទនេះមានចិត្តស្ម័គ្រស្រឡាញ់តែស្វែងទៅនៅក្នុងរូងភ្នំក្រំថ្ម នឹងទទួលយកមាសប្រាក់នូវអស់របស់ទ្រព្យទៅនោះ មិនជាប្រយោជន៍អ្វីទេ សូមជូនលោកទុកចែកពលទាហានតាមត្រូវការចុះ។

*លោកអ្នកអានអាចរកបានសៀវភៅផ្សេងទៀតតាមរយៈប្លក៖*

www.khmerliterature.wordpress.com

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៥៧

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ចោហង**លើកទ័ពទៅដល់ស្រុកហាន់តុង ហើយ**ចោហង**លើករំលងទៅប៉ះច្បាំងនឹង**តៀវហ៊ុយ, ម៉ាឈៀវ** នៅស្រុកប៉ាសេ រហូតដល់**ឡៅពី, ខុងបេង**លើកទ័ពទៅវាយស្រុកហាន់តុង)។*

ឯ**ចោហង**កាលទៅដល់ស្រុកហាន់តុងហើយ ក៏ចាត់ចែងឲ្យ**ហែហ៊្វូអៀន**និង**ទៀវខាប់**នៅរក្សាស្រុកគ្រប់គយផ្លូវនៅតំបន់ទីនោះ ហើយ**ចោហង**ក៏លើកទ័ពនឹងទៅច្បាំងនឹង**តៀវហ៊ុយ, ម៉ាឈៀវ**ឯស្រុកប៉ាសេ លុះទៅដល់កណ្ដាលផ្លូវទទួលដឹងដំណឹងថា **តៀវហ៊ុយ**ឲ្យ**ម៉ាឈៀវ**លើករំលងទៅដល់តំបន់ហែពៀន។

ខណៈនោះ **ម៉ាឈៀវ**ក៏ចាត់ឲ្យ**ង៉ំឡាន់**និង**ងិមអេង** លើកទាហានទៅល្បាតលាតក្រវែលទទួលប្រទះនឹង**ចោហង** **ង៉ំឡាន់**ក៏ប្រឹក្សានឹង**ងិមអេង**ថា បើប្រសិនជាយើងនឹងចូលទៅច្បាំងនឹងកងទ័ពនេះ ទាហានយើងក៏តិចពេក ត្រូវតែវិលត្រឡប់ទៅប្រាប់**ម៉ាឈៀវ**សិនទើបគួរ **ងិមអេង**ថា ដែលនឹងទៅវិញទទេនោះ មុខជា**ម៉ាឈៀវ**នឹងចាប់ទោសយើងវិញមិនខាន ឯកងទ័ព**ចោហង**ទើបតែនឹងមកដល់ គួរនឹងចូលទៅច្បាំងឲ្យដឹងដៃគ្នាសិនទើបគួរ ទោះបីយ៉ាងណាទាហាន**ចោហង**គង់នឹងថយដៃត្រឡប់ទៅវិញមិនខាន ទើប**ងិមអេង**បរសេះវាំលំពែងចូលទៅស្រែកឡកចំអកឲ្យ**ចោហង**ដល់មុខបន្ទាយ។

**ចោហង**ឮដូច្នោះក៏ខឹងណាស់ បរសេះចេញពីក្នុងបន្ទាយ មកតស៊ូគ្នានឹង**ងិមអេង**បានបីភ្លេង **ចោហង**យកលំពែងចាក់ត្រូវ**ងិមអេង**ធ្លាក់ពីលើសេះស្លាប់ ហើយកាប់សម្លាប់ទាហានស្លាប់ជាច្រើន។ **ង៉ំឡាន់**ឃើញកម្លាំងនឹងតទល់ពុំបាន ក៏

នាំទាហានដែលសល់នោះរត់ទៅដល់តំបន់ហៃពៀន ហើយចូលទៅប្តឹង**ម៉ាឈៀវ**គ្រប់ប្រការ។

**ម៉ាឈៀវ**បានដឹងដូច្នោះក៏ខឹងណាស់ថា ខ្លួនគ្រាន់ជាអ្នកយាមល្បាតទេ បើបានឃើញប្រទះនឹងសត្រូវ គួរតែវិលមកប្រាប់យើងសិន ហេតុអ្វីខ្លួនប្រញាប់តែច្បាំងឲ្យថ្លោះការដូច្នេះ? ទោសខ្លួនជាទម្ងន់ខ្លាំងណាស់។ **ង៉ឡាន់**ឆ្លើយថា កាលទៅប្រទះនឹងសត្រូវនោះ ខ្ញុំបាទបាននិយាយប្រាប់ថា ឲ្យវិលមកជម្រាបលោកឲ្យជ្រាបសិន **ង៉ិមអេង**មិនព្រមស្តាប់ត្រឡប់ចចេសចូលទៅតតាំងច្បាំងទាល់តែស្លាប់ខ្លួន បានជាខ្ញុំបាទបែករត់មកដល់លោកនេះ។ **ម៉ាឈៀវ**ក៏កាត់ទោសព្យួរ**ង៉ឡាន់**ឲ្យរាងចាល។ ទើបឲ្យត្រួតត្រាបណ្តាពលទាហានឲ្យបានព្រមព្រៀងហើយ ក៏ឲ្យតែងសំបុត្រមកប្តឹងរឿងរ៉ាវទាំងពួង ចូលទៅដល់ស្រុកសែឈ្វនមួយច្បាប់ ឲ្យ**តៀវហ៊ុយ**មួយច្បាប់។

ឯ**ចោហង**នោះ លុះមិនឃើញ**ម៉ាឈៀវ**ចេញមកច្បាំងជាយូរថ្ងៃ ក៏គិតបារម្ភក្រែង**ម៉ាឈៀវ**នឹងធ្វើកលឧបាយផ្សេងៗ ទើបលើកកងទ័ពត្រឡប់ថយទៅតាំងបន្ទាយនៅស្រុកហាន់តុងវិញ។ **ទៀវខាប់**ដឹងដូច្នោះ ក៏ចូលទៅសួរពិគ្រោះ**ចោហង**ថា ខ្លួនលោកបានលើកទ័ពចេញទៅកាប់សម្លាប់ទាហាន**ម៉ាឈៀវ**ស្លាប់ជាច្រើនហើយ ហេតុម្តេចក៏គេចត្រឡប់លើកទ័ពចូលមកវិញ?

**ចោហង**តបថា ខ្លួនយើងបានធ្វើការបានប្រៀបដល់សត្រូវក៏មែនហើយ តែមិនបានឃើញ**ម៉ាឈៀវ**ចេញមកតស៊ូគ្នាជាយូរថ្ងៃណាស់ យើងមានបារម្ភក្រែង**ម៉ាឈៀវ**នឹងធ្វើកលឧបាយផ្សេងៗ ប្រការមួយ កាលយើងនៅក្នុងស្រុកង៉ៀបកុននោះ**គួនឡូ**ទាយថា ព្រះចៅ**វ៉ុយអេង**នឹងខូចខាតបងប្អូន ឬទាហានឯកម្នាក់នៅភ្នំឡាំសាន់ យើងនឹកបារម្ភក្រែងដូចទំនាយ**គួនឡូ** បានជាថយទ័ពមកសិន។

**ទៀវខាប់**ស្តាប់ហើយអស់សំណើចថា ខ្លួនលោកជាវង្សព្រះចៅ**វ៉ុយអេង**ហើយលោកក៏ជាទាហានឯក ហេតុម្តេចទៅជឿស្តាប់ពាក្យទំនាយគ្រូមើលដូច្នោះ ខ្ញុំ

បាទនឹងសុំនាំទាហានរបស់ខ្ញុំបាទលើកទៅវាយយកស្រុកប៉ាសេឲ្យបាន បើបានស្រុកប៉ាសេវេលាណា ស្រុកសែឈ្នួនក៏ដូចនៅក្នុងកណ្ដាប់ដៃយើងវេលានោះ។

**ចោហង**តបថា អ្នកក៏បានដឹងមកហើយថា **តៀវហ៊ុយ**នោះមានថ្វីដៃខ្លាំងពូកែក្លាហានបានមកនៅស្រុកប៉ាសេនោះ ហេតុម្ដេចអ្នកមើលងាយ**តៀវហ៊ុយ**ដូច្នេះ? **ទៀវខាប់**ថា ឯមនុស្សឯទៀតៗ គេរមែងកោតខ្លាចថ្វីដៃ**តៀវហ៊ុយ**ទាំងអស់ តែខ្លួនខ្ញុំបាទនេះមើលទៅឃើញ**តៀវហ៊ុយ**មានគំនិតប្រាជ្ញាបីដូចកូនក្មេងប្រាំពីរខួប ខ្ញុំបាទនឹងសុំអាសាចេញទៅចាប់ខ្លួន**តៀវហ៊ុយ**ឲ្យខាងតែបាន។ **ចោហង**ថា បើអ្នកឯងធ្វើការនោះត្រឡប់ជាមិនបានវិញ តើនឹងឲ្យធ្វើប្រការម្ដេច?

**ទៀវខាប់**ថា ខ្ញុំបាទសុំសរសេរសំបុត្រសញ្ញាទុកជូនលោក បើមិនបានសមប្រកបដូចពាក្យថាទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទចេញចុះ ថាហើយក៏សរសេរសំបុត្រសញ្ញាទុកឲ្យ**ចោហង** ហើយចាត់ចែងទាហានបានបីម៉ឺន លើកទៅជិតតំបន់ហៃពៀន ទើបតាំងបន្ទាយមួយឈ្មោះផេកងៀម បន្ទាយមួយឈ្មោះបងថៅ បន្ទាយមួយឈ្មោះបងសេក បែងទាហានឲ្យនៅរក្សាបន្ទាយនីមួយៗទាហាមួយម៉ឺននាក់។ **ម៉ាឈៀវ**ក៏មិនបានចេញច្បាំង លុះនៅមកមួយថ្ងៃ **ទៀវខាប់**ក៏បែងទាហានបន្ទាយមួយទាហានប្រាំពាន់នាក់ លើកកាត់ផ្លូវតម្រង់ទៅវាយប៉ាសេ។

**តៀវហ៊ុយ**ដឹងដូច្នោះ ក៏ប្រឹក្សានឹង**លុយតង**ថា យើងនឹងគិតប្រការម្ដេច? **លុយតង**ថា ផ្លូវទាំងអស់នោះឆ្ងាយដាច់ស្រយាលណាស់ សុទ្ធតែច្រកជ្រោះជ្រលងដងស្ទឹង ក្នុងព្រៃភ្នំ ខ្ញុំបាទសុំទាហានទៅពួនបង្កប់ បើកងក្រវែល**ទៀវខាប់**មិនបានដើរមកដល់ ព្រោះផ្លូវនោះចំពោះច្រកភ្នំ ត្រូវឲ្យលោកលើកកងទ័ពធំចេញទៅតស៊ូនឹង**តៀវខាប់**ឲ្យជាប់ដៃ ខ្ញុំបាទនឹងនាំទាហានចេញមកវាយប្រសព្វពីក្រោយ គង់នឹងចាប់ខ្លួន**ទៀវខាប់**បាន។

**តៀវហ៊ុយ**យល់ឃើញត្រូវ ក៏ចាត់ចែងទាហានប្រាំពាន់ ឲ្យ**លុយតង**លើកទៅពួនបង្កប់នៅក្រៅស្រុក ហើយ**តៀវហ៊ុយ**ក៏នាំទាហានមួយម៉ឺន ចេញទៅតាំងបន្ទាយ

នៅបៀតជាប់គ្នា **តៀវហ៊ុយ**ក៏បរសេះនាំទាហានទៅស្រែកឡកចំអកឲ្យ**ទៀវខាប់** ៗ បានឮក៏ខឹងណាស់ បរសេះចេញមកតយុទ្ធនឹង**តៀវហ៊ុយ**បានសាមសិបភ្លែង។

**លុយតង**ឃើញដូច្នោះ ក៏លើកទាហានវាយស្កាត់ចុងផ្លូវចូលទៅសម្លាប់ទាហាន**ទៀវខាប់**ស្លាប់ជាច្រើន **ទៀវខាប់**ឃើញកម្លាំងនឹងធន់ពុំបាន ក៏ញាក់សេះនាំទាហានវេះរត់ **តៀវហ៊ុយ**ក៏តាមពីក្រោយបណ្ដោយទៅ **លុយតង**ក៏បញ្ចេញទាហានមកវាយស្ទាក់ពីមុខជាប់ **ទៀវខាប់**និងទាហានបំពានទៅមិនរួច ក៏ស្ទុះប៉ះទម្លាយទៅខាង បែកខ្ញែកគ្នារត់ចេញទៅ **តៀវហ៊ុយ**និង**លុយតង**លើកទ័ពប្រសព្វគ្នាដេញតាមទៅ **ទៀវខាប់**ក៏រត់ចូលបន្ទាយបាន **តៀវហ៊ុយ**និង**លុយតង**ក៏លើកទាហានបំពានវាយបន្ទាយផេកងៀម ហើយឲ្យទាហានបាញ់ធ្នូចម្រុះបោះចោលដុំថ្មទៅជាច្រើនណាស់ **ទៀវខាប់**ក៏ឲ្យទាហានត្រួតត្រារក្សាបន្ទាយមិនបានជាអន្តរាយ។

**តៀវហ៊ុយ**ឃើញដូច្នោះ ក៏លើកទាហានថយចេញមកវិញ ហើយឲ្យបោះបន្ទាយចម្ងាយពីគ្នាប្រហែលមួយរយសិន (៤ គ.ម) លុះវេលាព្រឹកឡើង ក៏លើកទៅមុខបន្ទាយ ឲ្យទាហានស្រែកជេរជាពាក្យទ្រគោះមាក់ងាយដូចម្ដេច **ទៀវខាប់**ក៏មិនបានចេញតដៃ ឲ្យទាហានរក្សាសើនបន្ទាយជាមាំមួន ហើយ**ទៀវខាប់**ឡើងទៅលេងភ្លេងតន្ត្រីចាប៉ីទ្រនៅលើភ្នំ។ **តៀវហ៊ុយ**ក៏ប្រើទាហានឲ្យស្រែកជេរ**ទៀវខាប់**ជាពាក្យអសុរោះរាល់ពេល **ទៀវខាប់**ក៏មិនបានចុះមកតយុទ្ធគ្នាសោះ **តៀវហ៊ុយ**ឃើញដូច្នោះ ក៏នាំទាហានវិលចូលបន្ទាយវិញ លុះព្រឹកឡើង**តៀវហ៊ុយ**ក៏នាំទាហានទៅឲ្យស្រែកជេរ**ទៀវខាប់**ប្រការម្ដេចៗ **ទៀវខាប់**ក៏នៅសំងំស្ងៀមក្នុងបន្ទាយ ចេះតែលេងភ្លេងមហោរីនៅលើភ្នំ។

**លុយតង**ឃើញដូច្នោះ ក៏នាំទាហានចូលវាយទម្លាយបន្ទាយផេកងៀមជាដរាប **ទៀវខាប់**ក៏ឲ្យទាហានចោលដុំថ្មចេញមកពីក្នុងបន្ទាយ ត្រូវទាហាន**តៀវហ៊ុយ**របួសពិការជាច្រើន។ **តៀវហ៊ុយ**ឲ្យថយចេញមកវិញ ហើយឲ្យទាហានស្រែកជេរប្រមាថ**ទៀវខាប់**ជាច្រើន **ទៀវខាប់**ក៏បង្គាប់ទាហានឲ្យជេរតបមកវិញថា

អា**តៀវហ៊ុយ**ជាអ្នកលក់ស្រា **តៀវហ៊ុយ**ខឹងណាស់មិនដឹងនឹងធ្វើយ៉ាងម្ដេចសោះ តាំងតែរារង់ប្រុងនឹងច្បាំងគ្នាក្នុងទីនោះអស់រវាងហាសិបថ្ងៃ **តៀវហ៊ុយ**ផឹកស្រាស្រវឹងហើយក៏ឲ្យទាហានស្រែកជេរ**ទៀវខាប់**គ្រប់វេលា **ទៀវខាប់**ក៏មិនចេញតច្បាំងសោះ។

ឯបណ្ដាទាហាន ដែលនាំស្បៀងមកជូន**តៀវហ៊ុយ**ឃើញដូច្នោះ លុះត្រឡប់ទៅស្រុកសៃឈ្វនវិញ ក៏យកសេចក្ដីនោះទៅពណ៌នាជម្រាប**ឡៅពី**ថា **តៀវហ៊ុយ**តាំងរាគ្នានឹង**ទៀវខាប់**គ្រប់ហាសិបថ្ងៃហើយ មិនបានតយុទ្ធគ្នាសោះ **តៀវហ៊ុយ**នោះចេះតែផឹកស្រាស្រវឹង ក្លែងឲ្យទាហានទៅស្រែកជេរ**ទៀវខាប់**គ្រប់វេលា **ទៀវខាប់**ក៏មិនបានចេញច្បាំងសោះ។

**ឡៅពី**ឮដូច្នោះក៏ប្រឹក្សានឹង**ខុងបេង**ថា **តៀវហ៊ុយ**ទៅធ្វើការសឹកសង្គ្រាម បើចេះតែផឹកស្រាស្រវឹងដូច្នោះយើងនឹងគិតប្រការដូចម្ដេច? **ខុងបេង**ថា ដែល**តៀវហ៊ុយ**ធ្វើដូច្នេះ ព្រោះមិនមានស្រាខ្លាំងក្នុងកងទ័ព សូមឲ្យចាត់ស្រា “បិតខ្លាំង” ហាសិបឪទិនផ្ញើទៅចុះ។ **ឡៅពី**ថា បើ**តៀវហ៊ុយ**ផឹកស្រាស្រវឹងធ្ងន់វេលាណា ក៏រមែងថ្លោះការគ្រប់គ្រា ហេតុម្ដេចលោកនឹងចង់ឲ្យផ្ញើស្រាទៅឲ្យទៀត នឹងមិនផឹកស្រវឹងឡើងខ្លាំងទេឬ? ការសង្គ្រាមដែលទៅធ្វើនោះ នឹងមិនខូចអសារទៅហើយឬ?

**ខុងបេង**អស់សំណើច ហើយថា លោកជាបងប្អូនបានរួមសុខទុក្ខនឹងគ្នាមកយូរហើយ ហេតុអ្វីនៅមិនស្គាល់ចិត្ត**តៀវហ៊ុយ**វេលានេះ កាលពីដើម**តៀវហ៊ុយ**ជាមនុស្សទ្រើសទ្រនង់អង់អាចកាចសាហាវណាស់មែន តែកាលគ្រាលើកទ័ពមកវាយយកស្រុកសៃឈ្វននេះ ខ្ញុំសម្គាល់ឃើញថា **តៀវហ៊ុយ**លះព្យុហៈកំណាចកាចសាហាវនោះអស់ហើយ មានតម្រេះចេះចាប់**ង៉ៀមង៉ាន់**បានដោយប្រាជ្ញា ក៏ជានិមិត្តប្រកបដោយបុណ្យសម្ភាររបស់លោកគ្រប់គ្រង ទំនងឲ្យ**តៀវហ៊ុយ**ចេះក្លែងនាំទាហានចេញទៅជេរ**ទៀវខាប់**នោះ ព្រោះជាកលបាយ។

**ឡៅពី**ថា ខ្ញុំនៅមិនទាន់ទុកចិត្តសោះ ត្រូវឲ្យ**អ៊ុយអៀន**លើកទាហានទៅជួយទៀត ហើយក៏ចាត់ស្រាបញ្ជូនទៅឲ្យ**តៀវហ៊ុយ**ផ្ទុកពេញរទេះ មានទង់ចារឹកអក្សរថា ឲ្យ**តៀវហ៊ុយ**ខំយកចិត្តគិតធ្វើការឲ្យមានជ័យជម្នះដល់**តៀវខាប់**ឲ្យបាន។ **អ៊ុយអៀន**ទទួលបណ្ដាំហើយ ក៏លា**ឡៅពី**នាំទាហានបររទេះដឹកស្រាទៅដល់បន្ទាយ**តៀវហ៊ុយ**គ្រប់ប្រការ។

**តៀវហ៊ុយ**ឮដូច្នោះ ក៏មានចិត្តសោមនស្សណាស់ ទើបបង្គាប់**លុយតង**និង**អ៊ុយអៀន**ថា យើងនឹងលៀងទាហានឲ្យមានចិត្តកម្រើកសប្បាយ អ្នកទាំងពីរនាយចូរចាំមើលឲ្យជាសុខសប្បាយចុះ បើកាលណាឃើញយើងលើកទង់ក្រហមឡើង ត្រូវឲ្យនាំទាហានចូលទៅព្រួតវាយបន្ទាយ**ទៀវខាប់**ជាប្រញាប់ចុះ ហើយឲ្យចងរូបយន្តបីដូចរូប**តៀវហ៊ុយ** ហើយលាក់ទុក លុះពេលល្ងាចក៏ឲ្យយកស្រាមកលៀងទាហានទាំងពួង រួចឲ្យវាយគងឈ្មោះស្រែកហ៊ោអឹងកងនៅក្នុងបន្ទាយ។ ឯទាហាន**ទៀវខាប់** ក៏លបចេញទៅមើលឃើញកលការហើយ វិលទៅប្រាប់**ទៀវខាប់** ៗដឹងហើយ ក៏នាំទាហានដែលទៅប្រាប់នោះ លបទៅមើលលើកំពូលភ្នំក្បែរបន្ទាយ ឃើញ**តៀវហ៊ុយ**អង្គុយផឹកស្រាឲ្យទាហានដាល់គ្នា **ទៀវខាប់**ក៏ត្រឡប់ទៅបន្ទាយវិញ ហើយគិតថា **តៀវហ៊ុយ**មិនបានឃើញយើងចេញច្បាំង បានជាមានចិត្តកម្រើកលេងល្បែងសប្បាយ មិនមានចិត្តកោតញញើតយើងសោះ។ គិតដូច្នោះហើយ ក៏បង្គាប់ទាហានថា ក្នុងពេលយប់នេះ យើងនឹងលើកទាហានចេញទៅប្លន់បន្ទាយ**តៀវហ៊ុយ** ឲ្យទាហានក្នុងបន្ទាយបងថៅនិងបន្ទាយបងសេក លើកចូលមកវាយខ្ទប់ប្រសព្វគ្នាទាំងឆ្វេងស្ដាំ។

លុះដល់ពេលយប់ខែភ្លឺច្បាស់ **តៀវហ៊ុយ**ក៏ឲ្យយករូបយន្តបំពាក់អាវអង្គុយកាន់ពែងស្រាបែបប្រុងនឹងផឹក មានទាហានចូលទៅចាំបម្រើជាច្រើននាក់ ឯខ្លួន**តៀវហ៊ុយ**នោះនៅពួនលាក់ខ្លួនមិនឲ្យឃើញ ហើយឲ្យ**អ៊ុយអៀន**, **លុយតង**ចាត់ចែងទាហានត្រៀមទុកព្រម។

ឯ**ទៀវខាប់**នោះ លុះនាំទាហានទៅដល់មុខបន្ទាយ**តៀវហ៊ុយ** ឃើញរូប**តៀវហ៊ុយ**នោះអង្គុយផឹកស្រា ក៏សម្គាល់ថា ជា**តៀវហ៊ុយ**ប្រាកដ **ទៀវខាប់**ក៏ប្រញាប់បរពលចូលទៅ ចោមព័ទ្ធវាយបន្ទាយផ្លាយចូលទៅបាន ក៏បរសេះបំពានទៅដល់ យល់**តៀវហ៊ុយ**អង្គុយផឹកស្រាក៏លើកលំពែងឡើង ចាក់ធ្លាក់រូប**តៀវហ៊ុយ**ពីលើកៅអី លុះក្រឡេកឃើញច្បាស់ជារូបយន្តមិនចេះស្តីក៏ភ័យណាស់ ក្រឡាស់បរសេះវេះថយមកក្រោយវិញនឹងចូលបន្ទាយ **តៀវហ៊ុយ**ពួនឃើញច្បាស់ ក៏ស្ទុះចេញមកដុតផាវជាសញ្ញា បណ្តាទាហានទាំងប៉ុន្មានក៏ដុតភ្លើងឡើងពេញក្នុងបន្ទាយ **តៀវហ៊ុយ**ក៏ឡើងសេះចេញទៅស្រែកជេរថា អញឯណេះគឺ**តៀវហ៊ុយ** ហើយក៏បរសេះស្ទុះចូលទៅច្បាំងប្រកាប់គ្នានឹង**ទៀវខាប់**បានសាមសិបភ្លែង។

ខណៈកាល **តៀវហ៊ុយនិងទៀវខាប់**ជាប់ដៃច្បាំងគ្នានោះ ទាហានទាំងពីរបន្ទាយក៏លើកចេញមកជួយ ព្រួតវាយខ្ទប់ប្រសព្វគ្នា ទទួល**អ៊ុយអៀននិងលុយតង**ចេញទៅស្ទាក់ពីមុខជាប់ ហើយ**អ៊ុយអៀន**និង**លុយតង** ក៏បរសេះចូលប្រកាប់សម្លាប់ទាហានទាំងពីរកងនោះបែកខ្ចាត់ខ្ចាយអស់ **អ៊ុយអៀន**និង**លុយតង**ក៏លើកតាមទៅ ហើយវាយទម្លាយយកបន្ទាយ**ទៀវខាប់**បាន ហើយក៏យកភ្លើងដុតបន្ទាយទាំងបីនោះឆេះឡើងព្រមគ្នា។

**ទៀវខាប់**ឃើញដូច្នោះក៏ដឹងថា បន្ទាយទាំងបីនោះវិនាសអស់ហើយដោយកលឧបាយ**តៀវហ៊ុយ** ក៏បំផាយសេះរត់ទម្លុះចេញទៅត្រង់គយថៅគួន **តៀវហ៊ុយ**នោះលុះបានជ័យជម្នះហើយ ក៏ឲ្យបម្រើសេះកាន់សំបុត្រទៅប្តឹង**ឡៅពី**តាមមុខរាជការ **ឡៅពី**បានទទួលដំណឹងដឹងការហើយ ក៏ត្រេកអរណាស់ និយាយថា **តៀវហ៊ុយ**ស្រវឹងស្រានោះជាកលឧបាយដូចពាក្យ**ខុងបេង**ថាមែនៗ។

ឯ**ទៀវខាប់**នោះខូចទាហានអស់ប្រមាណពីរម៉ឺននាក់ ទើបនាំទាហានដែលសល់មួយម៉ឺនទៅតាំងបន្ទាយនៅគយថៅគួន ហើយឲ្យទាហានទៅប្តឹង**ចោហាង**ឲ្យលើកមកជួយ។ **ចោហាង**បានដឹងហើយក៏ខឹងណាស់ថា ការនេះយើងបានហាមឃាត់

ហើយមិនព្រមស្តាប់តាមពាក្យយើងទេ ខំចចេសចចើងទៅច្បាំងនឹង**តៀវហ៊ុយ**ទាល់តែថ្លោះការដូច្នេះ ថែមឲ្យយើងលើកទ័ពទៅជួយទៀត។ **ចោហង**ក៏បង្គាប់ទាហាននោះថា ឲ្យ**ទៀវខាប់**ប្រញាប់លើកទ័ពទៅច្បាំងនឹង**តៀវហ៊ុយ**ទៀត ខំយកជ័យជម្នះវិញឲ្យបាន។ ទាហាននោះក៏ត្រឡប់ទៅប្រាប់**ទៀវខាប់**តាមពាក្យ**ចោហង**ថា។

**ទៀវខាប់**បានស្ដាប់ក៏គិតព្រួយវិតក្កណាស់ ទើបបំបែកទាហាមួយកងឲ្យទៅពួនបង្កប់នៅផ្លូវតូចក្បែរជើងភ្នំមុខគយ ហើយបង្គាប់ថា យើងនឹងលើកទៅច្បាំងនឹង**តៀវហ៊ុយ**ទៀត បើ**តៀវហ៊ុយ**ដេញយើងមកតាមផ្លូវនេះ ក៏ឲ្យអស់អ្នករាល់គ្នាលើកចេញស្ទាក់យកជ័យជម្នះឲ្យបាន។ លុះពេលព្រឹក **ទៀវខាប់**ក៏លើកទាហានចេញពីបន្ទាយ ប្រទះ**លុយតង**លើកទ័ពមក **ទៀវខាប់**ក៏បរសេះចូលច្បាំងនឹង**លុយតង**បានប្រាំភ្លែង **ទៀវខាប់**ធ្វើជារត់ថយ **លុយតង**មិនបានដឹងកលឧបាយក៏ដេញតាមទៅដល់ផ្លូវតូច ដែលទាហាន**ទៀវខាប់**ពួនបង្កប់នៅក្បែរនោះ ទាហានទាំងពួងក៏ដេញព្រមគ្នាមកស្ទាក់**លុយតង**ជាប់។

**ទៀវខាប់**ក៏ត្រឡប់មកព្រួតច្បាំងនឹង**លុយតង**ទៀត **ទៀវខាប់**យកលំពែងចាក់ត្រូវ**លុយតង**ធ្លាក់ពីលើសេះស្លាប់ ទាហានទាំងពួងក៏បែកខ្ចាត់ខ្ចាយរត់ចូលបន្ទាយវិញ ហើយនាំយកសេចក្ដីទៅប្ដឹង**តៀវហ៊ុយ** ៗខឹងណាស់ក៏លើកទាហានស្រូតទៅប្រញាប់ **ទៀវខាប់**ឃើញក៏បរសេះចូលច្បាំងនឹង**តៀវហ៊ុយ**បានប្រាំភ្លែង **ទៀវខាប់**ធ្វើជាចាញ់កន្ត្រាក់សេះរត់ទៅ **តៀវហ៊ុយ**ដឹងក្នុងកល**ទៀវខាប់**ក៏មិនបានដេញតាមទៅ។

**ទៀវខាប់**ឃើញដូច្នោះ ក៏ត្រឡប់សេះមកច្បាំងនឹង**តៀវហ៊ុយ**ទៀតបានប្រាំភ្លែង ហើយរត់ចេញទៅ **តៀវហ៊ុយ**ក៏នាំទាហានចូលបន្ទាយ ហើយនិយាយនឹង**អ៊ុយអៀន**ថា វេលានេះ**ទៀវខាប់**ធ្វើកលបង្កប់ទាហានទុកបញ្ឆោតសម្លាប់**លុយតង**ទៅហើយ ៗនៅចង់បញ្ឆោតយើងទៀត យើងក៏ត្រូវគិតត្រួតកលតនឹង**ទៀវខាប់**វិញឲ្យបាន។ **អ៊ុយអៀន**ថា លោកនឹងគិតធ្វើប្រការដូចម្ដេច?

**តៀវហ៊ុយ**ថា ពេលព្រឹកស្អែកយើងនឹងចេញទៅច្បាំងនឹង**ទៀវខាប់** អ្នកឯងចូរនាំទាហានទៅពួនបង្កប់ខាងក្រោយទាហាន**ទៀវខាប់** ដែលពួនបង្កប់ក្នុងផ្លូវតូចនោះ ហើយត្រូវបែងទាហានឲ្យជញ្ជូនស្មៅស្ងួតផ្ទុកឲ្យពេញរទេះ ហើយនាំយកមកឲ្យច្រើន យើងនឹងដេញ**ទៀវខាប់**ទៅដល់ផ្លូវតូច ត្រូវអ្នកឯងដុតស្មៅឲ្យឆេះឡើងស្ទាក់ពីមុខផ្លូវនិងក្រោយផ្លូវឲ្យបាន មុខជាយើងនឹងចាប់ខ្លួន**ទៀវខាប់**បានជាប្រាកដ **អ៊ុយអៀន**ទទួលពាក្យហើយ លុះដល់ពេលជិតភ្លឺ ក៏លើកទាហានចេញទៅធ្វើតាមពាក្យ**តៀវហ៊ុយ**បង្គាប់។

លុះព្រឹកឡើង **តៀវហ៊ុយ**ក៏នាំទាហានចេញទៅច្បាំង **ទៀវខាប់**ក្រឡេកឃើញក៏បរសេះចូលមកប្រយុទ្ធគ្នានឹង**តៀវហ៊ុយ**បានដប់ភ្លែង **ទៀវខាប់**ធ្វើជាកន្ត្រាក់សេះថយរត់ទៅ **តៀវហ៊ុយ**ក៏ដេញតាមទៅដល់ផ្លូវតូចប្របព្រៃ **ទៀវខាប់**ត្រឡប់វាមកតដៃនឹង**តៀវហ៊ុយ**វិញយូរណាស់ ក៏មិនបានឃើញទាហានដែលពួនបង្កប់នោះវាយប្រសព្វមកវិញសោះ។

ខណៈនោះ**អ៊ុយអៀន**ដែលនាំរទេះដើមភ្លើងទៅនោះ ក៏បានច្បាំងកាប់សម្លាប់ពួកទាហាន**ទៀវខាប់**ស្លាប់ច្រើនណាស់ ហើយភ្លើងដុតឆេះឡើងខាងដើមផ្លូវ និងចុងផ្លូវ **តៀវហ៊ុយ**ឃើញដូច្នោះ ក៏នាំទាហានស្រូតទៅតាមផ្លូវច្រកភ្នំ ឯ**ទៀវខាប់**នោះលុះឃើញភ្លើងឆេះរាលដាលពីមុខចូលមក ក៏នាំទាហានរត់ឆ្លងភ្នំទៅដល់បន្ទាយគយអ៊ួនថៅគួន ហើយឲ្យទាហានត្រួតត្រារក្សាបន្ទាយនោះឲ្យមាំមួន។

**តៀវហ៊ុយ**ក៏លើកទាហានតាមទៅ ព័ទ្ធប្រសព្វគ្នាជុំវិញបន្ទាយនោះ តាំងតែវាយបន្ទាយនោះអស់ប្រាំបួន ទៅដប់ថ្ងៃ ក៏មិនបែក **តៀវហ៊ុយ**ក៏នាំទាហានថយទៅតាំងបន្ទាយចម្ងាយពីគ្នាប្រហែលពីររយសិន (៨ គ.ម) ហើយ**តៀវហ៊ុយ**ក៏នាំទាហានប្រមាណ២៥នាក់ ជាមួយនឹង**អ៊ុនអៀន**ទៅគយគន់មើលផ្លូវតាមច្រកភ្នំ ឃើញផ្លូវនោះដាច់ស្រយាលឆ្ងាយណាស់ ចំពោះដើរឆ្លងកាត់ភ្នំទៅទើបដល់ ទទួល

ឃើញអ្នកស្រុក៥នាក់រែក (ខម) មកតាមជើងភ្នំ ហើយសម្រូតខ្លួនចុះមកតាមវល្លិ ព្រោះភ្នំនោះខ្ពស់ចោតខ្លាំងណាស់។

**តៀវហ៊ុយ**ក៏ប្រាបប្រាមទាហានកុំឲ្យបៀតបៀនអ្នកនោះ ហើយចុះពីលើសេះ នាំ**អ៊ុយអៀន**ដើរចូលទៅសួរសាកអ្នកស្រុកនោះថា អ្នកឯងនៅស្រុកណា នឹងនាំគ្នាទៅណាមកណា? មនុស្សទាំង៥នាក់នោះក៏ឆ្លើយថា ខ្ញុំបាទជាពួកស្រុកហាន់តុង ដើរមករកលក់ដូរ លុះនឹងវិលត្រឡប់ទៅវិញតាមផ្លូវធំ អារម្មណ៍ខ្លាចកងទ័ពដែលមកឈប់តាំងបន្ទាយនៅគយអ៊្វិនថៅគួន បានជានាំគ្នាឆ្លងកាត់រត់តាមផ្លូវនេះ។ **តៀវហ៊ុយ**សួរថា ផ្លូវនេះរហូតទៅដល់ណា? ពួកនោះឆ្លើយប្រាប់ថា ជាផ្លូវតូចចំពោះដើររហូតទៅចូលផ្លូវចុងគយអ៊្វិនថៅគួន។

**តៀវហ៊ុយ**ឮដូច្នោះក៏អរណាស់ នាំពួកនោះមកឯបន្ទាយឲ្យបរិភោគអាហារ ហើយបង្គាប់**អ៊ុយអៀន**ថា ព្រឹកស្អែកអ្នកចូរនាំទាហានមួយកងទៅវាយខាងគយអ៊្វិនថៅគួនខាងមុខ យើងនឹងរើសយកទាហានដែលខ្លាំងពូកែប្រមាណប្រាំរយនាក់ ឲ្យពួកអ្នកជំនួញនេះនាំទៅវាយពីក្រោយគយ។ **អ៊ុយអៀន**យល់ឃើញស្រួល លុះដល់ពេលព្រឹក **តៀវហ៊ុយ**ក៏ចាត់ចែងរើសយកទាហានដែលខ្លាំងពូកែបានប្រាំរយនាក់ ឲ្យពួកឈ្មួញនោះនាំទៅតាមផ្លូវកាត់ **អ៊ុយអៀន**ក៏លើកទាហានទៅដល់មុខគយ។

ឯ**ទៀវខាប់**នោះ លុះបរាជ័យរត់ពី**តៀវហ៊ុយ**ទៅ តាំងតែចាំមើលផ្លូវទាហានដែលពួនបង្កប់ចំនួនមួយយប់ហើយ ក៏មិនឃើញត្រឡប់វិលទៅវិញ ក៏គិតវិតក្កព្រួយណាស់ ទទួលមានទាហានចូលទៅប្រាប់ថា **អ៊ុយអៀន**លើកទាហានមកស្រែកជេរដល់មុខបន្ទាយហើយ **ទៀវខាប់**ស្តាប់ឮហើយក៏ខឹងណាស់ តាំងតែងខ្លួនពាក់ក្រឹស កាន់លំពែងចេញទៅដល់ទ្វារបន្ទាយ ទទួលទាហានខាងក្រោយបន្ទាយរត់ទៅប្រាប់ទៀតថា មានទ័ពមកលបដុតភ្លើងឆេះឡើងក្រោយបន្ទាយដល់ប្រាំអន្លើ ហើយលើកទាហានវាយចូលមកដល់ចុងបន្ទាយហើយ។

**ទៀវខាប់**ឮដូច្នោះក៏ភ័យណាស់ ត្រឡប់មកមិនទាន់ដល់ចុងបន្ទាយក៏ក្រឡេកទៅឃើញ**តៀវហ៊ុយ**លើកទាហានទន្ទ្រានចូលមក ដេញកាប់សម្លាប់ទាហានរបស់ខ្លួនក្នុងបន្ទាយស្លាប់ច្រើនណាស់ **ទៀវខាប់**ក៏បរសេះចេញទៅដល់មុខគយ នឹងចេញទៅតាមផ្លូវតូចច្រកភ្នំ សេះនោះត្រូវអាវុធដើរមិនរួចសោះ **ទៀវខាប់**លោតចោលសេះរត់ឆ្លងភ្នំទៅ មានទាហានតាមទៅផងដប់មួយ ដប់ពីរនាក់ លុះទៅដល់ស្រុកហាន់តុង ក៏ចូលទៅប្ដឹង**ចោហង**តាមហេតុពិតត្រង់គ្រប់ប្រការ។

**ចោហង**បានស្ដាប់ក៏ខឹងណាស់ថា ការនេះយើងបានហាមឃាត់ អ្នកឯងរឹងទទឹងមិនស្ដាប់អួតថ្វីដៃចំណាប់ បានធ្វើទាំងសំបុត្រសញ្ញាទុកផងទៀត ហើយលើកទាហានបីម៉ឺនទៅតតាំងច្បាំងនឹង**តៀវហ៊ុយ** សល់ទាហានមកវិញតែដប់មួយដប់ពីរនាក់ប៉ុណ្ណោះ ទោសអ្នកឯងមិនខុសតាមសញ្ញាហើយឬ? **ចោហង**ក៏បង្គាប់ឲ្យចាប់ខ្លួន**ទៀវខាប់**ទៅសម្លាប់ចេញ។

**កោឈុយ**ក៏ចូលទៅឃាត់ថា បណ្ដាកូនទាហានរកបានដោយងាយ ឯនាយទាហានមានថ្វីដៃឯកនោះរកបានដោយក្រណាស់ មួយទៀតព្រះចៅ**វុយអេង**ក៏ទ្រង់ប្រោសប្រណី**ទៀវខាប់**មកយូរហើយ ដែលលោកនឹងឲ្យសម្លាប់ចោលនោះ មុខគួរឲ្យស្ដាយណាស់ ខ្ញុំសុំឲ្យលោកលើកទោសចោលម្ដងចុះ ដើម្បីនឹងឲ្យ**ទៀវខាប់**លើកទ័ពទៅវាយយកបន្ទាយហែបេងគួនម្ដងទៀត កុំឲ្យកងទ័ពស្រុកសៃឈួនធ្វើអន្តរាយស្រុកហាន់តុងបាន អស់បណ្ដារាស្ត្រក្នុងស្រុកក៏នឹងបានសេចក្ដីសុខតទៅ បើ**ទៀវខាប់**បរាជ័យរត់មកទៀត សឹមលោកធ្វើទោសទាំងមុនក្រោយឲ្យធ្ងន់ទៅចុះ។

**ចោហង**យល់ឃើញត្រូវ ក៏ឲ្យព្យួរទោស**ទៀវខាប់**ទុក ហើយចាត់ទាហានប្រាំពាន់ឲ្យ**ទៀវខាប់**លើកទៅធ្វើការតាមពាក្យ**កោឈុយ**។ **ទៀវខាប់**ក៏ទទួលលើកទាហានប្រាំពាន់ទៅដល់បន្ទាយហែបេងគួន ហើយឲ្យទាហានចូលទៅព័ទ្ធបន្ទាយនោះ **បេងតាត់**និង**ង៉ាក់ជិន**ដែលត្រួតទាហាននៅរក្សាបន្ទាយហែបេងគួននោះ លុះ

ឃើញ**ទៀវខាប់**លើកព័ទ្ធបន្ទាយដូច្នោះ ក៏ប្រឹក្សាគ្នាថា យើងនឹងលើកពលចេញច្បាំងស្រួល ឬនឹងរក្សាការពារបន្ទាយទុកឲ្យនៅស្ងៀមស្រួល?

**ង៉ាក់ជិន**ថា ឲ្យតាំងរក្សាបន្ទាយទុកនៅស្ងៀមស្រួលជាង **បេងតាត់**ពុំជឿស្តាប់ ក៏លើកទាហានចេញតច្បាំងនឹង**ទៀវខាប់** ៗក៏ឡើងសេះចូលតស៊ូគ្នា ហើយ**ទៀវខាប់**ដេញកាប់សម្លាប់ទាហាន**បេងតាត់**ស្លាប់ជាច្រើន **បេងតាត់**ទល់កម្លាំងពុំបាន ក៏នាំទាហានដែលសល់នោះរត់ចូលបន្ទាយវិញ **ង៉ាក់ជិន**ឃើញដូច្នោះក៏បកសំបុត្រប្ដឹងជាផ្លូវការចូលទៅស្រុកសែឈ្នួន។

**ឡៅពី**ឃើញសេចក្ដីសំបុត្រហើយក៏ប្រឹក្សានឹង**ខុងបេង**ថា **ទៀវខាប់**លើកទ័ពទៅវាយបន្ទាយហែបេងគួនក្នុងដែនយើងដូច្នេះ លោកនឹងគិតប្រការម្ដេច? **ខុងបេង**ថា លោកកុំព្រួយ ខ្ញុំបាទនឹងគិតឲ្យទាហានយើងចេញពីនេះទៅវាយ**ទៀវខាប់**ឲ្យបែកបាន ថាហើយក៏ឲ្យប្រមូលនាហ្មឺនមុខមន្ត្រីទូវអស់សេនាទាហានតូចធំ ចូលមកប្រជុំចំពោះមុខ**ឡៅពី** ហើយ**ខុងបេង**ក្លែងនិយាយថា ដំណឹងថា **ទៀវខាប់**លើកទ័ពទៅព័ទ្ធបន្ទាយហែបេងគួន ឯ**ទៀវខាប់**នោះមានថ្វីដៃខ្លាំងពូកែណាស់ សុំឲ្យមានសំបុត្រទៅហៅ**តៀវហ៊ុយ**មក ប្រើឲ្យទៅតស៊ូនឹង**ទៀវខាប់**ទើបបាន។

**ហងតុង**ក៏ប្ដឹងជម្រាប**ខុងបេង**ថា លោកអាចារ្យលុបបំបាត់ពួកទាហានទាំងពួងយ៉ាងនេះ គេនឹងមិនតូចចិត្តទោមនស្សអស់ទៅហើយឬ? សូម្បីតែខ្លួនខ្ញុំបាទជរាដល់ប៉ុណ្ណេះ ក៏សុំអាសាទៅកាត់យកក្បាល**ទៀវខាប់**មកជូនលោកបាន។ **ខុងបេង**តបថា អ្នកមានថ្វីដៃពូកែក៏មែនហើយ តែថាវេលានេះខ្លួនអ្នកក៏ចាស់ជរាណាស់ យើងក្រែងអ្នកទប់កម្លាំងនឹង**ទៀវខាប់**ពុំបាន។

**ហងតុង**ឮដូច្នោះខឹងណាស់ ក្រោកឡើងឈរហើយថា ទោះបីខ្ញុំបាទជរាក៏គង់នៅមានកម្លាំងយឹតធ្នូយ៉ាងធំមាំទ្រទម្ងន់បីរយជញ្ជីងបាន គួរឬលោកមកប្រមាថថាតស៊ូនឹងថ្វីដៃ**ទៀវខាប់**មិនបាន។ **ខុងបេង**ថា បើអាយុអ្នកដល់ចិតប្លាយឆ្នាំហើយ នៅអួតថាមានកម្លាំងនោះ ខ្ញុំមិនយល់ឃើញផងសោះ។

**ហាងតុង**ឮដូច្នោះក៏រីកតែខឹងណាស់ ទើបចេញទៅយកដាវសម្រាប់ដៃ កាន់ចូលទៅរាំទាល់តែអស់ក្បួនដាវ។ **ឡៅពី, ខុងបេង** និងពួកនាហ្មឺនទាំងពួង ឃើញ**ហាងតុង**រាំដាវល្អស្ទាត់រហ័ស ក៏ទះដៃសរសើរថា ទោះថ្វីដៃកម្លោះដែលចំណានពូកែយ៉ាងណា ក៏រត់ឲ្យស្មើនឹង**ហាងតុង**នេះគ្មាន។ **ហាងតុង**ក៏យកធ្នូដែលរឹងមកយឹតដំឡើងល្បងកម្លាំងឲ្យ**ខុងបេង**មើល ទាល់តែធ្នូនោះបាក់ដងទាំងពីរ។

**ខុងបេង**ថា បើអ្នកត្រូវការទៅក៏ទៅចុះ តែនឹងចង់យកទាហានរងទៅកំដរផងប៉ុន្មាន នឹងបានជួយធ្វើការនោះ? **ហាងតុង**ថា **ង៉ៀមង៉ាន់**ជាមនុស្សចាស់ជរាដូចខ្ញុំបាទ ៗនឹងសុំយកទៅជាមួយផង បើទៅហើយមិនបានរាជការទេ សុំឲ្យលោកកាត់ក្បាលសម្លូវនេះចេញចុះ។

**ឡៅពី**ឮដូច្នោះក៏អរណាស់ ព្រមឲ្យ**ហាងតុង**និង**ង៉ៀមង៉ាន់**ទៅ។ **ជូឡុង**ឆ្លើយថា **ទៀវខាប់**នោះមានថ្វីដៃខ្លាំងណាស់ ដែលលោកនឹងឲ្យ**ហាងតុង**និង**ង៉ៀមង៉ាន់**ដែលជាមនុស្សជរាចេញទៅធ្វើការចម្បាំងនឹង**ទៀវខាប់**នោះ មិនគួរសោះ បើប្រសិនជាខូចបន្ទាយហែបេងគួន ស្រុកសៃឈួនក៏គង់នឹងខូចផង។ **ខុងបេង**តបថា អ្នកកុំអាលប្រមាថមើលងាយ**ហាងតុង** និង**ង៉ៀមង៉ាន់**ថាជរាចោលម្សៀតនោះឡើយ ឯស្រុកហាន់តុងនោះ គង់នឹងបានដោយគំនិតនិងថ្វីដៃចាស់ជរាពីរនាក់នេះឯងជាប្រាកដ។ **ជូឡុង**មិនបានតបថាប្រការម្ដេច។ **ហាងតុង**និង**ង៉ៀមង៉ាន់**ក៏លាចេញទៅទីលំនៅតាំងចាត់ចែងទាហានបានគ្រប់គ្រាន់ហើយ ក៏លើកចេញទៅដល់បន្ទាយគយហែបេងគួន។

**បេងតាត់**និង**ង៉ាក់ជិន**ឃើញតាជរាទាំងពីរលើកទ័ពទៅដល់ ក៏ចេះតែខ្សឹបនិយាយគ្នាថា **ខុងបេង**ប្រើ**ហាងតុង** និង**ង៉ៀមង៉ាន់**មកធ្វើការនេះ មុខជានឹងតទល់ថ្វីដៃ**ទៀវខាប់**ពុំបានទេ ក៏នាំគ្នាសើចជាទីចំអក។ **ហាងតុង**ឃើញដូច្នោះក៏និយាយនឹង**ង៉ៀមង៉ាន់**ថា អ្នកឃើញហើយឬ **បេងតាត់** និង**ង៉ាក់ជិន**សើចចំអកឲ្យយើងជរាពិការគ្មានដៃជើងអ្វីសោះ យើងត្រូវរិះគិតយកជ័យជម្នះ**ទៀវខាប់**ឲ្យបាន ទើបមនុស្សទាំង

ពីរនាក់នេះនឹងកោតខ្លាចយើងទៅ។ **ងៀមង៉ាន់**ថា អ្នកនឹងគិតប្រការម្តេច ខ្ញុំនឹងទទួលយល់តាមធ្វើតាម។ **ហងតុង**ថា ឲ្យអ្នកឃុំនាំទាហានវាងទៅពួនបង្កប់នៅពីក្រោយបន្ទាយ**ទៀវខាប់** បើបានឃើញយើងលើកចេញច្បាំងវេលាណា ត្រូវឲ្យលើកទាហានចេញមកវាយប្រសព្វចូលពីក្រោយ។ **ងៀមង៉ាន់**ក៏នាំទាហានទៅពួនបង្កប់តាមបង្គាប់**ហងតុង** ៗក៏លើកទាហានចេញទៅស្រែកជេរចំអកបញ្ឈឺចិត្ត**ទៀវខាប់**។

**ទៀវខាប់**ឮហើយក៏ខឹងណាស់ ឡើងសេះនាំទាហានចេញពីក្នុងបន្ទាយ ហើយនិយាយប្រាប់**ហងតុង**ថា ខ្លួនចាស់ជរាដល់ប៉ុណ្ណឹងហើយ ម្តេចក៏មិនអៀនខ្មាសអាចច្រឡាសចេញមុខយកអាសាមកធ្វើការសង្គ្រាម នឹងយកយសសក្តិទៅដល់ណាទៀត? **ហងតុង**តបថា ទោះបីខ្លួនអញចាស់ជរាក៏មែន តែដាវដែលអញកាន់នេះវានៅមុតមាំណាស់។ ថាហើយក៏បរសេះរាំដាវចូលទៅច្បាំងនឹង**ទៀវខាប់**បានដប់ភ្លែង ទាហានទាំងសងខាងក៏ស្រែកហ៊ោអឹងកង។

**ងៀមង៉ាន់**ឃើញបានចំណាប់ ក៏បញ្ចេញកងទ័ពមកវាយខ្ទប់ពីក្រោយជាជ្រួលច្របល់ ដេញកាប់សម្លាប់ទាហាន**ទៀវខាប់**នៅកណ្តាលចំណោមទ័ពនឹងតទល់ពុំបាន ក៏បំផាយសេះស្ទុះបំពានទាហានរត់ចេញទៅ។ **ហងតុង**និង**ងៀមង៉ាន់**ក៏លើកទាហានដេញតាម នៅចម្ងាយផ្លូវប្រហែលប្រាំបួនរយសិន (៣៦ គ.ម) លុះដល់ពេលព្រឹកឡើងទើបឲ្យទាហានតាំងបន្ទាយនៅទីនោះ។

ឯ**ចោហង**នោះ លុះដឹងថា**ទៀវខាប់**បែកទ័ពរត់មក ក៏បង្គាប់ទាហានឲ្យតាមរកខ្លួន**ទៀវខាប់**មកសម្លាប់ចេញ។ **កោឈុយ**ក៏ហាមឃាត់ទៀតថា ដែលលោកនឹងធ្វើដូច្នោះមិនគួរទេ បើដឹងទៅដល់**ទៀវខាប់**ហើយ ក៏នឹងរត់ទៅចូលខាងកងទ័ពស្រុកសែឈ្នួនវិញ ការសង្គ្រាមដែលនឹងធ្វើតទៅនោះ ក៏នឹងបានសេចក្តីលំបាក សុំឲ្យលោកចាត់ទាហានលើកទៅជួយការពារទើបស្រួល កុំឲ្យ**ទៀវខាប់**ប្រែចិត្តចេញបាន។ **ចោហង**យល់ឃើញត្រូវ ទើបប្រើ**ហែហ៊្វស៊ុង**ក្មួយ**ហែហ៊្វទុន** និង**ហាន់ហោ**ប្អូន**ហាន់ហៀន** លើកទាហានប្រាំពាន់ទៅជួយការពាររក្សា**ទៀវខាប់**ទុកតាមពាក្យ

**កោឈុយ**។ **ហៃហ៊្សុង**និង**ហាន់ហោ**លុះលើកទ័ពទៅជួបនឹង**ទៀវខាប់**ហើយ ក៏ប្រាប់ថា **ចោហាង**ឲ្យយើងទាំងពីរលើកមកជួយ។

**ទៀវខាប់**ថា **ហាងតុង**និង**ងៀមង៉ាន់**នោះ ជាមនុស្សចាស់ជរាក៏មែន តែមានថ្វីដៃខ្លាំងពូកែណាស់ ដែលយើងនឹងគិតយកជ័យជម្នះនោះ ដោយកម្រ។ **ហាន់ហោ**ថា **ហាងតុង**នោះខ្ញុំដឹងស្គាល់ច្បាស់ណាស់ កាលពីដើមគាត់នៅស្រុកទៀងសា ជាកលសឹកចូលទៅខាង**គួនអ៊ូ** ហើយឲ្យ**អ៊ុយអៀន**សម្លាប់**ហាន់ហៀន**ជាបងខ្ញុំស្លាប់ទៅ។ វេលានេះខ្លួនខ្ញុំនឹងសុំអាសាធ្វើការសងសឹក**ហាងតុង**វិញឲ្យបាន។ ថាហើយក៏នាំទាហាននិង**ហៃហ៊្សុង**លើកចេញទៅប៉ះច្បាំងនឹង**ហាងតុង**។

ឯ**ហាងតុង**នោះ លុះទៅតាំងបន្ទាយហើយ ក៏នាំ**ងៀមង៉ាន់**និងទាហានដើរត្រួតមើលច្រកល្ហក ឃើញយល់ស្គាល់ផ្លូវគ្រប់ទីតំបន់ ហើយឃើញទាហាន**ចូឆូ**ទៅនៅរក្សាស្បៀងលើភ្នំធៀងតងសាន់។ **ងៀមង៉ាន់**ក៏និយាយនឹង**ហាងតុង**ថា បើយើងរិះគិតកាត់យកស្បៀងនៅតំបន់នេះចេញបាន ទើបនឹងបានស្រុកហាន់តុងដោយងាយ។ **ហាងតុង**ថា អ្នកគិតនេះត្រូវដូចគំនិតខ្ញុំ ទើបខ្សឹបគ្នាឲ្យសញ្ញាជាស្រេច ក៏នាំគ្នាត្រឡប់ចូលបន្ទាយ។ **ងៀមង៉ាន់**ក៏ចាត់ចែងទាហានទៅធ្វើតាមពាក្យ**ហាងតុង**បង្គាប់។

ឯ**ហាងតុង** លុះដឹងថា**ហៃហ៊្សុង**និង**ហាន់ហោ**លើកទ័ពមក ក៏នាំទាហានចេញពីបន្ទាយទៅ។ **ហាន់ហោ**ក្រឡេកឃើញ**ហាងតុង**ចេញមក ក៏បរសេះទៅឈរមុខទាហាន ហើយស្រែកជេរ**ហាងតុង**ជាពាក្យគំរោះប្រមាថដល់ជាតិត្រកូលផ្សេងៗ រួចបរសេះចូលច្បាំងនឹង**ហាងតុង**។ **ហៃហ៊្សុង**ឃើញដូច្នោះ ក៏ចូលទៅជួយច្បាំង**ហាន់ហោ**។ **ហាងតុង**ច្បាំងការពារខ្លួនបានម្ភៃភ្លែង ក៏ក្លែងទាញសេះថយរត់ទៅក្រោយបណ្តោយផ្លូវប្រហែលពីររយសិន (៨ គ.ម) ក៏ឲ្យយកចំបើងធ្វើបន្ទាយទុក។

ឯ**ហៃហ៊្សុង**និង**ហាន់ហោ**ក៏លើកទាហានដេញតាមទៅជេរប្រមាថដល់មុខបន្ទាយ។ **ហាងតុង**ក៏ចេញមកតច្បាំងនឹង**ហៃហ៊្សុង**, **ហាន់ហោ**បានសែសិប ហា

សិបភ្លេង ហើយក៏ញាក់សេះនាំទាហានថយរត់ទៅទៀតបានពីររយសិន (៨ គ.ម) ក៏ឲ្យយកចំបើងធ្វើបន្ទាយទៀត។

**ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ក៏ឲ្យបម្រើសេះត្រឡប់ទៅប្រាប់សេចក្ដីឲ្យ**ទៀវខាប់**ដឹង និងឲ្យប្រុងប្រយ័ត្នរក្សាបន្ទាយឲ្យមាំមួន។ **ទៀវខាប់**ដឹងដូច្នោះក៏ស្រូតមកប្រាប់**ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ថាដែល**ហាងតុង**ថយរត់ទៅដល់ពីរលើកនេះ យើងយល់ឃើញថា មុខជាធ្វើកលឧបាយកុំបីលើកតាមទៅទៀតឡើយ។ **ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ឮដូច្នោះខឹងណាស់ ស្រែកគំហកហើយថា ខ្លួនអ្នកនេះជាមនុស្សឆោតខ្លាចពេកណាស់ បានជាថ្លោះការបរាជ័យនឹងសត្រូវមកច្រើនលើកហើយ កុំបីមកនិយាយផ្ដេសផ្ដាសដូច្នេះទៀត ត្រូវឲ្យស្ងៀមទៅវិញល្អជាង។

**ទៀវខាប់**បានស្ដាប់ដូច្នោះ ក៏មានសេចក្ដីអប្បយសខ្មាសទាហានទាំងពួងពេកណាស់ វិលត្រឡប់ទៅរក្សាបន្ទាយវិញ។ លុះវេលាព្រឹកឡើង **ហៃហ្វ៊ូស៊ុង**និង**ហាន់ហោ**ក៏លើកទាហានជាប់តាមទៅដល់មុខបន្ទាយ**ហាងតុង** ហើយស្រែកចំអកផ្សេងៗ។ **ហាងតុង**បានឮដូច្នោះក៏បរសេះចេញមកតស៊ូបានដប់ភ្លេង ហើយដេញទាហានរត់ថយទៅបានពីររយសិន (៨ គ.ម) ក៏ឲ្យយកមែកឈើមកធ្វើជាបន្ទាយទៀត។

ឯ**ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ក៏លើកទាហានតាមទៅចោមព័ទ្ធវាយបន្ទាយ**ហាងតុង**ៗស៊ូច្បាំងបានប្រាំភ្លេង ក៏នាំទាហានរត់ទៅចូលបន្ទាយហៃបេងគួន**ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ក៏លើកទាហានតាមទៅតាំងបន្ទាយភ្ជាប់គ្នានឹងបន្ទាយហៃបេងគួននោះ។ **បេងតាត់**ឃើញដូច្នោះ ក៏លបប្រាប់ដំណឹងទៅដល់**ឡៅពី**ជាសេចក្ដីថា **ហាងតុង**បែកទ័ពនឹង**ហៃហ្វ៊ូស៊ុង**និង**ហាន់ហោ**ជាច្រើនគ្រា ឥឡូវចូលទៅនៅក្នុងបន្ទាយហៃបេងគួនហើយ ឯ**ហៃហ្វ៊ូស៊ុង** និង**ហាន់ហោ**ក៏លើកទ័ពទៅតាំងបន្ទាយជាប់គ្នានឹងគយនោះ។

**ឡៅពី**ឮដូច្នោះក៏ភ័យណាស់ ទើបប្រឹក្សានឹង**ខុងបេង** ៗថា លោកកុំព្រួយព្រះចិត្តថ្វី ដែល**ហាងតុង**បែកទ័ពមកនោះ ប្រាថ្នានឹងធ្វើកលឧបាយបញ្ឆោតសត្រូវទេ។ **ឡៅពី, ជូឡុង**បានស្តាប់**ខុងបេង**ថា ក៏នៅមិនអស់សង្ស័យ។ **ឡៅពី**ក៏ប្រើ**ឡៅហាង**ជាបុត្រចិញ្ចឹមនាំទាហានទៅជួយ**ហាងតុង**ទៀត។ លុះ**ឡៅហាង**លើកពលទៅដល់គយហែបេងគួន ក៏និយាយប្រាប់**ហាងតុង**ថា ឥឡូវបិតាប្រើខ្ញុំឲ្យនាំទាហានមកជួយធ្វើការលោកមារ។ **ហាងតុង**សួរថា បិតាអ្នកដឹងការណ៍ហេតុយ៉ាងម្តេចបានជាប្រើអ្នកមក? **ឡៅហាង**ថា បិតាដឹងថាមាបែកទ័ពមកច្រើនលើកហើយ រហូតទាល់តែរត់ចូលបន្ទាយនេះ បានជាប្រើខ្ញុំនាំទាហានមកជួយ។

**ហាងតុង**ឮដូច្នោះក៏អស់សំណើចហើយថា ដែលយើងបែកទ័ពត្រឡប់ថយមកនេះ ដោយកលឧបាយនឹងឲ្យសត្រូវយកអាវុធ និងស្បៀងអាហារមករួមទុកឲ្យយើងនៅក្នុងបន្ទាយដែលនៅជិតនោះទេតើ។ ពេលយប់នេះឲ្យអ្នកចាំមើលចុះ យើងនឹងលើកចេញទៅវាយបន្ទាយ**ហែហ៊្វូសុង**និង**ហាន់ហោ**ឲ្យបែកបាន និងឲ្យទាហានរើសយកគ្រឿងសាស្ត្រាវុធនិងស្បៀងអាហារទាំងអស់។ លុះដល់ពេលយប់**ហាងតុង**ក៏បង្គាប់**ង៉ាក់ជិន**ថាឲ្យប្រុងប្រយ័ត្នត្រួតត្រាបន្ទាយឲ្យមាំមួន ហើយនិយាយនឹង**បេងតាត់**ថា ថ្ងៃនេះយើងនឹងចេញទៅធ្វើការ អ្នកចូរអាណិតយើងនាំទាហានចេញទៅជញ្ជូនយកស្បៀងអាហារ និងគ្រឿងសាស្ត្រាវុធចុះ។ នាយទាហានទាំងពីរនោះបានស្តាប់ក៏មិនជឿ គ្រាន់តែទទួលពាក្យដោយយល់មុខតាមសមគួរ។

ឯ**ហាន់ហោ** និង**ហែហ៊្វូសុង**ទៅតាំងបន្ទាយនៅផ្ទាប់គ្នាប្រហែលបីថ្ងៃ មិនបានឃើញ**ហាងតុង**ចេញច្បាំងសោះ ក៏មានចិត្តប្រមាថដោះគ្រឹសនិងកែបសេះចេញអស់ មិនបានត្រួតត្រារក្សាបន្ទាយឲ្យមាំមួន លុះដល់ពេលយាមពីរប្លាយ **ហាងតុង**ក៏នាំ**ឡៅហាង**លើកទាហានចេញទៅព័ទ្ធវាយបន្ទាយ**ហែហ៊្វូសុង** និង**ហាន់ហោ**កាប់សម្លាប់ទាហានពួកនោះស្លាប់ជាច្រើន។ **ហែហ៊្វូសុង** និង**ហាន់ហោ**មិនទាន់ដឹងខ្លួន ក៏

នាំទាហានរត់ចេញពីបន្ទាយ។ **ហងតុង**ក៏តាមវាយរាយតាមផ្លូវទៅគ្រប់ទាំងបីបន្ទាយ។

ឯ**បេងតាត់**នោះ លុះឃើញសត្រូវបែកទៅ ក៏លើកទាហានចេញទៅរើសយកគ្រឿងសាស្ត្រាវុធកែបសេះ នូវក្រឹសនិងស្បៀងអាហារបានជាច្រើន។ លុះព្រឹកឡើង **ហងតុង**នឹងតាម**ហែហ៊្សុង**និង**ហាន់ហោ**ទៅ **ឡៅហង**និយាយហាមឃាត់ថា ពេលនេះទាហានកំពុងនឿយហត់ណាស់ ត្រូវបង្អង់ឈប់ឲ្យទាហានមានកម្លាំងសិន រួចសឹមលើកតាមទៅទៀត។ **ហងតុង**តបថា ដែលយើងតាមទៅឃើញរូងខ្លាហើយ នឹងមិនស្រូតរូតចូលទៅចាប់កូនខ្លាឲ្យបានទេ នឹងបង្អែបង្អង់ទុកឲ្យវាមានកម្លាំងនោះក៏មិនស្រួល ទើបប្រកាសប្រាប់ទាហានទាំងពួងថា អស់អ្នករាល់គ្នាត្រូវជួយធ្វើការសម្រេចឲ្យបាន ហើយលើកទ័ពតាមទៅជិតបន្ទាយ**ទៀវខាប់**។

ឯ**ហែហ៊្សុង** និង**ហាន់ហោ**រត់ទៅហួសបន្ទាយ**ទៀវខាប់** ហើយពួកទាហាន**ទៀវខាប់**ឃើញក៏នាំគ្នាភ្ញាក់ផ្អើលជ្រួលច្របល់រត់ធ្លាយបន្ទាយទៅទៀត។ **ទៀវខាប់**បោកទង់ឲ្យឈប់ក៏មិនស្តាប់ ខ្លួន**ទៀវខាប់**ក៏ភ្លយរត់បណ្តោយពីក្រោយទៅទៀត ដល់ទៅទន្លេហាន់ស៊ុយប្រទះគ្នានឹង**ហែហ៊្សុង, ហាន់ហោ**។ **ទៀវខាប់**ក៏និយាយនឹងនាយទាហានទាំងពីរនេះថា ដែលយើងនឹងរត់ទៅពេលនេះមិនកើតទេ ព្រោះស្រុកហាន់តុងនោះបានអាស្រ័យស្បៀង ដែលប្រមូលទុកនៅភ្នំធៀនតងសាន់ និងភ្នំប៊ិសងសាន់ បើខូចស្បៀងពីរតំបន់នោះហើយ ស្រុកហាន់តុងក៏នឹងខូចតាមគ្នាមិនខាន ត្រូវតែយើងរិះគិតទៅថែរក្សាស្បៀងទាំងពីរអន្លើនេះទុកឲ្យបាន នឹងបានជាកម្លាំងធ្វើការតទៅ។

**ហែហ៊្សុង**តបថា ឯស្បៀងដែលប្រមូលទុកនៅភ្នំប៊ិសងសាន់នោះ កុំព្រួយគិត ដ្បិត**ហែហ៊្សអៀន**មាខ្ញុំបានទៅនៅតាំងទ័ពនៅភ្នំតេងកុនសាន់ជិតគ្នានៅទីនោះស្រាប់ហើយ មុខជាមាខ្ញុំបានចាត់ការឲ្យទៅរក្សាទុកមាំមួនមិនខាន។ ខ្ញុំបារម្ភតែកន្លែងភ្នំធៀនតងសាន់ ដែល**ហែហ៊្សតេក**បងខ្ញុំនៅរក្សានោះ ព្រោះទាហានក៏តិច

យើងត្រូវនាំគ្នាទៅជួយការពាររក្សាទុក។ **ទៀវខាប់**យល់ឃើញត្រូវ ក៏នាំទាហានទាំងពួងស្រូតរូតទៅដល់ភ្នំផៀនតងសាន់ ហើយក៏ពណ៌នាសេចក្ដីឲ្យ**ហៃហ្ស៊ូតេក**ស្ដាប់គ្រប់ប្រការ។

**ហៃហ្ស៊ូតេក**តបថា យើងលើកទាហានដប់ម៉ឺនមកនៅរក្សាស្បៀងនៅទីនេះធួនល្មមហើយ ចូរនាំគ្នាទៅធ្វើការយកជ័យជម្នះពួកសត្រូវទៅ! **ទៀវខាប់**ថា ទាហានច្រើនក៏មែន តែនឹងទុកចិត្តអ្នកពុំបានទេ លុះនិយាយគ្នាផុតសម្ដីស្រាប់តែឮសូរទាហានស្រែកហ៊ោឡើងពីខាងមុខភ្នំ មានបម្រើសេះចូលមកប្រាប់ថា **ហងតុង**លើកទាហានមកជាច្រើនណាស់។ **ហៃហ្ស៊ូតេក**ឮដូច្នោះក៏សើច ហើយថា អា**ហងតុង**កញ្ចាស់នេះ វាមានចិត្តកំរើបថាថ្វីដៃវាខ្លាំងពូកែ បានជាខំទន្ទ្រានចូលមកដល់ទីនេះ។

**ទៀវខាប់**តបថា ឯ**ហងតុង**នោះមិនមែននឹងមានត្រឹមតែថ្វីដៃម្យ៉ាងទេ គឺប្រកបទៅដោយតម្រិះប្រាជ្ញាចេះរិះគិតកលសឹកផ្សេងៗ។ **ហៃហ្ស៊ូតេក**ថា ទោះបី**ហងតុង**នឹងមានតម្រិះចេះកលឧបាយយ៉ាងណា ដែលបានកម្លងចូលមកដល់ទីនេះហើយ ក៏ដូចជាមិនមានប្រាជ្ញាទេ។ **ហាន់ហោ**ថា ខ្ញុំនឹងសុំទាហានបីពាន់លើកទៅធ្វើការយកជ័យជម្នះ**ហងតុង**ឲ្យបាន។ **ហៃហ្ស៊ូតេក**ក៏ចាត់ទាហានឲ្យបីពាន់។ **ហាន់ហោ**ក៏នាំចុះទៅស្រែកជេរបញ្ឈឺចិត្តឲ្យ**ហងតុង** ៗឮហើយក៏ខឹងណាស់ បរសេះចេញមកច្បាំង មិនទាន់បានមួយស្របក់ **ហងតុង**ក៏យកដាវកាប់ត្រូវ**ហាន់ហោ**ធ្លាក់ពីលើសេះស្លាប់ ហើយដេញកាប់សម្លាប់ទាហានទាំងពួងបែកបាក់អស់ទៅ។ **ទៀវខាប់, ហៃហ្ស៊ូសុង**ឃើញដូច្នោះ ក៏លើកទាហាននឹងចុះទៅតស៊ូនឹង**ហងតុង** ស្រាប់តែឮសូរផាវនិងទាហានស្រែកហ៊ោឡើងទៅពីក្រោយភ្នំ ហើយឃើញភ្លើងឆេះឡើងខាងក្រោយបន្ទាយជាច្រើនអន្លើ។ **ហៃហ្ស៊ូតេក**ក៏លើកទាហានចេញទៅប៉ងច្បាំងនឹងសត្រូវ **ងៀមង៉ាន់**ក៏បរសេះវាំលំពែងចូលទៅច្បាំងនឹង**ហៃហ្ស៊ូតេក**បានមួយភ្លែង **ងៀមង៉ាន់**ក៏លើកលំពែងចាក់ត្រូវ**ហៃហ្ស៊ូតេក**ធ្លាក់ពីលើសេះស្លាប់។

ឯ**ហាងតុង**ឃើញពន្លឺភ្លើង ដែល**ងៀមង៉ាន់**ដុតឆេះឡើងតាមសញ្ញាដូច្នោះ ក៏លើកទាហានវាយប្រសព្វចូលទៅពីខាងមកភ្នំ ហើយយកភ្លើងដុតបន្ទាយឆេះទាំងស្បៀងអាហារអស់ប្រហែលមួយភាគ ហើយដេញកាប់សម្លាប់ទាហានស្លាប់ជាច្រើន។ **ទៀវខាប់និងហែហ៊្វសុង**ឃើញកម្លាំងទល់មិនឈ្នះ ក៏នាំគ្នារត់ទៅរក**ហែហ៊្វអៀន**។ **ហាងតុង** និង**ងៀមង៉ាន់**ក៏ឲ្យទាហានចូលទៅលត់ភ្លើងដែលឆេះស្បៀងនោះទុកបានខ្លះ ទើបឲ្យទាហានធ្វើជាបន្ទាយនៅទីនោះ ដើម្បីនឹងរក្សាស្បៀងទុក ហើយក៏តែងសំបុត្របកប្តឹង ឲ្យបម្រើសេះនាំចូលទៅជូន**ឡៅពី**ឯស្រុកសែឈួន។

**ឡៅពី**ដឹងតាមសេចក្តីសំបុត្រដូច្នោះហើយ ក៏មានចិត្តសោមនស្សត្រេកអរណាស់។ **ហ្វួតចេង**ជម្រាប**ឡៅពី**ថា កាល**ចូឆូ**លើកទ័ពមកវាយយកស្រុកហាន់តុងនោះ ក៏គិតនឹងវាយយកស្រុកសែឈួនផង តឡូវ**ចូឆូ**ឲ្យ**ហែហ៊្វអៀន** និង**ទៀវខាប់**នៅរក្សាស្រុកហាន់តុង ខ្លួន**ចូឆូ**លើកទ័ពត្រឡប់ទៅនោះ បីដូចមិនមែនគំនិត**ចូឆូ**គិតឯងទេ ឯ**ទៀវខាប់**ក៏បែកទ័ពខ្ទេចខ្ទី ខូចខាតទាំងស្បៀងអាហារនៅភ្នំធៀនតងសាន់ គ្រានេះឃើញថាយើងក៏បានចំណាប់ល្អហើយ គួរនឹងលើកទ័ពធំទៅវាយយកស្រុកហាន់តុងឲ្យបានតែម្តងទៅ រួចសឹមលើកទ័ពទៅវាយកម្ចាត់អាសត្រូវរាជសម្បត្តិនោះចេញទៀត មុខជានឹងបានដោយស្រួលណាស់។ បើដូច្នោះក៏នឹងត្រូវចាត់មនុស្សរក្សាស្រុកហាន់តុងទុកជាស្រុកមុខគយ ឯខ្លួនលោកក៏ត្រូវលើកត្រឡប់មកឈរនៅស្រុកសែឈួនវិញ ដើម្បីឲ្យបានជាទីមាំមួនបានសេចក្តីសុខតទៅ។

**ឡៅពីនិងខុងបេង**បានស្តាប់សព្វសេចក្តីក៏ពេញចិត្តណាស់ ទើបចេញទៅកំជាប់នាយទាហាន និងនាយគយដានដែលត្រូវឡើងស្រុកសែឈួនទាំងប៉ុន្មាននោះឲ្យត្រួតត្រារក្សាស្រុកភូមិតាមនីគមជនបទធំ តូចកុំឲ្យធ្វេសប្រហែស ហើយឲ្យ**ជូឡុង**លើកទាហានជានាយកងទ័ពមុខ **ឡៅពីនិងខុងបេង**ក៏លើកពលដប់ម៉ឺនជាមេកងទ័ពហ្លួងចេញទៅ។

ឈឈឈ៚៚

**ខណៈនោះគួនប៉េងនិងលៀវហ្វ** ក៏ធ្វើជាបាក់ទ័ពត្រឡប់រត់ទៅ **ចោឃិន**ដេញតាមស្ទៅទៅចម្ងាយប្រហែលពីររយសិន (៨ គ.ម) ក៏ឮសំឡេងស្រែកហ៊ោពីខាងក្រោយ។ **ចោឃិន**នាំទាហាននោះត្រឡប់មកវិញ។ **គួនប៉េង**និង**លៀវហ្វ**ងាកដេញតាម។ **ចោឃិន**យល់ថា ជាកលឧបាយក៏ភិតភ័យណាស់ នាំទាហានរត់ឆ្លងតាមផ្លូវសំដៅទៅស្រុកសុងយ៉ុង ទទួលប្រទះនឹង**គួនអ៊្វ**ជិះសេះកាន់ដាវស្ទាក់ទទឹងពីមុខ។ **ចោឃិន**តក់ស្លុតរន្ធត់ស្មារតី ភ័យមិនប៊ានតស៊ូ ក៏ស្ទុះរត់កាត់ផ្លូវទៅត្រង់ស្រុកអ៊ួនសៀ។ **គួនអ៊្វ**ក៏ដេញតាមប្រទះនឹង**ហែហ៊្វជុន** លើកពលចូលមកក៏ប្រយុទ្ធគ្នាបានមួយភ្លែង **គួនអ៊្វ**ក៏កាប់នឹងដាវត្រូវ**ហែហ៊្វជុន**ធ្លាក់ពីលើសេះស្លាប់ ខាង**គួនប៉េង**ក៏បំផាយសេះដេញកាប់**តេកង្វន**ដាច់ពាក់កណ្ដាលខ្លួន ធ្លាក់ពីលើសេះស្លាប់។

ទាហាន**គួនអ៊្វ**ក៏កាប់សម្លាប់ទាហាន**ចោឃិន** ខ្ចាត់ព្រាត់ព្រាយធ្លាក់ទឹកអស់ជាច្រើន។ **គួនអ៊្វ**វាយបានស្រុកសុងយ៉ុង ហើយឲ្យបំណាច់រង្វាន់ទាហានតាមមានសេចក្ដីគាប់ប្រសើរតាមសមគួរ រួចបញ្ចុះបញ្ចូលអស់អាណាប្រជានុរាស្ត្រឲ្យនៅជាតាមប្រក្រតី។

**អងហ៊្វ**ទីប្រឹក្សាជម្រាប**គួនអ៊្វ**ថា លោកធ្វើសឹកគ្រានេះស្រួលណាស់ តែមួយប៉ប្រិចភ្នែកក៏បាន ខ្ញុំបាទគិតឃើញថា **ស៊ុនគួន**នៅស្រុកកាំងតាំងនោះ បានប្រើ**លីបង**ឲ្យលើកទាហានមកតាំងបោះទ័ពនៅទីគយឡុកខៅ ជាព្រំប្រទល់ដែន ដើម្បីនឹងវាយយកស្រុកកេងជីវ បើគេនឹងលើកទ័ពមក តើលោកនឹងគិតប្រការម្ដេច?

**គួនអ៊្វ**ថា យើងគិតឃើញស្រេចហើយ ចៅចូរទៅត្រៀមទាហានឲ្យសង់រានភ្លើងឲ្យហែទៅតាមក្បែរមាត់ទឹក ទីខ្ពស់នោះពីត្រឹមគយហែខៅចូលទៅដល់ស្រុកយើង ឲ្យធ្វើចម្ងាយពីគ្នាពីររយសិនខ្លះ បីរយសិនខ្លះ ហើយឲ្យចាត់មនុស្សនៅប្រចាំការក្នុងមួយអន្លើ៥០នាក់ បើឃើញ**ស៊ុនគួន**ឆ្លងមកហើយ ដល់ពេលយប់ឲ្យដុតភ្លើងឲ្យភ្លឺ បើពេលថ្ងៃឲ្យបង្កប់សម្រាប់ឲ្យកើតជាផ្សែងហុយឡើង នឹងបានសម្គាល់ដឹងកន្លែងនីមួយៗ យើងនឹងបានលើកទ័ពទៅជួយច្បាំង។

**អងហ៊្វ**ថា **ប៊ីហងនិងប៉ៅស៊្វយិន**ដែលឲ្យនៅឈររក្សាមាត់កំពង់ស្រុកទាំងពីរអន្លើនោះ ខ្លាចក្រែងចិត្តគេមិនត្រង់សុចរិត លោកត្រូវចាត់ទាហានថែម ទៅត្រួតត្រាមើលស្រុកកេងជីវសិន។ **គួនអ៊្វ**ថា យើងបានចាត់ឲ្យ**ភួយ៉ួយ**ទៅនៅរក្សាហើយ អ្នកកុំព្រួយចិត្តឡើយ។ **អងហ៊្វ**តបថា **ភួយ៉ួយ**នោះប្រកបទៅដោយចិត្តលោភប្រាថ្នារកលាភ ខ្ញុំបាទយល់ឃើញថានឹងទុកចិត្តមិនបានទេ សុំឲ្យលោកប្រើ**ទៀវលុយ** នាយកស្បៀងដែលជាមនុស្សទៀងត្រង់ទៅនៅវិញទើបមិនមានអន្តរាយ ទោះនឹងធ្វើការសឹកសង្គ្រាមលើសជាងនេះដល់មួយម៉ឺនដង ក៏ឥតញញើតកោតខ្លាចសោះ។ **គួនអ៊្វ**ថា ឯ**ភួយ៉ួយ**នោះអាក្រក់ល្អមកយ៉ាងណា យើងក៏បានផ្ទុកដាក់ឲ្យគេទៅហើយ ដែលនឹងឲ្យ**ទៀវលុយ**ទៅផ្លាស់ជំនួសវិញនោះមិនគួរទេ ព្រោះខ្លួន**ទៀវលុយ**សម្រាប់តែឃុំស្បៀងជាធំដោយឡែកទៅហើយ អ្នកកុំសង្ស័យអ្វីឡើយ ចូរទៅធ្វើការតាមពាក្យយើងចុះ! **អងហ៊្វ**ឮដូច្នោះ ក៏លា**គួនអ៊្វ**ទៅ។ **គួនអ៊្វ**ប្រើ**គួនប៉េង**ឲ្យចាត់ចែងទូកចម្បាំងនឹងលើកឆ្លងទន្លេងសុងកាំងទៅវាយយកស្រុកអ៊្វនសៀ។

ឯ**ចោយិន**នោះ លុះខូចនាយទាហានពីរនាក់ហើយ ក៏ថយទ័ពទៅបោះបន្ទាយមាំមួននៅស្រុកអ៊្វនសៀ ហើយនិយាយពិគ្រោះនឹង**ប៊្វនចុង**ថា **គួនអ៊្វ**ជាមនុស្សមានថ្វីដៃខ្លាំងពូកែណាស់ លោកគ្រូគិតការពារឲ្យមាំមួនចុះ។ **លីសៀង**ឆ្លើយថា ខ្ញុំបាទនឹងសុំទាហានបីពាន់ទៅតស៊ូនឹង**គួនអ៊្វ** យកជ័យជម្នះឲ្យបាន។ **ប៊្វនចុង**ថា ដែលអ្នកនឹងលើកទ័ពទៅធ្វើការនោះមិនឈ្នះគេទេ។

**លីសៀង**ថា ធ្វើម្តេចនឹងកម្ចាត់សត្រូវចេញបាន មិនដឹងទេឬក្នុងក្បួនពិជ័យសង្គ្រាមថាទុកមក បើសត្រូវលើកទ័ពមកដល់កណ្តាលទឹកនឹងលើកទៅវាយក៏មានជ័យជម្នះ។ ឥឡូវ**គួនអ៊្វ**លើកទ័ពមកដល់កណ្តាលទន្លេសុងកាំងហើយ ហេតុម្តេចចាំអីទៀតក៏មិនលើកទ័ពទៅវាយ បើទុកឲ្យគេឆ្លងមកដល់ប្រផិតគ្នានឹងជើងកំពែងបានហើយ នឹងមិនពិបាកទេឬ? **ចោយិន**ឮដូច្នោះ ក៏ឲ្យ**លីសៀង**នាំទាហានបីពាន់ចេញ

ទៅពីស្រុកអ៊្លូនសៀ ទទួលក្រឡេកឃើញ**គួនអ៊្វូ**ឆ្លងមកដល់គោក ឡើងជិះសេះកាន់ដាវឈរពីមុខទាហាន។

ទាហាន**លីសៀង**ក្រឡេកទៅឃើញ**គួនអ៊្វូ** ក៏ស្លុតរន្ធត់ស្មារតីទាំងអស់គ្នា ហើយបាក់ទ័ពនាំគ្នារត់ត្រឡប់ទៅវិញ **លីសៀង**ខំស្រែកហៅឲ្យឈប់ក៏ពុំស្ដាប់ **គួនអ៊្វូ**ក្រឡេកឃើញបានចំណាប់ក៏បរពលចូលប្រកាប់សម្លាប់ទាហាន**លីសៀង**ស្លាប់ច្រើនណាស់ ឯខ្លួន**លីសៀង**និងទាហានដែលនៅសល់ហើយរត់ទៅនោះ ក៏ត្រឡប់ចូលទៅក្នុងស្រុកអ៊្លូនសៀវិញ។ **ចោយិន**ឃើញដូច្នោះ ក៏ចាត់ប្រើបម្រើឲ្យចូលទៅដល់ស្រុកទៀងអាន ទូលព្រះចៅ**វុយអេង**ថា **គួនអ៊្វូ**លើកទ័ពទៅវាយបានស្រុកសុងយ៉ុងហើយ ឥឡូវលើកទៅព័ទ្ធស្រុកអ៊្លូនសៀទៀត សុំឲ្យលើកកងទ័ពទៅជួយ។

**ចូឆូ**ឮដូច្នោះក៏ប្រឹក្សានឹង**អ៊ីគឹម**ថា យើងឃើញតែអ្នកឯងមួយ អាចទៅជួយស្រុកអ៊្លូនសៀបាន។ **អ៊ីគឹម**ទូលថា ទូលបង្គំនឹងសុំទាហានជាកងមុខទៅផង។ **បាំងតេក**ទូលថា ទូលបង្គំសុំអាសាជាទ័ពមុខ ទៅចាប់យកខ្លួន**គួនអ៊្វូ**មកថ្វាយ។ **ចូឆូ**ថា ឯ**គួនអ៊្វូ**នោះជាមនុស្សមានថ្វីដៃខ្លាំងពូកែប្រាកដណាស់ មិនឃើញមាននរណានឹងអាចចេញទៅតស៊ូបាន ឃើញតែអ្នកមួយទើបនឹងតស៊ូបាន។ ទើបតាំង**អ៊ីគឹម**ជានាយទ័ពហ្លួង តាំង**បាំងតេក**ជានាយទ័ពមុខ ហើយប្រើ**តាំងហេង**, **តាំងឈៀវ**, **សេងហោ**ឲ្យលើកទាហានប្រាំពីរកងទៅជួយស្រុកអ៊្លូនសៀ។ **តាំងហេង**បាននិយាយនឹង**អ៊ីគឹម**ថា ដែលលោកនឹងលើកទៅជួយរាជការស្រុកអ៊្លូនសៀនោះ មុខជាបានហើយ ប៉ុន្តែ**បាំងតេក**ជាទ័ពមុខទៅនោះ មុខជានឹងខូចការ។

**អ៊ីគឹម**ឮដូច្នោះក៏ភ័យក្នុងចិត្តសួរថា អ្នកឃើញហេតុភេទប្រការម្ដេចបានជាថាដូច្នេះ? **តាំងហេង**ឆ្លើយថា ព្រោះ**បាំងតេក**នោះ កាលពីដើមជាទាហាន**ម៉ាឈៀវ** លុះមិននៅនឹង**ម៉ាឈៀវ**ក៏ចូលមកនៅនឹងព្រះចៅ**វុយអេង** ឯ**ម៉ាឈៀវ**ជានាយចាស់ក៏បានជាទាហានខ្លានៅក្នុងទ័ព**ឡៅពី** ទាំង**បាំងយីវ**ជាបងទៀតក៏នៅក្នុងស្រុកសែឈ្លួន បានជាមន្ត្រីក្រោម**ឡៅពី** ឥឡូវនឹងឲ្យ**បាំងតេក**ធ្វើជានាយកងនាយទ័ពទៅ

នោះ ដូចយកប្រេងទៅបាចសាចលើភ្លើង។ ហេតុម្ដេចបានជាលោកមិនពិតទូលព្រះចៅ**វុយអេង** ឲ្យចាត់ប្រើអ្នកឯទៀតទៅវិញ? **អ៊ីគឹម**ឮដូច្នោះ ក៏ចូលទៅទូលព្រះចៅ**វុយអេង**ទាំងវេលាយប់ តាមពាក្យ**តាំងហេង**គ្រប់ប្រការ។

**ចូឆូ**បានស្ដាប់ក៏បង្គាប់ឲ្យហៅ**បាំងតេក**ចូលមកហើយថា ដែលយើងតាំងអ្នកឯងជានាយកងទ័ពមុខនោះ អ្នកត្រូវឈប់បង្អង់សិនចុះ ព្រោះយើងចង់ដឹង ប្រើអ្នកឯទៀតឲ្យទៅវិញ។ **បាំងតេក**ទូលថា ទូលបង្គំនឹងតាំងចិត្តធ្វើរាជការ ថ្វាយស្នងព្រះតេជព្រះគុណដោយសុចរិតពិតត្រង់ ព្រះអង្គនឹងមិនឲ្យទូលបង្គំទៅនោះ ព្រោះហេតុអ្វី? **ចូឆូ**ថា ព្រោះវេលានេះ **បាំងយឺវ**ជាបងអ្នក និង**ម៉ាឈៀវ**ជានាយចាស់របស់អ្នកនៅក្នុងពួក**ឡៅពី** បើអ្នកនឹងធ្វើជានាយកងទ័ពមុខលើកទៅធ្វើការនោះ មុខជាទាហានទាំងពួងនឹងសន្និះសង្ស័យមិនតាំងចិត្តធ្វើការ ឲ្យពេញដៃពេញជើងទេ។

**បាំងតេក**ឮដូច្នោះ ក៏ដោះមួកចេញហើយទង្គិចមុខទៅប៉ះលើជញ្ជាំងឥដ្ឋទាល់តែបែកក្បាលហូរឈាមជោកអស់ទាំងខ្លួន ហើយទូលថា ទូលបង្គំមកចូលធ្វើរាជការថ្វាយព្រះអង្គតាំងពីវាយយកស្រុកហាន់តុង ព្រះអង្គក៏ទ្រង់មានគុណជាទម្ងន់លើទូលបង្គំជាអនេកណាស់ វេលានេះក៏មិនទាន់បានធ្វើការអ្វីតបព្រះគុណនៅឡើយ ហេតុម្ដេចហើយទ្រង់សង្ស័យដូច្នេះ? កាលទូលបង្គំនៅជាមួយបងនោះ បងថ្លៃក៏បានប្រទូសរ៉ាយដល់ទូលបង្គំ ៗទទួលទានស្រាស្រវឹងហើយក៏សម្លាប់បងថ្លៃនោះស្លាប់ បងប្រុសទូលបង្គំគេក៏ខឹងសម្បារ តាំងកាត់កាល់ដាច់ពីគ្នានោះមក កាលទូលបង្គំទៅនៅនឹង**ម៉ាឈៀវ**ទៀត ព្រោះឃើញថា**ម៉ាឈៀវ**គ្រាន់តែជាមនុស្សចិត្តជាទាហាន តែគ្មានប្រាជ្ញាស្មារតីឲ្យមាំមួននាំទាហានទៅធ្វើសង្គ្រាមស្លាប់អស់ទាហាន នៅតែខ្លួនមួយបានជាចូលទៅនៅនឹង**ឡៅពី** ទូលបង្គំក៏បានចូលមកធ្វើជាខ្ញុំក្រោមល្អងធូលីព្រះបាទ ខំសង្វាតយកចិត្តទុកដាក់ គិតធ្វើរាជការថ្វាយមិនស្ដាយអាល័យជីវិតរាងកាយសោះ ឯគេអស់នោះ ក៏មានចៅហ្វាយនាយដោយខ្លួន ហើយផ្លូវមេត្រីចិត្តក៏កាត់

អាល័យពីគ្នាសោះសូន្យបានជាទូលបង្គំខំទាំងម្ល៉េះ ព្រោះឃើញថាព្រះអង្គមានព្រះគុណពិត បានជាគិតសុំអាសាទៅធ្វើសង្គ្រាមតបព្រះតេជព្រះគុណគ្រានេះ។

**ចូឆ្លូ**ក៏ក្រោកឡើងទៅដឹកដៃ**បាំងតេក**ឱ្យចូលមកជិត ហើយក៏លួងលោមថា ឯសេចក្ដីដែលពិតនោះ យើងក៏អាចដឹងថា ខ្លួនអ្នកពេញជាមនុស្សមានសត្យកតញ្ញូនឹងរាប់អានជាប្រាកដ ដែលយើងបាននិយាយតាមបូរបទហេតុផលទាំងអម្បាលនេះ ព្រោះយើងក្លែងបណ្ដាលឱ្យមនុស្សទាំងពួងអស់សង្ស័យប៉ុណ្ណោះទេ វេលានេះចូរអ្នកចេញទៅធ្វើការដោយសុចរិតពិតត្រង់ទៅចុះ។ **បាំងតេក**បានឮដូច្នោះក៏គោរពលាព្រះចៅ**វុយអេង**ទៅផ្ទះ ហើយឱ្យធ្វើមឈូសមួយ រួចហៅអស់ពួកអ្នកស្រុកមកតាំងតុលៀងអាហារជាមួយគ្នា ហើយលើកយកមឈូសនោះចេញមកតាំងទុកនៅមុខអ្នកទាំងពួង ៗឃើញហើយក៏សួរថា ហេតុអ្វីលោកនេះរៀបដំណើរលើកទ័ពទៅធ្វើសង្គ្រាមជាជ័យមង្គល ក៏មកធ្វើការអពមង្គលវិញដូច្នេះ មិននាំឱ្យជាប្រច្ចូលចង្រៃទៅវិញទេឬ?

**បាំងតេក**លើកពែងស្រាឡើង ហើយថា ព្រះចៅ**វុយអេង**មានព្រះគុណលើយើងច្រើនណាស់ ឥឡូវយើងនឹងអាសាទៅធ្វើការសង្គ្រាមនឹង**គួនអ៊ូ** គ្រានេះក៏ជាទីបំផុតពេលហើយ បើ**គួនអ៊ូ**មិនស្លាប់យើងក៏ត្រូវតែស្លាប់វិញជាប្រាកដ។ មនុស្សទាំងពួងក៏សរសើរថា លោកមានប្រសាសន៍នេះប្រសើរណាស់ ហើយ**បាំងតេក**ក៏ហៅនាង**លិស៊ី**ជាភរិយាចូលមក ហើយផ្ដាំថា បើយើងអស់ព្រេងសំណាងទៅ **បាំងហ្លួយ**ជាបុត្ររបស់យើងនេះមានលក្ខណៈល្អណាស់ ចៅត្រូវឧស្សាហ៍ចិញ្ចឹមវាទុក ដើម្បីនឹងបានទៅច្បាំងសងសឹកនឹង**គួនអ៊ូ**ជំនួសយើងតទៅ។

ខណៈកាលនឹងលើកទ័ពចេញទៅនោះ **បាំងតេក**បង្គាប់ទាហានព្រមគ្នាថា បើយើងស្លាប់អស់អ្នកទាំងឡាយត្រូវយកមឈូសនេះដាក់ខ្មោចយើង នាំទៅថ្វាយព្រះចៅ**វុយអេង**ផងចុះ។ បើយើងសម្លាប់**គួនអ៊ូ**ស្លាប់វិញ នឹងកាត់យកក្បាល**គួនអ៊ូ**ដាក់ក្នុងមឈូសនេះនាំទៅថ្វាយដូចគ្នា។ ពួកទាហានទាំងប្រាំរយក៏សោមនស្សត្រេក

អរថា បើលោកតាំងនៅសេចក្ដីសត្យកតញ្ញូដូច្នេះហើយ យើងខ្ញុំទាំងឡាយក៏ពេញចិត្តខិតខំធ្វើរាជការជាមួយនឹងលោកឲ្យអស់តម្រិះប្រាជ្ញា។ លុះថាដូច្នោះហើយក៏លើកទ័ពទៅ។ ក្រោយនោះមានមនុស្សយកសម្ដីដែល**បាំងតេក**និយាយនោះទៅទូលព្រះចៅ**វុយអេង** ៗក៏ទ្រង់សោមនស្សត្រេកអរណាស់ថា បើ**បាំងតេក**ទៀងត្រង់នឹងយើងដូច្នេះពិត យើងក៏មិនត្រូវគិតព្រួយចិត្តនឹងសត្រូវប៉ុណ្ណោះឡើយ។

**កែអ៊ូ**បានឮដូច្នោះក៏ទូលថា **បាំងតេក**នេះល្អតែពាក្យអួតខ្លាំងពូកែម្យ៉ាង ខ្ញុំគិតព្រួយណាស់ព្រោះឃើញថា ទោះយ៉ាងម្ដេចក៏មិនឈ្នះ**គួនអ៊ូ**ទេ។ ព្រះចៅ**វុយអេង**ក៏យល់ឃើញផង ទើបឲ្យបម្រើកាន់សំបុត្រតាមទៅនិយាយនឹង**បាំងតេក**ថា **គួនអ៊ូ**នោះមានកម្លាំងខ្លាំងពូកែណាស់ ទាំងតម្រិះប្រាជ្ញាវិះគិតគំនិតមារយាទក៏ឆ្លាតទាំងព្រម បើបានទៅច្បាំងគ្នាហើយកុំបីប្រមាទ បើឃើញបានចំណាប់វេលាណាសឹមធ្វើការ បើមិនបានការទេ ក៏ត្រូវតែរវាំងរក្សាការពារខ្លួនកុំឲ្យមានសេចក្ដីអន្តរាយ។

ឯ**បាំងតេក**នោះ លុះដឹងក្នុងសេចក្ដីព្រះតម្រាស់ព្រះចៅ**វុយអេង**ហើយ ក៏និយាយនឹងទាហានទាំងពួងថា **គួនអ៊ូ**នោះជាមនុស្សទាហាន ហានក្លាប្រាកដមក៣០ឆ្នាំហើយ ឥឡូវយើងទៅកម្ចាត់ចេញឲ្យបាន ហេតុម្ដេចម្ចាស់យើងមកលើកតម្កើងសរសើរ**គួនអ៊ូ**នោះដូច្នេះ? **អ៊ីគឹម**ដែលជាមេទ័ពធំបានឮ**បាំងតេក**និយាយដូច្នោះក៏ថា ដែលមានព្រះតម្រាស់បង្គាប់មកដូច្នេះ ក៏គួរតែយើងនឹងទទួលធ្វើតាមទើបត្រូវ។ លុះ**អ៊ីគឹម** និង**បាំងតេក**ប្រឹក្សាគ្នាដូច្នោះហើយ ក៏លើកទ័ពធំចូលទៅជិតស្រុកអ៊្វនសៀ ទើបឲ្យទាហានហ៊ោស្រែកវាយឃ្មោះគងទូងស្គរព្រមគ្នា។

ឯ**គួនអ៊ូ**ដែលតាំងបន្ទាយភ្ជាប់គ្នានឹងស្រុកអ៊្វនសៀនោះ លុះដឹងថា**អ៊ីគឹម**និង**បាំងតេក**លើកទ័ពមកហើយ ធ្វើអាស្រូវភាសយកមឈូសមកប្រមាទ នឹងដាក់ក្បាលដូច្នោះ **គួនអ៊ូ**ក៏មានសេចក្ដីខឹងក្ដៅខ្លាំងណាស់ថា ខ្លួនយើងក៏មានថ្វីដៃល្បីល្បាញទូទៅក្នុងផែនដី ហេតុអ្វីអា**បាំងតេក**ដែលជាមនុស្សទាបថោក វាមកប្រមាទមើលងាយយើងដូច្នេះ? **គួនអ៊ូ**ក៏ប្រើ**គួនប៉េង**ជាកូនចិញ្ចឹមនោះ លើកទ័ពទៅវាយស្រុកអ៊្វនសៀ

ឯ**គួនអ៊្វ**ក៏លើកទៅច្បាំងនឹង**បាំងតេក**។ **គួនប៉េង**ក៏ជម្រាបបិតាថា លោកអាពុកប្រៀបបីដូចជាភ្នំដ៏ធំខ្ពស់ ឯ**បាំងតេក**នោះប្រៀបបីដូចជាដំបូកតូចមួយ គួរឬអញ្ជើញទៅតនឹងវា មិនសមគួរសោះ។ ខ្ញុំបាទនឹងសុំទៅតស៊ូនឹង**បាំងតេក**ជំនួសបិតាវិញ។ **គួនអ៊្វ**ថា បើចៅនឹងទៅក៏ទៅចុះ បិតានឹងលើកពលទៅតាមជាក្រោយ។ **គួនប៉េង**ក៏លើកទាហានចេញទៅ។

ឯ**បាំងតេក**នោះ លុះឃើញ**គួនប៉េង**លើកទាហានមក ក៏ឲ្យទាហានយកទង់ធំដែលសរសេរជាអក្សរបួនតួ ឈ្មោះថាពួកឡាំហាន់ **បាំងតេក**កាន់ដឹកមុខ។ **បាំងតេក**នោះពាក់អាវក្រោះ កាន់លំពែងជិះសេះចេញទៅឈរមុខទាហានទាំងពួងប្រាំរយនាក់ ហើយឲ្យលើកយកមឈូសទៅតាំងទុកពីមុខ**គួនប៉េង** លុះឃើញ**បាំងតេក**ជិះសេះទៅបញ្ឈរនៅដូច្នោះ ក៏ស្រែកជេរថា អាចោរទុយ៏សទ្រុស្តក្បត់នាយចៅហ្វាយ។ **បាំងតេក**ឮដូច្នោះក៏សួរទាហានទាំងពួងថា ដែលចេញខ្លួនមកនេះគឺឈ្មោះអ្វី? ទាហានឆ្លើយថា ឈ្មោះ**គួនប៉េង**ជាបុត្រចិញ្ចឹម**គួនអ៊្វ**។ **បាំងតេក**ក៏ស្រែកថា ព្រះចៅ**វុយអេង**ប្រើឲ្យយើងលើកទ័ពមកកាត់យកក្បាល**គួនអ៊្វ**ជាបិតាឯង ៗគ្រាន់តែជាកូនតូច មិនគួរនឹងមកជាគូសង្គ្រាមនឹងគ្នាទេ ឯងចូរវិលទៅប្រាប់បិតាឯងឲ្យចេញមកតដៃនឹងយើងវិញទើបត្រូវ។ **គួនប៉េង**ឮដូច្នោះខឹងណាស់ បំបោលសេះចូលទៅប្រយុទ្ធគ្នានឹង**បាំងតេក**ដោយក្បួនសេះបានសាមសិបភ្លែង ក៏មិនទាន់ចាញ់ឈ្នះគ្នា ហើយទាំងសងខាងក៏ថយរាទៅក្រោយវិញ។

ខណៈនោះមានទាហានទៅប្តឹង**គួនអ៊្វ**ថា **គួនប៉េង**ដែលលើកទៅតដៃនឹង**បាំងតេក**នោះ មិនទាន់ចាញ់ឈ្នះគ្នាទេ។ **គួនអ៊្វ**ឮដូច្នោះខឹងណាស់ ទើបបង្គាប់**លៀវហ៊្វ**ឲ្យចូលវាយយកស្រុកអ៊្វនសៀ ឯ**គួនអ៊្វ**ក៏លើកទ័ពស្រូតតាម**គួនប៉េង**ចេញទៅ។ **គួនប៉េង**ឃើញ**គួនអ៊្វ**ទៅដល់ក៏ជម្រាបថា ខ្ញុំបាទច្បាំងនឹង**បាំងតេក**បានសាមសិបភ្លែងមិនទាន់ចាញ់ឈ្នះ **បាំងតេក**ក៏ថយទ័ពត្រឡប់ទៅ ខណៈនោះ**គួនអ៊្វ**ក៏

បរពលចូលទៅប្រជាប់គ្នានឹងបន្ទាយ**បាំងតេក**ហើយស្រែកថា យើងឈ្មោះ**គួនអ៊ូ**អ្នកឯងចូរមកប្រញាប់យកជីវិតមកឲ្យយើងចុះ។

**បាំងតេក**ឮដូច្នោះក៏ចេញមកស្រែកថា ព្រះចៅ**វុយអេង**ប្រើយើងឲ្យមកយកក្បាលអ្នកឯង បើមិនជឿមើលមឈូសនេះចុះ បើខ្លាចសេចក្ដីស្លាប់ ត្រូវប្រញាប់ចុះពីលើសេះមកចំណុះចុះចូលយើង ៗនឹងទុកជីវិតឲ្យរស់នៅតទៅ។ **គួនអ៊ូ**ថា ពាក្យដែលឯងថានោះ អញស្ដាប់មើលទៅឃើញលើសហួសនិស្ស័យពេកណាស់ អញនឹងសម្លាប់ឯង ក៏ដូចសម្លាប់ជ្រូកតូចមួយ អញគិតស្ដាយមុខដាវរបស់អញណាស់។ **គួនអ៊ូ**ថាដូច្នោះហើយក៏បំបោលសេះកាន់ដាវចូលច្បាំងនឹង**បាំងតេក**បានមួយរយភ្លេងប្លាយ ក៏នៅមិនទាន់ចាញ់ឈ្នះគ្នា ទាហានខាង**បាំងតេក**នឹកខ្លាចក្រែងនាយនឹងចាញ់ ក៏ឲ្យវាយឃ្មោះជាសម្គាល់ឡើងឲ្យថយទៅ។ **គួនប៉េង**ឃើញថា បិតាជរាក្រែងថ្កោះការ ក៏ឲ្យវាយឃ្មោះថយទ័ព ទាំងសងខាងក៏រាថយទៅឈប់។

ឯ**បាំងតេក**នោះ លុះទៅដល់បន្ទាយហើយ ក៏និយាយនឹងទាហានទាំងពួងថា គេនិយាយឮល្បីល្បាញថា **គួនអ៊ូ**មានថ្វីដៃខ្លាំងពូកែណាស់ យើងទើបនឹងបានប្រទះថ្ងៃនេះ ឃើញថាពិតប្រាកដមែន។ ខណៈនោះ**អ៊ីគឹម**និយាយនឹង**បាំងតេក**ថា អ្នកចូរច្បាំងគ្នានឹង**គួនអ៊ូ**ដល់មួយរយភ្លេងហើយ ហេតុម្ដេចបានជាអ្នកមិនថយទ័ពចេញនឹងមិនខុសអំពីព្រះតម្រាស់ទេឬ? **បាំងតេក**តបថា ព្រះចៅ**វុយអេង**តាំងលោកជាមេទ័ពធំ ហេតុម្ដេចលោកមកខ្លាចញញើតដល់សត្រូវដូច្នេះ មិនគួរសោះ។ វេលាព្រឹកស្អែកខ្ញុំចេញច្បាំងនឹង**គួនអ៊ូ**ម្ដងទៀត ត្រាតែអស់ជីវិតមិនគិតថយក្រោយឡើយ។ **អ៊ីគឹម**មិនអាចនឹងទទឹងរាំងរាបាន ក៏ត្រឡប់ទៅបន្ទាយរបស់ខ្លួនវិញ។

ឯ**គួនអ៊ូ**នោះ លុះត្រឡប់ទៅដល់បន្ទាយក៏និយាយនឹង**គួនប៉េង**ថា **បាំងតេក**នេះគេក៏គ្រាន់បើមែន ក្នុងគុនអាវុធថ្វីដៃក៏ល្មម ប្រហែលនឹងយើងដែរ។ **គួនប៉េង**និយាយនឹងបិតាថា ទោះបីលោកអាពុកនឹងតច្បាំងសម្លាប់**បាំងតេក**បាន បើឈ្នះក៏ដូចឈ្នះស្រី បើត្រឡប់ជាផុងស្មារតីឲ្យចាញ់**បាំងតេក**វិញ ក៏នឹងអាស្រូវដល់កិត្តិយសរបស់

ព្រះចៅ**ហាន់តុង** មិនគួរសោះ។ **គួនអ៊ូ**ថា បើបិតាមិនសម្លាប់អា**បាំងតេក**ចេញឲ្យបាន ក៏អស់រំខាននឹងចិត្តក្តៅ ចៅកុំថាដូច្នោះឡើយ។ លុះវេលាព្រឹកឡើង **គួនអ៊ូ**ក៏លើកទ័ពចេញទៅទៀត ចំណែកខាង**បាំងតេក**ក៏ចេញតស៊ូច្បាំងគ្នាបានសាមសិបភ្លែង **បាំងតេក**ក៏ក្លែងធ្វើជាចាញ់ទម្លាក់លំពែងចុះ ហើយរត់ទៅក្រោយ។ **គួនអ៊ូ**ក៏ដេញបណ្តោយទៅតាមហើយស្រែកជេរថា អាឯងកុំអាលក្លែងធ្វើក្បួនរត់ដូច្នេះឡើយ អញដឹងដល់គំនិតអាឯងហើយ មិនខ្លាចទេ។

**គួនប៉េង**ខ្លាចបិតានឹងថ្លោះការអន្តរាយ ក៏ដេញតាមទៅទៀត ទទួលក្រឡេកឃើញ**បាំងតេក**យកដាវច្រកក្នុងស្រោម កន្ត្រាក់យកធ្នូចេញនឹងបាញ់ ហើយ**គួនប៉េង**ស្រែកជេរទៅថា អាសត្រូវកុំអាលបាញ់បិតាអញ **គួនអ៊ូ**ក៏ងាកមុខមើលក្រោយ **បាំងតេក**ក៏បាញ់បណ្តោយមក ការមិនទាន់ក៏ត្រូវចុងស្មារ**គួនអ៊ូ**ខាងស្តាំ **គួនប៉េង**ក៏ស្ទុះទៅជួយគ្រាហ៍យកបិតាមកបន្ទាយបាន។ **អ៊ីគឹម**នៅក្នុងបន្ទាយឃើញ**បាំងតេក**បាញ់ត្រូវ**គួនអ៊ូ** ក៏គិតឥច្ឆាក្រែង**បាំងតេក**នឹងមានជ័យ បានសេចក្តីគាប់ប្រសើរ ក៏ក្លែងវាយឈ្មោះ ឲ្យសញ្ញាថយទ័ព។

**បាំងតេក**ឮស្នូរឈ្មោះក៏គិតថា មានកើតហេតុមិនស្រួល ទើបថយត្រឡប់ចូលបន្ទាយហើយសួរ**អ៊ីគឹម**ថា ខ្ញុំមានជ័យជម្នះនឹងដេញសត្រូវទៅ ហេតុម្តេចបានជាវាយឈ្មោះ? **អ៊ីគឹម**តបថា មានព្រះតម្រាស់ព្រះចៅ**រុយអេង**បង្គាប់ថា **គួនអ៊ូ**ជាមនុស្សមានប្រាជ្ញាប្រើកលឧបាយក៏ច្រើន ដែលត្រូវព្រួញប៉ុណ្ណោះក្រែងនឹងបញ្ឆោតបានជាយើងវាយឈ្មោះឃាត់ហាម។ **បាំងតេក**ថា បើកុំតែលោកឃាត់ហាមខ្ញុំ ៗក៏នឹងតាមសម្លាប់**គួនអ៊ូ**ឲ្យ។ **អ៊ីគឹម**ថា ដែលនឹងធ្វើចិត្តរហ័សនោះមិនស្រួលទេ ក្រែងមានភ័យដល់ខ្លួន យើងត្រូវតែគិតមើលមុខមើលក្រោយឲ្យស្រួលបួលសិន។ **បាំងតេក**មិនបានដឹងចិត្ត**អ៊ីគឹម**សោះ ចេះតែគិតស្តាយការដែលបានចំណាប់ហើយនោះមិនអស់មិនហើយក្នុងចិត្តសោះ។

ឯ**គួនអ៊ី**លុះត្រឡប់ទៅដល់បន្ទាយហើយ ក៏ឲ្យកន្ត្រាក់ដកយកព្រួញដែលជាប់នៅចុងស្មាចេញបាន ហើយឲ្យយកថ្នាំទៅលាបបិទមុខរបួសនោះ តែនៅនឹកខឹងក្តៅមិនរសាយ ទើបនិយាយប្រាប់ទាហានទាំងឡាយថា អស់អ្នករាល់គ្នាចូរធ្វើជាសាក្សីយើងផង យើងនឹងសងសឹកថ្វីដៃអា**បាំងតេក**ឲ្យទាល់តែបានវិញ បើសងសឹកវាមិនបានទេ យើងក៏មិនធ្វើសឹកសង្គ្រាមតទៅទៀតឡើយ។ ទាហានទាំងពួងឆ្លើយថា លោកត្រូវខំព្យាបាលរក្សារបួសក្នុងខ្លួនលោកឲ្យជាទៅសិនចុះ រួចសឹមលើកទ័ពទៅច្បាំងនឹងសត្រូវទៀត។

លុះវេលាព្រឹក**គួនអ៊ី**ដឹងថា **បាំងតេក**នឹងចេញមកច្បាំងទៀត **គួនអ៊ី**ក៏ចេញទៅច្បាំងនឹង**បាំងតេក** ទាហានទាំងពួងក៏និយាយឃាត់ហាម **បាំងតេក**ក៏ឲ្យទាហានទៅស្រែកជេរ ប្រាថ្នានឹងឲ្យ**គួនអ៊ី**ខឹងលើកទ័ពចេញមកច្បាំងទៀត **គួនអ៊ី**ក៏មិនបានចេញច្បាំង នោះ**គួនប៉េង**ជាបុត្រក៏ចាត់ឲ្យត្រួតត្រារក្សាបន្ទាយដោយមាំមួន ហើយទើបបង្គាប់ទាហានមិនឲ្យយកដំណឹងទៅជម្រាប**គួនអ៊ី**សោះ។ **បាំងតេក**ចេះតែលើកទៅបញ្ឈឺចិត្ត**គួនអ៊ី**រាល់ថ្ងៃ គម្រប់ដប់ថ្ងៃ លុះមិនឃើញទ័ព**គួនអ៊ី**ចេញមកច្បាំង ក៏ប្រឹក្សានឹង**អ៊ីគឹម**ថា ប្រហែល**គួនអ៊ី**ត្រូវព្រួញនៅឈឺធ្ងន់ ទើបមិនឃើញមកច្បាំងនឹងយើង ឥឡូវគួរយើងនិងពួកទាំងប្រាំពីរកងចូលវាយយកបន្ទាយ**គួនអ៊ី**ចុះ ទើបនឹងកែខៃយកស្រុកអ៊ួនសៀបាន។ **អ៊ីគឹម**ខ្លាចក្រែង**បាំងតេក**នឹងបានសេចក្តីគាប់ប្រសើរ ក៏និយាយទទឹងទាស់ព្រះតម្រាស់មិនឲ្យលើកទ័ពទៅ តាំងតែហាមឃាត់ច្រើនគ្រាណាស់។ ឯ**អ៊ីគឹម**នោះ ក៏លើកទាហានទៅស្កាត់ផ្លូវធំចំទីវាលចាន់ខៅ ឆ្ងាយពីស្រុកអ៊ួនសៀប្រហែលមួយរយសិន (៤ គ.ម) ហើយ**បាំងតេក**ទៅតាំងពួនបង្កប់នៅខាងក្រៅប្រាថ្នាមិនឲ្យចេញច្បាំង។

ចំណែកឯខាង**គួនប៉េង** លុះដឹងដំណឹងហើយ ក៏ចូលទៅជម្រាប**គួនអ៊ី**ថា ឥឡូវ**អ៊ីគឹម**និង**បាំងតេក**លើកទ័ពទៅតាំងនៅទីប្រហាបភ្នំ មិនដឹងថានឹងគិតធ្វើប្រការម្តេច **គួនអ៊ី**ក៏រក្សារបួសចង់ជាហើយ បានឮដំណឹងដូច្នោះក៏ឡើងសេះនាំទាហានទៅ

ឈរនៅលើភ្នំមួយអន្លើ ក្រឡេកទៅឃើញក្នុងស្រុកអ៊ួនសៀ មានទង់ជ័យនិងទាហានក៏រៀវរោយស្ងួចស្ងើង មិនប្រុងប្រៀបរៀបជាក្បួនទ័ព ទើបក្រឡេកទៅឃើញវាលមួយ មានត្រង់ចន្លោះភ្នំនៅទិសខាងជើង ឃើញពួក**អ៊ីគឹម** និង**ប៉ាំងតេក**តាំងទ័ពនៅចម្ងាយពីស្រុកប្រហែលមួយរយសិន (៤ គ.ម) ហើយឃើញទន្លេសុងកាំងហូរទឹកធ្លាក់ទៅតាមកម្លាំងទំនាប ទើបឲ្យពួកអ្នកស្រុកចេញមក ហើយសួរថា វាលនោះឈ្មោះអ្វី? អ្នកស្រុកឆ្លើយថា វាលចាន់ខៅ។ **គួនអ៊ូ**មានអំណរណាស់ថា **អ៊ីគឹម**គ្រានេះមុខជាមិនរួចពីកណ្ដាប់ដៃយើងទេ។ ទាហានជម្រាបសួរថា លោកឃើញហេតុប្រការម្ដេច? **គួនអ៊ូ**ឆ្លើយថា សត្រូវចូលទៅតាំងនៅទីចង្អៀត យើងគិតធ្វើការបានស្រួល ហើយក៏នាំទាហានមកបន្ទាយវិញ ទើបបង្គាប់ឲ្យទាហានធ្វើទូកចម្បាំងទាំងតូចទាំងធំបម្រុងទុកជាច្រើន។

**គួនប៉េង**សួរ**គួនអ៊ូ**ថា ឥឡូវធ្វើម្ដេចយើងនឹងបានលើកដោយក្បួនទ័ពគោកទៀត បើលោកអាពុកឲ្យបម្រុងទូកចម្បាំងដូច្នេះ? **គួនអ៊ូ**ប្រាប់ថា ព្រោះវេលានេះ **អ៊ីគឹម** និង**ប៉ាំងតេក**លើកថយចេញទៅតាំងបន្ទាយនៅវាលចាន់ខៅខាងក្នុងប្រហបភ្នំ បិតាឃើញថាទីនោះជាទីទំនាប តំបន់យើងជាទីទួល ឃើញថាក្នុងរវាងខែភទ្របទនឹងមានភ្លៀងជញ្ជ្រាំធ្លាក់មករាល់វេលា គង់នឹងដក់ទឹកឡើងច្រើនលិចបន្ទាយនោះ មនុស្សទាំងឡាយក៏គង់នឹងលំបាករកទីស្នាក់អាស្រ័យមិនបាន យើងនឹងលើកទ័ពទូកចូលទៅច្បាំង គង់នឹងវាយយកបានដោយងាយ។ **គួនប៉េង**ស្ដាប់ឮដូច្នោះក៏ចុះទៅក្រាបសំពះសរសើរគំនិតបិតា។

បណ្ដាទាហានទាំងអស់ ដែលបានទៅតាំងបន្ទាយនៅទីនោះ លុះឃើញភ្លៀងរំលាមិនដែលដាច់សោះ ទឹកក៏កាន់តែឡើងខ្ពស់គ្រប់ថ្ងៃ **សេងហោ**ក៏និយាយនឹង**អ៊ីគឹម**ថា ដែលយើងតាំងបន្ទាយនៅទីនេះ គឺជាទីចង្អៀត ទីទំនាប នៅក្នុងចន្លោះភ្នំ ឥឡូវក៏ត្រូវភ្លៀងជញ្ជ្រាំធ្លាក់មកមិនដាច់គ្រប់យប់ថ្ងៃ ទាហានដែលនៅអាស្រ័យក៏បានសេចក្ដីព្រួយលំបាកណាស់ ឥឡូវឮដំណឹងថា **គួនអ៊ូ**ឲ្យតាំងបន្ទាយនៅលើភ្នំខ្ពស់

ហើយឲ្យបម្រុងទាហានទូកចម្បាំងធំតូចទុកច្រើនណាស់ បើទឹកឡើងមកច្រើនមុខជាពួកយើងនឹងលំបាកដោយទឹក រកទីឈប់អាស្រ័យពុំបាន យើងនឹងគិតប្រការម្ដេច? **អ៊ីគឹម**ក៏ស្រែកគំហកថា អាចោលម្សៀត ឯងមកនិយាយយ៉ាងនេះប្រាថ្នានឹងឲ្យទាហានយើងខូចចិត្តគំនិតអស់ទៅឬ? ឯងកុំនិយាយដូច្នេះទៀត! បើមិនស្ដាប់អញ ៗនឹងសម្លាប់ចេញ។

**សេងហោ**ឮដូច្នោះក៏ភ័យស្លុតស្មារតី បានសេចក្ដីខ្មាសណាស់ថយចុះចេញទៅ ហើយក៏ទៅនិយាយប្រាប់**បាំងតេក**តាមពាក្យរបស់ខ្លួន និងពាក្យដែល**អ៊ីគឹម**ខឹងថានោះ **បាំងតេក**ថា អ្នកនិយាយនេះត្រូវណាស់ តែបើ**អ៊ីគឹម**ជាមេទ័ពធំ គេមិនព្រមប្រែប្រួលចេញទេ ក៏តាមគំនិតផងគេចុះ តែវេលាព្រឹកស្អែក យើងនឹងលើកទៅតាំងទ័ពនៅទីដទៃទៀត។ លុះប្រឹក្សាគ្នាហើយ វេលាយប់នោះ ទទួលធ្លាក់ខ្យល់ព្យុះភ្លៀងរំលាធំណាស់ **បាំងតេក**បានឮសូរខ្យល់ព្យុះ និងឃើញភ្លៀងសន្ធឹកសន្ធាប់មកដូច្នោះ ក៏ភ័យខ្លាំងណាស់ ទើបឡើងសេះទៅឈរនៅមុខបន្ទាយ ក្រឡេកទៅទាំងប្រាំបីទិស ក៏ឃើញទឹកឡើងមកជាច្រើន លិចបន្ទាយនោះជម្រៅប្រាំមួយហត្ថ ទាហានបានសេចក្ដីលំបាកលង់ទឹកស្លាប់ជាច្រើន។ **អ៊ីគឹម**និង**បាំងតេក**នូវអស់ទាហានដែលសល់ពីស្លាប់នោះ ទាំងអស់គ្នាក៏រត់ឡើងទៅអាស្រ័យនៅលើកំពូលភ្នំតូចមួយ តែ**អ៊ីគឹម**និង**បាំងតេក**នោះ មិនមាននៅជាមួយគ្នាទេ លុះដល់ព្រឹកឡើង **គួនអ៊ូ**ក៏ឲ្យទាហានស្រែកហ៊ោលើកទង់គ្រវីវាយឈ្មោះទូងស្គរ ហើយលើកទ័ពទូកចូលទៅ។

**អ៊ីគឹម**ឃើញ**គួនអ៊ូ**លើកទ័ពមកក៏ភ័យណាស់ ព្រោះមានទាហាននៅជាមួយប្រមាណតែហាសិប ឬហុកសិបនាក់ប៉ុណ្ណោះ ឃើញថាតស៊ូមិនបាន ទើបស្រែកទៅថា គ្រានេះខ្ញុំបាទមិនតច្បាំងទេ នឹងសុំចំណុះចុះចូលទៅនៅជាខ្ញុំរាជការលោកហើយ។ **គួនអ៊ូ**ឲ្យ**អ៊ីគឹម**ដោះអាវ ចោលគ្រឿងសាស្ត្រាវុធទាំងអស់ ហើយយកទូកចម្បាំងទៅទទួលឲ្យចុះមកក្នុងទូកទាំងអស់គ្នា។ **គួនអ៊ូ**ក៏លើកតាមទៅចាប់ខ្លួន**បាំងតេក**។

ឯ**បាំងតេក, តាំងហេង, តាំងឈៀវ, សេងហោ** មានទាហាននៅជាមួយប្រហែលប្រាំរយនាក់ ឈរនៅលើកំពូលភ្នំ ក្រឡេកឃើញ**គួនអ៊្វ**ក៏មិនមានខ្លាច **គួនអ៊្វ**ក៏ឲ្យយកទូកចម្បាំងព័ទ្ធជុំវិញ ហើយឲ្យលើកធ្នូបាញ់ចម្រុះចូលទៅ ត្រូវទាហាន**បាំងតេក**ស្លាប់អស់ប្រហែលពីរភាគ។

ឯ**តាំងហេង, តាំងឈៀវ** លុះឃើញនឹងដល់ទីអាប់ចុនហើយ ក៏និយាយនឹង**បាំងតេក**ថា ទាហានយើងស្លាប់ជាងពាក់កណ្ដាលទៅហើយ សូម្បីផ្លូវច្រកល្ហកក៏រកនឹងរត់ទៅពុំរួច គួរយើងនឹងព្រមចុះចាញ់**គួនអ៊្វ**យកតែជីវិតឲ្យរួចទៅចុះ។ **បាំងតេក**ឮដូច្នោះក៏ខឹងណាស់ថា យើងជាខ្ញុំព្រះចៅ**វុយអេង** យើងបានឲ្យសេចក្ដីសត្យពិតត្រង់ទុកទៅហើយ ដែលនឹងព្រមចំណុះចុះចាញ់ទៅធ្វើជាខ្ញុំ**គួនអ៊្វ**វិញនោះ មិនត្រូវសោះ។ ពួកទាហានទាំងអស់ឮហើយក៏ខំប្រឹងចូលទៅច្បាំងនឹង**គួនអ៊្វ**មិនបានកោតញញើត តាំងពីពេលព្រឹកទាល់ដល់ថ្ងៃត្រង់ **គួនអ៊្វ**ក៏ឲ្យទាហានបាញ់ធ្នូនិងចោលដុំថ្មតម្រង់ទៅបីដូចគ្រាប់ភ្លៀង។

ឯ**បាំងតេក**នោះ ក៏ឲ្យពលច្បាំងមិនរាថយសោះ ហើយនិយាយឡើង យើងបានឮគេនិយាយមកពីដើមថា ដែលនឹងឡើងឈ្មោះពេញជាទាហាននោះ លុះតែបានចូលក្នុងសង្គ្រាមមិនបានកោតញញើតនឹងសត្រូវសោះ មានចិត្តស្មោះឧស្សាហ៍ធ្វើការចម្បាំងតាំងយកជ័យជម្នះឲ្យបាន ដូចយើងវេលានេះ ក៏អាប់ចុនសុនខ្លួននៅក្នុងចំណោមទ័ព យើងត្រូវតែស្លាប់ ប៉ុន្តែត្រូវមានមានះទាំងអស់គ្នាកុំរាថយឡើយ ចូរស៊ូច្បាំងឲ្យទាល់តែស្លាប់ឲ្យហើយទៅចុះ។ **សេងហោ**ឮដូច្នោះក៏គិតមានះស្ទុះកាន់ដាវចេញទៅមុខ ចូលគ្រលុកតនឹង**គួនអ៊្វ**ក៏ត្រូវធ្នូស្លាប់។

បណ្ដាទាហានទាំងពួងឃើញ**សេងហោ**ស្លាប់ ក៏ត្រឡប់ចិត្តគិតញញើតទាំងអស់គ្នា បបួលគ្នាទៅចំណុះចុះចូលជាពួក**គួនអ៊្វ**ទាំងអស់ ឯ**បាំងតេក**នោះនៅតែម្នាក់ឯង ក្រឡេកឃើញទូកតូចមួយមានមនុស្សដប់នាក់ចែវចូលមកជិត **បាំតេក**កាន់ដាវ

មិតរត់ចុះទៅក្នុងទូកបាន ហើយបង្ខំទាហានជើងថែវទាំងនោះឱ្យចែវរត់ទៅ **បាំងតេក**នៅឈរលើទូកដៃមួយកាន់ដាវហោបង្ខំពួកជើងថែវ ៗតម្រង់ទៅស្រុកអ៊្វនសៀ។

ខណៈនោះ**ជីវឆង**ទាហាន**គួនអ៊ូ** មានកម្លាំងចំណានតស៊ូច្បាំងក្នុងក្បូនទូក លុះក្រឡេកឃើញ**បាំងតេក**ឱ្យចែវទូករត់ទៅដូច្នោះ ក៏បង្ខំទាហានឱ្យចែវទូកចម្បាំងដេញទៅប្រកើលលើទូក**បាំងតេក**លិចទៅ **បាំងតេក**ក៏បោះចោលដាវចេញ ហើយលោតចុះទឹកហែលទៅ **ជីវឆង**ក៏ព្រួតគ្នាចាប់បាន ហើយចងនាំយកទៅជូន**គួនអ៊ូ** ៗលើកទ័ពត្រឡប់ចូលបន្ទាយវិញ ទើបឱ្យនាំយកខ្លួន**អ៊ីគឹម**ឡើងមកពីក្នុងទូកហើយសួរថា ហេតុម្ដេចបានជាខ្លួនហ៊ានទ្រនង់អង់អាចមកច្បាំងនឹងយើង? **អ៊ីគឹម**ឆ្លើយថា ខ្ញុំបាទជាខ្ញុំព្រះចៅ**វុយអេង** ៗត្រាស់ប្រើហើយនឹងទទឹងម្ដេចបាន ដែលមកច្បាំងនឹងលោកនោះ មានទោសខុសណាស់ទៅហើយ សូមឱ្យលោកអនុគ្រោះលោះលាជីវិតទុកឱ្យទានចុះ ខ្ញុំបាទនឹងសុំនៅធ្វើរាជការសឹកតបគុណលោកតទៅ។

**គួនអ៊ូ**ឮដូច្នោះក៏អស់សំណើចហើយថា យើងនឹងសម្លាប់ជីវិតខ្លួនចេញក៏បីដូចជាសម្លាប់ឆ្កែមួយប៉ុណ្ណោះ ទើបបង្គាប់ទាហានឱ្យចងខ្លួន**អ៊ីគឹម**ត្រឡប់ទៅដាក់គុកទុកឯស្រុកកេងជីវ ទម្រាំនឹងសម្រេចការរណរង្គសង្គ្រាម ហើយបង្គាប់ឱ្យយកខ្លួន**បាំងតេក**ចូលមកទៀត សួរថា ឥឡូវយើងចាប់ខ្លួនឯងបាន តើឯងនឹងគិតប្រការម្ដេច?

**បាំងតេក**មានសេចក្ដីមានះឈរនៅ មិនគំនាប់**គួនអ៊ូ**សោះ។ **គួនអ៊ូ**សួរថា **បាំងហ៊ីរ**បងឯងហើយនិង**ម៉ាឈៀវ**ជានាយចៅហ្វាយចាស់នោះ ក៏ទៅនៅជាខ្ញុំរាជការព្រះចៅ**ឡៅពី**ឯស្រុកសែឈួន ឥឡូវយើងលើកទ័ពមកបង្ក្រាបសត្រូវ ហេតុម្ដេចខ្លួនឯងទើបមិនស្ម័គ្រមកនៅនឹងយើង? **បាំងតេក**ឆ្លើយថា យើងជាខ្ញុំព្រះចៅ**វុយអេង** ៗប្រើមកឱ្យយើងច្បាំងនឹងខ្លួន ៗចាប់យើងបានហើយ ត្រូវធ្វើតាមចិត្តចុះ ដែលមកល្បួងឱ្យយើងព្រមចំណុះធ្វើរាជការផងនោះ យើងមិនត្រូវការទេ ព្រោះយើងដឹងថា ព្រះចៅ**វុយអេង**មានព្រះគុណជាទម្ងន់ណាស់ យើងស៊ូតែស្លាប់នឹងមុខ

ដាវ លំពែង ហើយមិនអាចមានអាល័យស្តាយរូបកាយនេះប៉ុន្មានទេ។ ហើយក៏និយាយទ្រគោះអសុរោះ ជេរប្រមាថ**គួនអ៊ូ**ជាច្រើន។ **គួនអ៊ូ**ខឹងណាស់ ក៏បង្គាប់ឱ្យទាហាននាំខ្លួន**បាំងតេក**ទៅប្រហារជីវិត ហើយក៏ត្រឡប់គិតអាណិតអានាថពន់ប្រមាណ បានឱ្យយកសពទៅកប់តាមប្រពៃណី។

ឯ**ចៅយិន**ដែលនៅក្នុងស្រុកអ៊្លូនសៀនោះ លុះឃើញទឹកជំនន់ឡើងច្រើន ក៏បង្ខំទាហាននិងបណ្ដាអ្នកស្រុកបិទរង្វះព្រែកទាំងអស់ ទឹកនោះក៏ហូរបាក់ធ្លាយរលាយទំនប់ចូលទៅក្នុងស្រុកបាន ប្រជាជនក្នុងភូមិឋានក៏បានសេចក្ដីលំបាកណាស់។ **ចៅយិន**និយាយនឹងទាហានទាំងពួងថា គ្រានេះមុខជាយើងនឹងមានអន្តរាយជាប្រាកដហើយ ព្រោះទឹកឡើងច្រើនណាស់ មនុស្សទាំងពួងបានសេចក្ដីលំបាកវេទនា បើសត្រូវចូលមកពាធាក៏តទល់ពុំឈ្នះ គួរយើងនឹងលះបង់ចោលស្រុកវេះវត់ទៅរក្សាអាយុជីវិតសិនចុះ ហើយបង្គាប់ឱ្យប្រុងប្រៀបរៀបទូកនឹងឆ្លងរត់ទៅ។

ខណៈនោះ **ប៊ួនថុង**ទីប្រឹក្សាហាមឃាត់**ចៅយិន**ថា ដែលនឹងលះបង់ចោលស្រុកអ៊្លូនសៀនោះ មិនគួរសោះ ព្រោះនៅតែពីរបីថ្ងៃទៀត ទឹកនឹងស្រកចុះទៅវិញហើយ ខ្ញុំបាទយល់ឃើញថា ឯ**គួនអ៊ូ**ដែលនឹងលើកទ័ពមកច្បាំងក្នុងគ្រានេះ ក៏ឃើញថាមានមុខជាមិនមកទេ មុខជានឹងឱ្យតែទាហានទៅឃាំងទ័ពនៅកៀបហៃ ដែលជាផ្លូវនឹងចូលមកស្រុកអ៊្លូនសៀ ព្រោះខ្លាចពួកយើងនឹងលើកទៅលុកពីក្រោយ ឯស្រុកអ៊្លូនសៀនេះជាបង្គោល មាំជាងអាណាខេត្តទិសខាងត្បូងទាំងអស់ បើចោលស្រុកអ៊្លូនសៀបង់ហើយ ស្រុកទៀងអាន់ ក៏នឹងរវាលទទេទៅ។

**ចៅយិន**ឆ្លើយតបទៅនឹង**ប៊ួនថុង**ថា អ្នកឯងនិយាយនេះយើងក៏យល់ឃើញផងដែរ បើប្រសិនជាអ្នកមិនបានឃាត់ឃាំងយើង មុខជាខូចការរាជការទៅទទេឥតប្រយោជន៍។ និយាយហើយក៏ឡើងជិះសេះសបរទៅបញ្ឈរលើសើនបន្ទាយ ហើយស្រែកប្រកាសប្រាប់ពួកទាហានទាំងពួងថា គ្រានេះយើងកាន់ព្រះតម្រាស់ព្រះចៅ

**វុយអេង**មក បើនរណាធ្វើរាជការកោតញញើតចេញពាក្យថានឹងចោលស្រុកអ៊ួនសៀទៀត យើងនឹងកាត់ក្បាលអ្នកនោះចេញ។ ទាហានទាំងពួងក៏ស្រែកឡើងព្រមគ្នាថា យើងខ្ញុំរក្សាស្រុកនេះទុកត្រាតែអស់ជីវិត។ **ចោយិន**ឮដូច្នោះពេញចិត្តណាស់ ទើបប្រុងប្រៀបរៀបទាហានឲ្យមានគ្រឿងសាស្ត្រាវុធ និងធ្នូស្នាត្រួតត្រាទាំងយប់ទាំងថ្ងៃ លុះរំលងមកពីរបីថ្ងៃ ទឹកក៏ស្រកចុះទៅអស់ ឯ**គួនអ៊ូ**កាលមានជ័យជម្នះក៏ល្បីរន្ទឺកេរ្តិ៍ឈ្មោះទូទៅដល់មនុស្សទាំងពួងលើសជាងពីដើម។

ឯ**គួនហ៊ិន**ជាបុត្រទីពីរនៃ**គួនអ៊ូ**ដែលនៅស្រុកកេងជីវក៏លើកពលមកសួរបិតា **គួនអ៊ូ**ក៏ប្រើ**គួនហ៊ិន**ឲ្យកាន់សំបុត្រមួយច្បាប់ ទៅក្រាបទូលព្រះចៅ**ហាន់តុង**ឯស្រុកសេងតោថា ឥឡូវ**គួនអ៊ូ**ទូលបង្គំវាយយកបានស្រុកសុងយ៉ុងហើយ ចាប់បានទាំងខ្លួន**អ៊ុគីម**បញ្ជូនទៅស្រុកកេងជីវ ឯ**បាំងតេក**នោះទូលព្រះបង្គំក៏ចាប់បានសម្លាប់ចោលទៅហើយ បណ្ដាទាហានដែលទៅធ្វើរាជការសង្គ្រាមគ្រានេះ ក៏មានសេចក្ដីគាប់ប្រសើរជាច្រើនណាស់។ **គួនហ៊ិន**ទទួលយកសំបុត្រនោះហើយ ក៏លាបិតាចេញទៅស្រុកសេងតោ។

ខណៈនោះ **គួនអ៊ូ**ក៏បែងទាហានទៅតាំងនៅទីតំបន់កៀបហែ ដ៏ជាផ្លូវដែលចូលទៅស្រុកអ៊ួនសៀ ហើយក៏លើកទាហានចូលទៅនឹងវាយទម្លាយយកស្រុកអ៊ួនសៀ។ **គួនអ៊ូ**ជិះសេះបញ្ឈរនៅត្រង់ទ្វារទិសខាងជើង ហើយយកស៊ែចង្អុលមុខ**ចោយិន**ស្រែកថា អាពួកជ្រូក ហេតុម្ដេចឯងទើបមិននាំគ្នាចេញមកស៊ូគ្រព្រមចំណុះចុះចូលអញ នឹងបង្អង់ចាំដល់កាលណាទៅទៀត?

**ចោយិន**នៅឈរលើសើន ក្រឡេកឃើញ**គួនអ៊ូ**ពាក់អាវមានតែក្រោះបិទទ្រូងមកឈរនៅដូច្នោះ ក៏ឲ្យទាហានប្រាំរយយកធ្នូបាញ់ចម្រុះចុះមក **គួនអ៊ូ**គេចរត់មិនទាន់ ព្រួញធ្នូក៏លឿនទៅត្រូវស្មាខាងឆ្វេងធ្លាក់ពីលើខ្នងសេះ **ចោយិន**ក្រឡេកឃើញដូច្នោះ ក៏ឲ្យទាហានលើកចេញច្បាំង។

ឯ**គួនប៉េង**ជាបុត្រក៏ឲ្យទាហានចូលច្បាំងនឹងទាហាន**ចោយិន** ៗក៏ថយត្រឡប់ទៅវិញចូលស្រុក **គួនប៉េង**ក៏នាំយកបិតាវិលទៅបន្ទាយ ហើយឲ្យមនុស្សទាញកន្ត្រាក់ដកយកព្រួញចេញបាន ឯព្រួញនោះលាបចុងដោយថ្នាំពិស ជ្រាបចូលទៅដល់ឆ្អឹងមានពិសពើតចាប់ជាខ្លាំងណាស់ **គួនអ៊ូ**ទឹងកម្រើកខ្លួនស្ទើរមិនបាន។ **គួនប៉េង**និងទាហានទាំងពួងឃើញថា **គួនអ៊ូ**ឈឺខ្លាំងដូច្នោះ ក៏នាំគ្នាចូលទៅនិយាយនឹង**គួនអ៊ូ**ថា ឥឡូវនេះលោកក៏មានរបួសឈឺ ដែលនឹងធ្វើការតទៅនោះ ឃើញថាលោកបានសេចក្ដីលំបាកណាស់ ខ្ញុំបាទប្រឹក្សាព្រមគ្នានឹងសុំលើកទ័ពត្រឡប់ទៅស្រុកកេងជីវ រក្សារបួសលោកឲ្យសះជាសិន សឹមធ្វើការតទៅ។

**គួនអ៊ូ**បានឮ ក៏មានសេចក្ដីខឹងខ្លាំងណាស់ថា យើងនឹងខ្លាចអ្វីដល់សេចក្ដីឈឺចាប់បន្តិចបន្តួចប៉ុណ្ណោះ យើងនឹងវាយយកស្រុកអ៊ួនសៀឲ្យបាន ហើយនឹងលើកទៅវាយយកស្រុកហ៊ួតោទៀត ដើម្បីកម្ចាត់**ចូឆូ**ចេញឲ្យព្រះចៅ**ហៀនតេ**បានសេចក្ដីសុខចៅកុំថាដូច្នេះតទៅទៀតឡើយ អស់អាណាប្រជាជនទាំងពួងក៏នឹងបានសេចក្ដីតូចចិត្ត។ **គួនប៉េង**និងទាហានទាំងពួងបានឮ**គួនអ៊ូ**ថា ក៏មិនអាចនឹងទាស់ទែងបាន ទាំងអស់គ្នាក៏លាថយមក ក្នុងថ្ងៃនោះស្រាប់តែពេទ្យ**ហ៊ួតោ**ជាគ្រូឯកពួកស្រុកចៅកុនមកដល់បន្ទាយ ទាហានទាំងពួងក៏ទៅប្រាប់**គួនប៉េង**ៗក៏ឲ្យអញ្ជើញពេទ្យ**ហ៊ួតោ**ចូលទៅ។ ពេទ្យ**ហ៊ួតោ**សួរថា ខ្ញុំបានឮបិតាអ្នកត្រូវព្រួញរបួសធ្ងន់ បានជាខ្ញុំស្វះស្វែងមកនឹងជួយព្យាបាលរក្សា។ **គួនប៉េង**ថា កាលគ្រារក្សារបួស**ជីវថាយ**ក្នុងស្រុកកាំងតាំងនោះ គឺលោកនេះឯងឬ? ពេទ្យ**ហ៊ួតោ**ឆ្លើយថា គឺខ្ញុំនេះឯងហើយ។ **គួនប៉េង**ឮដូច្នោះក៏មានអំណរណាស់ ទើបឲ្យទាហាននាំពេទ្យ**ហ៊ួតោ**ចូលទៅក្នុងបន្ទាយ។

ឯ**គួនអ៊ូ**បានសេចក្ដីឈឺចាប់ជាខ្លាំងណាស់ តែគិតក្រែងទាហានទាំងពួងដឹងនឹងនាំឲ្យខូចចិត្តគំនិត បានជាខំឧស្សាហ៍អត់ទ្រាំធ្វើជាបែបសប្បាយ ហើយហៅ**ម៉ាលៀង**ចូលលេងបាសកា ប្រាថ្នានឹងឲ្យទាហានទាំងពួងមានចិត្តស្រើបស្រាល ស្រាប់តែយើងពេទ្យ**ហ៊ួតោ**ចូលទៅដល់ ក៏អញ្ជើញឲ្យពិសាតែ ហើយឲ្យពិចារណា

មើលរបួសខ្លួន។ ពេទ្យ**ហ្វ៊ូតោ**ថា របួសព្រួញនេះលាបដោយថ្នាំពិសជ្រាបចូលទៅក្នុងឆ្អឹង បើមិនប្រឹងមើលឲ្យឆាប់ យូរទៅនឹងខូចស្នានេះអសារ។ **គួនអ៊ូ**ថា លោកនឹងប្រកបថ្នាំមើលបានឬទេ? ពេទ្យ**ហ្វ៊ូតោ**ខ្ញុំនឹងមើលជូនបាន តែខ្លាចលោកអត់ធន់ពុំបាន។

**គួនអ៊ូ**អស់សំណើចហើយថា ខ្ញុំមិនខ្លាចទេ កុំបាច់យកច្បោសរុំឡើយ លោកនឹងធ្វើយ៉ាងម៉េចក៏តាមតែធ្វើចុះ ខ្ញុំនៅស្ងៀមឲ្យធ្វើ។ ទើបបួល**ហ្វ៊ូតោ**ផឹកស្រា លុះស្រវឹងហើយក៏ហៅ**ម៉ាលៀង**ឲ្យចូលមកលេងបាសកា ហើយក៏ផ្អៀងស្នាម្ខាងឲ្យ**ហ្វ៊ូតោ** ៗក៏យកកាំបិតមុតវះសាច់អាក្រក់ចេញអស់ ហើយក៏យកថ្នាំលាប ហើយទើបយក ម្ជុលមកដេររុំទុក។ មនុស្សទាំងពួងឃើញដូច្នោះស្ទើរនឹងមិនហ៊ានមើល។ **គួនអ៊ូ**ក្រោកឡើងស្រែកថា យើងមិនមានឈឺទេ ជាអស់ហើយ ៗសរសើរថា ពេទ្យនេះវិសេសណាស់ បីដូចទេវតាក៏ថាបាន។ **ហ្វ៊ូតោ**ថា តាំងពីខ្ញុំបាទចេះមើលរបួសជំងឺមនុស្សក៏ច្រើនណាស់មកហើយ មិនមាននរណាដូចលោកនេះទេ ឯលោកនេះចិត្តជាអ្នកពូកែអត់ធន់ទ្រាំជំងឺ មិនតក់ស្លុតរន្ធត់ខ្លាចអ្វីសោះ ល្អណាស់ៗ។

ឯ**គួនអ៊ូ** លុះសះជាជំងឺរបួសនេះហើយក៏អរណាស់ ទើបឲ្យលើកតុអាហារនិងស្រាបាយមកឲ្យ**ហ្វ៊ូតោ**បរិភោគតាមសប្បាយ។ **ហ្វ៊ូតោ**និយាយនឹង**គួនអ៊ូ**ថា របួសនេះទើបនឹងសះជា លោកត្រូវរម្ងាប់សេចក្ដីកំហឹងត្រាតែគ្រប់មួយរយថ្ងៃ ទើបពិសព្រួញនេះនឹងជាអស់ស្អិទ្ធ។ **គួនអ៊ូ**ក៏ទទួលពាក្យនិងមានអំណរគុណ**ហ្វ៊ូតោ**ច្រើនណាស់ ទើបយកមាសទម្ងន់បីជញ្ជីងដប់បាតឲ្យ**ហ្វ៊ូតោ**ជាបំណាច់រង្វាន់។ **ហ្វ៊ូតោ**ថា ដែលខ្ញុំបាទបានមកព្យាបាលជំងឺរបួសលោកទាំងនេះ នឹងបានតាំងចិត្តប្រាថ្នាដោយរង្វាន់បំណាច់នោះក៏ទេ ខ្ញុំបាទឃើញលោកនេះប្រកបដោយសេចក្ដីសត្យពិតត្រង់បានជាមកជួយព្យាបាល ដើម្បីមិនឲ្យមានអន្តរាយ ដែលលោកនឹងឲ្យទានបំណាច់រង្វាន់មកខ្ញុំបាទ ៗមិនយកទេ សូមបង្វិលទុកជូនលោកវិញ ថាតែប៉ុណ្ណោះហើយក៏យកថ្នាំលាបរបួសម្ដងទៀត ហើយក៏លាចេញទៅ។

ចប់ភាគទីប្រាំពីរ

សូមរង់ចាំអានភាគទីប្រាំបីបន្តទៀត។

សូមអរគុណ។

ណុល ដារ៉ា

លោកអ្នកអានអាចស្វែងរកសៀវភៅផ្សេងទៀតតាមរយៈប្លក៖

www.khmerliterature.wordpress.com